**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de Droit et des Science Economiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ការលែងលះរវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ នៅកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ កញ្ញា **សារិន មាសរក្សា**

សាស្ត្រាចារ្យណែនាំ
**ម៉ួយ ធីតា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ២០

ឆ្នាំចូលសិក្សា ២០១៦
ឆ្នាំសរសេរសារណា ២០២០

# **សេចក្តីថ្លែងអំណរគុណ**

ជាដំបូងនាងខ្ញុំឈ្មោះ **សារិន មាសរក្សា** ជានិស្សិត ថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២០ ក្នុងឆ្នាំសិក្សា២០១៦-២០២០ សូមសម្តែងនូវកតញ្ញូ និងដឹងគុណដ៏ជ្រាលជ្រៅ មិនអាចកាត់ថ្លៃបានដល់លោកអ្នកមានគុណទាំងពីរ គឺលោកឪពុក **សារិន សុភក្តី** និងអ្នកម្តាយ **គា ម៉ាន់លេង** ដែលបានផ្តល់នូវកំណើតដល់រូបនាងខ្ញុំ និងចិញ្ចឹមបីបាច់ថែរក្សា ព្រមទាំងបានផ្តល់នូវការស្នាក់នៅ និងការរៀនសូត្រតាំងពីថ្នាក់មត្តេយ្យ រហូតមកដល់កម្រិតថ្នាក់បរិញ្ញាបត្រ។ លោកទាំងពីរបានរួមចំណែកទាំងការផ្តល់នូវកម្លាំងចិត្ត ការអប់រំ ការទូន្មានប្រៀនប្រដៅ និងផ្តល់នូវព្រហ្មវិហារធម៌ដល់រូបនាងខ្ញុំ។

នាងខ្ញុំសូមថ្លែងអំណរគុណដល់ **ក្រសួងអប់រំ យុវជន និងកីឡា** ព្រមទាំង **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ដែលបានផ្តល់នូវកន្លែងបណ្តុះបណ្តាលចំណេះដឹង និងសមត្ថភាព ក៏ដូចជាការបង្ហាត់បង្ហាញចំពោះផ្នែកនីតិសាស្ត្រនេះ តាំងពីឆ្នាំទីមួយ រហូតមកដល់ការបញ្ចប់ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ ប្រកបដោយភាពជោគជ័យ ផ្លែផ្កា និងសមិទ្ធផលចំណេះដឹងយ៉ាងគាប់ប្រសើរ។

នាងខ្ញុំសូមថ្លែងអំណរគុណដល់ **ឯកឧត្តមសាកលវិទ្យាធិការ** សាកលវិទ្យាធិការរង ព្រឹទ្ធបុរសថ្នាក់ដឹកនាំ គណៈគ្រប់គ្រង និង លោក-លោកស្រីសាស្ត្រាចារ្យ នៃសាកលវិទ្យាល័យភូមិន្ទនីតិស្រាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលលោក លោកស្រី បានធ្វើការផ្តល់នូវចំណេះដឹង ការអប់រំ និងសីលធម៌ដល់នាងខ្ញុំក្នុងរយៈពេល ៤ ឆ្នាំមកនេះ។

ពិសេសបំផុតនោះ នាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ **សាស្ត្រាចារ្យ ម៉ូយ ធីតា** ដែលជាសាស្ត្រាចារ្យណែនាំ និងដឹកនាំការសរសេរសារណារបស់នាងខ្ញុំ ដោយលោកជំទាវបានខិតខំទាំងកម្លាំងកាយកម្លាំងចិត្ត និងពេលវេលាដ៏មានតម្លៃ ក្នុងការផ្តល់នូវដំបូន្មាន គំនិត ចំណេះដឹង យោបល់ ការលើកទឹកចិត្ត និងការបង្ហាញផ្លូវដល់នាងខ្ញុំ ចាប់តាំងពីថ្ងៃដែលនាងខ្ញុំផ្តើមសរសេរ រហូតដល់ទទួលបានស្នាដៃមួយនេះជាស្ថាពរដែលគុណទាំងនេះ គឺពិតជាមានតម្លៃវិសេសវិសាលឥតកាត់ថ្លៃបានចំពោះនាងខ្ញុំ។

ជាចុងក្រោយ នាងខ្ញុំសូមសម្តែងនូវអំណរគុណដល់ប្រធានថ្នាក់ មិត្តល្អ និងសិស្សច្បងទាំងអស់ ដែលបានរួមចំណែកក្នុងការជួយសម្របសម្រួលផ្សេងៗ ការផ្តល់នូវកម្លាំងចិត្ត ពិសេសគឺភាពជឿជាក់មកលើរូបនាងខ្ញុំ ដែលសកម្មភាពទាំងនោះគឺជាចំណែកយ៉ាងធំមួយ ក្នុងដំណើរការសរសេរសារណាមួយនេះរហូតបានបញ្ចប់ជាស្ថាពរ និងប្រកបដោយលទ្ធផលវិជ្ជមាន។ ហើយជាកិច្ចបញ្ចប់ នាងខ្ញុំសូមឱនកាយលើកដៃសំពះប្រណមបួងសួងជូនដល់ មាតាបិតា ញាតិមិត្ត ព្រមទាំងថ្នាក់ដឹកនាំសាកលវិទ្យាល័យ លោក-លោកស្រីសាស្ត្រាចារ្យ និងមិត្តនិស្សិតគ្រប់រូប ឲ្យជួបប្រទះនូវពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

នាងខ្ញុំឈ្មោះ **សារិន មាសរក្សា** ជានិស្សិតឆ្នាំទី៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាន់ទី២០ បានឆ្លងកាត់ការសិក្សា និងការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រអស់រយៈពេល ៤ ឆ្នាំរួចមកហើយ។ តាមរយៈការសិក្សាក្នុងពេល ៤ ឆ្នាំមកនេះ ឃើញថាការសិក្សាបរិញ្ញាបត្រផ្នែកនីតិសាស្ត្រនេះ ពិតជាផ្តល់នូវសារៈសំខាន់យ៉ាងខ្លាំងសម្រាប់នាងខ្ញុំក្នុងនាមជាយុវជនជំនាន់ក្រោយ។

ជាក់ស្តែង នាងខ្ញុំទទួលបាននូវចំណេះដឹង និងបទពិសោធន៍ជាច្រើនពីការសិក្សាកន្លងមក។ ទោះបីជានៅកាលៈទេសៈខ្លះ នាងខ្ញុំបានជួបប្រទះនូវឧបសគ្គ និងការលំបាកយ៉ាងណាក៏ដោយ ប៉ុន្តែនាងខ្ញុំនៅតែព្យាយាមតស៊ូប្រឹងប្រែងសន្សំចំណេះវិជ្ជា ដោយមិនព្រមបោះបង់ចោលនូវការសិក្សាដ៏មានសារៈសំខាន់នេះឡើយ ក្នុងគោលបំណងមួយដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រនេះឲ្យបានជោគជ័យជាស្ថាពរ។ ទន្ទឹមនឹងការបញ្ចប់បរិញ្ញាបត្រឲ្យបានជោគជ័យ នាងខ្ញុំក៏មានគោលបំណងក្នុងការបញ្ចប់ការសិក្សា ដោយការសរសេរសារណាមួយដ៏សមប្រកប ដែលជាលទ្ធផល និងជាស្នាដៃដ៏សំខាន់បំផុតមួយសម្រាប់នាងខ្ញុំ បន្ទាប់ពីបានសិក្សាអស់រយៈពេល ៤ ឆ្នាំកន្លងមកនេះ។ បន្ទាប់ពីបានសិក្សារួចកន្លងមកនូវមុខវិជ្ជាសំខាន់ៗជាច្រើន នៅក្នុងបរិញ្ញាបត្រនីតិសាស្ត្រនេះ នាងខ្ញុំមានការចាប់អារម្មណ៍ជាងគេលើមុខវិជ្ជានីតិវិធីរដ្ឋប្បវេណី ពីព្រោះថា មុខវិជ្ជានេះសិក្សាទាក់ទងនឹងវិធានដែលប្រើសម្រាប់ដឹកនាំការដោះស្រាយវិវាទ ឬ បញ្ហាដែលមានបញ្ញត្តិនៅក្នុងក្រមរដ្ឋប្បវេណីដែលទាក់ទងនឹងសកម្មភាពប្រចាំថ្ងៃ។ ទន្ទឹមនឹងនេះដែរ ការដោះស្រាយវិវាទរដ្ឋប្បវេណីមានលក្ខណៈពិសេសត្រង់ថា ការដោះស្រាយក្នុងករណីខ្លះត្រូវរួមបញ្ចូលជាមួយវិធានច្បាប់ផ្សេងៗទៀត។ ស្របពេលជាមួយគ្នានេះដែរ នាងខ្ញុំយល់ឃើញថា ការលែងលះនៅកម្ពុជាសព្វថ្ងៃ គឺជាបញ្ហាមួយដែលទាក់ទងនឹងរឿងក្តីរដ្ឋប្បវេណី ហើយត្រូវដោះស្រាយ ដោយចាំបាច់យកនូវវិធានច្បាប់ផ្សេងៗដែលមានក្នុងប្រព័ន្ធច្បាប់នៃនីតិវិធីរដ្ឋប្បវេណីមកដោះស្រាយ។ អាស្រ័យហេតុនេះហើយ ទើបនាងខ្ញុំសម្រេចចិត្តជ្រើសរើសយក ប្រធានបទស្រាវជ្រាវមួយស្តីអំពី «**ការលែងលះរវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ នៅកម្ពុជា**» មកធ្វើការសិក្សាស្រាវជ្រាវ។

នាងខ្ញុំសង្ឃឹមថាការស្រាវជ្រាវនេះ នឹងមានគុណប្រយោជន៍ទៅដល់អ្នកស្រលាញ់ការសិក្សាស្រាវជ្រាវដទៃទៀត។ យ៉ាងណាមិញ ដោយហេតុថា ប្រធានបទ «**ការលែងលះរវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ នៅកម្ពុជា**» មានភាពធំទូលាយ ដូច្នេះនាងខ្ញុំសូមអភ័យទោសជាមុន ប្រសិនបើមានភាពខ្វះខាតត្រង់ចំណុចណាមួយ ឬ មានការប្រើប្រាស់នូវពាក្យពេចន៍ខុសឆ្គងដោយអចេតនាណាមួយ។ នាងខ្ញុំក៏មានក្តីសោមនស្សរីករាយក្នុងការទទួលយកនូវរាល់ការិះគន់ក្នុងន័យដើម្បីស្ថាបនា ពីសំណាក់ លោក-លោកស្រីសាស្ត្រាចារ្យ បងៗប្អូនៗ និងមិត្តនិស្សិតទាំងអស់ដែលបានអានស្នាដៃមួយនេះ។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........ ១

**ជំពូកទី១**

**សញ្ញាណទូទៅនៃការលែងលះ**

**១.១. និយមន័យនៃការលែងលះ** ........ ៥

១.១.១. និយមន័យការលែងលះដោយការព្រមព្រៀង ........ ៦

១.១.២. និយមន័យការលែងលះដោយគ្មានការព្រមព្រៀង ........ ៦

**១.២. ស្ថានភាពទូទៅពាក់ព័ន្ធនឹងសហព័ទ្ធក្នុងចំណងអាពាហ៍ពិពាហ៍** ........ ៧

**១.៣. មូលហេតុនៃការលែងលះ** ........ ៨

១.៣.១. អំពើផិតក្បត់ ........ ៨

១.៣.២. ការបោះបង់សហព័ទ្ធចោលដោយគ្មានមូលហេតុត្រឹមត្រូវ ........ ៩

១.៣.៣. អវត្តមាន ឬ ការបាត់ខ្លួន ........ ៩

១.៣.៤. ការរស់នៅបែកគ្នារវាងសហព័ទ្ធ ........ ១០

១.៣.៥. ករណីធ្ងន់ធ្ងរមិនអាចបដិទានទំនាក់ទំនងឡើងវិញបាន ........ ១០

**១.៤. បទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការលែងលះ** ........ ១១

១.៤.១. ក្រមរដ្ឋប្បវេណី (ឆ្នាំ២០០៧) ........ ១២

១.៤.២. ក្រមនីតិវិធីរដ្ឋប្បវេណី (ឆ្នាំ២០០៦) ........ ១២

១.៤.៣. ច្បាប់ស្តីពីនីតិវិធីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង (ឆ្នាំ២០១០) ........ ១៣

១.៤.៤. ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល (ឆ្នាំ២០១០) ........ ១៣

**ជំពូកទី២**

**ការលែងលះដោយការព្រមព្រៀង**

**២.១. ទិដ្ឋភាពទូទៅនៃការលែងលះដោយការព្រមព្រៀង** ........ ១៥

**២.២. អាជ្ញាធរមានសមត្ថកិច្ច** ........ ១៦

២.២.១. ក្រុមប្រឹក្សាឃុំ-សង្កាត់ ក្នុងការផ្សះផ្សា ........ ១៦

២.២.២. តុលាការរាជធានី-ខេត្ត ........ ១៦

**២.៣. នីតិវិធីដែលត្រូវបំពេញដោយភាគី** ........ ១៧

២.៣.១. ការស្នើសុំការលែងលះ ........ ១៧

២.៣.១.១. ពាក្យសុំលែងលះ ........ ១៧

ក. ពាក្យសុំដោយផ្ទាល់មាត់ ........ ១៧

ខ. ពាក្យសុំដោយលាយលក្ខណ៍អក្សរ ........ ១៨

២.៣.១.២. ការដាក់ពាក្យសុំលែងលះ និងការបង់ពន្ធ ........ ១៩

២.៣.២. ឯកសារភ្ជាប់ ........ ២០

**២.៤. នីតិវិធីដោះស្រាយការលែងលះដោយព្រមព្រៀង** ........ ២០

២.៤.១. ការកោះហៅគូភាគី ........ ២១

២.៤.២. ការផ្សះផ្សា ........ ២១

២.៤.៣. ការទាញហេតុផលដោយផ្ទាល់មាត់ ........ ២២

២.៤.៤. ការសម្រេចលើពាក្យស្នើសុំ ........ ២៣

២.៤.៤.១. ការចេញដីកាសម្រេច ........ ២៣

២.៤.៤.២. បណ្ដឹងជំទាស់ ........ ២៣

## ជំពូកទី៣

## ការលែងលះដោយគ្មានការព្រមព្រៀង

**៣.១. ទិដ្ឋភាពទូទៅនៃការលែងលះដោយគ្មានការព្រមព្រៀង** ........ ២៥

**៣.២. អាជ្ញាធរមានសមត្ថកិច្ច** ........ ២៦

៣.២.១. ក្រុមប្រឹក្សាឃុំ-សង្កាត់ ក្នុងការផ្សះផ្សា ........ ២៦

៣.២.២. តុលាការរាជធានី-ខេត្ត ........ ២៧

**៣.៣. នីតិវិធីដែលត្រូវបំពេញដោយភាគី** ........ ២៨

៣.៣.១. ការធ្វើបណ្ដឹងលែងលះ ........ ២៨

៣.៣.១.១. និយមន័យនៃបណ្ដឹង ........ ២៨

៣.៣.១.២. ការសរសេរពាក្យបណ្តឹង ........................................ ២៩

៣.៣.១.៣. ការដាក់ពាក្យបណ្តឹង និងការបង់ពន្ធ ........................................ ៣១

៣.៣.២. ឯកសារភ្ជាប់ និងភស្តុតាង ........................................ ៣២

**៣.៤. នីតិវិធីក្នុងការជំនុំជម្រះ** ........................................ ៣៣

៣.៤.១. ការពិនិត្យលើបណ្តឹងទាមទារការលែងលះ ........................................ ៣៣

៣.៤.១.១. ការទទួលយកបណ្តឹងតាមផ្លូវតុលាការ ........................................ ៣៣

៣.៤.១.២. ការលើកពាក្យបណ្តឹងចោល ........................................ ៣៤

៣.៤.១.៣. ការបន្ថែម ឬផ្លាស់ប្តូរកម្មវត្ថុនៃបណ្តឹង ........................................ ៣៤

៣.៤.១.៤. ការប្តឹងតបរបស់ចុងចម្លើយ ........................................ ៣៥

៣.៤.២. ការកោះហៅគូភាគី និងការបញ្ជូនបណ្តឹងទាមទារការលែងលះ ........................................ ៣៥

៣.៤.២.១. ការបញ្ជូនដោយប្រគល់ ........................................ ៣៦

៣.៤.២.២. ការបញ្ជូនដោយជួបប្រទះ ........................................ ៣៦

៣.៤.២.៣. ការបញ្ជូនដោយបង្គ្រប់កិច្ច ........................................ ៣៧

៣.៤.២.៤. ការបញ្ជូនដោយទុកចោល ........................................ ៣៧

៣.៤.៣. ការផ្សះផ្សា ........................................ ៣៨

៣.៤.៤. ការចាត់ចែងរក្សាការពារបណ្តោះអាសន្ន ........................................ ៣៩

៣.៤.៤.១. ការកំណត់អំពីការរស់នៅរបស់សហព័ទ្ធ ........................................ ៤០

៣.៤.៤.២. ការថែរក្សាកូនជាបណ្តោះអាសន្ន ........................................ ៤១

៣.៤.៤.៣. ការថែរក្សាទ្រព្យជាបណ្តោះអាសន្ន ........................................ ៤១

៣.៤.៥. នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ........................................ ៤២

៣.៤.៦. នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ........................................ ៤៤

៣.៤.៧. ការសម្រេចសេចក្តី ........................................ ៤៦

៣.៤.៧.១. ការចេញសាលក្រមលែងលះ ........................................ ៤៧

៣.៤.៧.២. ការសម្រេចមិនឲ្យមានការលែងលះ ........................................ ៤៨

ក. ស្ថានភាពលំបាកធ្ងន់ធ្ងរ ........................................................................ ៤៨
ខ. ទាមទារផ្ទុយពីភាពសុចរិត ........................................................................ ៤៩
៣.៤.៧.៣. ការប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ........................................................ ៤៩
ក. បណ្តឹងឧទ្ធរណ៍ ........................................................................ ៤៩
ខ. បណ្តឹងសាទុក្ខ ........................................................................ ៥០
គ. បណ្តឹងជំទាស់ ........................................................................ ៥១

## ជំពូកទី៤
## អានុភាពនៃការលែងលះ

**៤.១. ការកាត់ផ្តាច់ទំនាក់ទំនងគតិយុត្ត** ........................................................................ ៥៣
៤.១.១. ការកាត់ផ្តាច់ចំណងគតិយុត្តរវាងសហព័ទ្ធ ........................................................ ៥៣
៤.១.២. ការកាត់ផ្តាច់ទំនាក់ទំនងញាតិពន្ធ ........................................................ ៥៣
**៤.២. សិទ្ធិ និងកាតព្វកិច្ចបន្សល់ក្រោយការលែងលះ** ........................................................ ៥៤
៤.២.១ សិទ្ធិបន្សល់ក្រោយការលែងលះ ........................................................................ ៥៤
៤.២.១.១. សិទ្ធិទទួលបានអត្តាធិនភាពដដែល ........................................................ ៥៥
៤.២.១.២. សិទ្ធិក្នុងការប្រើប្រាស់នាមត្រកូល ........................................................ ៥៥
៤.២.១.៣. សិទ្ធិលើអំណាចមេបា ........................................................................ ៥៦
៤.២.១.៤. សិទ្ធិលើទ្រព្យសម្បត្តិ ........................................................................ ៥៧
ក. ទ្រព្យសម្បត្តិរួម ........................................................................ ៥៨
ខ. ប្រព័ន្ធទ្រព្យសម្បត្តិដោយឡែក ........................................................................ ៥៩
៤.២.១.៥ សិទ្ធិក្នុងការបង្កើតចំណងអាពាហ៍ពិពាហ៍ថ្មី ........................................................ ៦០
៤.២.១.៦ ការបញ្ចប់ករណីយកិច្ចសហព័ទ្ធ ........................................................ ៦០
៤.២.២. កាតព្វកិច្ចបន្សល់ក្រោយការលែងលះ ........................................................ ៦១
៤.២.២.១. អាហារកាតព្វកិច្ច ........................................................................ ៦១
ក. អាហារកាតព្វកិច្ចចំពោះកូន ........................................................................ ៦១

ខ. អាហារកាតព្វកិច្ចចំពោះសហព័ទ្ធ ..................................................... ៦២
៤.២.២.២. កាតព្វកិច្ចសងសំណងជម្ងឺចិត្ត..................................................... ៦២
៤.២.២.៣. កាតព្វកិច្ចចំពោះតតិយជន..................................................... ៦៣
**សេចក្ដីសន្និដ្ឋាន** ..................................................... ៦៤
**អនុសាសន៍**..................................................... ៦៦
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

នៅក្នុងសង្គមមនុស្ស នៅពេលដែលមនុស្សម្នាក់ដល់អាយុពេញវ័យ គឺតែងតែមានការរើសគូស្រករ ដើម្បីរៀបអាពាហ៍ពិពាហ៍។ ជាក់ស្តែង ការរៀបអាពាហ៍ពិពាហ៍ គឺមានគោលបំណងដើម្បីបង្កើតនូវគ្រួសារ និងការផ្តល់សុភមង្គលដល់មនុស្ស។ បើក្រឡេកទៅមើលក្នុងសកលលោក ដែលមានលាយឡំដោយជាតិសាសន៍ជាច្រើន បានបង្ហាញថា ទំនៀមទម្លាប់ ប្រពៃណី របស់ជាតិសាសន៍នីមួយៗ មានលក្ខណៈខុសៗគ្នា ជាហេតុនាំឲ្យការរៀបអាពាហ៍ពិពាហ៍នៅក្នុងរដ្ឋនីមួយៗ ប្រព្រឹត្តទៅតាមបែបផ្សេងគ្នារៀងៗខ្លួន។ ចំណែកឯ ចំណុចដែលគួរឲ្យកត់សម្គាល់នៅក្នុងប្រទេសកម្ពុជាវិញ គឺប្រទេសកម្ពុជាមានការរៀបអាពាហ៍ពិពាហ៍ទាំងបែបប្រពៃណី និងការរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់។ ការរៀបអាពាហ៍ពិពាហ៍តាមបែបប្រពៃណី ទំនៀមទម្លាប់ គឺជាការរក្សាអភិរក្ស និងប្រតិបត្តិនូវអរិយធម៌ ដ៏មានតម្លៃរបស់ប្រទេសកម្ពុជាតាំងពីបុរាណកាលមកដល់បច្ចុប្បន្ន។ ហើយការរៀបអាពាហ៍ពិពាហ៍តាមច្បាប់វិញ ដោយសារតែប្រទេសកម្ពុជា គឺជានីតិរដ្ឋ ដែលការរៀបអាពាហ៍ពិពាហ៍តាមច្បាប់សំដៅលើការបង្ហាញឆន្ទៈ ក្នុងការបង្កើតចំណងគតិយុត្តចងភ្ជាប់រូបវន្តបុគ្គលឲ្យក្លាយទៅជាសហព័ទ្ធស្របច្បាប់តាមរយៈការចុះសំបុត្រអាពាហ៍ពិពាហ៍។ ការរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់នេះ ត្រូវបានច្បាប់នៃប្រទេសកម្ពុជាទទួលស្គាល់ និងការពារ។ ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩ នៃព្រះរាជាណាចក្រកម្ពុជាបានឲ្យនិយមន័យ អាពាហ៍ពិពាហ៍ ថាជាកិច្ចសន្យាដ៏ឱឡារិកមួយ ធ្វើឡើងដោយបុរសម្នាក់ និងស្ត្រីម្នាក់ ដែលបានប្តេជ្ញាថាខ្លួននឹងរួមសមគ្គសង្វាសជាមួយគ្នាតាមបញ្ញត្តិច្បាប់ ហើយមិនអាចរំលាយទៅវិញបានតាមទំនើងចិត្តរបស់ខ្លួន។[1] សូមបញ្ជាក់ផងដែរថា បើពលរដ្ឋគ្រាន់តែរៀបអាពាហ៍ពិពាហ៍តាមបែបប្រពៃណីតែមួយមុខ នោះភាគីមិនទាន់បង្កើតនូវទំនាក់ទំនង គតិយុត្តជាមួយគ្នានៅឡើយទេ ហើយការរស់នៅបែបនេះ ច្បាប់កំណត់ថាភាគីជាអនីតិសង្វាសនឹងគ្នា។ ដោយហេតុនេះហើយ ទើបបានជាការរៀបអាពាហ៍ពិពាហ៍ដែលទទួលស្គាល់ដោយច្បាប់ មានអានុភាពគតិយុត្តដល់ ភាគីដែលជាសហព័ទ្ធ ជាហេតុនាំឲ្យភាគីមិនអាចរំលាយបានដោយងាយៗ ដូចការរៀបអាពាហ៍ពិពាហ៍តាមបែបប្រពៃណីតែមួយមុខឡើយ។

យ៉ាងណាមិញ នៅក្នុងផ្លូវជីវិតជា ប្តី និងប្រពន្ធជាមួយគ្នា តែងតែមានជួបនូវប្រទះបញ្ហាមួយចំនួនទាក់ទងនឹងជីវភាពរស់នៅក្នុងគ្រួសារ។ មានគ្រួសារខ្លះ ក៏ជួបនូវបញ្ហាតូច ដែលងាយនឹងដោះស្រាយ ហើយគ្រួសារខ្លះទៀត ក៏ជួបនូវបញ្ហាធំ ពិបាកនឹងដោះស្រាយ ហើយអាចនឹងប្រឈមទៅដល់ការបែកបាក់។ គោលបំណងនៃអាពាហ៍ពិពាហ៍ គឺការផ្តល់សុភមង្គលដល់មនុស្ស តែបើអាពាហ៍ពិពាហ៍នោះបន្សល់ត្រឹមតែ ភាពឈឺចាប់ផ្សាទំនាស់ នោះការលែងលះនឹងឈានមកដល់ផ្លូវនៃជីវិតអាពាហ៍ពិពាហ៍។ ច្បាប់មិនបានបង្ខិតបង្ខំឲ្យពលរដ្ឋដែលរស់នៅមិនចុះសម្រុងនឹងគ្នា នៅតែបន្តឲ្យរស់នៅទាំងលំបាកជាមួយគ្នា ហេតុនេះហើយ ច្បាប់បានផ្តល់សិទ្ធិឲ្យភាគី

[1] មាត្រា៣ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារ, លេខ ៥៦ ក្រ, ២៦ កក្កដា ១៩៨៩។

ទាមទារការលែងលះបាន។ ត្រង់ចំណុចនេះ ចំពោះប្តី និងប្រពន្ធដែលរស់នៅក្នុងលក្ខណៈជា អនីតិសង្វាស មិនចាំបាច់ទាមទារការលែងលះស្របច្បាប់ដោយតុលាការ ដូចប្តី និងប្រពន្ធដែលរស់នៅក្នុង លក្ខណៈជាសហព័ទ្ធឡើយ ពីព្រោះថាការរស់នៅបែបអនីតិសង្វាស គឺមិនទាន់បង្កើតចំណងគតិយុត្តរវាងភាគីនៅឡើយ។ តែប្តី និងប្រពន្ធដែលរស់នៅជាសហព័ទ្ធនឹងគ្នាវិញ គឺត្រូវប្តឹងទាមទារទៅតុលាការដើម្បី រំលាយទំនាក់ទំនងគតិយុត្តនោះ។ មួយវិញទៀត ការរស់នៅជាប្តី និងប្រពន្ធជាមួយគ្នា ប្រាកដណាស់ថាមានការជាប់ពាក់ព័ន្ធនឹងកម្មវត្ថុផ្សេងទៀតជាច្រើនដូចជា៖ ការមានកូនជាមួយគ្នា ទ្រព្យសម្បត្តិ សិទ្ធិ កាតព្វកិច្ច និងការប្រើប្រាស់នាមត្រកូលជាដើម។ ម៉្យាងវិញទៀត ការបញ្ចប់ទំនាក់ទំនងអាពាហ៍ពិពាហ៍ គឺបណ្តាលមកពីមូលហេតុផ្សេងៗនៅក្នុងគ្រួសារនីមួយៗ ដូចសុភាសិតបុរាណលោកតែងពោលថា *«ចង្អៀងផ្ទះអ្នកណា ក្តៅតែផ្ទះអ្នកនោះ»*។ ការលែងលះខ្លះភាគីបញ្ចប់ទៅ ទាំងចងភ្ជាប់ជាមួយទំនាស់ទទឹងទទៃ លើការសម្រេចបែកចែកគ្នានូវសិទ្ធិ និងកាតព្វកិច្ច ហើយការលែងលះខ្លះទៀត ភាគីយល់ព្រមបញ្ចប់ដោយសន្តិវិធី ដើម្បីកាត់បន្ថយនូវការខាតបង់។ ដូចនេះហើយ នៅព្រះរាជាណាចក្រកម្ពុជា ចំពោះការដោះស្រាយ រឿងក្តីលែងលះគឺត្រូវបានដោះស្រាយអាស្រ័យលើការព្រមព្រៀង ឬ មិនព្រមព្រៀងរបស់ភាគី។ ព្រះរាជាណាចក្រកម្ពុជា មានច្បាប់មួយចំនួន សម្រាប់ដោះស្រាយរឿងក្តីលែងលះ របស់ពលរដ្ឋខ្មែរ ដូចជា៖ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ២០១០, និងច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ឆ្នាំ២០១០ ជាដើម។

ដោយសារតែនៅក្នុងសង្គមសព្វថ្ងៃនេះ ការលែងលះរវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ នៅកម្ពុជា មានការជាប់ពាក់ព័ន្ធច្រើនចំណុច ទាំងកូន ទាំងទ្រព្យសម្បត្តិ អាហារកាតព្វកិច្ចផ្សេងៗ ដូចនេះហើយទើបបានជា នាំឲ្យកើតមានចម្ងល់ជាច្រើននៅជុំវិញការលែងលះនៅកម្ពុជា។ ចម្ងល់ទាំងឡាយជុំវិញនឹងការលែងលះមានដូចជា៖

- តើមូលហេតុអ្វីខ្លះដែលបណ្តាលឲ្យភាគីទាមទារការលែងលះ?
- តើការលែងលះនៅកម្ពុជា ត្រូវអនុលោមតាមបទដ្ឋានគតិយុត្តអ្វីខ្លះ?
- តើការលែងលះដែលភាគីមានការព្រមព្រៀងរវាងគ្នា ត្រូវប្រព្រឹត្តទៅបែបណាខ្លះ តាមរយៈការដោះស្រាយនៅតុលាការ?
- ចុះចំណែកឯ ការលែងលះដែលភាគីគ្មានការព្រមព្រៀងរវាងគ្នាវិញ តើត្រូវប្រព្រឹត្តទៅបែបណាខ្លះ តាមរយៈការដោះស្រាយនៅតុលាការ?
- ការលែងលះតែងពាក់ព័ន្ធនឹងការបែងចែកច្រើនចំណុចដូចជា៖ កូន ទ្រព្យសម្បត្តិ អាហារកាតព្វកិច្ច សិទ្ធិ និងករណីយកិច្ចផ្សេងទៀត ដូច្នេះតើតុលាការត្រូវសម្រេចបែបណាលើការបែងចែកទាំងនោះ?
- តើការលែងលះបន្សល់នូវអានុភាពបែបណាខ្លះដល់ភាគី និងបុគ្គលដែលពាក់ព័ន្ធ?

ដោយសង្កេតឃើញថា ការលែងលះមានលក្ខណៈស្មុគស្មាញ ជាងការរៀបអាពាហ៍ពិពាហ៍ទៅទៀត ហើយការលែងលះនេះក៏មានបន្សល់នូវចម្ងល់ជាច្រើនដល់ពលរដ្ឋក្នុងសង្គម អ្នកសិក្សាស្រាវជ្រាវ ពិសេសសាមីជន ដែលមានបំណងលែងលះ ទើបនាំឲ្យមានការស្រាវជ្រាវប្រធានបទខាងលើនេះឡើង។ កាន់តែពិសេសជាងនេះទៅទៀត ដោយសារតែនីតិវិធីក្នុងការលែងលះ ត្រូវអនុលោមដោយប្រព័ន្ធច្បាប់នីតិវិធីជាច្រើន ហើយនីតិវិធីក្នុងការដោះស្រាយទាំងនោះ មានលក្ខណៈប្លែកពីគ្នាអាស្រ័យលើរឿងក្តីលែងលះ ទើបបង្កើតជាការជំរុញកម្លាំងចិត្តឲ្យមានការខិតខំស្រាវជ្រាវប្រធានបទ «**ការលែងលះរវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរនៅកម្ពុជា**» ដើម្បីបកស្រាយចម្ងល់ និងជាកូនសោរបំភ្លឺចំណោទបញ្ហាខាងលើ។

ដោយសារតែ ការលែងលះមានច្រើនប្រភេទណាស់ ដូចជា៖ ការលែងលះរវាងពលរដ្ឋដែលមានសញ្ជាតិខ្មែរដូចគ្នា, ការលែងលះរវាងពលរដ្ឋសញ្ជាតិខ្មែរ និងជនបរទេស, ការលែងលះរវាងពលរដ្ឋសញ្ជាតិខ្មែរដូចគ្នា តែធ្វើនៅបរទេស, ការលែងលះរវាងពលរដ្ឋសញ្ជាតិបរទេស តែចង់លែងលះនៅលើទឹកដីប្រទេសកម្ពុជា និងការលែងលះផ្សេងៗទៀតជាច្រើន។ ដូចនេះ ដើម្បីរក្សាប្រសិទ្ធភាពលើការស្រាវជ្រាវ ប្រធានបទអំពីការលែងលះខាងលើនេះ នឹងសិក្សាស្រាវជ្រាវត្រឹមកម្រិតនៃការលែងលះដែលធ្វើឡើង រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ ហើយប្រព្រឹត្តទៅនៅលើទឹកដីនៃប្រទេសកម្ពុជាតែប៉ុណ្ណោះ។

សារៈប្រយោជន៍នៃប្រធានបទស្រាវជ្រាវនេះ គឺអាចធ្វើឲ្យអ្នកសិក្សាទាំងឡាយ យល់ដឹងកាន់តែស៊ីជម្រៅអំពីស្ថានភាពក្នុងការដោះស្រាយវិវាទលែងលះនៅកម្ពុជា ព្រមទាំងយល់ដឹងអំពី នីតិវិធីដែលបានប្រព្រឹត្តទៅនៅក្នុងការលែងលះរវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរនៅប្រទេសកម្ពុជា ចាប់ពីពេលដែលកើតមាន មូលហេតុនៃការលែងលះ រហូតឈានទៅដល់ដំណាក់កាល នៃការដាក់ពាក្យសុំ ឬ ពាក្យបណ្តឹងលែងលះទៅកាន់តុលាការដែលមានសមត្ថកិច្ច ហើយនឹងការដោះស្រាយទៅតាមលំហូរនីតិវិធីរដ្ឋប្បវេណីរហូតដល់បញ្ចប់នីតិវិធីរដ្ឋប្បវេណីនៅក្នុងរឿងក្តីលែងលះ។ លើសពីនេះទៅទៀត តាមរយៈប្រធានបទនេះ នឹងបង្ហាញឲ្យកាន់តែច្បាស់ទៀត អំពីបទបញ្ញត្តិច្បាប់ ដែលត្រូវយកមកអនុលោមនៅក្នុងនីតិវិធីដោះស្រាយការលែងលះរវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរនៅកម្ពុជា ដោយមានការព្រមព្រៀង និងការលែងលះដោយមិនមានការព្រមព្រៀង។ ជាពិសេស គឺការបំភ្លឺនូវចម្ងល់ជុំវិញការលែងលះដែលកំពុងកើតមាននៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្ននេះ។

ដូចនេះ ប្រធានបទស្រាវជ្រាវអំពី «**ការលែងលះរវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ នៅកម្ពុជា**» ខាងលើនេះ ត្រូវបានបែងចែកការបកស្រាយជា បួនជំពូក ដូចខាងក្រោម៖

**ជំពូកទី១ ៖ សញ្ញាណទូទៅនៃការលែងលះ** ដែលបកស្រាយ ជុំវិញមូលហេតុដែលនាំឲ្យមានការលែងលះ ព្រមជាមួយនឹងបទដ្ឋានគតិយុត្តសំខាន់ៗ ដែលត្រូវប្រើប្រាស់ក្នុងការដោះស្រាយការលែងលះនៅប្រទេសកម្ពុជា។

**ជំពូកទី២ ៖ ការលែងលះដោយការព្រមព្រៀង** ដែលបកស្រាយអំពី នីតិវិធីក្នុងការដោះស្រាយរឿងក្តីលែងលះ ក្នុងករណីដែលភាគីព្រមព្រៀងបញ្ចប់ទំនាក់ទំនងអាពាហ៍ពិពាហ៍ដោយសន្តិវិធី និងគ្មានការខ្វែងគំនិតលើចំណុចណាមួយនៅក្នុងការស្នើសុំលែងលះ។

**ជំពូកទី៣ ៖ ការលែងលះដោយគ្មានការព្រមព្រៀង** ដែលបកស្រាយអំពី នីតិវិធីក្នុងការដោះស្រាយរឿងក្តីលែងលះដែលមានលក្ខណៈជាបណ្តឹង ដោយសារតែភាគីមិនមានការព្រមព្រៀងគ្នា មួយផ្នែក ឬទាំងស្រុងនៅក្នុងការលែងលះ។

**ជំពូកទី៤ ៖ អានុភាពនៃការលែងលះ** ដែលបកស្រាយអំពី អានុភាពដែលបន្សល់ក្រោយពេលចំណងអាពាហ៍ពិពាហ៍ត្រូវបានបញ្ចប់ ជាពិសេសគឺបកស្រាយអំពីការសម្រេចបែងចែក សិទ្ធិ និងកាតព្វកិច្ចទាំងឡាយជូនភាគីលែងលះ។

# ជំពូកទី១
# សញ្ញាណទូទៅ
# នៃការលេខលះ

# ជំពូកទី១

# សញ្ញាណទូទៅនៃការលែងលះ

ការរៀបអាពាហ៍ពិពាហ៍ ត្រូវបានច្បាប់កំណត់ថា គឺជាកិច្ចសន្យាដ៏ឱឡារិករវាងគូស្រករពីរនាក់ បុរស និង នារី ដែលសម្រេចចិត្តបង្កើតចំណងគតិយុត្តរួមគ្នាក្នុងនាមជា សហព័ទ្ធ ហើយព្រមរួមរស់ជាមួយគ្នា ដែល ទំនាក់ទំនងនេះក៏ត្រូវបានទទួលស្គាល់ដោយច្បាប់បន្ទាប់ពីពេលដែលអ្នកទាំងពីរ បានទៅចុះសំបុត្រអាពាហ៍ពិពាហ៍ ជាមួយគ្នា។[2] ចំណងអាពាហ៍ពិពាហ៍ គឺជាការប្តេជ្ញាចិត្តរវាងសហព័ទ្ធទាំងពីរនៅចំពោះមុខច្បាប់ ដូច្នេះចំណង គតិយុត្តនេះ មិនអាចបញ្ចប់ទៅវិញបានតាមទំនើងចិត្តរបស់ភាគីបានឡើយ។ អាពាហ៍ពិពាហ៍ ដែលត្រូវបាន ទទួលស្គាល់ដោយច្បាប់ ទាមទារឲ្យភាគីដែលមានឆន្ទៈចង់បញ្ចប់ទំនាក់ទំនងគតិយុត្តនឹងគ្នា ត្រូវធ្វើការ លែងលះតាមផ្លូវតុលាការទើបមានអានុភាពកាត់ផ្តាច់ចំណងអាពាហ៍ពិពាហ៍នោះបាន។ ម៉្យាងវិញទៀត នៅក្នុង អំឡុងពេលដែលភាគីបានរស់នៅជាសហព័ទ្ធនឹងគ្នា ភាគីបានបង្កើតនូវចំណងរវាងគ្នាជាច្រើនដូចជា មានបុត្រ, ការប្រើនាមត្រកូល, ទ្រព្យសម្បត្តិដែលទទួលបានរួមគ្នា ព្រមទាំងសិទ្ធិ និងកាតព្វកិច្ចផ្សេងទៀត។ ហេតុនេះ នៅ ពេលដែលមានការបញ្ចប់ចំណងអាពាហ៍ពិពាហ៍ ក៏នាំឲ្យមានការបែងចែងទៅលើសិទ្ធិ និងកាតព្វកិច្ចទាំងនេះ។ ការដោះស្រាយ លើបញ្ហាទាំងនោះ គឺមានតែតុលាការប៉ុណ្ណោះដែលមានអំណាចក្នុងការសម្រេចលើការលែងលះ និងការទាមទារបន្ទាប់បន្សំក្នុងការលែងលះ។ ជាបឋមនៅក្នុងជំពូកទី១ អំពីសញ្ញាណទូទៅនៃការលែងលះនេះ នឹងសិក្សាលម្អិតអំពី (១.១.) **និយមន័យនៃការលែងលះ**, (១.២.) **ស្ថានភាពទូទៅពាក់ព័ន្ធនឹង សហព័ទ្ធក្នុងចំណងអាពាហ៍ពិពាហ៍**, (១.៣.) **មូលហេតុនៃការលែងលះ**, និង (១.៤.) **បទដ្ឋាន គតិយុត្តពាក់ព័ន្ធនឹងការលែងលះ ។**

## ១.១. និយមន័យនៃការលែងលះ

ការលែងលះរវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ នៅក្នុងព្រះរាជាណាចក្រកម្ពុជា គឺសំដៅដល់ការបញ្ចប់នូវ ទំនាក់ទំនងអាពាហ៍ពិពាហ៍ស្របច្បាប់រវាង សហព័ទ្ធជាពលរដ្ឋខ្មែរដែលនៅរស់។ ពលរដ្ឋខ្មែរ នៅត្រង់ចំណុចនេះ គឺសំដៅដល់រូបវន្តបុគ្គលដែលត្រូវបានច្បាប់នៃព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ថា ជននោះមានសញ្ជាតិខ្មែរ។[3] រីឯ និយមន័យនៃការលែងលះនៅកម្ពុជាក្នុងន័យនេះ គឺសំដៅដល់ប្តី និងប្រពន្ធ ដែលជាសហព័ទ្ធស្របច្បាប់បាន សម្រេចធ្វើការលែងលះនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា តាមរយៈពាក្យសុំ ឬ ពាក្យបណ្តឹង ដោយអនុលោម ទៅតាមច្បាប់រដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា។ ដូច្នេះ អត្ថន័យនៃការលែងលះរវាងពលរដ្ឋខ្មែរ និង ពលរដ្ឋខ្មែរ នៅកម្ពុជា គឺជាការលែងលះដែលធ្វើឡើងរវាងពលរដ្ឋដែលមានសញ្ជាតិខ្មែរ និងជាសហព័ទ្ធស្រប

[2] មាត្រា៣ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារ, លេខ ៥៦ ក្រ, ២៦ កក្កដា ១៩៨៩។

[3] មាត្រា៦ នៃច្បាប់ស្តីពីសញ្ជាតិ, លេខ នស/រកម/០៦១៨/០០៨, ២១ មិថុនា ២០១៨។

ច្បាប់នឹងគ្នា ទាមទាររំលាយចំណងអាពាហ៍ពិពាហ៍ដោយតុលាការ។[4] គួរបញ្ជាក់នៅត្រង់ចំណុចនេះផងដែរថា ការលែងលះទាំងអស់នោះ មិនមែនសុទ្ធសឹងតែបង្កឲ្យកើតមានជាជម្លោះរវាងភាគីនៃអាពាហ៍ពិពាហ៍ទាំងសងខាងឡើយ។ នៅក្នុងសង្គមសព្វថ្ងៃមាន ការលែងលះខ្លះ ភាគីបានព្រមព្រៀងក្នុងការបញ្ចប់ចំណងអាពាហ៍ពិពាហ៍ដោយសន្តិវិធីហើយក៏មានការលែងលះខ្លះទៀតដែលភាគីបញ្ចប់ទៅដោយមិនមានការព្រមព្រៀងរវាងគ្នា។ ដូច្នេះ សម្រាប់និយមន័យអំពីការលែងលះដែលអនុលោមតាមប្រព័ន្ធច្បាប់នៃព្រះរាជាណាចក្រកម្ពុជា គឺបានឲ្យនិយមន័យការលែងលះ ចែកចេញជាពីរប្រភេទដូចជា៖ (**១.១.១.**) **និយមន័យការលែងលះដោយការព្រមព្រៀង** និង (**១.១.២.**) **និយមន័យការលែងលះដោយគ្មានការព្រមព្រៀង។**

### ១.១.១. និយមន័យការលែងលះដោយការព្រមព្រៀង

ការលែងលះដោយការព្រមព្រៀង គឺជាការរំលាយនូវចំណងអាពាហ៍ពិពាហ៍ស្របច្បាប់រវាងសហព័ទ្ធនៅរស់ដែលការព្រមព្រៀងនេះ កើតចេញពីឆន្ទៈពិតប្រាកដរបស់សហព័ទ្ធទាំងពីរ។[5] ការលែងលះដោយមានការព្រមព្រៀងនេះ អាចប្រព្រឹត្តទៅបាន គឺនៅពេលដែលសហព័ទ្ធទាំងពីរមានឆន្ទៈស្របគ្នា ក្នុងការព្រមព្រៀងលែងលះ ហើយថែមទាំងបានព្រមព្រៀងគ្នារួចជាស្រេច ក្នុងការកំណត់អំពីការបែងចែកទ្រព្យសម្បត្តិក្រោយការលែងលះ ឬ ការព្រមព្រៀងលើការកំណត់ពីអំណាចមេបា ឬអាហារកាតព្វកិច្ចជាដើម។ បន្ថែមឲ្យកាន់តែច្បាស់ទៅលើចំណុចនេះ គឺចង់សំដៅថា ករណីដែលសហព័ទ្ធ មានការព្រមព្រៀងលែងលះគ្នា ដោយការឯកភាពនេះមានត្រឹមតែការព្រមព្រៀងផ្តាច់នូវចំណងអាពាហ៍ពិពាហ៍ ក៏ប៉ុន្តែភាគីពុំមានការព្រមព្រៀងគ្នាទៅលើការបែងចែកសិទ្ធិ និងកាតព្វកិច្ចផ្សេងៗក្រោយការលែងលះ នោះតាមរយៈស្មារតីនៃច្បាប់រដ្ឋប្បវេណីមិនកំណត់ថាចូលជាការលែងលះដោយព្រមព្រៀងឡើយ។ ការលែងលះដោយព្រមព្រៀង អាចប្រព្រឹត្តទៅបានលុះត្រាតែភាគីបានព្រមព្រៀងគ្នារួចជាស្រេចលើសិទ្ធិ និងកាតព្វកិច្ច ដោយពុំមានវិវាទ រវាងគ្នា ហើយសកម្មភាពនេះកើតឡើងដោយឆន្ទៈផ្ទាល់ និងពិតប្រាកដរបស់ភាគី។ ជាទូទៅ នៅក្នុងសង្គមជាក់ស្តែងសហព័ទ្ធ ដែលសម្រេចចិត្តក្នុងការលែងលះដោយព្រមព្រៀង តែងតែធ្វើនូវកិច្ចសន្យាព្រមព្រៀងលែងលះ ដែលមានកំណត់យ៉ាងច្បាស់ពីការព្រមព្រៀងក្នុងការបែងចែកសិទ្ធិ និងកាតព្វកិច្ចផ្សេងៗរវាងភាគីទាំងពីរ ដោយភ្ជាប់មកជាមួយឯកសារពាក់ព័ន្ធផ្សេងៗ នៅពេលដែលភាគីដាក់ពាក្យសុំលែងលះ មកកាន់តុលាការ។

### ១.១.២. និយមន័យការលែងលះដោយគ្មានការព្រមព្រៀង

ការលែងលះដោយគ្មានការព្រមព្រៀង គឺជាការទាមទារឲ្យបញ្ចប់ចំណងអាពាហ៍ពិពាហ៍ ស្របច្បាប់ដោយសាលក្រមរបស់តុលាការ តាមរយៈការដាក់ពាក្យបណ្តឹងដោយភាគី។ ការលែងលះដោយគ្មានការព្រមព្រៀង

[4] មាត្រា៩៧៨-៩៧៩ នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[5] មាត្រា៩៧៩ នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

នេះកើតមានជារឿយៗ នៅក្នុងសង្គមខ្មែរបច្ចុប្បន្ន ដោយសារតែភាគីលែងលះ មិនចុះសម្រុងរវាងគ្នារហូតឈាន ដល់ការសម្រេចចិត្តចែកផ្លូវគ្នាទាំងជម្លោះ។ ការបែកបាក់ទំនាក់ទំនងអាពាហ៍ពិពាហ៍បែបនេះ មិនមែនបញ្ចប់ ដោយសន្តិវិធីនោះទេ ពោលគឺភាគីអាចមានមូលហេតុច្រើនដែលនាំឲ្យខ្វែងគំនិតយោបល់ ឆន្ទៈផ្ទុយគ្នា បណ្ដាល ឲ្យមានការប្ដឹងលែងលះ។ គួរបញ្ជាក់ផងដែរថា ការលែងលះដោយគ្មានការព្រមព្រៀង កើតឡើងដោយសារ ស្ថានភាពវិវាទដូចជា៖ ភាគីណាមួយទាមទារលែងលះតែភាគីម្ខាងទៀតមិនឯកភាពលែងលះ ឬ បញ្ហាមិន ព្រមព្រៀងលើការបែងចែកទ្រព្យសម្បត្តិ និង អំណាចមេបាលើកូនៗ។ ភាគីមានសិទ្ធិក្នុងការដាក់បណ្ដឹងទាមទារ លែងលះ នៅតុលាការដែលមានសមត្ថកិច្ច ឬនៅក្រុមប្រឹក្សាឃុំ-សង្កាត់។[6] ប្ដី ឬប្រពន្ធដែលដាក់ពាក្យបណ្ដឹង លែងលះនៅសាលាដំបូងរាជធានី-ខេត្ត ហៅថា «ដើមចោទ» និងភាគីម្ខាងទៀត ហៅថា «ចុងចម្លើយ»។

## ១.២. ស្ថានភាពទូទៅពាក់ព័ន្ធនឹងសហព័ទ្ធក្នុងចំណងអាពាហ៍ពិពាហ៍

នៅមុនពេលលែងលះ គឺនៅពេលដែលសហព័ទ្ធកំពុងស្ថិតក្នុងចំណងអាពាហ៍ពិពាហ៍រួមគ្នា នោះភាគីប្ដី និងប្រពន្ធ តែងតែមាននូវទំនាក់ទំនង ឬ ករណីយកិច្ចដែលជាកម្មវត្ថុត្រូវធ្វើរួមគ្នា។ ចំពោះ ទំនាក់ទំនងរវាង សហព័ទ្ធ គឺជាភាពចំបាច់ខ្លាំងណាស់ ពីព្រោះថាទំនាក់ទំនងមនោសញ្ចេតនារវាងគ្នា, ទំនាក់ទំនងសាច់ញាតិរួម គ្នា និងការរស់នៅក្នុងលក្ខណៈជាប្ដីប្រពន្ធរួមគ្នាមិនអាចខ្វះបានឡើយសម្រាប់ចំណងអាពាហ៍ពិពាហ៍។ ចំណែកឯ ករណីយកិច្ចរួមគ្នាមួយចំនួនវិញ ប្ដីប្រពន្ធត្រូវតែមានករណីយកិច្ចដូចតទៅ៖ ករណីយកិច្ចរួមរស់ជីវភាពជាមួយគ្នា គឺ ប្ដី និងប្រពន្ធត្រូវតែរួបរួមគ្នាកសាងគ្រួសារ មួយរួមគ្នាដោយរស់នៅក្នុងជីវភាពមាន ឬ ក្រជាមួយគ្នា, ករណីយកិច្ច សហការគ្នា គឺ ប្ដីនិងប្រពន្ធត្រូវតែសហការគ្នានៅក្នុងគ្រួសារ ទាំងការស្វែងរកប្រាក់មកចិញ្ចឹមផ្គត់ផ្គង់គ្រួសារ និងការចិញ្ចឹមបីបាច់ថែរក្សាកូនៗ, ករណីយកិច្ចសង្គ្រោះគ្នាទៅវិញទៅមក គឺ ប្ដី និងប្រពន្ធត្រូវរស់នៅរួមសុខទុក្ខ ជាមួយគ្នា មិនបោះបង់ចោលគ្នា ហើយជួយគ្នាទៅវិញទៅមក។[7] លើសពីនេះទៅទៀត នៅក្នុងស្ថានភាពជាក់ស្ដែង សហព័ទ្ធតែងមានករណីយកិច្ចរួមគ្នាផ្សេងៗទៀតជាច្រើន ដែលភាគីទាំងពីរត្រូវការឲ្យដៃគូបំពេញឲ្យគ្នាទៅវិញ ទៅមក។ បន្ថែមត្រង់ចំណុចនេះ នៅក្នុងអំឡុងពេលនៃអាពាហ៍ពិពាហ៍ សហព័ទ្ធតែងតែមានការជាប់ពាក់ព័ន្ធ គ្នាទៅនឹងស្ថានភាព សំខាន់ៗដូចជា ការមានកូនរួមគ្នា, ឬការប្រើប្រាស់នាមត្រកូលរួមគ្នា, ឬការបន្សល់នូវ ទ្រព្យសម្បត្តិរួមគ្នា។ ផ្ទុយមកវិញ ប្រសិនបើភាគីដែលជាសហព័ទ្ធនឹងគ្នា មិនអាចខិតខំថែរក្សានូវទំនាក់ទំនង មនោសញ្ចេតនានៃអាពាហ៍ពិពាហ៍ទេ និងមិនបានចូលរួមក្នុងបំពេញករណីយកិច្ចជាមួយគ្នាឲ្យបានល្អទេ នោះ ចំណងអាពាហ៍ពិពាហ៍នឹងត្រូវបែកបាក់ ហើយអាចឈានដល់ការលែងលះ និងការទាមទារឲ្យមានការបែងចែកលើ សិទ្ធិ និងកាតព្វកិច្ចក្រោយការលែងលះ។ ភាគីនៃអាពាហ៍ពិពាហ៍អាចមានសិទ្ធិ ធ្វើបណ្ដឹងទាមទារលែងលះ

[6] មាត្រា៩៨២ នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[7] មាត្រា៩៦៦ នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

ដោយឈរលើបញ្ហាទាក់ទងនឹងកម្មវត្ថុដូច ដែលមានរៀបរាប់ខាងលើនេះ និងមូលហេតុដែលច្បាប់អាចទទួលយកមកសម្រេចសេចក្តីបាន។

### ១.៣. មូលហេតុនៃការលែងលះ

សហព័ទ្ធនៃចំណងអាពាហ៍ពិពាហ៍ដែលសម្រេចចិត្តទាមទារការលែងលះ គឺប្រាកដជាមានមូលហេតុនៅពីក្រោយដែលនាំឲ្យភាគីសម្រេចចិត្តដូច្នេះ។ ជាការពិតណាស់ នៅក្នុងរង្វង់គ្រួសារនីមួយៗ តែងតែកើតមានបញ្ហាខុសប្លែកគ្នា ដែលមានតែសមាជិកនៃក្រុមគ្រួសារផ្ទាល់តែប៉ុណ្ណោះដែលដឹង ហេតុនេះការបែកបាក់នៃចំណងអាពាហ៍ពិពាហ៍រហូតឈានដល់ការលែងលះ អាចបណ្តាលមកពីមូលហេតុផ្សេងៗគ្នាចំពោះគ្រួសារនីមួយៗ។ ច្បាប់ត្រូវបានបង្កើតឡើងដើម្បីធានា និងការពារផលប្រយោជន៍របស់មនុស្សក្នុងសង្គម ជាពិសេសបញ្ញត្តិអំពីអាពាហ៍ពិពាហ៍ត្រូវបានការពារដោយច្បាប់រដ្ឋប្បវេណី ក្នុងគោលបំណងរក្សាសុភមង្គលក្នុងគ្រួសារ ហេតុនេះស្មារតីរបស់ច្បាប់រដ្ឋប្បវេណី ក៏គ្មានចរិកលក្ខណៈបង្ខំឲ្យមនុស្សពីរនាក់ដែលមិនមានមនោសញ្ចេតនានឹងគ្នា បន្តរស់នៅជាមួយគ្នាទាំងលំបាកនោះឡើយ។ ដោយយល់ឃើញដូចនេះ ក្រមរដ្ឋប្បវេណីបានកំណត់ពីមូលហេតុសមហេតុផលមួយចំនួន ដើម្បីឲ្យភាគីដែលរៀបបានអាពាហ៍ពិពាហ៍ស្របតាមច្បាប់ មានសិទ្ធិក្នុងការដាក់ពាក្យបណ្តឹងទាមទារលែងលះ។[8] មូលហេតុនៃការលែងលះរវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ នៅកម្ពុជាដែលសមហេតុផលទៅតាមច្បាប់បច្ចុប្បន្ននេះ គឺមាន៖ (**១.៣.១.**) **អំពើផិតក្បត់**, (**១.៣.២.**) **ការបោះបង់សហព័ទ្ធចោលដោយគ្មានមូលហេតុត្រឹមត្រូវ**, (**១.៣.៣.**) **អវត្តមាន ឬ ការបាត់ខ្លួន**, (**១.៣.៤.**) **ការរស់នៅបែកគ្នារវាងសហព័ទ្ធ** និង (**១.៣.៥.**) **ករណីធ្ងន់ធ្ងរមិនអាចបដិទានទំនាក់ទំនងឡើងវិញបាន។**

#### ១.៣.១. អំពើផិតក្បត់

អំពើផិតក្បត់ គឺជាមូលហេតុមួយដែលត្រូវបានកំណត់ដោយច្បាប់រដ្ឋប្បវេណី ដែលភាគីមានសិទ្ធិលើកជាមូលហេតុក្នុងការដាក់ពាក្យបណ្តឹងលែងលះ ដោយសំអាងលើចំណុចនេះ។[9] ការផិតក្បត់ គឺសំដៅដល់ការរួមសេវនកិច្ចរវាងបុរស ឬ ស្ត្រីដែលមានចំណងអាពាហ៍ពិពាហ៍ពីមុនមិនទាន់រលាយជាមួយនឹងបុរស ឬ ស្ត្រីដទៃផ្សេងទៀត ក្រៅពីសហព័ទ្ធរបស់ខ្លួន។[10] ទន្ទឹមនឹងនេះដែរ ហេតុផលដែលច្បាប់កំណត់ថាការផិតក្បត់ ក៏អាចជាមូលហេតុដែលភាគីមានសិទ្ធិទាមទារនូវការលែងលះ ព្រោះថាទង្វើផិតក្បត់ គឺជាការប្រាស់ចាកពីគោលបំណងនៃអាពាហ៍ពិពាហ៍។ អាពាហ៍ពិពាហ៍ តម្រូវឲ្យប្តី និងប្រពន្ធ មានស្វាមីភក្តីជាមួយគ្នា មិនក្បត់ផិតគ្នា។ ជាពិសេសប្រទេសកម្ពុជា មានច្បាប់ដែលទទួលស្គាល់ថា អាពាហ៍ពិពាហ៍ត្រូវតែគោរពតាមគោលការណ៍ឯកពន្ធភាព មាន

[8] មាត្រា៩៧៨ នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[9] មាត្រា៩៧៨(១) ចំណុច(ក) នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[10] មាត្រា៧ នៃច្បាប់ស្តីពីឯកពន្ធភាព, លេខ នស/រកម/១០០៦/០២៦, ២១ តុលា ២០០៦។

ន័យថាជាគោលការណ៍ប្តីមួយប្រពន្ធមួយ (Monogamy)។[11] ស្វែងយល់ពីតថភាពជាក់ស្តែងនៅក្នុងសង្គមវិញ បានបង្ហាញថា អាពាហ៍ពិពាហ៍ដែលមានជនទីបីជ្រៀតជ្រែក មានការលួចលាក់ គ្មានភាពស្មោះត្រង់នឹងគ្នា គឺជាអាពាហ៍ពិពាហ៍ដែលប្រេះស្រាំ ហើយទង្វើផិតក្បត់នេះ ក៏ជះឥទ្ធិពលមិនល្អដល់ប្រពៃណីទំនៀមទម្លាប់ និងសេចក្តីថ្លៃថ្នូរនៅក្នុងសង្គមផងដែរ។ អំពើផិតក្បត់ផ្តល់នូវទុក្ខទាំងផ្លូវកាយ និង ផ្លូវចិត្តចំពោះភាគីនៃអាពាហ៍ពិពាហ៍ ហេតុនេះហើយទើបក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា កំណត់ថា អំពើផិតក្បត់ជាមូលហេតុដើម្បីទាមទារការលែងលះ។

### ១.៣.២. ការបោះបង់សហព័ទ្ធចោលដោយគ្មានមូលហេតុត្រឹមត្រូវ

ការបោះបង់សហព័ទ្ធចោលដោយគ្មានមូលហេតុត្រឹមត្រូវ ក៏ជាមូលហេតុដែលច្បាប់រដ្ឋប្បវេណីបានកំណត់ថាជាមូលហេតុនៃការលែងលះ។[12] ការចុះចោលត្រង់ចំណុចនេះ ចង់សំដៅថាភាគីទាំងពីរមិនបានរស់នៅក្រោមដំបូលតែមួយ មិនបានសហការគ្នា មិនបានជួយសង្គ្រោះគ្នា ដែលទង្វើទាំងអស់នេះសបញ្ជាក់ឲ្យឃើញថាភាគីមិនមានឆន្ទៈក្នុងការបន្តចំណងអាពាហ៍ពិពាហ៍នឹងគ្នាទៀតឡើយ។[13] ការបោះបង់សហព័ទ្ធចោលដោយគ្មានមូលហេតុត្រឹមត្រូវបែបនេះ គឺជាទង្វើមិនត្រឹមត្រូវ ដូចនេះ ការដែលឲ្យភាគីម្ខាងទង្វឹងរង់ចាំទាំងបែបនេះមិនយុត្តិធម៌ឡើយ។ មនុស្សម្នាក់ៗគួរតែទទួលបានសិទ្ធិ និង សេរីភាព និងសុភមង្គល ហេតុនេះការដែលទទួលរងការបោះបង់ចោលដោយសហព័ទ្ធ ទាំងដែលទង្វើនោះគ្មានមូលហេតុត្រឹមត្រូវទាល់តែសោះ ភាគីរងគ្រោះអាចលើកចំណុចនេះជាមូលហេតុ នៃបណ្តឹងទាមទារលែងលះបាន។

### ១.៣.៣. អវត្តមាន ឬ ការបាត់ខ្លួន

ការបាត់ដំណឹងរបស់សហព័ទ្ធរបស់ខ្លួន ទាំងមិនដឹងថា សហព័ទ្ធនោះនៅមានជីវិត ឬបានបាត់បង់ជីវិតចាប់ពីរយៈពេលមួយឆ្នាំឡើងទៅ គឺជាមូលហេតុមួយដែលនាំឲ្យមានការប្តឹងលែងលះ។[14] ទោះបីជាមូលហេតុទី៣ ដែលកំណត់ដោយច្បាប់រដ្ឋប្បវេណី មានលក្ខណៈប្រហាក់ប្រហែលនឹងមូលហេតុទី២ខាងលើ តែមូលហេតុទាំងពីរនេះគឺ មិនដូចគ្នាឡើយ។ បើធ្វើការប្រៀបធៀបរវាងអត្ថន័យទាំងពីរខាងលើ ដើម្បីធ្វើការកត់សម្គាល់ពីលក្ខណៈរវាងមូលហេតុទាំងពីរគឺៈ ការបោះបង់សហព័ទ្ធចោលដោយគ្មានមូលហេតុត្រឹមត្រូវ ចង់សំដៅលើអាពាហ៍ពិពាហ៍ដែលសហព័ទ្ធបានដឹងថា សហព័ទ្ធម្ខាងទៀតនៅរស់ ក៏ប៉ុន្តែសហព័ទ្ធនោះសម្រេចចិត្តថាចាកចេញដោយបោះបង់ មិនមានបំណងក្នុងការបន្តនូវចំណងអាពាហ៍ពិពាហ៍ ហើយការបោះបង់នោះទៀតសោត

---

[11] មាត្រា២ នៃច្បាប់ស្តីពីឯកពន្ធភាព, លេខ នស/រកម/១០០៦/០២៦, ២១ តុលា ២០០៦។

[12] មាត្រា៩៧៨(១) ចំណុច(ខ) នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[13] សៀវភៅជំនួយស្មារតីនីតិគ្រួសារ របស់លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត(២០១៧), ទំព័រ ៣៧៧-៣៧៨។

[14] មាត្រា៩៧៨(១) ចំណុច(គ) នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

ក៏មិនមានមូលហេតុត្រឹមត្រូវចំពោះភាគីដែលទទួលរងការបោះបង់។ ចំណែកឯ មូលហេតុទី៣នៅក្នុងចំណុចនេះវិញ គឺការដែលសហព័ទ្ធបែកគ្នាដោយមិនដឹងដំណឹងជាក់លាក់ ថាសហព័ទ្ធម្ខាងទៀតដែលអវត្តមាន ឬបាត់ខ្លួននោះនៅរស់ ឬ ក៏ស្លាប់។ ជាពិសេស គោលគំនិតនៃមូលហេតុទី៣នេះគឺចង់សំដៅលើការដែលសហព័ទ្ធបែកគ្នាក្នុងព្រឹត្តិការណ៍គ្រោះថ្នាក់ផ្សេងៗ ដូចជា សង្គ្រាម លិចទូក វង្វេងក្នុងព្រៃជាដើម ហើយភាគីអាចព្យាករណ៍ដឹងមុនថាគ្មានសង្ឃឹមនឹងមានជីវិតនៅរស់។[15] ចំណុចសំខាន់មួយទៀត នៅក្នុងមូលហេតុទី៣នេះ គឺភាគីមានសិទ្ធិទាមទារការលែងលះដោយប្រើប្រាស់មូលហេតុនេះបាន លុះត្រាតែការអវត្តមាន ឬ ការបាត់ខ្លួនមានរយៈពេលលើសពី ១ឆ្នាំ។

**១.៣.៤. ការរស់នៅបែកគ្នារវាងសហព័ទ្ធ**

ការរស់នៅបែកពីគ្នាអស់រយៈពេលជាង ១ឆ្នាំ ជាបន្តបន្ទាប់ ក៏ជាមូលហេតុនៃការលែងលះផងដែរ ហើយការរស់នៅបែកពីគ្នាជាបន្តបន្ទាប់នេះ ចង់សំដៅដល់សហព័ទ្ធដែលរស់នៅមិនចុះសម្រុងនឹងគ្នា រួចសម្រេចចិត្តទៅរស់នៅបែកផ្ទះសម្បែងទីទៃពីគ្នា ពោលគឺកាត់ផ្តាច់ចោលនូវសម្ព័ន្ធភាព និងការរស់នៅទាំងឡាយដែលមានលក្ខណៈជាប្តីប្រពន្ធ។[16] ការរស់នៅបែកគ្នាជាបន្តបន្ទាប់នេះ គឺចង់សង្កត់អត្ថន័យ លើការដែលភាគីមានជម្លោះជាមួយគ្នា និងមិនអាចបន្តរស់នៅក្រោមដំបូលផ្ទះតែមួយ ជាមួយគ្នាបានតទៅទៀត។ ត្រង់ចំណុចនេះដែរតុលាការនឹងពិចារណាលើឆន្ទៈរបស់ភាគី ដែលនាំឲ្យមាននូវការរស់នៅបែកពីគ្នានេះ។ ឆន្ទៈក្នុងការរស់នៅបែកពីគ្នា អាចលើជាមូលហេតុទាមទារការលែងលះបាន លុះត្រាតែឆន្ទៈរបស់ភាគី គឺអស់មនោសញ្ចេតនា ពិសេសមិនចង់បន្តចំណងអាពាហ៍ពិពាហ៍ជាមួយគ្នា។ គួរបញ្ជាក់ផងដែរថា មិនមែនរាល់ការរស់នៅឃ្លាតពីគ្នាលើសពីមួយឆ្នាំសុទ្ធតែជាមូលហេតុនៃការលែងលះនោះទេ ព្រោះថាបើគ្រាន់តែប្តី និងប្រពន្ធរស់នៅឃ្លាតពីគ្នា ដោយមូលហេតុផ្សេងទៀត ក្រៅពីទំនាស់មិនចុះសម្រុងគ្នា ជាពិសេសភាគីក៏គ្មានឆន្ទៈក្នុងការលែងលះ នោះមិនមែនអាចលើកជាមូលហេតុបានទេ។ ជាក់ស្តែងនៅក្នុងប្រទេសកម្ពុជាសព្វថ្ងៃមានប្តី ឬ ប្រពន្ធខ្លះត្រូវរស់នៅទីទៃផ្សេងពីគ្នាដោយសារតែជាប់កាតព្វកិច្ចក្នុងការបំពេញការងារ, ជាប់បេសកកម្ម, ឬការបន្តការសិក្សានៅក្រៅប្រទេសជាដើម។ ការរស់នៅបែកពីគ្នាទាំងនេះ ភាគីក៏មិនមានឆន្ទៈក្នុងការកាត់ផ្តាច់ចំណងអាពាហ៍ពិពាហ៍ឡើយ គឺគ្រាន់តែឃ្លាតដោយសារ តែកាលៈទេសៈតម្រូវមកបែបនោះ ហើយស្ថានភាពទាំងអស់នេះ នឹងមិនមែនជាមូលហេតុក្នុងការប្តឹងទាមទារលែងលះនោះទេ។

**១.៣.៥. ករណីធ្ងន់ធ្ងរមិនអាចបដិសានទំនាក់ទំនងឡើងវិញបាន**

ការបែកបាក់គ្នានូវចំណងអាពាហ៍ពិពាហ៍ ក៏អាចបណ្តាលមកពីមូលហេតុផ្សេងៗទៀតជាច្រើន។ ហេតុនេះទើបបានជាក្នុងចំណុចនេះ ច្បាប់រដ្ឋប្បវេណីបានបញ្ញត្តិថា មូលហេតុនៃការលែងលះ មានករណីផ្សេងទៀត ដែល

[15] មាត្រា៩៨១(២) នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[16] មាត្រា៩៧៨(១) ចំណុច(ឃ) នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

មានសភាពធ្ងន់ធ្ងរ នាំឲ្យសហព័ទ្ធទាំងពីរមិនអាចបដិទាននឹងគ្នាឡើងវិញបាន។ ជាក់ស្តែង បញ្ញត្តិនេះបានផ្តល់នូវអត្ថិភាពនៃសិទ្ធិឲ្យភាគីប្តឹងលែងលះ តាមរយៈមូលហេតុផ្ទាល់របស់ភាគី ដែលមិនមានកំណត់ក្នុងចំណុចខាងលើដោយច្បាប់។[17] នៅក្នុងការអនុវត្តជាក់ស្តែងភាគីដែលប្តឹងលែងលះ និយមលើកយកមូលហេតុ រស់នៅមិនចុះសម្រុងនឹងគ្នា ដោយយោងលើមាត្រាច្បាប់ត្រង់ចំណុចនេះ មកធ្វើជាមូលហេតុនៅក្នុងបណ្តឹងទាមទារការលែងលះ។ មូលហេតុផ្សេងៗទាំងនោះ ត្បិតតែមិនមានកំណត់បន្ថែមដោយច្បាប់រដ្ឋប្បវេណីបច្ចុប្បន្នក៏ពិតមែន តែមូលហេតុទាំងនោះ ច្រើនជាមូលហេតុដែលធ្លាប់បានបញ្ញត្តិពីមុន ក្នុងច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ដូចជា៖ អំពើហិង្សាវាយដំ, ធ្វើទុក្ខបុកម្នេញ ជេរប្រមាថ មើលងាយធ្ងន់ធ្ងរ, ពុំមានសីលធម៌ ឬ បានប្រព្រឹត្តអំពើអបាយមុខអនាចារ, ឬ អពលានុភាពនៃលិង្គ ដែលជាមូលហេតុនាំឲ្យភាគីទាមទារលែងលះ។[18] រីឯ មូលហេតុនៃការលែងលះខ្លះទៀត កើតចេញពីឆន្ទៈរបស់សហព័ទ្ធទាំងសងខាងដោយការព្រមព្រៀង ដោយគ្មានបង្ខិតបង្ខំ ឬ វិការៈ ឬ ទំនាស់ឡើយ។ នៅក្នុងសង្គមនៃប្រទេសកម្ពុជាសព្វថ្ងៃ មូលហេតុកើតចេញពីឆន្ទៈរបស់ភាគីដោយព្រមព្រៀងទាំងពីរ ច្រើនតែពួកគាត់បាត់បង់នូវមនោសញ្ចេតនារវាងគ្នា នៅក្នុងចំណងអាពាហ៍ពិពាហ៍ ដោយមានមូលហេតុផ្ទាល់ខ្លួន ហើយភាគីបានដឹងយ៉ាងច្បាស់ថា ចំណងអាពាហ៍ពិពាហ៍នោះគ្មានសង្ឃឹម ក្នុងការផ្សះផ្សា ឬ ធ្វើបដិទានឲ្យត្រូវគ្នាវិញ ហើយជះឥទ្ធិពលធ្ងន់ធ្ងរឲ្យភាគីមិនអាចបន្តរួមរស់ជាមួយគ្នាទៀតបាន រហូតឈានដល់ការព្រមព្រៀងគ្នាដាក់ពាក្យស្នើសុំលែងលះ។ សរុបមកបង្ហាញថាចំណុចចុងក្រោយនៃមូលហេតុទាមទារលែងលះច្បាប់រដ្ឋប្បវេណី បានចែងក្នុងន័យទូលាយ សម្រាប់ឲ្យពលរដ្ឋមានសិទ្ធិលើកឡើងនូវមូលហេតុផ្សេងៗ ជាច្រើនដែលសមហេតុផល មកកំណត់ជាមូលហេតុក្នុងការប្តឹងទាមទារលែងលះពីតុលាការ។

### ១.៤. បទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការលែងលះ

ការលែងលះរវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ នៅកម្ពុជា ត្រូវអនុលោមទៅតាមបទដ្ឋានគតិយុត្តមួយចំនួន។ ដោយមូលហេតុថា អាពាហ៍ពិពាហ៍ដែលភាគីបានចុះសំបុត្រអាពាហ៍ពិពាហ៍ គឺជាអាពាហ៍ពិពាហ៍ស្របច្បាប់ ហើយភាគីដែលជាសហព័ទ្ធ មិនអាចរំលាយចំណងអាពាហ៍ពិពាហ៍នេះតាមអំពើចិត្តដោយមិនឆ្លងកាត់នីតិវិធីច្បាប់ ដូចភាគីដែលរស់នៅក្នុងលក្ខណៈជាអនីតិសង្វាសបានឡើយ។ នៅក្នុងប្រទេសកម្ពុជា ការលែងលះ ត្រូវបានបែងចែកជា ពីរប្រភេទ ដូចដែលធ្លាប់បានរៀបរាប់ក្នុងចំណុចខាងលើ ហេតុនេះការសម្រេចសេចក្តីលើការទាមទារលែងលះនៅកម្ពុជា មានជាប់ពាក់ព័ន្ធ នឹងបទដ្ឋានគតិយុត្តនៃប្រទេសមួយចំនួន។ ក្នុងចំណោម បទដ្ឋានគតិយុត្តទាំងអស់ មានបទដ្ឋានគតិយុត្តចំនួន បួន ដែលជាមូលដ្ឋានក្នុងការដោះស្រាយ ការលែងលះនៅកម្ពុជា ដូចជា៖ (១.៤.១.) **ក្រមរដ្ឋប្បវេណី**, (១.៤.២.) **ក្រមនីតិវិធីរដ្ឋប្បវេណី**, (១.៤.៣.) **ច្បាប់ស្តីពី**

[17] មាត្រា៩៧៨(១) ចំណុច(ង) នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[18] មាត្រា៣៩ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារ, លេខ ៥៦ ក្រ, ២៦ កក្កដា ១៩៨៩។

**នីតិវិធីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង**, និង (១.៤.៤.) **ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល។**

**១.៤.១. ក្រមរដ្ឋប្បវេណី** (**ឆ្នាំ២០០៧**)

ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានព្រះមហាក្សត្រឡាយព្រះហស្តលេខាប្រកាសឲ្យប្រើនៅថ្ងៃ០៨ ខែធ្នូ ឆ្នាំ២០០៧។ ក្រមរដ្ឋប្បវេណី បានបញ្ញត្តិពីគោលការណ៍ទូទៅដែលពាក់ព័ន្ធនឹងទំនាក់ទំនងគតិយុត្តផ្នែករដ្ឋប្បវេណី។ បញ្ញត្តិនៃក្រមរដ្ឋប្បវេណីនេះផងដែរ ក៏បានចែកអំពីទំនាក់ទំនងញាតិ និងទំនាក់ទំនងទ្រព្យសម្បត្តិផងដែរ។[19] ដូច្នេះហើយ ការលែងលះនៅកម្ពុជាដែលពាក់ព័ន្ធនឹង ការកាត់ផ្តាច់ទំនាក់ទំនងគតិយុត្តរវាងសហព័ទ្ធ និងការបែងចែកផ្សេងទៀតក្រោយការលែងលះ គឺត្រូវអនុលោមទៅតាមក្រមរដ្ឋប្បវេណី។ ជាក់ស្តែងបញ្ញត្តិមួយចំនួននៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលពាក់ព័ន្ធនឹងការលែងលះ មានមាត្រាមួយចំនួនដែលចែងក្នុងគន្ថីទី៧ អំពីញាតិ ជាពិសេសគឺនៅក្នុង ជំពូកទី១ អំពីបញ្ញត្តិទូទៅ, ជំពូកទី៣ អំពីអាពាហ៍ពិពាហ៍, និងជំពូកទី៥ អំពីអំណាចមេបាជាដើម។ នៅក្នុងជំពូកទី៣ គន្ថីទី៧ នៃក្រមរដ្ឋប្បវេណី បានចែងលម្អិតទាក់ទងនឹង មូលហេតុនៃការលែងលះ, នីតិវិធីនៃការលែងលះ, និងការបែងចែកប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ។ ក្រៅពីបញ្ញត្តិដែលបានលើកយកមកបកស្រាយខាងលើនេះ ក៏មានបញ្ញត្តិមួយចំនួនទៀតនៅក្នុងក្រមរដ្ឋប្បវេណីដែលមានពាក់ព័ន្ធនឹងការលែងលះ អាស្រ័យលើរឿងក្តីជាក់ស្តែងផងដែរ។ ដូចនេះ ក្រមរដ្ឋប្បវេណី គឺជាមូលដ្ឋានច្បាប់ដ៏សំខាន់មួយក្នុងការលែងលះរវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ នៅកម្ពុជា។

**១.៤.២. ក្រមនីតិវិធីរដ្ឋប្បវេណី** (**ឆ្នាំ២០០៦**)

ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានព្រះមហាក្សត្រឡាយព្រះហស្តលេខា នៅថ្ងៃ០៦ ខែកក្កដា ឆ្នាំ២០០៦។ ក្រមនីតិវិធីរដ្ឋប្បវេណីនេះ គឺជាច្បាប់ដែលចែងទាក់ទងនឹង នីតិវិធីលើបណ្តឹងរដ្ឋប្បវេណី។[20] គោលបំណងនៃក្រមនីតិវិធីរដ្ឋប្បវេណីនេះ គឺដើម្បីឲ្យតុលាការប្រើប្រាស់នីតិវិធីដែលមានចែងនៅក្នុងក្រមនេះ ទៅដោះស្រាយរាល់បណ្តឹងរដ្ឋប្បវេណី និងដើម្បីធានាសិទ្ធិពឹងពាក់តុលាការចំពោះវិវាទរដ្ឋប្បវេណីដល់ជនគ្រប់រូប។[21] ដោយហេតុថា ការលែងលះនៅកម្ពុជា គឺត្រូវបានច្បាប់កំណត់ថាជាប្រភេទបណ្តឹងរដ្ឋប្បវេណី ដូច្នេះ ការលែងលះរវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរនៅកម្ពុជានេះ ត្រូវអនុលោមទៅតាមក្រមនីតិវិធីរដ្ឋប្បវេណី។ គួរបញ្ជាក់ផងដែរថា ការលែងលះខ្លះកើតឡើងដោយការព្រមព្រៀងរវាងភាគី ដោយមិនមានបណ្តឹងដែលបង្កជាវិវាទ ហើយការលែងលះខ្លះទៀត គឺជាការលែងលះដោយគ្មានការព្រមព្រៀង ហេតុនេះហើយដើម្បីឲ្យនីតិវិធីនៅក្នុងការដោះស្រាយមាន

[19] មាត្រា១ នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[20] មាត្រា១ នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

[21] មាត្រា២ នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

ភាពឆាប់រហ័ស ពិសេសការពារមិនឲ្យភាគី និងបុគ្គលពាក់ព័ន្ធខូចប្រយោជន៍ច្រើន នាំឲ្យនីតិវិធីក្នុងការលែងលះក៏ត្រូវអនុលោមរួមគ្នារវាងក្រមនីតិវិធីរដ្ឋប្បវេណីជាមួយនឹងច្បាប់ស្តីពីនីតិវិធីផ្សេងទៀត ដូចជា ច្បាប់ស្តីពីនីតិវិធីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង និងច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គលជាដើម។

**១.៤.៣. ច្បាប់ស្តីពីនីតិវិធីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង (ឆ្នាំ២០១០)**

ច្បាប់ស្តីពីនីតិវិធីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានព្រះមហាក្សត្រឡាយព្រះហស្តលេខានៅថ្ងៃ១០ ខែកក្កដា ឆ្នាំ២០១០។ ច្បាប់នេះបង្កើតឡើង និងប្រកាសឲ្យប្រើប្រាស់ក្នុងគោលបំណងធានាការអនុវត្តឲ្យបានត្រឹមត្រូវនូវនីតិវិធីក្នុងការដោះស្រាយ រឿងក្តីរដ្ឋប្បវេណីដែលមិនមានវិវាទ ពោលគឺមិនមានពាក់ព័ន្ធទៅនឹងបណ្តឹង។[22] ការអនុលោមច្បាប់នេះមកដោះស្រាយ បានផ្តល់ជាប្រយោជន៍ក្នុងការពន្លឿននីតិវិធីក៏ដូចជាការធានាមិនឲ្យភាគីដែលពាក់ព័ន្ធមានការប៉ះពាល់ច្រើនលើប្រយោជន៍បុគ្គល។ ជាក់ស្តែង ចំពោះរឿងក្តីលែងលះដែលមានការព្រមព្រៀងគ្នារវាងសហព័ទ្ធ ដោយភាគីមិនមានទំនាស់នឹងគ្នា ហើយថែមទាំងបានពិភាក្សាព្រមព្រៀងគ្នារួចជាស្រេចក្នុងការបែងចែកសិទ្ធិ និងករណីយកិច្ចក្រោយការលែងលះ នោះរឿងក្តីរដ្ឋប្បវេណីប្រភេទនេះ នឹងត្រូវដោះស្រាយ ដោយអនុលោមតាមច្បាប់ពីនីតិវិធីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង។ ជាការពិតណាស់ ចំពោះរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង មិនត្រឹមតែមានរឿងលែងលះតែមួយមុខនោះទេ ហេតុនេះហើយច្បាប់ស្តីពីនីតិវិធីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ក៏មានកំណត់អំពីវិសាលភាពនៃច្បាប់លើប្រភេទរឿងក្តីនីមួយៗ នៅក្នុងមាត្រា៣ នៃច្បាប់នេះ។ ការស្នើសុំលែងលះដោយការព្រមព្រៀង តាមបញ្ញត្តិមាត្រា ៩៧៩ នៃក្រមរដ្ឋប្បវេណី មានចែងច្បាស់ក្នុងតារាងឧបសម្ព័ន្ធនៃ ច្បាប់ស្តីពីនីតិវិធីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង។ យ៉ាងណាមិញ នៅក្នុងករណីខ្លះដែលច្បាប់បានកំណត់ ការដោះស្រាយរឿងក្តីលែងលះដោយការព្រមព្រៀង ក៏ត្រូវអនុលោមជាមួយនឹងនីតិវិធីរដ្ឋប្បវេណីទូទៅផងដែរ។ ដូច្នេះ ច្បាប់ស្តីពីនីតិវិធីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ត្រូវបានយកមកប្រើប្រាស់ ក្នុងការដោះស្រាយរឿងក្តីលែងលះដោយការព្រមព្រៀងគ្នា រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ នៅកម្ពុជា។

**១.៤.៤. ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល (ឆ្នាំ២០១០)**

ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានព្រះមហាក្សត្រឡាយព្រះហស្តលេខានៅថ្ងៃ០៨ ខែមិថុនា ឆ្នាំ២០១០។ ច្បាប់នេះបង្កើតឡើង និងប្រកាសឲ្យប្រើប្រាស់ក្នុងគោលបំណងធានាការអនុវត្តឲ្យបានត្រឹមត្រូវនូវនីតិវិធីក្នុងការដោះស្រាយ រឿងក្តីរដ្ឋប្បវេណីទាំងឡាយណាដែលមានពាក់ព័ន្ធទៅនឹងឋានៈបុគ្គល។[23] ការលើកយកច្បាប់នេះមកដោះស្រាយ គឺដោយសារតែរឿងក្តីរដ្ឋប្បវេណីដែល

[22] មាត្រា២ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០។

[23] មាត្រា២ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/រកម/០៦១០/០០៨, ០៨ មិថុនា ២០១០។

ទាក់ទងនឹងឋានៈបុគ្គល គឺសំដៅលើរឿងក្តីរដ្ឋប្បវេណីដែលមានពាក់ព័ន្ធនឹងញាតិ ហេតុនេះហើយ ច្បាប់នេះត្រូវបានបង្កើតឡើងជាពិសេស ដើម្បីជានាផលប្រយោជន៍ភាគី និងបុគ្គលដែលជាប់ពាក់ព័ន្ធទាំងឡាយ។ ជាក់ស្តែងចំពោះរឿងក្តីលែងលះដែលគ្មានការព្រមព្រៀងគ្នារវាងសហព័ទ្ធ ហើយភាគីថែមទាំងមានទំនាស់នឹងគ្នាក្នុងការបែងចែកសិទ្ធិ និងករណីយកិច្ច ក្រោយការលែងលះ នោះរឿងក្តីរដ្ឋប្បវេណីប្រភេទនេះ នឹងត្រូវដោះស្រាយដោយអនុលោមតាមច្បាប់ស្តីពីនីតិវិធីរដ្ឋប្បវេណីដែលទាក់ទងនឹងឋានៈបុគ្គល។ លើសពីនេះទៅទៀត ច្បាប់ស្តីពីនីតិវិធីរដ្ឋប្បវេណីដែលទាក់ទងនឹងឋានៈបុគ្គល មានកំណត់អំពីវិសាលភាពនៃច្បាប់ នៅក្នុងមាត្រា៣ នៃច្បាប់នេះ។ ការស្នើសុំលែងលះដោយគ្មានការព្រមព្រៀងតាមរយៈការដាក់ពាក្យបណ្តឹង អនុលោមតាមបញ្ញត្តិមាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណី ត្រូវដោះស្រាយដោយអនុវត្តតាមច្បាប់ស្តីពីនីតិវិធីរដ្ឋប្បវេណីដែលទាក់ទងនឹងឋានៈបុគ្គល ត្រង់មាត្រា៣ ចំណុច(គ)។ យ៉ាងណាមិញ នៅក្នុងករណីខ្លះដែលច្បាប់បានកំណត់ នោះការដោះស្រាយរឿងក្តីលែងលះដោយគ្មានការព្រមព្រៀង ក៏ត្រូវអនុលោមជាមួយនឹងនីតិវិធីរដ្ឋប្បវេណីទូទៅផងដែរ។ ដូច្នេះ ច្បាប់ស្តីពីនីតិវិធីរដ្ឋប្បវេណីដែលទាក់ទងនឹងឋានៈបុគ្គល គឺជាច្បាប់ដ៏សំខាន់មួយសម្រាប់អនុលោមនៅក្នុងនីតិវិធីលែងលះដោយគ្មានការព្រមព្រៀងរវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ នៅកម្ពុជាផងដែរ។

គួរបញ្ជាក់ផងដែរថា ក្រៅពីច្បាប់សំខាន់ៗដែលបានរៀបរាប់ទាំងបួនខាងលើនេះ ការដោះស្រាយរឿងក្តីលែងលះ ក៏ត្រូវអនុលោមទៅតាមច្បាប់ផ្សេងៗទៀត អាស្រ័យលើរឿងក្តីជាក់ស្តែងផងដែរ។ ដោយមូលហេតុថា រឿងក្តីលែងលះបច្ចុប្បន្ននេះ មិនមែនត្រឹមតែដើម្បីរំលាយចំណងអាពាហ៍ពិពាហ៍នោះទេ តែរឿងក្តីលែងលះខ្លះទៀត ពាក់ព័ន្ធនឹងកម្មវត្ថុផ្សេងជាច្រើន។ ជាឧទាហរណ៍ ដូចជាការលែងលះដែលបណ្តាលមកពីអំពើហិង្សា នៅក្នុងគ្រួសារ ដូច្នេះចំណុចខ្លះនៃបណ្តឹងនឹងត្រូវបានពាក់ព័ន្ធជាមួយ ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះជាដើម។

ដូចនេះ ជំពូកទី១ អំពីសញ្ញាណទូទៅនៃការលែងលះ បានចង្អុលបង្ហាញឲ្យដឹងថា ការលែងលះរវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ នៅកម្ពុជា បានបែងចែកជាពីរប្រភេទគឺ ការលែងលះដោយការព្រមព្រៀង និងការលែងលះដោយគ្មានការព្រមព្រៀង។ ហើយការលែងលះទាំងពីរប្រភេទនេះ ត្រូវបានដោះស្រាយដោយអនុលោមតាមនីតិវិធីច្បាប់ពីរប្រភេទផ្សេងគ្នា។ ដូច្នេះហើយ ដើម្បីស្វែងយល់ពីនីតិវិធីក្នុងការលែងលះទាំងពីរខាងលើនេះឲ្យកាន់តែលម្អិតជាងនេះទៅទៀត ចាំបាច់ឲ្យមានការសិក្សាបន្ថែមលើ ជំពូកទី២ អំពីការលែងលះដោយការព្រមព្រៀង និងជំពូកទី៣ អំពីការលែងលះដោយមិនមានការព្រមព្រៀងបន្តទៀត។

# ជំពូកទី២
# ការលែងលះដោយ
# ការព្រមព្រៀង

# ជំពូកទី២
# ការលែងលះដោយការព្រមព្រៀង

ការលែងលះដោយការព្រមព្រៀង ត្រូវធ្វើឡើងនៅពេលដែលភាគីនៃចំណងអាពាហ៍ពិពាហ៍ បានព្រមព្រៀងគ្នាក្នុងការបញ្ចប់នូវចំណងអាពាហ៍ពិពាហ៍ ដោយមិនមានទំនាស់លើការបែងចែកសិទ្ធិ និងកាតព្វកិច្ចផ្សេងៗក្រោយការលែងលះឡើយ។ ការលែងលះដោយការព្រមព្រៀង គឺស្ថិតនៅក្រោមវិសាលភាពនៃច្បាប់ស្តីពីនីតិវិធីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង។[24] ដូចនេះហើយ សម្រាប់នីតិវិធីក្នុងការលែងលះដោយព្រមព្រៀង ជំពូកទី២ នេះ នឹងធ្វើការសិក្សាទៅលើ៖ (២.១.) **ទិដ្ឋភាពទូទៅនៃការលែងលះដោយការព្រមព្រៀង**, (២.២.) **អាជ្ញាធរមានសមត្ថកិច្ច**, (២.៣.) **នីតិវិធីដែលត្រូវបំពេញដោយភាគី**, និង (២.៤.) **នីតិវិធីដោះស្រាយការលែងលះដោយព្រមព្រៀង**។

## ២.១. ទិដ្ឋភាពទូទៅនៃការលែងលះដោយការព្រមព្រៀង

ការលែងលះដោយការព្រមព្រៀង គឺជាការរំលាយនូវចំណងអាពាហ៍ពិពាហ៍ស្របច្បាប់រវាងសហព័ទ្ធនៅរស់ដែលការព្រមព្រៀងនេះកើតចេញពីឆន្ទៈពិតប្រាកដរបស់សហព័ទ្ធទាំងពីរ។[25] ជាទូទៅ នៅក្នុងអាពាហ៍ពិពាហ៍ សហព័ទ្ធតែងមានទំនាក់ទំនង រួមគ្នាជាច្រើនដូចជា៖ ការប្រើប្រាស់នាមត្រកូល, ការមានកូនជាមួយគ្នា និងទ្រព្យសម្បត្តិដែលរកបាន។ ពិសេសក្នុងអាពាហ៍ពិពាហ៍ សហព័ទ្ធត្រូវបំពេញនូវករណីយកិច្ចជាប្តីប្រពន្ធនឹងគ្នា តែបើសហព័ទ្ធមិនបានបំពេញករណីយកិច្ចទាំងនោះទេ ករណីនេះនឹងនាំឲ្យកើតមានជាកម្មវត្ថុនៃការទាមទារលែងលះ។ ចំពោះការលែងលះដោយព្រមព្រៀង ភាគីត្រូវព្រមព្រៀងគ្នារួចជាស្រេច ទាំងការព្រមព្រៀងកាត់ផ្តាច់ចំណងអាពាហ៍ពិពាហ៍ និងព្រមព្រៀងលើការបែងចែកលើកម្មវត្ថុនៃសិទ្ធិ និងកាតព្វកិច្ចផ្សេងៗទៀត តាមរយៈការធ្វើពាក្យសុំទៅកាន់តុលាការ។ ដើម្បីឲ្យភាគីមានសិទ្ធិក្នុងការធ្វើពាក្យសុំលែងលះ នោះភាគីត្រូវតែបង្ហាញឲ្យតុលាការបានយល់ដឹងពី មូលហេតុដែលនាំឲ្យភាគីសម្រេចស្នើសុំលែងលះ។ មូលហេតុដែលតុលាការយល់ព្រមទទួលយករឿងក្តីលែងលះរបស់ភាគីមកសម្រេច លុះត្រាតែមូលហេតុទាំងនោះត្រឹមត្រូវទៅតាមផ្លូវច្បាប់ ដូចដែលបានរៀបរាប់ពីខាងដើមក្នុង ជំពូកទី១ អំពីមូលហេតុនៃការលែងលះ។ យ៉ាងណាមិញ នៅក្នុងសង្គមបច្ចុប្បន្ន ភាគីមួយចំនួន ដែលស្នើសុំលែងលះដោយព្រមព្រៀង ច្រើនតែលើកយកចំណុចចុងក្រោយមកធ្វើជាមូលហេតុ គឺមូលហេតុផ្សេងៗដែលនាំឲ្យការរស់នៅមិនចុះសម្រុង ហើយមិនអាចបដិទានវិញបាន មកធ្វើជាមូលហេតុសុំឲ្យតុលាការសម្រេចការលែងលះ។ ការលែងលះដោយការព្រមព្រៀង ច្រើនតែមិនមានលក្ខណៈស្មុគស្មាញនោះទេ ពីព្រោះថាភាគីបានព្រមព្រៀងគ្នាលើកម្មវត្ថុផ្សេងៗ និងគ្រាន់តែសុំឲ្យតុលាការសម្រេចតាមការព្រមព្រៀងទាំងអស់

[24] មាត្រា១ និងមាត្រា៣ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០។

[25] មាត្រា៩៧៩ នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

នោះតែប៉ុណ្ណោះ។ ទោះបីជាយ៉ាងនេះក្ដី ការលែងលះនេះនៅតែត្រូវអនុវត្តតាមនីតិវិធីរបស់តុលាការ និងឆ្លងកាត់ការសម្រេចរបស់តុលាការទើបនាំឲ្យការលែងលះនោះ មានអត្ថិភាពទៅតាមផ្លូវច្បាប់។

### ២.២. អាជ្ញាធរមានសមត្ថកិច្ច

នៅក្នុងការលែងលះដោយព្រមព្រៀង ភាគីដែលមានឆន្ទៈចង់ស្នើសុំលែងលះ ត្រូវទៅដាក់ពាក្យសុំពីអាជ្ញាធរដែលមានសមត្ថកិច្ច លើការដោះស្រាយរឿងក្ដីលែងលះ។ អាជ្ញាធរដែលមានសមត្ថកិច្ចមានចំនួន ពីរ គឺៈ (២.២.១.) **ក្រុមប្រឹក្សាឃុំ-សង្កាត់ក្នុងការផ្សះផ្សា** និង (២.២.២.) **តុលាការរាជធានី-ខេត្ត**។

#### ២.២.១. ក្រុមប្រឹក្សាឃុំ-សង្កាត់ ក្នុងការផ្សះផ្សា

នៅក្នុងនីតិវិធីនៃការលែងលះ ក្រុមប្រឹក្សាឃុំ-សង្កាត់ គ្មានយុត្តាធិការនោះទេ ក្នុងការសម្រេចសេចក្ដីលើការលែងលះ ក៏ប៉ុន្តែក្រុមប្រឹក្សាឃុំ-សង្កាត់ មានដើរតួនាទីយ៉ាងចម្បងក្នុងការការផ្សះផ្សា។ ថ្វីត្បិតតែ តាមគោលការណ៍ច្បាប់ មានតែតុលាការមួយគត់ដែលមានសិទ្ធិអំណាចក្នុងការចេញដីកាសម្រេច លើការលែងលះក៏ពិតមែន តែបច្ចុប្បន្នភាពក្នុងការអនុវត្ត ប្រជាពលរដ្ឋខ្មែរមួយចំនួន នៅតែដាក់ពាក្យសុំលែងលះ នៅក្រុមប្រឹក្សាឃុំ-សង្កាត់ ខាងលំនៅឋានជាមុនសិន មុននឹងបញ្ជូនបន្តទៅតុលាការ។ ដូចនេះ ក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវគោរពតួនាទីនៅក្នុងការផ្សះផ្សាដល់ភាគីដែលមកដាក់ពាក្យសុំលែងលះ។ ការផ្សះផ្សា ដែលបានធ្វើឡើងដោយក្រុមប្រឹក្សាឃុំ-សង្កាត់ ក្នុងគោលបំណងខិតខំធ្វើយ៉ាងណាឲ្យប្ដីប្រពន្ធមានការសះជាគ្នាឡើងវិញ។ ក្រុមប្រឹក្សាឃុំ-សង្កាត់មានរយៈពេលត្រឹមតែ ១៥ថ្ងៃ ប៉ុណ្ណោះនៅក្នុងការផ្សះផ្សា។[26] បើកន្លងផុតរយៈពេលកំណត់ ភាគីនៅតែគ្មានការសះជាទៀតនោះ ក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវបញ្ជូនពាក្យសុំលែងលះ មកតុលាការដើម្បីឲ្យតុលាការធ្វើចំណាត់ការលើរឿងក្ដីស្របតាមនីតិវិធី។ ក្នុងករណីដែលការផ្សះផ្សារបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ធ្វើឡើងបានសម្រេច ពីព្រោះភាគីព្រមសះជានឹងគ្នាវិញ នោះក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវធ្វើកំណត់ហេតុ និងធ្វើកិច្ចសន្យាសះជាដល់ភាគី។

#### ២.២.២. តុលាការរាជធានី-ខេត្ត

ជាការពិតណាស់ សមត្ថកិច្ចក្នុងការជម្រះលើរឿងក្ដីលែងលះ គឺត្រូវបានកំណត់ដោយច្បាប់។ ចំពោះការលែងលះដោយព្រមព្រៀង មិនមែនគ្រប់តុលាការទាំងអស់សុទ្ធតែមានសមត្ថកិច្ចលើរឿងក្ដីលែងលះនោះទេ ព្រោះរឿងក្ដីប្រភេទនេះ ត្រូវស្ថិតក្រោមសមត្ថកិច្ចផ្ដាច់មុខរបស់តុលាការ ដែលត្រូវបានកំណត់ដោយច្បាប់ពិសេស។[27] សមត្ថកិច្ចផ្ដាច់មុខចំពោះរឿងក្ដីលែងលះដោយព្រមព្រៀង គឺជាតុលាការលំនៅឋានរបស់ប្ដីប្រពន្ធ។[28] សរុបជាខ្លីមក តុលាការដែលមានសមត្ថកិច្ចលើរឿងក្ដីលែងលះដោយការព្រមព្រៀង គឺតុលាការរាជធានី-ខេត្តនៃលំនៅឋាន

---

[26] មាត្រា៩៨២(២) នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[27] មាត្រា៤ នៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង, នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០។

[28] មាត្រា៤ នៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង, នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០ និងតារាងឧបសម្ព័ន្ធផ្នែក៤, ចំណុច(៥)។

ប្តីប្រពន្ធ ដែលដាក់ពាក្យសុំលែងលះដោយការព្រមព្រៀង។ ដូច្នេះ នៅក្នុងការលែងលះដោយព្រមព្រៀង ភាគីក៏ត្រូវបំពេញ កាតព្វកិច្ចមួយចំនួនពាក់ព័ន្ធនឹងលំហូរនៃនីតិវិធីរដ្ឋប្បវេណីផងដែរ។

### ២.៣. នីតិវិធីដែលត្រូវបំពេញដោយភាគី

ភាគីនៃអាពាហ៍ពិពាហ៍ដែលបានព្រមព្រៀងគ្នាក្នុងការលែងលះ ត្រូវការដាក់ពាក្យសុំទៅតុលាការមានសមត្ថកិច្ច ដើម្បីឲ្យរឿងក្តីលែងលះមានដំណើរនីតិវិធីទៅមុខ។ ក្នុងនោះផងដែរភាគីក៏ត្រូវបំពេញនូវកាតព្វកិច្ចមួយចំនួន ក្នុងការចូលរួមក្នុងដំណើរនីតិវិធីរដ្ឋប្បវេណី រហូតដល់មានការបញ្ចប់នីតិវិធី និងការសម្រេចសេចក្តីដោយដីកាសម្រេច។ នីតិវិធីរដ្ឋប្បវេណីដែលជាកាតព្វកិច្ចរបស់ភាគីត្រូវបំពេញ មានដូចជា៖ (២.៣.១.) **ការស្នើសុំការលែងលះ** និងការដាក់ជូនតុលាការនូវ (២.៣.២.) **ឯកសារភ្ជាប់**។

#### ២.៣.១. ការស្នើសុំការលែងលះ

ការលែងលះដោយការព្រមព្រៀង ចាប់ផ្តើមដំណើរការនីតិវិធីនៅពេលដែលសហព័ទ្ធទាំងពីរសម្រេចដាក់ពាក្យស្នើសុំទៅតុលាការ ដោយអនុលោមតាមច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង។ នៅក្នុងដំណើរការនីតិវិធីនេះ ជំហានដំបូង គឺភាគីត្រូវធ្វើពាក្យសុំលែងលះ ដោយការធ្វើលិខិតព្រមព្រៀងលែងលះគប្បីភ្ជាប់ជាមួយនឹងឯកសារពាក់ព័ន្ធ រួចហើយនៅជំហានបន្ទាប់ គឺភាគីត្រូវយកពាក្យស្នើសុំទៅដាក់នៅតុលាការដែលមានសមត្ថកិច្ចព្រមទាំងត្រូវបង់ពន្ធតាមការកំណត់នៃច្បាប់។

##### ២.៣.១.១. ពាក្យសុំលែងលះ

ពាក្យសុំលែងលះ ត្រូវបានធ្វើឡើងដោយសហព័ទ្ធ ដែលមានការឯកភាពព្រមព្រៀងទាំងស្រុង នៅក្នុងការលែងលះ។ សហព័ទ្ធត្រូវធ្វើពាក្យស្នើសុំតាមរយៈទម្រង់ពីរយ៉ាងគឺ៖ ការដាក់ពាក្យសុំដែលធ្វើឡើងដោយផ្ទាល់មាត់ និងការដាក់ពាក្យសុំដែលធ្វើឡើងក្រោមទម្រង់ជាលាយលក្ខណ៍អក្សរ។[29] នៅក្នុងពាក្យសុំលែងលះនេះត្រូវបញ្ជាក់ឲ្យច្បាស់លាស់ពីអត្តសញ្ញាណ កម្មវត្ថុ អង្គហេតុ និងខ្លឹមសារនៃការទាមទាររបស់ភាគី។ ចំណុចគួរឲ្យកត់សម្គាល់នៅក្នុងនីតិវិធីលែងលះដោយការព្រមព្រៀងគ្នានេះ ប្តី ឬ ប្រពន្ធដែលបានដាក់ពាក្យសុំលែងលះច្បាប់សន្មតឲ្យហៅថា «អ្នកដាក់ពាក្យសុំ» ហើយភាគីម្ខាងទៀតនៃការសុំលែងលះដោយព្រមព្រៀងនេះ ច្បាប់សន្មតឲ្យហៅថា «ភាគីម្ខាងទៀត»។ ការហៅនេះ គឺមានលក្ខណៈខុសប្លែកពីនីតិវិធីរដ្ឋប្បវេណីទូទៅ ដែលតែងតែហៅភាគីថា «ដើមចោទ» និង «ចុងចម្លើយ»។

**ក. ពាក្យសុំដោយផ្ទាល់មាត់**

សហព័ទ្ធ ដែលមានបំណងដាក់ពាក្យសុំលែងលះដោយការព្រមព្រៀង អាចធ្វើពាក្យសុំផ្ទាល់មាត់ បាននៅចំពោះមុខក្រឡាបញ្ជី។ កាតព្វកិច្ច ដែលសហព័ទ្ធត្រូវធ្វើនោះគឺត្រូវធ្វើនូវសេចក្តីថ្លែងការណ៍អំពី ឈ្មោះរបស់ភាគី

[29] មាត្រា២៦(១) នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០។

ប្តី និងប្រពន្ធ រួមទាំងអាសយដ្ឋាន ឬ អ្នកតំណាង (ប្រសិនបើមានអ្នកតំណាង)។ បន្ថែមពីនេះទៅទៀត ការដាក់ពាក្យសុំដោយផ្ទាល់មាត់នេះ ភាគីនៅតែចាំបាច់ធ្វើសេចក្តីថ្លែងការណ៍អំពីខ្លឹមសារនៃការទាមទារ ដែលចង់ឲ្យតុលាការចេញនូវសេចក្តីសម្រេច គួបផ្សំជាមួយនឹងអង្គហេតុផ្សេងៗ ដែលមូលហេតុនាំឲ្យមានការស្នើសុំលែងលះ។ ចំណែកឯក្រឡាបញ្ជីវិញ ត្រូវមានកាតព្វកិច្ចធ្វើនូវកំណត់ហេតុទាំងនោះ និងឲ្យអ្នកដាក់ពាក្យសុំចុះហត្ថលេខាលើពាក្យសុំនោះ។ គួបញ្ជាក់ផងដែរថា កំណត់ហេតុអំពីសេចក្តីថ្លែងការណ៍ ដែលធ្វើដោយផ្ទាល់មាត់ជាមួយក្រឡាបញ្ជីនេះ ត្រូវបានច្បាប់ចាត់ទុកជាលិខិតពាក្យសុំ។[30]

**ខ. ពាក្យសុំដោយលាយលក្ខណ៍អក្សរ**

សហព័ទ្ធ ដែលចង់ធ្វើការលែងលះដោយព្រមព្រៀង អាចធ្វើពាក្យសុំលែងលះ ក្នុងទម្រង់លាយលក្ខណ៍អក្សរដើម្បីយកទៅដាក់នៅតុលាការ។ ពាក្យសុំលែងលះ ដែលធ្វើក្នុងទម្រង់ជាលាយលក្ខណ៍អក្សរនោះត្រូវសរសេរពីចំណុចសំខាន់ៗ មួយចំនួនដូចជា៖ ឈ្មោះ របស់អ្នកដាក់ពាក្យសុំលែងលះ។ ជាទូទៅ គឺក្នុងពាក្យសុំក៏ត្រូវបញ្ជាក់ឲ្យច្បាស់នូវអត្តសញ្ញាណរបស់ ប្តី និងប្រពន្ធ ដូចជាថ្ងៃខែឆ្នាំកំណើត និងទីកន្លែងកំណើតជាដើម។ម៉្យាងវិញទៀត ក្នុងករណីដែលភាគីប្តី ឬ ប្រពន្ធមានអ្នកតំណាង នាំឲ្យឈ្មោះ ឬ នាមករណ៍ ព្រមទាំងអត្តសញ្ញាណផ្សេងៗនៃអ្នកតំណាង ក៏ត្រូវសរសេរនៅក្នុងពាក្យសុំលែងលះនោះដែរ។ បន្ថែមពីនេះ អាសយដ្ឋាន គឺជាចំណុចសំខាន់បន្ទាប់ពីឈ្មោះ របស់សហព័ទ្ធដែលបានដាក់ពាក្យសុំលែងលះដោយព្រមព្រៀង។ ក្នុងអាសយដ្ឋានត្រូវកំណត់អំពីលេខផ្ទះ, ផ្លូវ, ភូមិ, ឃុំ/សង្កាត់, ក្រុង/ស្រុក/ខណ្ឌ និងរាជធានី/ខេត្ត។

លើសពីនេះទៅទៀត ក្នុងករណីដែលអ្នកដាក់ពាក្យសុំ មានអ្នកតំណាង នៅក្នុងពាក្យសុំលែងលះក៏ត្រូវសរសេរបន្ថែមនូវអាសយដ្ឋានរបស់អ្នកតំណាងផងដែរ។[31] ចំណុចដែលសំខាន់បន្ទាប់គឺ នៅក្នុងពាក្យសុំលែងលះ ត្រូវតែបញ្ជាក់ឲ្យច្បាស់អំពីកម្មវត្ថុដែលបង្កឲ្យមានការលែងលះ ជាមួយនឹងខ្លឹមសារដែលអ្នកដាក់ពាក្យសុំ និងភាគីម្ខាងទៀតចង់ឲ្យតុលាការចេញនូវដីកាសម្រេចលើការសុំទាមទារនោះ។ ក្នុងខ្លឹមសារដែលត្រូវបញ្ជាក់នោះមាន ខ្លឹមសារអំពីការទាមទារចម្បង និងខ្លឹមសារទាមទារបន្ទាប់បន្សំ។ ចំពោះការទាមទារចម្បងក្នុងបរិបទនេះ គឺសំដៅដល់ការទាមទារឲ្យតុលាការចេញដីកាសម្រេចការលែងលះ។ ចំណែកឯការទាមទារបន្ទាប់បន្សំ គឺសំដៅលើ ការទាមទារឲ្យតុលាការចេញនូវដីកាសម្រេចស្របតាមការព្រមព្រៀងទាំងឡាយ របស់ភាគីលែងលះ ដែលការទាមទារនោះពាក់ព័ន្ធទៅនឹង ការបែងចែកទ្រព្យសម្បត្តិ, ការបែងចែកអំណាចមេបា, និងការទទួលខុសត្រូវលើអាហារកាតព្វកិច្ចផ្សេងៗទៀតជាដើម។[32]

[30] មាត្រា២៦(៣) នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០។

[31] មាត្រា២៦(២) ចំណុច(ក) នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០។

[32] មាត្រា២៦(២) ចំណុច(ខ) នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០។

ចំណុចចុងក្រោយដែលត្រូវបញ្ជាក់នៅក្នុងពាក្យសុំ គឺអង្គហេតុនៃការទាមទារ។ ដោយហេតុថា អង្គហេតុគឺជាព្រឹត្តិការណ៍មួយដែលសំខាន់ណាស់ សម្រាប់តុលាការ ធ្វើជាមូលដ្ឋានក្នុងការគិតពិចារណា មុននឹងធ្វើការសម្រេចសេចក្តី។ អង្គហេតុចម្បង គឺតម្រូវឲ្យភាគីបង្ហាញពីចំណងគតិយុត្តដោយស្របច្បាប់ ពីព្រោះការលែងលះអាចប្រព្រឹត្តទៅបានលុះត្រាតែមាននូវចំណងអាពាហ៍ពិពាហ៍ដែលទទួលស្គាល់ដោយច្បាប់ ដែលមិនមែនគ្រាន់តែជាដៃគូ បែបអនីតិសង្វាសឡើយ។ ចំណុចនេះហើយ ដែលជាតឹកតាងបញ្ជាក់ពីអង្គហេតុចម្បង ពិតជាមានលក្ខណៈសំខាន់ខ្លាំង ដែលអ្នកដាក់ពាក្យសុំត្រូវធ្វើការបញ្ជាក់ដាច់ខាត។ មួយវិញទៀត អ្នកដាក់ពាក្យសុំ តែបញ្ជាក់បន្ថែមអង្គហេតុបន្ទាប់បន្សំនោះមានដូចជា សារតានៃទ្រព្យសម្បត្តិដែលបរិយាយពី បរិមាណនៃទ្រព្យរួមទ្រព្យដោយឡែក ចំនួនកូនក្នុងបន្ទុក និងការចិញ្ចឹមបីបាច់ថែរក្សាកូន គួបផ្សំនឹងចំណុចពាក់ព័ន្ធផ្សេងៗទៀតដែលមានការពាក់ព័ន្ធនឹងការស្នើសុំលែងលះដោយព្រមព្រៀង។

**២.៣.១.២. ការដាក់ពាក្យសុំលែងលះ និងការបង់ពន្ធ**

ការដាក់ពាក្យសុំលែងលះ គឺអ្នកដាក់ពាក្យសុំ ត្រូវទៅដាក់ពាក្យសុំលែងលះនៅសាលាដំបូងរាជធានី/ខេត្តដែលមានសមត្ថកិច្ចលើរឿងក្តីលែងលះដោយខ្លួនឯងផ្ទាល់។[33] នៅក្នុងករណីខ្លះទៀត ប្រសិនបើអ្នកដាក់ពាក្យសុំបានធ្វើការពឹងពាក់មេធាវីតំណាងដោយអាណត្តិ នោះមេធាវីនឹងដើរតួនាទីក្នុងការទៅដាក់ពាក្យសុំនៅសាលាដំបូងតំណាងឲ្យកូនក្តីរបស់ខ្លួន។[34] នៅពេលដែលពាក្យសុំលែងលះត្រូវបានដាក់ ទៅដល់សាលាដំបូងរាជធានី/ខេត្តក្រឡាបញ្ជី គឺជាអ្នកដែលមានកាតព្វកិច្ចក្នុងការទទួលនូវពាក្យសុំលែងលះមកធ្វើការពិនិត្យ និងចុះលេខសំណុំរឿង។ ក្រឡាបញ្ជីត្រូវធ្វើការពិនិត្យពាក្យសុំលែងលះ ដោយផ្អែកតាមទម្រង់ច្បាប់ដែលបានកំណត់។ បន្ទាប់ពីបានពិនិត្យឃើញថាពាក្យសុំលែងលះនោះត្រឹមត្រូវទៅតាមទម្រង់ច្បាប់រួចហើយ ក្រឡាបញ្ជីត្រូវបញ្ជូនរឿងក្តីនេះទៅដល់ចៅក្រមដើម្បីដំណើរការនីតិវិធីបន្ត ពោលគឺដើម្បីបើកការជំនុំជម្រះ។ ក៏ប៉ុន្តែ ក្នុងករណីដែលក្រឡាបញ្ជីពិនិត្យឃើញថា ពាក្យសុំលែងលះមិនត្រឹមត្រូវតាមទម្រង់ច្បាប់ដែលបានកំណត់ទេនោះ ក្រឡាបញ្ជីត្រូវប្រញាប់រាយការណ៍ទៅចៅក្រម ដើម្បីឲ្យចៅក្រមធ្វើការសម្រេចថា ពាក្យសុំលែងលះនោះគួរឲ្យអ្នកដាក់ពាក្យសុំធ្វើការកែតម្រូវ ឬ ចៅក្រមសម្រេចលើកចោលពាក្យសុំនោះតាមរយៈដីកាសម្រេច។

បន្ថែមពីនេះ អ្នកដាក់ពាក្យសុំលែងលះ ត្រូវមានកាតព្វកិច្ចនៅក្នុងការបង់ពន្ធសម្រាប់ពាក្យសុំនោះផងដែរ។ ចំពោះករណីពាក្យសុំលែងលះ ប្រាក់ដែលត្រូវបង់ពន្ធមានចំនួន ៥.០០០ (ប្រាំពាន់) រៀល។[35] ពន្ធលើពាក្យសុំជាគោលការណ៍ច្បាប់ គឺជាបន្ទុករបស់អ្នកដាក់ពាក្យសុំលើកលែងតែក្នុងករណី ដែលមានការកំណត់ពិសេសអំពី

[33] មាត្រា១៥ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០។

[34] មាត្រា១៨ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០។

[35] មាត្រា២២(១) នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០ និង មាត្រា៦១(៦) នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

អ្នកត្រូវទទួលបន្ទុកនេះដោយច្បាប់។[36] ប្រសិនបើអ្នកដាក់ពាក្យសុំលែងលះមិនបានធ្វើការបង់ពន្ធទេនោះ តុលាការនឹងធ្វើការកំណត់រយៈពេលសមរម្យមួយឲ្យអ្នកដាក់ពាក្យសុំបង់ប្រាក់ពន្ធ តែបើអ្នកដាក់ពាក្យសុំនៅតែមិនព្រមបង់ពន្ធជូនទៀត តុលាការនឹងលើកចោលពាក្យសុំលែងលះតាមរយៈដីកាសម្រេច។[37] ទាំងអស់ខាងលើនេះ គឺជាកាតព្វកិច្ចរបស់ភាគី ដែលមានឆន្ទៈចង់ស្នើសុំការលែងលះដោយការព្រមព្រៀងពីតុលាការ។ បន្ថែមពីនេះ នៅពេលដាក់ពាក្យសុំលែងលះ ភាគីក៏ត្រូវភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធផ្សេងៗមកជូនតុលាការផងដែរ។

### ២.៣.២. ឯកសារភ្ជាប់

នៅក្នុងពេលដែលអ្នកដាក់ពាក្យសុំ បានដាក់ពាក្យសុំលែងលះទៅតុលាការ នោះអ្នកដាក់ពាក្យសុំក៏ត្រូវភ្ជាប់មកជាមួយនូវឯកសារដែលមានអានុភាពគតិយុត្តមួយចំនួន ដែលមានការពាក់ព័ន្ធជាមួយរឿងក្តីមកជាមួយផងដែរ។ ឯកសារទាំងនោះមានដូចជា សំបុត្រអាពាហ៍ពិពាហ៍ សំបុត្រកំណើតរបស់កូនៗ(ប្រសិនបើភាគីមានកូន) ព្រមទាំងឯកសារដែលពាក់ព័ន្ធនឹងទ្រព្យសម្បត្តិ។ គុណប្រយោជន៍នៃឯកសារទាំងនេះ គឺដើម្បីសម្រួលឲ្យតុលាការ កាន់តែមានភាពងាយស្រួលស្វែងយល់លើរឿងក្តី និងដំណើរការនីតិវិធីបានឆាប់រហ័ស។ ឯកសារដែលកាន់តែសំខាន់នោះគឺ ពាក្យព្រមព្រៀងលែងលះដែលបានធ្វើឡើងរវាងភាគីប្តីប្រពន្ធ ដោយឆន្ទៈផ្ទាល់រវាងប្តីប្រពន្ធ និងគ្មានការបង្ខិតបង្ខំផ្សេងៗ។ ហេតុនេះហើយ កិច្ចព្រមព្រៀងលែងលះ ច្រើនតែធ្វើឡើងក្នុងទម្រង់លាយលក្ខណ៍អក្សរ ដែលបានសរសេរកំណត់យ៉ាងច្បាស់អំពី ការឯកភាពគ្នាក្នុងការព្រមព្រៀងលែងលះ និងការព្រមព្រៀងក្នុងការបែងចែកសិទ្ធិ និងកាតព្វកិច្ចផ្សេងទៀតក្រោយការលែងលះរវាងភាគីទាំងសងខាង។ យ៉ាងណាមិញ នៅក្នុងការអនុវត្តជាក់ស្តែង មានករណីខ្លះគូភាគី ធ្វើកិច្ចព្រមព្រៀងលែងលះនេះឡើង តាមរយៈការទៅធ្វើសេចក្តីថ្លែងការណ៍ដោយផ្ទាល់មាត់នៅចំពោះមុខក្រឡាបញ្ជីតែម្តងនៅពេលដាក់ពាក្យសុំលែងលះ តែករណីបែបនេះគឺមានតិចតួចខ្លាំងណាស់ និងត្រូវបានប្រើប្រាស់ដោយប្រជាជនមួយចំនួនតូចដែលមិនបានយល់ច្បាស់ពីច្បាប់ និងពុំមានលទ្ធភាពគ្រប់គ្រាន់ក្នុងការពឹងពាក់មេធាវី។[38]

## ២.៤. នីតិវិធីដោះស្រាយការលែងលះដោយព្រមព្រៀង

នីតិវិធីលែងលះចាប់ផ្តើម នៅពេលដែលពាក្យសុំលែងលះបានដាក់ទៅតុលាការ បន្ទាប់មកពាក្យសុំលែងលះនោះ ត្រូវបានពិនិត្យដោយក្រឡាបញ្ជី ថាពិតជាត្រឹមត្រូវទៅតាមទម្រង់ដែលច្បាប់បានកំណត់។ នៅអំឡុងពេលនៃនីតិវិធីការលែងលះដោយព្រមព្រៀង គឺប្រព្រឹត្តទៅ ឲ្យស្របតាមលំហូរនៃនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីមិនមែនជាបណ្តឹង ដូចតទៅ៖ (**២.៤.១.**) **ការកោះហៅគូភាគី**, (**២.៤.២.**) **ការផ្សះផ្សា**, (**២.៤.៣.**)

[36] មាត្រា២២(៣) នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០។

[37] មាត្រា២២(៦) នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០។

[38] មាត្រា២៦(៤) នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០។

**ការទាញហេតុផលដោយផ្ទាល់មាត់**, និង (២.៤.៤.) **ការសម្រេចសេចក្តីលើពាក្យស្នើសុំ**។

### ២.៤.១. ការកោះហៅគូភាគី

បន្ទាប់ពីក្រឡាបញ្ជីបានធ្វើការពិនិត្យទៅលើពាក្យសុំលែងលះរួចរាល់ហើយ ក្រឡាបញ្ជីចាប់ផ្តើមចុះលេខសំណុំរឿង និងប្រញាប់ធ្វើការបញ្ជូនសំណុំរឿង លែងលះដោយការព្រមព្រៀងនោះ ទៅឲ្យចៅក្រមបើកការជំនុំជម្រះ។ តុលាការ ដើរតួនាទីក្នុងការ កំណត់កាលបរិច្ឆេទ ដើម្បីកោះហៅគូភាគី និងបុគ្គលពាក់ព័ន្ធ ឲ្យចូលមកសវនាការ។[39] គោលបំណង ដែលតុលាការកោះហៅគូភាគី និងបុគ្គលពាក់ព័ន្ធ គឺដើម្បីឲ្យភាគីចូលមកបំភ្លឺឲ្យកាន់តែច្បាស់អំពីអង្គហេតុ ការអះអាង និងការផ្តល់ជាព័ត៌មានផ្សេងៗទៀតមកកាន់តុលាការ តាមរយៈការថ្លែងការណ៍ដោយផ្ទាល់មាត់ ឬ ជាលក្ខណៈលាយលក្ខណ៍អក្សរ។ គួរបញ្ជាក់ផងដែរថា នៅក្នុងដំណាក់កាលនេះ ភាគីអាចមកធ្វើការបង្ហាញខ្លួនដោយខ្លួនឯងផ្ទាល់ ឬ ពឹងពាក់អ្នកតំណាងដោយអាណត្តិមកជំនួសក៏បាន។ ប៉ុន្តែ ប្រសិនបើតុលាការយល់ឃើញថា មានភាពចាំបាច់នៅក្នុងការស្វែងយល់ពីរឿងក្តី ហើយទាមទារឲ្យមានការបង្ហាញខ្លួនដោយផ្ទាល់ នោះភាគីត្រូវតែចូលមកបង្ហាញខ្លួន នៅតុលាការជាដាច់ខាត។ អ្នកតំណាងដោយអាណត្តិ ក៏នៅតែមានសិទ្ធិក្នុងការចូលរួមជាមួយភាគីលែងលះដដែល។ ត្រង់ចំណុចនេះ បានបង្ហាញថានីតិវិធីលែងលះដោយព្រមព្រៀង មានលក្ខណៈខុសប្លែកពីនីតិវិធីលែងលះដោយគ្មានការព្រមព្រៀង ត្រង់នីតិវិធីលែងលះដោយការព្រមព្រៀង មិនទាមទារដាច់ខាតឲ្យមាននូវគោលការណ៍ចំពោះមុខឡើយ។[40] ទោះជាយ៉ាងនេះក្តី ករណីយកិច្ចបង្ហាញខ្លួន ក៏នៅតែសំខាន់ខ្លាំងនៅក្នុងនីតិវិធីដដែល ព្រោះភាគីអាចឲ្យអ្នកតំណាងមកជំនួសបានតែក្នុងករណីដែលតុលាការស្វែងយល់ថា ពុំជាការចាំបាច់ពីសំណាក់គូភាគី។ បន្ថែមត្រង់ចំណុចនេះ ក្នុងករណីដែលតុលាការបានកោះហៅគូភាគីឲ្យត្រូវតែចូលមកបង្ហាញខ្លួន ហើយភាគីលែងលះមួយណាដែលមិនសហការបំពេញករណីយកិច្ចទេ នោះតុលាការមានសិទ្ធិក្នុងការពិន័យជាប្រាក់ពីភាគីមិនលើសពី ១.០០០.០០០ (មួយលាន) រៀល។[41]

### ២.៤.២. ការផ្សះផ្សា

នៅខណៈពេលដែលភាគីបានចូលមកតុលាការ ដើម្បីចូលរួមក្នុងនីតិវិធី ចៅក្រមដែលទទួលបន្ទុកលើសំណុំរឿង គឺមានករណីយកិច្ចក្នុងការផ្សះផ្សា មុននឹងឈានដល់ការសម្រេចសេចក្តី។ ទោះបីជាភាគីធ្លាប់បានផ្សះផ្សា នៅដំណាក់កាលក្រុមប្រឹក្សាឃុំ-សង្កាត់យ៉ាងណាក៏ដោយ កាលបើចៅក្រមសង្កេតឃើញថាស្ថានភាពលែងលះរបស់ភាគីអាចនឹងមានការប៉ះពាល់ដល់ប្រយោជន៍របស់កូន ឬ ចៅក្រមមើលឃើញថាភាគីនៅសល់

[39] មាត្រា២៩(១) នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០។

[40] មាត្រា៣ នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[41] មាត្រា២៩(២) នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០។

មនោសញ្ចេតនារវាងគ្នា ឬ ភាគីមានឆន្ទៈមិនទាន់ច្បាស់លាស់លើការសម្រេចចិត្តលែងលះ នោះចៅក្រមនឹងធ្វើការសាកល្បងផ្សះផ្សា រវាងភាគីបន្តទៀត ។ ការផ្សះផ្សាប្រព្រឹត្តទៅក្នុងគោលបំណងឲ្យភាគី ព្រមសះជានឹងគ្នាឡើងវិញ ហើយព្រមដកនូវពាក្យសុំលែងលះ។ ការផ្សះផ្សា មិនមែនគ្រាន់តែធ្វើឡើងឲ្យភាគីកាត់បន្ថយនូវការទាមទារ ក្នុងពាក្យសុំលែងលះប៉ុណ្ណោះទេ គឺការផ្សះផ្សាដោយចៅក្រម និងការសហការជាមួយក្រឡាបញ្ជី ដើម្បីផ្សះផ្សានូវចំណងអាពាហ៍ពិពាហ៍របស់ភាគីឡើងវិញ។[42] ទោះបីជាយ៉ាងនោះក្តី បើភាគីនៅតែមានគោលជំហររឹងមាំក្នុងការឯកភាពគ្នាលែងលះ ចៅក្រមនឹងបន្តនីតិវិធីលែងលះដោយព្រមព្រៀងនេះទៅមុខបន្តទៀត។

### ២.៤.៣. ការទាញហេតុផលដោយផ្ទាល់មាត់

ការលែងលះដោយការព្រមព្រៀង គឺជាការលែងលះដែលភាគីបានបង្ហាញឆន្ទៈរួមគ្នា ក្នុងការកាត់ផ្តាច់ចំណងអាពាហ៍ពិពាហ៍ និងមិនមានការខ្វែងគំនិត លើការទាមទារណាមួយឡើយ ដោយហេតុនេះ នាំឲ្យដំណើររឿងមិនសូវមានលក្ខណៈស្មុគស្មាញ និងឧបសគ្គខ្លាំង ទើបតុលាការមិនចាំបាច់ធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនោះទេ។ បន្ថែមពីនេះ យោងតាមច្បាប់ស្តីពីនីតិវិធីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ចៅក្រមអាចធ្វើការចេញដីកាសម្រេច ដោយពុំចាំបាច់ឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ក៏បាន។[43] បានសេចក្តីថា ចំពោះការទាញហេតុផលដោយផ្ទាល់មាត់ គឺចៅក្រមមានឆន្ទានុសិទ្ធិក្នុងការសម្រេចថា តុលាការគួរធ្វើនីតិវិធីក្នុងការទាញហេតុផលដោយផ្ទាល់មាត់ ឬ មិនបាច់ធ្វើនីតិវិធីក្នុងការទាញហេតុផលដោយផ្ទាល់មាត់ក៏បាន។ ក្នុងករណីដែលតុលាការយល់ឃើញថាចាំបាច់ តុលាការមានសិទ្ធិក្នុងការសាកសួរអ្នកដាក់ពាក្យសុំ ឬ ភាគីម្ខាងទៀត ឬ បុគ្គលដែលពាក់ព័ន្ធដោយឆន្ទានុសិទ្ធិរបស់តុលាការ។[44] តុលាការមានសិទ្ធិអំណាចក្នុងការស្រាវជ្រាវលើអង្គហេតុ និងត្រួតពិនិត្យលើភស្តុតាងផ្សេងៗ ដែលបានដាក់មកតុលាការតាមឆន្ទានុសិទ្ធិ។[45]

នៅក្នុងការអនុវត្តជាក់ស្តែង ប្រសិនបើតុលាការយល់ឃើញថា នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់មានភាពចាំបាច់ក្នុងការសម្រេចសេចក្តី នោះតុលាការនឹងកំណត់កាលបរិច្ឆេទ និងកោះហៅភាគីឲ្យចូលរួមក្នុងដំណើរនីតិវិធី ។ សព្វថ្ងៃនេះ ការអនុវត្តលើការសាកសួរអ្នកដាក់ពាក្យសុំ ឬ ភាគីម្ខាងទៀត ឬ បុគ្គលដែលពាក់ព័ន្ធ គឺធ្វើនៅក្នុងបន្ទប់របស់ចៅក្រម ដោយក្រឡាបញ្ជីនៅអមដើម្បីជាជំនួយការនៅក្នុងការកត់ត្រា រីឯនីតិវិធី ទាញហេតុផលដោយផ្ទាល់មាត់ តែងធ្វើឡើងនៅក្នុងសាលសវនាការ។ ទន្ទឹមនឹងនេះ ចៅក្រមត្រូវជូនដំណឹងអំពីការសាកសួរ និងកាលបរិច្ឆេទនៃការទាញហេតុផលផ្ទាល់មាត់ទៅតំណាងអយ្យការ[46] ក្នុងករណីដែលការលែងលះ

---

[42] មាត្រា៩៨៤ នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[43] មាត្រា២៨(១) នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០។

[44] មាត្រា២៨(២) នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០។

[45] មាត្រា២៧ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០។

[46] មាត្រា៣០ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០។

ដោយព្រមព្រៀង មិនមានអ្វីប៉ះពាល់ដោយផលប្រយោជន៍សាធារណៈ នោះចៅក្រមមិនចាំបាច់ជូនដំណឹងដល់តំណាងអយ្យការក្នុងការចូលរួមក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ក៏បាន។

### ២.៤.៤. ការសម្រេចលើពាក្យស្នើសុំ

នីតិវិធីចុងក្រោយបង្អស់ នៅក្នុងការស្នើសុំលែងលះដោយការព្រមព្រៀង គឺ ការចេញសេចក្តីសម្រេចដោយតុលាការ លើពាក្យសុំលែងលះរបស់ភាគី ដោយការចេញនូវដីកាសម្រេចចំពោះការស្នើសុំទាំងឡាយ ដែលភាគីបានដាក់ទៅតុលាការ។ ក្នុងករណីដែលភាគីណាម្ខាង មិនពេញចិត្តចំពោះសេចក្តីសម្រេចរបស់តុលាការមួយផ្នែក ឬទាំងស្រុងទេនោះ ភាគីមានសិទ្ធិក្នុងការធ្វើបណ្តឹងជំទាស់លើដីកាសម្រេច។

#### ២.៤.៤.១. ការចេញដីកាសម្រេច

អនុលោមតាមស្មារតីនៃ ច្បាប់ស្តីពីនីតិវិធីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ការសម្រេចសេចក្តីលើការស្នើសុំលែងលះ គឺតាមរយៈការចេញដីកាសម្រេច ពីតុលាការបន្ទាប់ ពីតុលាការបានពិនិត្យនូវឯកសារភស្តុតាង និងបានស្តាប់ការពិចារណាលើការអះអាងទាំងឡាយរបស់ភាគី។[47]

តុលាការត្រូវចេញដីកាសម្រេច ដោយធ្វើឡើងក្នុងទម្រង់ជាលាយលក្ខណ៍អក្សរ ហើយមានសរសេរសំអាងហេតុ និងសេចក្តីសម្រេចបញ្ចប់ និងមានចុះហត្ថលេខាលើសេចក្តីសម្រេចនោះ។[48] ដីកាសម្រេចនេះតុលាការត្រូវធ្វើការជូនដំណឹងឲ្យទៅអ្នកដាក់ពាក្យសុំលែងលះ និងភាគីម្ខាងទៀត តាមរយៈការបញ្ជូន ឬ តាមរយៈការផ្ញើជាឯកសារថតចម្លងយថាភូត។[49] គួរបញ្ជាក់ផងដែរថា ដីកាសម្រេចនេះ គឺមានអានុភាពដូចជាសាលក្រមលែងលះដែរ។ ដីកាសម្រេច មានអានុភាពបន្ទាប់ពីចូលជាស្ថាពរ។ ការចូលជាស្ថាពរ នៃដីកាសម្រេច គឺមានរយៈពេល ២សប្តាហ៍ គិតចាប់ពីថ្ងៃជូនដំណឹងអំពីដីកាសម្រេច ហើយមិនមានបណ្តឹងជំទាស់ពីភាគី។[50]

#### ២.៤.៤.២. បណ្តឹងជំទាស់

ចំណែកឯ ការប្តឹងជំទាស់វិញ ភាគីមានសិទ្ធិក្នុងការធ្វើបណ្តឹងជំទាស់លើការសម្រេចទាំងឡាយណាដែលមានឥទ្ធិពលនាំឲ្យខូចប្រយោជន៍របស់ភាគី។ ភាគីដែលមានបំណងចង់ដាក់ពាក្យសុំប្តឹងជំទាស់ត្រូវតែធ្វើឡើងក្នុងអំឡុងពេល ២ (ពីរ)សប្តាហ៍គិតចាប់ពីថ្ងៃទទួលបានការជូនដំណឹង។[51] ការប្តឹងជំទាស់នេះមិនអាចស្នើសុំឲ្យតុលាការមានការពន្យាពេលឡើយ ភាគីដែលខកខានមិនបានដាក់ការប្តឹងជំទាស់ ដោយគ្មានកំហុសរបស់ខ្លួននោះអាចមានឱកាសដាក់បណ្តឹងជំទាស់ក្នុងអំឡុងពេល ១ (មួយ) សប្តាហ៍ ក្រោយមូលហេតុដែលនាំឲ្យការ

[47] មាត្រា៣(២) នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០។

[48] មាត្រា៣៥ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០។

[49] មាត្រា៣៦ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០។

[50] មាត្រា៣៧, មាត្រា៤០ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០។

[51] មាត្រា៤០ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០។

ខកខាននោះរលត់។[52] ចំពោះការជំនុំជម្រះលើការប្ដឹងជំទាស់ គឺអនុវត្តដូចគ្នានឹងនីតិវិធីនៃការជំនុំជម្រះលើបណ្ដឹងជំទាស់ដែលមានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី។[53] មូលហេតុដែលនាំឲ្យការជំនុំជម្រះលើបណ្ដឹងជំទាស់ត្រូវផ្លាស់ប្ដូរការអនុវត្តតាមក្រមនីតិវិធីរដ្ឋប្បវេណីវិញ គឺដោយសារតែភាគីពុំមានការព្រមព្រៀងគ្នាលើការសម្រេចតទៅទៀតឡើយ ដូចនេះហើយវិវាទនោះត្រូវផ្ទេរទៅដោះស្រាយបន្តនៅតុលាការជាន់ខ្ពស់។

បើក្រឡេកមកមើលការអនុវត្តជាក់ស្ដែងវិញ ឃើញថាការធ្វើសេចក្ដីសម្រេច លើពាក្យសុំលែងលះដោយព្រមព្រៀង ពុំសូវមានការធ្វើបណ្ដឹងជំទាស់ច្រើនឡើយ ដោយសារតែភាគីបានព្រមព្រៀងគ្នាជាមុនក្នុងការសម្រេចចិត្តលែងលះ និងការបែងចែកផ្សេងៗជាមួយគ្នារួចជាស្រេច មុននឹងភាគីយកពាក្យសុំលែងលះមកដាក់នៅតុលាការ។ រីឯតុលាការវិញ បានសម្រេចសេចក្ដីលើការលែងលះ ដោយព្រមព្រៀង តាមការពិចារណាដោយផ្អែកលើការអះអាង និងភស្ដុតាងដែលភាគីបានដាក់ជូនមកតុលាការពិនិត្យ។ ចំណុចសំខាន់ដែលតុលាការត្រូវយកចិត្តទុកដាក់ គឺឆន្ទៈរបស់គូភាគី ថាតើភាគីពិតជាមានឆន្ទៈពិតប្រាកដក្នុងការលែងលះ ឬ យ៉ាងណា ? ក្នុងករណីដែលតុលាការ យល់ឃើញថា ភាគីពិតជាមានឆន្ទៈច្បាស់លើការលែងលះដោយព្រមព្រៀង តុលាការនឹងធ្វើការសម្រេចសេចក្ដីដោយ ចេញដីកាសម្រេចជូនគូភាគី។

ក្នុងករណីដែលភាគីលែងលះ មានចំណុចខ្វែងគ្នាលើកម្មវត្ថុណាមួយនោះ ការទាមទារលែងលះដោយព្រមព្រៀង នឹងក្លាយជា ការលែងលះដោយគ្មានការព្រមព្រៀង។ ដូចនេះ បន្ទាប់ពីបានសិក្សាស្រាវជ្រាវលើជំពូកទី២ អំពីនីតិវិធីនៃការលែងលះដោយព្រមព្រៀងរួចហើយ ក្នុងជំពូកបន្ទាប់នេះដែលជា ជំពូកទី៣ នឹងបកស្រាយ អំពីនីតិវិធីនៃការលែងលះដោយមិនមានការព្រមព្រៀង វិញម្ដង។

---

[52] មាត្រា៤១ នៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង, នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០។

[53] មាត្រា៤២ នៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង, នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០។

# ជំពូកទី៣
# ការលែងលះដោយគ្មានការព្រមព្រៀង

# ជំពូកទី៣

# ការលែងលះដោយគ្មានការព្រមព្រៀង

ការលែងលះដោយគ្មានការព្រមព្រៀង ត្រូវធ្វើឡើងនៅពេលដែលភាគីនៃចំណងអាពាហ៍ពិពាហ៍ មិនបានព្រមព្រៀងគ្នាក្នុងការបញ្ចប់នូវចំណងអាពាហ៍ពិពាហ៍ ឬ ភាគីមានទំនាស់លើការបែងចែកសិទ្ធិ និងកាតព្វកិច្ចផ្សេងៗក្រោយការលែងលះ។ ការលែងលះដោយគ្មានការព្រមព្រៀង គឺស្ថិតនៅក្រោមវិសាលភាព នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល។[54] ការលែងលះដោយគ្មានការព្រមព្រៀងនេះ ត្រូវឆ្លងកាត់នូវដំណាក់កាលនីតិវិធីរដ្ឋប្បវេណីជាច្រើន មុននឹងឈានដល់ការសម្រេចសេចក្តីដោយសាលក្រមរបស់តុលាការ។ អាស្រ័យហេតុនេះ នៅក្នុងនីតិវិធីនៃការលែងលះដោយគ្មានការព្រមព្រៀង នឹងត្រូវធ្វើការសិក្សាទៅលើ៖ (៣.១.) **ទិដ្ឋភាពទូទៅនៃការលែងលះដោយការព្រមព្រៀង**, (៣.២.) **អង្គាធរមានសមត្ថកិច្ច**, (៣.៣.) **នីតិវិធីដែលត្រូវបំពេញដោយភាគី**, និង(៣.៤.) **នីតិវិធីក្នុងការជំនុំជម្រះ**។

## ៣.១. ទិដ្ឋភាពទូទៅនៃការលែងលះដោយគ្មានការព្រមព្រៀង

ការលែងលះដោយគ្មានការព្រមព្រៀង ត្រូវធ្វើឡើងនៅពេលដែលភាគីនៃចំណងអាពាហ៍ពិពាហ៍ មានការបែកបាក់នូវចំណងអាពាហ៍ពិពាហ៍រវាងគ្នា រហូតឈានដល់ការធ្វើបណ្តឹងលែងលះ។ ការលែងលះដោយគ្មានការព្រមព្រៀងនេះ មានភាពស្មុគស្មាញច្រើន ព្រោះភាគីមានទំនាស់លើការបញ្ចប់អាពាហ៍ពិពាហ៍ រួមទាំងការបែងចែកសិទ្ធិ និងកាតព្វកិច្ចផ្សេងៗទៀតរវាងគ្នា ក្រោយការលែងលះ។ ការដែលនាំឲ្យកើតមានការលែងលះដោយគ្មានការព្រមព្រៀង គឺដោយសារតែភាគីមិនបានបំពេញនូវករណីយកិច្ចសហព័ទ្ធរវាងគ្នាឲ្យបានល្អ ដូចជា៖ ការចូលរួមកសាងជីវភាពជាមួយគ្នា, ការសហការគ្នាក្នុងរង្វង់គ្រួសារ, ការជួយមើលថែ សង្គ្រោះគ្នាទៅវិញទៅមកជាដើម។ មូលហេតុដែលការលែងលះដោយគ្មានការព្រមព្រៀង ត្រូវដោះស្រាយដោយ ប្រព័ន្ធនីតិវិធីរដ្ឋប្បវេណីដែលមានទាំងការអនុលោមនូវ ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល និងក្រមនីតិវិធីរដ្ឋប្បវេណី គឺដោយសារតែគោលបំណងចង់ឲ្យតុលាការ ជួយដោះស្រាយវិវាទរដ្ឋប្បវេណីទាំងឡាយ ជាពិសេសការលែងលះជាដើមឲ្យឆាប់រហ័ស និងដើម្បីការពារសិទ្ធិ ព្រមទាំងផលប្រយោជន៍របស់ភាគីទាំងសងខាងនៃបណ្តឹងលែងលះ។[55] មូលហេតុមួយទៀតគឺ ដោយសារតែការដោះស្រាយរឿងលែងលះដោយគ្មានការព្រមព្រៀងមានលក្ខណៈស្មុគស្មាញ ព្រោះនៅក្នុងអាពាហ៍ពិពាហ៍សហព័ទ្ធតែងមានទំនាក់ទំនង កម្មវត្ថុរួមគ្នាជាច្រើនដូចជា៖ ការប្រើប្រាស់នាមត្រកូល, ការមានកូនជាមួយគ្នា និងទ្រព្យសម្បត្តិដែលរកបានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។ ការលែងលះដោយគ្មានការព្រមព្រៀងកើតឡើង គឺដោយសារតែភាគីមានការខ្វែងគំនិតគ្នា លើការពិភាក្សា

[54] មាត្រា៣ ចំណុច( គ ) នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/រកម/០៦១០/០០៨, ០៨ មិថុនា ២០១០។

[55] កិច្ចសហប្រតិបត្តិការរវាងអង្គការ JICA និងក្រសួងយុត្តិធម៌, *សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី* ( ០២ មិថុនា ២០០៨ ), ៤-៥។

បែងចែកអំពីកម្មវត្ថុទាំងនោះ ឬ ភាគីតែម្ខាងទាមទារលែងលះ ហើយភាគីម្ខាងទៀតមិនព្រមលែងលះ។ ក្នុងករណីនេះ ភាគីដែលចង់ទាមទារលែងលះ ត្រូវតែធ្វើបណ្ដឹងទាមទារលែងលះដាក់ទៅតុលាការ ដោយភ្ជាប់នូវមូលហេតុស្របច្បាប់មកជាមួយ។ មូលហេតុដែលអាចឲ្យតុលាការ យល់ព្រមទទួលយករឿងក្ដីលែងលះ របស់ភាគីមកសម្រេចបាន លុះត្រាតែមូលហេតុទាំងនោះត្រឹមត្រូវទៅតាមផ្លូវច្បាប់ ដូចដែលបានរៀបរាប់ពីខាងដើម ក្នុង ជំពូកទី១ អំពីមូលហេតុនៃការលែងលះ។

## ៣.២. អាជ្ញាធរមានសមត្ថកិច្ច

នៅក្នុងនីតិវិធីនៃការលែងលះដោយគ្មានការព្រមព្រៀង ភាគីនៃបណ្ដឹងលែងលះត្រូវទៅដាក់ពាក្យបណ្ដឹងនៅអាជ្ញាធរមានសមត្ថកិច្ច ដើម្បីបន្តចំណាត់ការទៅលើរឿងក្ដីលែងលះ។ អាជ្ញាធរដែលមានសមត្ថកិច្ចនៅក្នុងការដោះស្រាយ ការលែងលះដោយគ្មានការព្រមព្រៀង មានចំនួនពីរ គឺៈ (**៣.២.១.**) **ក្រុមប្រឹក្សាឃុំ-សង្កាត់ ក្នុងការផ្សះផ្សា** និង (**៣.២.២.**) **តុលាការរាជធានី-ខេត្ត**។

### ៣.២.១. ក្រុមប្រឹក្សាឃុំ-សង្កាត់ ក្នុងការផ្សះផ្សា

នៅក្នុងនីតិវិធីនៃការលែងលះដោយគ្មានការព្រមព្រៀង ក្រុមប្រឹក្សាឃុំ-សង្កាត់ គ្មានយុត្តាធិការលើការសម្រេចសេចក្ដីចំពោះ ការលែងលះនោះទេ ក៏ប៉ុន្តែក្រុមប្រឹក្សាឃុំ-សង្កាត់ បានដើរតួនាទីយ៉ាងចម្បងក្នុងការផ្សះផ្សាបន្ទាប់ពីទទួលបានពាក្យបណ្ដឹងលែងលះពីភាគី។ បច្ចុប្បន្នភាព តាមគោលការណ៍នៃច្បាប់ មានតែស្ថាប័នតុលាការមួយគត់ ដែលមានយុត្តាធិការក្នុងការសម្រេចលើការលែងលះរបស់ភាគី។ យ៉ាងណាមិញចំពោះការអនុវត្តជាក់ស្ដែង ប្រជាពលរដ្ឋកម្ពុជាដែលទាមទារលែងលះ មួយចំនួននិយមដាក់ពាក្យបណ្ដឹងលែងលះ នៅក្រុមប្រឹក្សាឃុំ-សង្កាត់ខាងលំនៅឋានជាមុនសិន ទើបឈានដល់តុលាការជាក្រោយ។ នៅពេលទទួលបានពាក្យបណ្ដឹងលែងលះពីភាគី ក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវគោរពតួនាទីចម្បង នៅក្នុងការផ្សះផ្សាដល់ភាគីខាងប្ដី និងប្រពន្ធ។ ការផ្សះផ្សាដែលបានធ្វើឡើងដោយក្រុមប្រឹក្សាឃុំ-សង្កាត់ ធ្វើឡើងក្នុងគោលដៅដើម្បីឲ្យប្ដី និងប្រពន្ធមានការសះជានឹងគ្នាឡើងវិញ។ មូលហេតុថា ការលែងលះតែងនាំឲ្យភាគីបាត់បង់ផលប្រយោជន៍ច្រើនដូចជា៖ ពេលវេលា ទ្រព្យសម្បត្តិ និងសុភមង្គលក្នុងគ្រួសារ។ ក្រុមប្រឹក្សាឃុំ-សង្កាត់មានរយៈពេលត្រឹមតែ ១៥ថ្ងៃប៉ុណ្ណោះ នៅក្នុងការព្យាយាមផ្សះផ្សា។ បើកន្លងផុតរយៈពេលកំណត់ ភាគីនៅតែគ្មានការសះជាទៀតនោះ ក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវបញ្ជូនពាក្យបណ្ដឹងលែងលះមកតុលាការ ដើម្បីឲ្យតុលាការធ្វើចំណាត់ការលើរឿងក្ដីស្របតាមនីតិវិធី។ ក្នុងករណីដែលការផ្សះផ្សា របស់ក្រុមប្រឹក្សាឃុំ-សង្កាត់ធ្វើឡើងបានសម្រេច ដោយភាគីព្រមសះជានឹងគ្នាវិញ នោះក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវធ្វើកំណត់ហេតុ និងធ្វើកិច្ចសន្យាសះជាដល់ភាគីទាំងពីរ។[56]

[56] មាត្រា៩៨២(២) នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

### ៣.២.២. តុលាការរាជធានី-ខេត្ត

នៅក្នុងរឿងក្តីរដ្ឋប្បវេណី សមត្ថកិច្ចរបស់តុលាការ ត្រូវបានបែងចែក ដោយសំអាងលើបទដ្ឋានដែលច្បាប់បានកំណត់មួយចំនួនដូចជា៖ សមត្ថកិច្ចតាមភារកិច្ច, សមត្ថកិច្ចតាមដែនដី, សមត្ថកិច្ចដែលត្រូវបានកំណត់ដោយតុលាការជាន់ខ្ពស់, និងសមត្ថកិច្ចតាមការព្រមព្រៀងជាដើម។[57] កត្តាទាំងនេះ ជាហេតុនាំឲ្យដើមចោទដែលជាម្ចាស់នៃបណ្តឹងរដ្ឋប្បវេណី មានជម្រើសច្រើននៅក្នុងការជ្រើសរើសតុលាការ ដែលមានសមត្ថកិច្ច។ រឿងក្តីរដ្ឋប្បវេណីមួយចំនួន ច្បាប់បានកំណត់ដែនសមត្ថកិច្ច ក្នុងគោលបំណងដើម្បីរក្សាការពារនូវផលប្រយោជន៍សាធារណៈ។ តុលាការដែលត្រូវបានច្បាប់កំណត់សមត្ថកិច្ចជាដាច់ខាតនោះ ហៅថាសមត្ថកិច្ចផ្តាច់មុខ ឬសមត្ថកិច្ចសាលាជម្រះក្តីពិសេស។[58]

ជាទូទៅ នៅពេលដែលភាគីខាងដើមចោទ ចង់ដាក់ពាក្យបណ្តឹង គឺត្រូវទៅដាក់ពាក្យបណ្តឹងនៅតុលាការខាងលំនៅឋានរបស់ភាគីប្តី ឬ ប្រពន្ធ(ខាងចុងចម្លើយ)។[59] ក្នុងរឿងក្តីលែងលះមានការជាប់ពាក់ព័ន្ធនឹងកម្មវត្ថុច្រើនរវាងភាគី ជាពិសេសកូនៗរបស់ឪពុក និងម្តាយដែលសម្រេចចិត្តប្តឹងលែងលះ ជាហេតុនាំឲ្យច្បាប់កំណត់បន្ថែមឲ្យរឿងក្តីលែងលះ ស្ថិតនៅក្រោមសមត្ថកិច្ចផ្តាច់មុខ របស់សាលាដំបូងដែលមានខាងលំនៅឋានរបស់ភាគីនៃបណ្តឹងលែងលះ ឲ្យមានសមត្ថកិច្ចក្នុងការបើកការជំនុំជម្រះ។[60] ការដោះស្រាយវិវាទលែងលះ គឺមានជាប់ពាក់ព័ន្ធសំខាន់ទៅនឹងឋានៈបុគ្គល ដោយហេតុនេះ ស្មារតីនៃច្បាប់ត្រូវកំណត់សមត្ថកិច្ចផ្តាច់មុខតុលាការខាងលំនៅឋានចំពោះរឿងក្តីលែងលះ ក្នុងគោលបំណងការពារផលប្រយោជន៍បុគ្គលដែលពាក់ព័ន្ធ ពិសេសនោះគឺកូនៗរបស់ភាគី។[61]

ជាពិសេស ការកំណត់សមត្ថកិច្ចផ្តាច់មុខលើរឿងក្តីលែងលះ គឺដើម្បីឲ្យការដោះស្រាយរឿងក្តី ដំណើរការបានងាយស្រួល ពីព្រោះថាតុលាការខាងលំនៅឋានមានទីតាំងជិតនឹងលំនៅឋានគ្រួសារ ដែលងាយស្រួលក្នុងការស្វែងយល់ពីស្ថានភាព និងអង្គហេតុនៃរឿងក្តីបានត្រឹមត្រូវ និងជាពិសេសចំណេញពេលវេលាដល់ភាគីលែងលះថែមទៀតផង។[62] វិវាទរដ្ឋប្បវេណី ដែលត្រូវបានច្បាប់នីតិវិធី ចែងច្បាស់អំពីសមត្ថកិច្ចផ្តាច់មុខ ដូច្នេះនាំឲ្យភាគីមិនអាចដាក់បណ្តឹងលែងលះទៅតុលាការផ្សេងទៀតតាមឆន្ទៈ ឬ ការព្រមព្រៀងរបស់ភាគី ដូចគ្នានឹងប្រភេទវិវាទរដ្ឋប្បវេណីដទៃទៀតឡើយ។

---

[57] កិច្ចសហប្រតិបត្តិការរវាងអង្គការ JICA និងក្រសួងយុត្តិធម៌, *សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី* (០២ មិថុនា ២០០៨), ១៣-២០។

[58] សៀវភៅនីតិវិធីរដ្ឋប្បវេណី របស់ឯកឧត្តម ហ៊ី សោភា, ទំព័រ២៤។

[59] មាត្រា៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

[60] មាត្រា១០ នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

[61] មាត្រា៥ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/រកម/០៦១០/០០៨, ០៨ មិថុនា ២០១០។

[62] សៀវភៅនីតិវិធីរដ្ឋប្បវេណី របស់ឯកឧត្តម ហ៊ី សោភា, ទំព័រ២៤។

## ៣.៣. នីតិវិធីដែលត្រូវបំពេញដោយភាគី

ភាគីដែលចង់រំលាយអាពាហ៍ពិពាហ៍ ត្រូវដាក់ពាក្យបណ្តឹងទៅអាជ្ញាធរមានសមត្ថកិច្ចដូចដែលបានរៀបរាប់ពីខាងលើនេះ ដើម្បីឲ្យរឿងក្តីលែងលះមានដំណើរនីតិវិធីទៅមុខ។ នៅក្នុងនីតិវិធីលែងលះដោយគ្មានការព្រមព្រៀង ភាគីក៏ត្រូវបំពេញនូវកាតព្វកិច្ចមួយចំនួនក្នុងការចូលរួមក្នុងដំណើរនីតិវិធី រហូតដល់មានការបញ្ចប់នីតិវិធីតាមរយៈសេចក្តីសម្រេចរបស់តុលាការ។ នីតិវិធីរដ្ឋប្បវេណីដែលជាកាតព្វកិច្ចរបស់ភាគីត្រូវបំពេញ មានដូចជា៖ (៣.៣.១.) **ការធ្វើបណ្តឹងលែងលះ** និងការដាក់ជូនតុលាការនូវ (៣.៣.២.) **ឯកសារភ្ជាប់ និងភស្តុតាង**។

### ៣.៣.១. ការធ្វើបណ្តឹងលែងលះ

ការលែងលះដោយការគ្មានការព្រមព្រៀង ចាប់ផ្តើមដំណើរការនីតិវិធី នៅពេលដែលសហព័ទ្ធម្ខាងបានដាក់ពាក្យបណ្តឹងទាមទារលែងលះ ដោយអនុលោមតាមច្បាប់ស្តីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ឆ្នាំ២០១០ និងក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។ នៅក្នុងដំណើរការនីតិវិធីនេះ ជំហានដំបូង គឺភាគីត្រូវធ្វើបណ្តឹងលែងលះដោយភ្ជាប់មកជាមួយនឹងឯកសារ ព្រមទាំងភស្តុតាងពាក់ព័ន្ធផ្សេងៗ។ នៅជំហានបន្ទាប់ គឺភាគីត្រូវយកពាក្យបណ្តឹងលែងលះនោះទៅដាក់នៅក្រុមប្រឹក្សាឃុំ-សង្កាត់ ខាងលំនៅឋានប្តីប្រពន្ធ ឬ ទីសំណាក់ ឬ ក៏យកទៅដាក់នៅតុលាការដែលមានសមត្ថកិច្ច និងត្រូវបង់ពន្ធតាមការកំណត់នៃច្បាប់។[63]

#### ៣.៣.១.១. និយមន័យនៃបណ្តឹង

«បណ្តឹង» គឺជាសកម្មភាពទាមទាររបស់ដើមចោទ ដែលបានធ្វើឡើងចំពោះចុងចម្លើយតាមរយៈតុលាការដែលមានសមត្ថកិច្ច ដោយដើមចោទបានអះអាងអំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត តាមផ្លូវច្បាប់នីតិឯកជនកំណត់មួយ ហើយទាមទារឲ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារកំណត់មួយ ផ្អែកលើការអះអាង និងភស្តុតាង។

តាមរយៈការដាក់ពាក្យបណ្តឹងនេះ នីតិវិធីនៃបណ្តឹងនៅក្នុងលំហូរនៃនីតិវិធីរដ្ឋប្បវេណីត្រូវបានចាប់ផ្តើមឡើង។[64] ជាបឋម ប្រភេទនៃបណ្តឹងនៅក្នុងនីតិវិធីរដ្ឋប្បវេណីត្រូវបានចែកចេញជា៖ បណ្តឹងទាមទារឲ្យផ្តល់តាវកាលិក, បណ្តឹងទាមទារឲ្យបញ្ជាក់, បណ្តឹងទាមទារឲ្យបង្កើត ឬ ផ្លាស់ប្តូរ ឬរំលត់នូវទំនាក់ទំនងគតិយុត្តជាដើម។[65] ប្រភេទនៃបណ្តឹងទាំងនោះត្រូវបានកំណត់អត្តសញ្ញាណ ដោយផ្អែកលើខ្លឹមសារនៃបណ្តឹង។[66] ចំពោះរឿងក្តីរដ្ឋប្បវេណីពាក់ព័ន្ធនឹងការលែងលះ គឺជាប្រភេទបណ្តឹងទាមទារឲ្យរំលត់ទំនាក់ទំនងគតិយុត្តរវាងសហព័ទ្ធ។

---

[63] មាត្រា៩៨២ នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[64] កិច្ចសហប្រតិបត្តិការរវាងអង្គការ JICA និងក្រសួងយុត្តិធម៌, *សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី* (០២ មិថុនា ២០០៨), ៥០-៥១។

[65] កិច្ចសហប្រតិបត្តិការរវាងអង្គការ JICA និងក្រសួងយុត្តិធម៌, *សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី* (០២ មិថុនា ២០០៨), ៥៤-៥១។

[66] កិច្ចសហប្រតិបត្តិការរវាងអង្គការ JICA និងក្រសួងយុត្តិធម៌, *សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី* (០២ មិថុនា ២០០៨), ៥១។

ជារួមគឺ បណ្តឹងទាមទារលែងលះនេះ គឺជាប្រភេទបណ្តឹងដែលប្តី ឬ ប្រពន្ធ ណាម្ខាងនៃអាពាហ៍ពិពាហ៍ស្របច្បាប់ (ឋានៈជាដើមចោទ) បានធ្វើសកម្មភាពប្តឹងទាមទារលែងលះ ពីប្តី ឬ ប្រពន្ធរបស់ខ្លួន (ឋានៈជាចុងចម្លើយ) ក្នុងករណីដែលពុំមានការព្រមព្រៀងរវាងគ្នាក្នុងការលែងលះ ដូចនេះភាគីដែលជាដើមចោទ ប្តឹងទៅតុលាការដែលមានសមត្ថកិច្ច ដើម្បីទទួលបានសាលក្រមលែងលះ និងសេចក្តីសម្រេចលើចំណុចវិវាទផ្សេងៗដូចជា៖ សិទ្ធិអំណាចមេបា, អាហារកាតព្វកិច្ច, ទ្រព្យសម្បត្តិជាដើម។

នៅក្នុងរឿងក្តីលែងលះដោយគ្មានការព្រមព្រៀង ជនដែលមានសិទ្ធិក្នុងការធ្វើបណ្តឹងទាមទារលែងលះទៅតុលាការ គឺជាសហព័ន្ធ ឬ ជានីតិសង្វាសជន។ ពាក្យ «នីតិសង្វាសជន» នៅក្នុងបរិបទគតិយុត្តនៃព្រះរាជាណាចក្រកម្ពុជា គឺសំដៅដល់ប្តី និងប្រពន្ធស្របច្បាប់ ដែលបានចុះសំបុត្រអាពាហ៍ពិពាហ៍ នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន។[67] អាពាហ៍ពិពាហ៍នោះគឺត្រូវបានទទួលស្គាល់ដោយច្បាប់ ដោយភាគីក៏ត្រូវបានច្បាប់ទទួលស្គាល់ថាជាសហព័ទ្ធផងដែរ។ ក្នុងករណីដែលសហព័ទ្ធចង់បញ្ចប់នូវទំនាក់ទំនងគតិយុត្តនេះ ភាគីត្រូវធ្វើបណ្តឹងទាមទារលែងលះទៅតុលាការ ដើម្បីឲ្យតុលាការធ្វើការជំនុំជម្រះសេចក្តី លើការប្តឹងសុំទាមទារឲ្យរំលត់នូវទំនាក់ទំនងគតិយុត្ត ហើយក៏ដើម្បីឲ្យតុលាការធ្វើការវិនិច្ឆ័យសេចក្តីលើការ ប្តឹងសុំទាមទារបន្ទាប់បន្សំផ្សេងៗទៀត ដោយការចេញនូវសាលក្រមសម្រេចដល់ភាគី។ ការលែងលះដោយគ្មានការព្រមព្រៀងរវាងនីតិសង្វាសជន មានអានុភាពស្ថាពរ លុះត្រាតែមានសាលក្រមស្ថាពរពីតុលាការ តាមរយៈការធ្វើបណ្តឹងទាមទារការលែងលះពីភាគី។ នៅក្នុងការធ្វើបណ្តឹងទាមទារលែងលះ ភាគីក៏ត្រូវអនុវត្តកាតព្វកិច្ចមួយចំនួនរបស់ខ្លួនពាក់ព័ន្ធនឹងនីតិវិធីបណ្តឹងផងដែរ ដើម្បីឲ្យនីតិវិធីរបស់តុលាការមិនមានភាពស្មុគស្មាញ និងឆាប់រហ័ស។

### ៣.៣.១.២. ការសរសេរពាក្យបណ្តឹង

នៅក្នុងនីតិវិធីរដ្ឋប្បវេណី ពាក្យបណ្តឹងមានសារៈសំខាន់ខ្លាំងណាស់ ពីព្រោះថា មានពាក្យបណ្តឹង ទើបនាំឲ្យមានការបើកការជំនុំជម្រះដោយតុលាការ។ ជាពិសេសនោះគឺ នៅក្នុងរឿងក្តីរដ្ឋប្បវេណី តុលាការនឹងធ្វើការជំនុំជម្រះតែលើការទាមទារដែលភាគីបានសរសេរច្បាស់នៅក្នុងពាក្យបណ្តឹងតែប៉ុណ្ណោះ។[68] ចំពោះការសរសេរពាក្យបណ្តឹងលែងលះទៅសាលាដំបូងរាជធានី-ខេត្ត សហព័ទ្ធដែលជាអ្នកធ្វើបណ្តឹងលែងលះ ត្រូវបានច្បាប់កំណត់ឲ្យហៅថា «ភាគីដើមបណ្តឹង ឬ ភាគីដើមចោទ» ហើយសហព័ទ្ធម្ខាងទៀតដែលទទួលរងការប្តឹងពីបណ្តឹងលែងលះនោះ ត្រូវបានច្បាប់កំណត់ឲ្យហៅថាជា «ចុងចម្លើយ»។[69] ពាក្យបណ្តឹងលែងលះនេះមានអានុភាព និងមិនត្រូវបានលុបចោលដោយតុលាការលុះត្រាតែពាក្យបណ្តឹងត្រឹមត្រូវតាមទម្រង់ដែលច្បាប់បានកំណត់។[70]

[67] មាត្រា៣០ នៃអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន, លេខ ១០៣ អនក្រ.បក, ២៩ ធ្នូ ២០០០។

[68] មាត្រា១៨២ នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

[69] មាត្រា៣២(១) នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

[70] មាត្រា៧៨(២) នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

នៅក្នុងពាក្យបណ្តឹងដើមចោទត្រូវសរសេរអំពី៖ ឈ្មោះ របស់ដើមចោទ និងចុងចម្លើយ។ ជាទូទៅ គឺនៅក្នុងពាក្យបណ្តឹងក៏ត្រូវបញ្ជាក់ឲ្យច្បាស់នូវអត្តសញ្ញាណផ្សេងៗរបស់ប្តី និងប្រពន្ធដូចជា ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើតជាដើម។ ម៉្យាងវិញទៀត ក្នុងករណីដែលភាគីខាងប្តី ឬ ប្រពន្ធមានអ្នកតំណាងនោះ ឈ្មោះ ឬ នាមករណ៍ ព្រមទាំងអត្តសញ្ញាណផ្សេងៗនៃអ្នកតំណាងក៏ត្រូវសរសេរនៅក្នុងពាក្យបណ្តឹងលែងលះនោះផងដែរ។ អាសយដ្ឋាន គឺជាចំណុចសំខាន់បន្ទាប់ពីឈ្មោះ របស់សហព័ទ្ធ ដែលបានដាក់ពាក្យបណ្តឹងលែងលះដោយគ្មានការព្រមព្រៀង។ នៅក្នុងអាសយដ្ឋានត្រូវកំណត់អំពី៖ លេខផ្ទះ, ផ្លូវ, ភូមិ, ឃុំ/សង្កាត់, ក្រុង/ស្រុក/ខណ្ឌ, និងរាជធានី/ខេត្ត។[71] ភាគីត្រូវសរសេររៀបរាប់មកកាន់តុលាការអំពីកម្មវត្ថុនៃបណ្តឹង ដែលក្នុងន័យនេះ គឺសំដៅលើការបញ្ជាក់មកតុលាការឲ្យយល់ច្បាស់ថា កម្មវត្ថុនៃបណ្តឹងនេះ គឺជាបណ្តឹងលែងលះ និងការប្តឹងទាមទារឲ្យតុលាការសម្រេចអំពីសិទ្ធិ និងកាតព្វកិច្ចមួយចំនួនទៀតដល់ភាគីនៅក្រោយពេលដែលភាគីបានលែងលះ។

បន្ថែមពីនេះ នៅក្នុងពាក្យបណ្តឹងត្រូវតែបញ្ជាក់ឲ្យច្បាស់អំពីខ្លឹមសារដែលដើមចោទ ចង់ឲ្យតុលាការចេញនូវសាលក្រមលើការទាមទារនោះ។ ក្នុងនោះផងដែរខ្លឹមសារដែលត្រូវបញ្ជាក់រួមមាន ខ្លឹមសារទាមទារចម្បង និងខ្លឹមសារទាមទារបន្ទាប់បន្សំ។ ចំពោះខ្លឹមសារទាមទារចម្បងក្នុងបរិបទនេះ គឺជាការទាមទារនូវការលែងលះ។ ចំណែកឯ ការទាមទារបន្ទាប់បន្សំ គឺសំដៅលើការទាមទារឲ្យតុលាការចេញនូវការសម្រេច លើការទាមទារផ្សេងៗទៀត ដែលភាគីលែងលះបានខ្វែងគំនិតនឹងគ្នា ហើយមិនអាចពិភាក្សាគ្នាដូចជា វិវាទពាក់ព័ន្ធនឹងការបែងចែកទ្រព្យសម្បត្តិ ការបែងចែកអំណាចមេបា និងការទទួលខុសត្រូវលើអាហារកាតព្វកិច្ចជាដើម។ ចំណុចចុងក្រោយ ដែលត្រូវបញ្ជាក់នៅក្នុងបណ្តឹង គឺអង្គហេតុនៃការទាមទារដោយហេតុផលថា នៅក្នុងមូលដ្ឋានគតិយុត្ត អង្គហេតុ គឺជាព្រឹត្តិការណ៍សំខាន់ដើម្បីឲ្យតុលាការអាចធ្វើការសម្រេចសេចក្តី។ អង្គហេតុចម្បងនៅក្នុងរឿងក្តីលែងលះ គឺតម្រូវឲ្យភាគីធ្វើការបង្ហាញ ពីចំណងគតិយុត្តដោយស្របច្បាប់ ទៅកាន់តុលាការពីព្រោះការលែងលះអាចទាមទារទៅបាន លុះត្រាតែមានចំណងអាពាហ៍ពិពាហ៍កើតឡើង ជាមុនសិន។ តុលាការយល់ព្រមទទួលបណ្តឹងលែងលះ លុះត្រាតែភាគីពិតជាមានអត្ថិភាពនៃសិទ្ធិក្នុងការធ្វើបណ្តឹងលែងលះ។[72]

លើសពីនេះទៅទៀត នៅក្នុងបណ្តឹងលែងលះ ដើមចោទត្រូវបញ្ជាក់ឲ្យបានច្បាស់លាស់នូវអង្គហេតុដែលជាមូលហេតុនៃការទាមទារ។[73] អង្គហេតុដែលជាមូលហេតុនៃការទាមទារ ជាអង្គហេតុទាំងឡាយណា ដែលជាហេតុការណ៍នាំឲ្យដើមចោទសម្រេចចិត្តធ្វើបណ្តឹងលែងលះ។ អង្គហេតុទាំងនេះភាគច្រើនមានព្រឹត្តិការណ៍

[71] មាត្រា៧៥(២) ចំណុច(ក) នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

[72] មាត្រា៧៥(២) ចំណុច(ខ) នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

[73] មាត្រា៧៥(៣) នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

ប្រហាក់ប្រហែល ឬ ដូចនឹងការកំណត់នៃច្បាប់រដ្ឋប្បវេណីអំពីមូលហេតុនៃការទាមទារលែងលះ នៅក្នុងមាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណី។ ដើម្បីបំភ្លឺនូវអង្គហេតុទាំងនោះឲ្យកាន់តែច្បាស់លាស់ ភាគីត្រូវភ្ជាប់មកជាមួយនូវឯកសារជាភស្តុតាងជូនដល់តុលាការពិនិត្យផងដែរ។

### ៣.៣.១.៣. ការដាក់ពាក្យបណ្តឹង និងការបង់ពន្ធ

ការដាក់ពាក្យបណ្តឹងលែងលះជាទូទៅ គឺដើមចោទនៃបណ្តឹងលែងលះមានជម្រើសចំនួនពីរ។ ជម្រើសទី១ គឺដើមចោទ អាចដាក់ពាក្យបណ្តឹងទៅក្រុមប្រឹក្សាឃុំ-សង្កាត់។[74] ក្រុមប្រឹក្សាឃុំ-សង្កាត់នឹងធ្វើការផ្សះផ្សា ក្នុងរយៈពេល ១៥ថ្ងៃ ហើយប្រសិនបើគ្មានការសះជានឹងគ្នារវាងភាគីលែងលះទេនោះ ក្រុមប្រឹក្សាឃុំ-សង្កាត់ នឹងបញ្ជូនពាក្យបណ្តឹងលែងលះទៅតុលាការដើម្បីបន្តនីតិវិធីនៃការលែងលះដោយគ្មានការព្រមព្រៀង។ ជម្រើសទី២ គឺដើមចោទទៅដាក់ពាក្យបណ្តឹង នៅសាលាដំបូងរាជធានី-ខេត្ត ដែលមានសមត្ថកិច្ចលើរឿងក្តីលែងលះរបស់ខ្លួនតែម្តង ដោយមិនឆ្លងកាត់ការដាក់ពាក្យបណ្តឹងលែងលះនៅក្រុមប្រឹក្សាឃុំ-សង្កាត់ឡើយ។[75] មូលហេតុដែលភាគីលែងលះមានសិទ្ធិដាក់ពាក្យបណ្តឹងលែងលះទៅក្រុមប្រឹក្សាឃុំ-សង្កាត់ ឬ តុលាការបាន ព្រោះថាស្ថាប័នទាំងពីរនេះមានសមត្ថកិច្ចលើរឿងក្តីលែងលះតាមការបញ្ញត្តិក្នុងមាត្រា ៩៨២ នៃក្រមរដ្ឋប្បវេណី។ នៅក្នុងករណីជាក់ស្តែង ប្រសិនបើដើមចោទបានធ្វើការពឹងពាក់មេធាវីតំណាងដោយអាណត្តិ នោះមេធាវីនឹងដើរតួនាទីក្នុងការទៅដាក់ពាក្យបណ្តឹង នៅសាលាដំបូងតំណាងឲ្យកូនក្តីរបស់ខ្លួន។[76] នៅពេលដែលពាក្យបណ្តឹងត្រូវបានដាក់ទៅដល់សាលាដំបូង ក្រឡាបញ្ជី គឺជាអ្នកដែលមានកាតព្វកិច្ចក្នុងការទទួលនូវពាក្យបណ្តឹងលែងលះមកធ្វើការពិនិត្យ និងចុះលេខសំណុំរឿង។ ក្រឡាបញ្ជីត្រូវធ្វើការពិនិត្យពាក្យបណ្តឹងលែងលះ ដោយផ្អែកតាមទម្រង់ដែលច្បាប់បានកំណត់។ បន្ទាប់ពីបានពិនិត្យឃើញថា ពាក្យបណ្តឹងលែងលះនោះត្រឹមត្រូវទៅតាមទម្រង់ច្បាប់រួចហើយ ក្រឡាបញ្ជីត្រូវបញ្ជូនរឿងក្តីនេះទៅដល់ចៅក្រមដើម្បីដំណើរការនីតិវិធីបន្ត។[77] ក៏ប៉ុន្តែ ក្នុងករណីដែលក្រឡាបញ្ជីពិនិត្យឃើញថា ពាក្យបណ្តឹងលែងលះមិនត្រឹមត្រូវតាមទម្រង់ច្បាប់ដែលបានកំណត់ទេនោះ ក្រឡាបញ្ជីត្រូវប្រញាប់រាយការណ៍ទៅចៅក្រម ដើម្បីឲ្យចៅក្រមធ្វើការសម្រេចថា ពាក្យបណ្តឹងលែងលះនោះគួរតែឲ្យអ្នកដាក់ពាក្យបណ្តឹងធ្វើការកែតម្រូវ ឬ សម្រេចលើកចោលតាមរយៈដីកាសម្រេច។ ចៅក្រមមានឆន្ទានុសិទ្ធិសម្រេចលើកចោលពាក្យបណ្តឹងតាមរយៈដីកាសម្រេច កាលបើបណ្តឹងនោះ មានលក្ខណៈផ្ទុយនឹងច្បាប់។[78]

---

[74] មាត្រា៩៨២(២) នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[75] មាត្រា១០ នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦ និងមាត្រា៥ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/រកម/០៦១០/០០៨, ០៨ មិថុនា ២០១០។

[76] មាត្រា៥៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

[77] មាត្រា៧៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

[78] មាត្រា៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

បន្ថែមពីនេះ ដើមចោទនៃបណ្តឹងលែងលះ ត្រូវមានកាតព្វកិច្ចនៅក្នុងការបង់ពន្ធលើដំណើរការរឿងក្តីរដ្ឋប្បវេណី ជូនរដ្ឋផងដែរ។ ចំពោះករណីពាក្យបណ្តឹងលែងលះដោយគ្មានការព្រមព្រៀង ចំនួនទឹកប្រាក់លើពន្ធដាក់ពាក្យបណ្តឹងត្រូវស្មើនឹង ៥.៥០០.០០០ (ប្រាំលានប្រាំសែន) រៀល ។[79] ប្រសិនបើដើមចោទ មិនបានបង់ពន្ធនៅពេលដាក់ពាក្យបណ្តឹងទេ នោះតុលាការនឹងធ្វើការកំណត់រយៈពេលសមរម្យមួយឲ្យដើមចោទបង់ប្រាក់ តាមរយៈដីកាបង្គាប់ឲ្យបង់ពន្ធ។ បើដើមចោទនៅតែមិនព្រមបង់ពន្ធឲ្យបានត្រឹមត្រូវ តុលាការនឹងលើកចោលពាក្យសុំលែងលះតាមរយៈដីកាសម្រេច។[80]

### ៣.៣.២. ឯកសារភ្ជាប់ និងភស្តុតាង

នៅក្នុងពេលដែលដើមចោទ បានដាក់ពាក្យបណ្តឹងលែងលះទៅតុលាការ នោះដើមចោទក៏ត្រូវភ្ជាប់មកជាមួយនូវឯកសារដែលមានតម្លៃគតិយុត្តមួយចំនួន ដែលមានការពាក់ព័ន្ធជាមួយរឿងក្តីមកជាមួយផងដែរ។ ឯកសារទាំងនោះមានដូចជា សំបុត្រអាពាហ៍ពិពាហ៍ សំបុត្រកំណើតរបស់កូនៗ(ប្រសិនបើភាគីមានកូន) និងឯកសារផ្សេងៗទៀត ដែលពាក់ព័ន្ធនឹងទ្រព្យសម្បត្តិ។ គុណប្រយោជន៍នៃការបង្ហាញឯកសារទាំងនេះទៅកាន់តុលាការ គឺដើម្បីសម្រួលឲ្យតុលាការ កាន់តែមានភាពងាយស្រួល ស្វែងយល់លើរឿងក្តី និងងាយស្រួលក្នុងដំណើរការនីតិវិធីឲ្យបានឆាប់រហ័ស។ ចំណែកឯ កាតព្វកិច្ចក្នុងការស្វែងរកភស្តុតាងវិញ ដោយហេតុថារឿងក្តីលែងលះ ជាប្រភេទវិវាទរដ្ឋប្បវេណី ដូចនេះតុលាការពឹងផ្អែកតែលើអង្គហេតុ ភស្តុតាង និងសាក្សីទាំងឡាយណាដែលភាគីបានអះអាង មកកាន់តុលាការតែប៉ុណ្ណោះ។ ទន្ទឹមនឹងនេះ តុលាការទទួលពិនិត្យរាល់ភស្តុតាងទាំងឡាយ ដែលភាគីបានស្នើសុំឲ្យពិនិត្យ សម្រាប់យកមកធ្វើជាមូលដ្ឋានក្នុងការសម្រេចសេចក្តី។[81] តុលាការគ្មានកាតព្វកិច្ចក្នុងការស្វែងរកភស្តុតាង នៅក្នុងរឿងក្តីរដ្ឋប្បវេណីឡើយ ដូចចំណាត់ការរឿងក្តីព្រហ្មទណ្ឌឡើយ។ នៅក្នុងការសម្រេចសេចក្តីលែងលះ ភស្តុតាងមានសារៈសំខាន់ខ្លាំងណាស់ ពីព្រោះតុលាការទទួលស្គាល់អង្គហេតុទាំងឡាយដែលភាគីបានព្យាយាមអះអាង ដោយពឹងផ្អែកលើភស្តុតាងជាមូលដ្ឋាន។[82] ភាគីមានសិទ្ធិក្នុងការស្នើសុំឲ្យតុលាការធ្វើការពិនិត្យភស្តុតាងទាំងនោះ។ ក្នុងករណីដែលភាគីមានបំណងចង់ស្នើសុំឲ្យតុលាការពិនិត្យភស្តុតាង ភាគីត្រូវតែបំភ្លឺឲ្យបានច្បាស់លាស់អំពីអង្គហេតុ និងទំនាក់ទំនងរវាងអង្គហេតុនិង

[79] ប្រកាសស្តីពីការកែសម្រួលឧបសម្ព័ន្ធ១ និងឧបសម្ព័ន្ធ៤ នៃប្រកាសលេខ ២៨ កយ ប្រក,០៧ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីប្រភេទពាក្យសុំដែលតម្រូវឲ្យបង់ពន្ធ ចំនួនទឹកប្រាក់ នៃពន្ធដាក់ពាក្យសុំ និងចំនួនពន្ធដែលត្រូវបង់ដើម្បីធ្វើសកម្មភាពក្រៅពីពាក្យសុំទៅតុលាការឲ្យសម្រេចសេចក្តី និងមាត្រាដ្ឋានសម្រាប់គណនាប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ និងតម្លៃកម្មវត្ថុនៃបណ្តឹង, លេខ ៥៤ កយ ប្រក/០៩, ២២ មិថុនា ២០០៩, ឧបសម្ព័ន្ធ ៤ ថ្មី, ញាតិ ឬ សន្តតិកម្ម ចំណុច(១)។

[80] មាត្រា៦១(៧) និងមាត្រា៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

[81] សៀវភៅនីតិវិធីរដ្ឋប្បវេណី របស់ឯកឧត្តម ហ៊ី សោភា, ទំព័រ១៨។

[82] មាត្រា១២៣(១) នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

ភស្តុតាងទាំងនោះ។ ការស្នើសុំឲ្យពិនិត្យភស្តុតាង អាចធ្វើនៅមុនពេលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងនីតិវិធីក្នុងការទាញហេតុផលផ្ទាល់មាត់។[83] ចំពោះសាក្សីវិញ តុលាការមានសិទ្ធិកោះហៅសាក្សីមកធ្វើការសាកសួរ កាលបើយល់ឃើញថាជាការចាំបាច់ ឬ មានការស្នើសុំឲ្យសាកសួរសាក្សីដោយភាគីនៃបណ្តឹងលែងលះ។[84]

## ៣.៤. នីតិវិធីក្នុងការជំនុំជម្រះ

តុលាការរដ្ឋប្បវេណី អាចដំណើរការជំនុំជម្រះរឿងក្តីរដ្ឋប្បវេណីបានលុះត្រាតែ មានបណ្តឹងត្រឹមត្រូវពីដើមចោទ។ ហេតុនេះហើយនីតិវិធីក្នុងការជំនុំជម្រះនឹងដំណើរការចាប់ពីពេលមានបណ្តឹង ដោយអនុលោមតាមច្បាប់នីតិវិធីរដ្ឋប្បវេណី និងច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល។[85] លំហូរនៃនីតិវិធីនៅក្នុងការដោះស្រាយវិវាទលែងលះដោយគ្មានការព្រមព្រៀង មានដូចតទៅនេះ៖ (៣.៤.១.) **ការពិនិត្យលើបណ្តឹងទាមទារការលែងលះ**, (៣.៤.២.) **ការកោះហៅគូភាគី និងការបញ្ជូនបណ្តឹងទាមទារការលែងលះ**, (៣.៤.៣.) **ការផ្សះផ្សា**, (៣.៤.៤.) **ការចាត់ចែងរក្សាការពារបណ្តោះអាសន្ន**, (៣.៤.៥.) **នីតិវិធីក្នុងការត្រៀមទាញហេតុផល**, (៣.៤.៦.) **នីតិវិធីក្នុងការទាញហេតុផលផ្ទាល់មាត់**, និង (៣.៤.៧.) **ការសម្រេចសេចក្តី។**

### ៣.៤.១. ការពិនិត្យលើបណ្តឹងទាមទារការលែងលះ

នៅពេលដែលបណ្តឹងទាមទារលែងលះ ដែលដាក់ដោយដើមចោទមកកាន់តុលាការ ក្រឡាបញ្ជីត្រូវមានកាតព្វកិច្ច ក្នុងការពិនិត្យមើលបណ្តឹងនោះភ្លាមៗជាមុន ដោយមូលហេតុថា តុលាការទទួលយកតែបណ្តឹងដែលត្រឹមត្រូវតាមច្បាប់មកជំនុំជម្រះតែប៉ុណ្ណោះ។ នីតិវិធីនៅក្នុងការពិនិត្យលើបណ្តឹងទាមទារលែងលះ មានដូចជាការទទួលយកបណ្តឹងដែលត្រឹមត្រូវហើយ, ការជូនដំណឹងទៅចៅក្រមពាក់ព័ន្ធនឹងបណ្តឹងដែលខុសឆ្គងដើម្បីឲ្យចៅក្រមសម្រេចថាត្រូវកែតម្រូវ ឬ លើកបណ្តឹងនោះចោល, និងការបន្ថែម ឬ ការផ្លាស់ប្តូរកម្មវត្ថុនៃបណ្តឹងជាដើម។

#### ៣.៤.១.១. ការទទួលយកបណ្តឹងតាមផ្លូវតុលាការ

នៅពេលដែលក្រឡាបញ្ជី ទទួលបាននូវពាក្យបណ្តឹង ត្រូវមានកាតព្វកិច្ចត្រួតពិនិត្យទៅលើ ពាក្យបណ្តឹងនោះ។ ពាក្យបណ្តឹងត្រូវតែមានលក្ខណៈត្រឹមត្រូវ និងគ្រប់គ្រាន់តាមការកំណត់នៅក្នុងមាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ បន្ទាប់ពីបានពិនិត្យឃើញថា ពាក្យបណ្តឹងមានលក្ខណៈត្រឹមត្រូវ ទៅតាមទម្រង់ដែលច្បាប់បានកំណត់រួចហើយនោះ ព្រមជាមួយការបង់ពន្ធលើការដាក់ពាក្យសុំលែងលះតាមការកំណត់ ក្រឡាបញ្ជីត្រូវទទួលយកបណ្តឹងនោះ ដើម្បីធ្វើការចុះលេខលើសំណុំរឿង ហើយបញ្ជូនទៅឲ្យចៅក្រម និងត្រូវប្រញាប់រៀបចំដំណើរ

[83] មាត្រា១២៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

[84] មាត្រា១២៥(៤) និងមាត្រា១៣២ នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

[85] មាត្រា៣(គ) នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/រកម/០៦១០/០០៨, ០៨ មិថុនា ២០១០។

នីតិវិធីបន្តទៀត។ ទន្ទឹមនឹងនេះ ពាក្យបណ្តឹងលែងលះច្រើនតែមានការពាក់ព័ន្ធច្រើនចំណុច ពិសេសលើការទាមទារលើការបែងចែកសិទ្ធិអំណាចមេបា និងទ្រព្យសម្បត្តិ។ ហេតុនេះហើយចំពោះការទាមទារសំណងទាំងឡាយណា ដែលពាក់ព័ន្ធនឹងអង្គហេតុនៃការលែងលះ នាំឲ្យបណ្តឹងទាមទារទាំងនោះ អាចធ្វើការបញ្ចូលគ្នានៅក្នុងបណ្តឹងទាមទារការលែងលះតែមួយបាន។[86] ទាំងអស់នេះគឺជាការទទួលយកបណ្តឹងតាមផ្លូវតុលាការ ហើយបណ្តឹងនេះ នាំឲ្យនីតិវិធីរដ្ឋប្បវេណីពាក់ព័ន្ធនឹងការលែងលះកើតមានឡើង។

### ៣.៤.១.២. ការលើកពាក្យបណ្តឹងចោល

បណ្តឹងទាមទារទាំងឡាយ ដែលបានដាក់ចូលមកតុលាការ ពុំមែនសុទ្ធតែត្រឹមត្រូវទាំងអស់នោះទេ ហេតុនេះហើយទើបនាំឲ្យមានការពិនិត្យរាល់ពាក្យបណ្តឹងទាំងនោះ។ កាលបើពិនិត្យឃើញថា ពាក្យបណ្តឹងមានភាពមិនត្រឹមត្រូវលើចំណុចណាមួយដូចជា ភាពកង្វះខាតព័ត៌មានលម្អិត, ការសរសេរពាក្យបណ្តឹងមិនត្រឹមត្រូវតាមទម្រង់ដែលច្បាប់បានកំណត់, កម្មវត្ថុនៃការលែងលះ, អង្គហេតុចម្បង, និងអង្គហេតុបន្ទាប់បន្សំមិនច្បាស់លាស់ ឬ ពុំទាន់បានបង់ពន្ធ ក្រឡាបញ្ជីនឹងជូនដំណឹងពីសំណុំរឿងនេះទៅចៅក្រម ដើម្បីឲ្យចៅក្រមពិចារណាបង្គាប់ឲ្យដើមចោទយកទៅកែតម្រូវ។[87]

ម្យ៉ាងវិញទៀត ក្នុងករណីដែលពិនិត្យឃើញថា បណ្តឹងនោះមានលក្ខណៈផ្ទុយនឹងច្បាប់ ហើយចំណុចខ្វះខាតធ្ងន់ធ្ងរមិនអាចកែតម្រូវបានទេ តុលាការមានសិទ្ធិក្នុងការលើកបណ្តឹងនោះចោលតែម្តងតាមរយៈការចេញនូវសាលក្រម។ គួរបញ្ជាក់ផងដែរថា ការលើកចោលចំពោះបណ្តឹងដែលផ្ទុយនឹងច្បាប់ អាចធ្វើឡើងដោយមិនបាច់ឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់បាន។[88]

### ៣.៤.១.៣. ការបន្ថែម ឬផ្លាស់ប្តូរកម្មវត្ថុនៃបណ្តឹង

បណ្តឹងលែងលះដែលដើមចោទបានដាក់ទៅកាន់តុលាការរួចហើយ ដើមចោទនៅតែមានសិទ្ធិ ក្នុងការបន្ថែម ឬ ផ្លាស់ប្តូរនូវការទាមទារ រហូតដល់ចប់ការទាញហេតុផលផ្ទាល់មាត់នៃការជម្រះលើកទី១ ឬ ការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍បាន។[89] ត្រង់ចំណុចនៃការបន្ថែម ឬ ផ្លាស់ប្តូរនេះអាចធ្វើឡើងបានលុះត្រាតែ មិនប៉ះពាល់ដល់មូលដ្ឋាននៃការទាមទារលែងលះ ឬ រាំងស្ទះដល់ដំណើរនីតិវិធីរបស់តុលាការ។ ពាក់ព័ន្ធនឹងការបន្ថែម ឬ ផ្លាស់ប្តូរការទាមទារនៃបណ្តឹង ដើមចោទត្រូវតែធ្វើឡើងក្នុងទម្រង់ជាលាយលក្ខណ៍អក្សរ។[90] តុលាការ

---

[86] មាត្រា១១ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/រកម/០៦១០/០០៨, ០៨ មិថុនា ២០១០ និង មាត្រា៧៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

[87] មាត្រា៧៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

[88] មាត្រា៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

[89] មាត្រា១២ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/រកម/០៦១០/០០៨, ០៨ មិថុនា ២០១០។

[90] មាត្រា៨៤(២) នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

នៅតែធ្វើការពិនិត្យលើការបន្ថែម ឬ ផ្លាស់ប្តូរទាំងនោះជាមុន ទើបអនុញ្ញាតឲ្យមានការបន្ថែម ឬ ផ្លាស់ប្តូរជាក្រោយ ដើម្បីជៀសវាងការបន្ថែម ឬ ការផ្លាស់ប្តូរណាដែលមានលក្ខណៈផ្ទុយទៅនឹងច្បាប់។

### ៣.៤.១.៤. ការប្តឹងតបរបស់ចុងចម្លើយ

ភាគីដែលជាចុងចម្លើយនៃបណ្តឹងលែងលះ មានសិទ្ធិធ្វើបណ្តឹងតបទៅវិញ តាមរយៈតុលាការ។ បណ្តឹងតប មានអានុភាពស្របច្បាប់សម្រាប់សម្រេចសេចក្តី លុះត្រាកម្មវត្ថុនៅក្នុងបណ្តឹងតបនោះ មានទំនាក់ទំនងទៅនឹងកម្មវត្ថុដើម អំពីការលែងលះពីខាងដើមចោទ ឬ មធ្យោបាយការពាររបស់ដើមចោទ។ ចុងចម្លើយ មានសិទ្ធិធ្វើបណ្តឹងតប ទៅដើមចោទ រហូតដល់ការចប់ការទាញហេតុផលផ្ទាល់មាត់ នៃការជម្រះលើកទី១ ឬ ការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍។[91]

ទាំងអស់ខាងលើនេះ គឺជានីតិវិធីបណ្តឹងនៅក្នុងការប្តឹងទាមទារលែងលះ ដោយមិនមានការព្រមព្រៀងរវាងភាគី។ បន្ទាប់ពីនីតិវិធីបណ្តឹងត្រូវបានបំពេញរួចហើយ នាំឲ្យតុលាការមានកាតព្វកិច្ចបញ្ជូនបណ្តឹងទាំងនោះ និងចាប់ផ្តើមកោះហៅភាគីលែងលះចូលមកបំភ្លឺ។

### ៣.៤.២. ការកោះហៅគូភាគី និងការបញ្ជូនបណ្តឹងទាមទារការលែងលះ

នៅពេលដែលដំណាក់កាលដាក់ពាក្យបណ្តឹង ត្រូវបានបំពេញរួចរាល់ និងត្រឹមត្រូវហើយ តុលាការត្រូវតែប្រញាប់មានចំណាត់ការបន្តទៅលើរឿងក្តីលែងលះ។ តុលាការត្រូវប្រញាប់កំណត់កាលបរិច្ឆេទ នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកដំបូងឲ្យបានឆាប់ ក្នុងអំឡុងពេលមិនលើសពី ៣០ថ្ងៃ គិតចាប់ពីថ្ងៃដាក់ពាក្យបណ្តឹងរបស់ខាងដើមចោទ។[92] ដូចនេះតុលាការត្រូវធ្វើការកោះហៅគូភាគី និងបុគ្គលពាក់ព័ន្ធទាំងឡាយឲ្យចូលមកបំភ្លឺនៅតុលាការ។ មូលហេតុនៃការកោះហៅគឺ នៅក្នុងនីតិវិធីរដ្ឋប្បវេណីតុលាការ ត្រូវគោរពគោលការណ៍ចំពោះមុខរបស់ភាគី ដែលបានបញ្ញត្តិថា ភាគីមិនត្រូវបានជម្រះក្តី ដោយគ្មានការសាកសួរ ឬ គ្មានការកោះហៅឡើយ។[93] ជាពិសេស គោលបំណងនៃការកោះហៅដំបូង គឺធ្វើឡើងដើម្បីផ្សះផ្សា និងសាកសួរពីដំណើរអង្គហេតុរបស់គូភាគី។ ការកោះហៅ គឺដើម្បីឲ្យគូភាគីមានឱកាសបានចូលខ្លួនមកបំភ្លឺឲ្យបានកាន់តែច្បាស់ពីកម្មវត្ថុ, អង្គហេតុ, ចំណុចវិវាទ, និងការទាមទារផ្សេងៗដែលនាំឲ្យឈានដល់ដាក់បណ្តឹងទាមទារលែងលះ។ ក្នុងករណីភាគីណាម្ខាងមានអ្នកតំណាងដោយអាណត្តិ នោះភាគីអាចឲ្យអ្នកតំណាង ចូលរួមមកជាមួយតាមរយៈការកោះហៅផងដែរ។ នៅក្នុងការអនុវត្តជាក់ស្តែង ក្រោយពីតុលាការបានធ្វើការពិនិត្យបណ្តឹងទាមទារលែងលះរួច តុលាការនឹងធ្វើការកំណត់នូវកាលបរិច្ឆេទដំបូង ចំពោះនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកដំបូង

[91] មាត្រា១២ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/រកម/០៦១០/០០៨, ០៨ មិថុនា ២០១០។

[92] មាត្រា៨០(២) នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

[93] មាត្រា៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

តាមរយៈការកោះហៅគូភាគី និងការបញ្ជូនពាក្យបណ្តឹងពីដើមចោទ ភ្ជាប់ជាមួយនឹង ដីកាកោះទៅចុងចម្លើយតែម្តង។[94] ដំណាក់កាលនៃការបញ្ជូនពាក្យបណ្តឹង និងដីកាកោះ ព្រមទាំងឯកសារពាក់ព័ន្ធផ្សេងទៀតអាចធ្វើឡើងស្របតាម នីតិវិធីនៃការបញ្ជូន។ នីតិវិធីនៃការបញ្ជូននេះ ត្រូវឡើងដោយមន្ត្រីអនុវត្តច្បាប់។ កិច្ចការនៅក្នុងការបញ្ជូនត្រូវធ្វើឡើងដោយក្រឡាបញ្ជី ហើយការបញ្ជូននេះផងដែរ ត្រូវបានប្រតិបត្តិដោយបុគ្គលិកប្រៃសណីយ៍ អាជ្ញាសាលា ឬ ក្រឡាបញ្ជីដោយផ្ទាល់។[95] ការបញ្ជូនអាចធ្វើឡើងតាមទម្រង់ផ្សេងៗ ដូចខាងក្រោម៖

**៣.៤.២.១. ការបញ្ជូនដោយប្រគល់**

ជាគោលការណ៍ ពាក្យបណ្តឹងត្រូវតែបញ្ជូនទៅឲ្យដល់ចុងចម្លើយជាចាំបាច់។[96] ចំពោះការបញ្ជូនដោយប្រគល់ គឺសំដៅលើការប្រគល់ឯកសារដោយផ្ទាល់ដៃ រវាងមន្ត្រីទទួលបន្ទុកក្នុងការបញ្ជូន និងអ្នកទទួលនៅលំនៅឋាន ឬទីសំណាក់។[97] នៅក្នុងការបញ្ជូននេះ មន្ត្រីនៅក្នុងការអនុវត្ត ត្រូវបញ្ជូនឯកសារចម្លងទាំងអស់ដែលពាក់ព័ន្ធទៅភាគីដែលត្រូវទទួលនោះ។ ហើយក្នុងករណីដែលភាគីមិនចេះអក្សរ មន្ត្រីទទួលបន្ទុកក្នុងការបញ្ជូនត្រូវ ពន្យល់ពីអត្ថន័យខ្លឹមសារនៃឯកសារទាំងនោះទៅភាគី។[98] ចំពោះការអនុវត្តជាក់ស្តែង គឺរាល់ពេលដែលធ្វើការបញ្ជូនមន្ត្រីដែលទទួលបន្ទុកក្នុងការបញ្ជូន ត្រូវការចម្លងថតឯកសារទាំងនោះទុក ព្រមទាំងត្រូវកត់ត្រាជារបាយការណ៍ឲ្យបានច្បាស់លាស់នៃហេតុការណ៍ ដែលបានកើតឡើងក្នុងការបញ្ជូន។ ហើយកិច្ចចុងក្រោយនៅក្នុងការបញ្ជូនដោយប្រគល់ គឺមន្ត្រីទទួលបន្ទុកក្នុងការបញ្ជូនត្រូវសុំហត្ថលេខា ឬ ស្នាមមេដៃពីអ្នកទទួលដើម្បីទុកជាភស្តុតាង។

**៣.៤.២.២. ការបញ្ជូនដោយជួបប្រទះ**

ការបញ្ជូនដោយជួបប្រទះ គឺជាការបញ្ជូនរាល់ឯកសារទាំងឡាយ ដែលពាក់ព័ន្ធនឹងរឿងលែងលះទៅដល់ដៃអ្នកទទួល ដែលមានស្ថានភាពប្រហាក់ប្រហែលនឹងការបញ្ជូនដោយប្រគល់ដែរ ក៏ប៉ុន្តែមានលក្ខណៈខុសប្លែកត្រង់ថា ការបញ្ជូនដោយជួបប្រទះ នឹងអនុវត្តឡើងតែក្នុងករណីដែលពុំច្បាស់ថាអ្នកទទួល មានលំនៅឋាន ឬ ទីសំណាក់ច្បាស់លាស់ក្នុងការប្រគល់ជូន។[99] នៅក្នុងករណីដែលពុំបានដឹងច្បាស់ពីលំនៅឋាន ឬ ទីសំណាក់ច្បាស់លាស់បែបនេះ ការបញ្ជូនដោយជួបប្រទះ ច្រើនត្រូវបានបញ្ជូនទៅអ្នកទទួលនៅទីកន្លែងដែលសមរម្យក្រៅពីលំនៅឋាន ឬ ទីសំណាក់របស់ជននោះ។ ជាក់ស្តែង មន្ត្រីដែលទទួលបន្ទុកនៅក្នុងការបញ្ជូន ច្រើនអនុវត្ត

[94] មាត្រា២៤២ នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

[95] មាត្រា២៤៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

[96] មាត្រា៧៩(១) នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

[97] សាស្ត្រាចារ្យ កេត សុជាតិ (កញ្ញា ២០១៧), *សង្ខេបលំហូរនីតិវិធីរដ្ឋប្បវេណី*, ទំព័រ៤៣។

[98] មាត្រា២៤៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

[99] សាស្ត្រាចារ្យ កេត សុជាតិ (កញ្ញា ២០១៧), *សង្ខេបលំហូរនីតិវិធីរដ្ឋប្បវេណី*, ទំព័រ៤៤។

បញ្ជូនទៅទីកន្លែងសមរម្យមួយចំនួនដូចជា ការប្រគល់ជូននៅទីកន្លែងអាជីវកម្ម ឬ កន្លែងការងារ ឬ ទីស្នាក់ការរបស់អ្នកទទួលជាដើម។ គួរបញ្ជាក់ផងដែរថា ការបញ្ជូនដោយជួបប្រទះ គឺមន្ត្រីទទួលបន្ទុកក្នុងការបញ្ជូននៅតែបញ្ជូនដោយផ្ទាល់ដៃដល់អ្នកទទួលដដែល គ្រាន់តែការបញ្ជូននោះមិនបានធ្វើនៅលំនៅឋាន ឬ ទីសំណាក់របស់អ្នកទទួល។[100] មន្ត្រីអ្នកទទួលបន្ទុកក្នុងការបញ្ជូន នៅតែមានកាតព្វកិច្ចក្នុងការកត់ត្រារបាយការណ៍នៅក្នុងការបញ្ជូនដដែល។

### ៣.៤.២.៣. ការបញ្ជូនដោយបង្គ្រប់កិច្ច

ការបញ្ជូនបណ្តឹងលែងលះ ទៅចុងចម្លើយតាមរយៈការបញ្ជូនដោយបង្គ្រប់កិច្ច ធ្វើឡើងនៅក្នុងករណីដែលមន្ត្រីទទួលបន្ទុកក្នុងការបញ្ជូន ពុំបានជួបផ្ទាល់នឹងភាគីលែងលះ ដែលត្រូវមកទទួលឯកសារ ជាហេតុតម្រូវឲ្យមន្ត្រីទទួលបន្ទុកក្នុងការបញ្ជូន ត្រូវប្រគល់រាល់ឯកសារពាក់ព័ន្ធទាំងនោះ តាមបុគ្គលដែលមានសមត្ថភាពយល់ដឹងសមរម្យហើយងាយនឹងជួបភាគី ឲ្យទទួលជំនួស ដើម្បីជួយប្រគល់បន្តទៅឲ្យភាគី។[101] បុគ្គលទាំងនោះមានដូចជា៖ សមាជិកគ្រួសារដែលស្នាក់នៅក្នុងផ្ទះតែមួយជាមួយភាគី ឬ អ្នកបម្រើ ឬ អ្នកធ្វើការជាមួយភាគីប្រចាំថ្ងៃជាដើម។[102] សូមបញ្ជាក់ផងដែរថា "អ្នកមានសមត្ថភាព" ក្នុងន័យនេះ គឺសំដៅដល់ អ្នកដែលអាចយល់ច្បាស់ពីសារៈសំខាន់នៃការបញ្ជូន, អត្ថន័យគោល នៃឯកសារដែលបានបញ្ជូន និងជាពិសេសនោះគឺមានសមត្ថភាពអាចជួយប្រគល់ឯកសារទាំងនោះទៅឲ្យដល់ដៃរបស់ភាគី។ ក្នុងករណីដែលភាគីមានមេធាវីតំណាងដោយអាណត្តិ ការបញ្ជូនតាមរយៈមេធាវីទៅឲ្យភាគី ក៏រាប់ជាការបញ្ជូនដោយបង្គ្រប់កិច្ចដែរ។

### ៣.៤.២.៤. ការបញ្ជូនដោយទុកចោល

នៅក្នុងករណីដែលមន្ត្រីទទួលក្នុងការបញ្ជូន បានខិតខំអស់ពីសមត្ថភាពហើយ ក្នុងការបញ្ជូនឯកសារពាក់ព័ន្ធទាំងឡាយ ទៅតាមរយៈវិធីផ្សេងៗ ក៏ប៉ុន្តែការបញ្ជូននោះនៅតែមិនបានសម្រេច ដោយសារតែភាគីដែលត្រូវទទួលឯកសារពីតុលាការ ហាក់ដូចជាព្យាយាមគេចវេស មិនព្រមទទួល ដោយមិនមានមូលហេតុត្រឹមត្រូវចំពោះការបដិសេធរបស់ខ្លួន នោះមន្ត្រីដែលទទួលបន្ទុកក្នុងការបញ្ជូនអាចទុកឯកសារពាក់ព័ន្ធទាំងនោះនៅកន្លែងដែលជួបប្រទះមុខនឹងភាគី។[103] ស្ថានភាពនេះ មន្ត្រីទទួលបន្ទុកត្រូវកត់ក្នុងរបាយការណ៍ ឲ្យច្បាស់លាស់ជាចាំបាច់ ពីព្រឹត្តិការណ៍ផ្សេងៗដែលបានកើតឡើងនៅពេលសកម្មភាពនៃការបញ្ជូនត្រូវបានធ្វើឡើង។ សកម្មភាពបញ្ជូនបែបនេះ ត្រូវបានកំណត់ថាជាការបញ្ជូនដោយទុកចោល។[104]

[100] មាត្រា២៥១ នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

[101] សាស្ត្រាចារ្យ កេត សុជាតិ (កញ្ញា ២០១៧), *សង្ខេបលំហូរនីតិវិធីរដ្ឋប្បវេណី*, ទំព័រ៤៥។

[102] មាត្រា២៥២(១) នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

[103] សាស្ត្រាចារ្យ កេត សុជាតិ (កញ្ញា ២០១៧), *សង្ខេបលំហូរនីតិវិធីរដ្ឋប្បវេណី*, ទំព័រ៤៦។

[104] មាត្រា២៥២(២) នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

ក្រៅពីការបញ្ជូនដែលបានរៀបរាប់ទាំងអស់ខាងលើនេះ ក៏មានការបញ្ជូនតាមរយៈរបៀបផ្សេងទៀត ដូចជាការផ្សព្វផ្សាយជាសាធារណៈជាដើម ក៏ប៉ុន្តែស្ថានភាពបែបនេះពុំសូវមានប្រទះ ក្នុងការអនុវត្តជាក់ស្តែងដូចការបញ្ជូនដោយប្រគល់ទ្បើយ។

### ៣.៤.៣. ការផ្សះផ្សា

ការផ្សះផ្សា គឺជាការសម្របសម្រួល ដោយមានការចូលរួមអន្តរាគមន៍ពីមន្ត្រីមានសមត្ថកិច្ច ដើម្បីធ្វើយ៉ាងណាឲ្យភាគីដើមចោទ និងចុងចម្លើយនៃបណ្តឹងលែងលះ យល់ព្រមសះជានឹងគ្នាវិញ ហើយយល់ព្រមបញ្ឈប់ការប្តឹងទាមទារសាលក្រមលែងលះពីតុលាការបន្តទៀត។ ជាទូទៅ ប្រសិនបើភាគីខាងដើមចោទ ធ្លាប់បានដាក់ពាក្យបណ្តឹងលែងលះនៅក្រុមប្រឹក្សាឃុំ-សង្កាត់ម្តងហើយ នោះក្រុមប្រឹក្សាឃុំ-សង្កាត់ ប្រាកដជាធ្លាប់បានផ្សះផ្សាភាគីទាំងពីរ ក្នុងរយៈពេល១៥ថ្ងៃ មុននឹងក្រុមប្រឹក្សាឃុំ-សង្កាត់ សម្រេចបញ្ជូនបន្តមកដល់តុលាការដោះស្រាយ។[105] ទោះបីជាធ្លាប់មាន ឬ មិនធ្លាប់មានការផ្សះផ្សានៅដំណាក់កាលក្រុមប្រឹក្សាឃុំ-សង្កាត់ក៏ដោយ តុលាការនៅតែត្រូវមានកាតព្វកិច្ច ក្នុងការសាកល្បងផ្សះផ្សាគូភាគីឲ្យអស់ពីសមត្ថភាព។ ជាពិសេស ទោះបីជាភាគីខាងដើមចោទ ទាមទារលែងលះខ្លាំងយ៉ាងណាក៏ដោយតុលាការត្រូវតែសាកល្បងការផ្សះផ្សាជាមុនសិនសឹមឈានទៅដល់នីតិវិធីបន្ទាប់ទៀត។[106] មូលហេតុដែលច្បាប់រដ្ឋប្បវេណី ក៏ដូចជានីតិវិធីរដ្ឋប្បវេណីព្យាយាមលើកទឹកចិត្តឲ្យមានការផ្សះផ្សា រវាងភាគី ពីព្រោះបណ្តឹងលែងលះ ជាប្រភេទបណ្តឹងពាក់ព័ន្ធ ដល់បុគ្គលផ្សេងៗទៀតដូចជា៖ កូនៗរបស់ភាគី ក្រុមគ្រួសារ និងសាច់ញាតិ ដូច្នេះគោលបំណងរបស់ច្បាប់ មិនចង់ឲ្យពលរដ្ឋខ្មែរក្នុងសង្គមមានការបែកបាក់ក្រុមគ្រួសារ ដែលនាំឲ្យខូចខាតប្រយោជន៍ និងប៉ះពាល់ដល់កិត្តិយសនោះទ្បើយ។ ទាំងអស់នេះហើយ ដែលនាំឲ្យនៅក្នុងដំណើរនីតិវិធីលែងលះតប្បីមាន ឆ្លងកាត់ការផ្សះផ្សា រវាងភាគីដើមចោទ និងចុងចម្លើយជាមុនសិន។ ទោះបីជាច្បាប់បានកម្រិតឲ្យស្ថាប័នតុលាការ មានការចាត់តាំងចៅក្រមដើម្បីខិតខំផ្សះផ្សា យ៉ាងណាក្តី ក៏ប៉ុន្តែបើមានស្ថានភាពធ្ងន់ធ្ងរខ្លាំងនៅក្នុងក្រុមគ្រួសារ គឺចៅក្រមមិនចាំបាច់ធ្វើការផ្សះផ្សារវាងភាគីប្តី និងប្រពន្ធនោះទ្បើយ។ ជាឧទាហរណ៍ដូចជា៖ អំពើហិង្សា កើតមានក្នុងគ្រួសារដែលមានលក្ខណៈជាបទល្មើសព្រហ្មទណ្ឌឧក្រិដ្ឋ ឬ មជ្ឈិមធ្ងន់ធ្ងរ ហើយអំពើនេះបានជះឥទ្ធិពលខ្លាំងដល់ភាគីដែលជាជនរងគ្រោះ តុលាការពុំចាំបាច់ធ្វើការផ្សះផ្សាទ្បើយ។[107] ក្នុងស្ថានភាពបែបនេះតុលាការមានឆន្ទានុសិទ្ធិក្នុងការមិនចាំបាច់ផ្សះផ្សាព្រោះស្វែងយល់ឃើញថា មានភាពមិនសមរម្យ។[108]

---

[105] មាត្រា៩៨២(២) នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[106] មាត្រា៩៨៤(១) នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[107] មាត្រា១៧ ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ, លេខ នស/រកម/១០០៥/០៣១, ២៤ តុលា ២០០៥។

[108] មាត្រា១០៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

### ៣.៤.៤. ការចាត់ចែងរក្សាការពារបណ្តោះអាសន្ន

ដំណើរនីតិវិធីលែងលះដោយគ្មានការព្រមព្រៀង មានលក្ខណៈស្មុគស្មាញ និងត្រូវចំណាយពេលវេលាវែងនៅក្នុងការដោះស្រាយ ហេតុនេះភាគីទាំងសងខាងអាចមាននឹងការព្រួយបារម្ភ ឬ ក៏ជួបប្រទះនឹងបញ្ហាទាក់ទងនឹងស្ថានភាពរស់នៅ ឬ ក៏ជួបប្រទះនឹងបញ្ហាពាក់ព័ន្ធការចាត់ចែងផ្សេងៗ ដែលអាចកើតមាននៅអំឡុងពេលនីតិវិធីលែងលះ។ ដំណោះស្រាយនៅលើសេចក្តីព្រួយបារម្ភទាំងនោះគឺ ភាគីលែងលះមានសិទ្ធិក្នុងការស្នើសុំនូវដីកាសម្រេចចាត់ចែងការពារពីតុលាការបាន។ ការចាត់ចែងរក្សាការពារទៅលើ កម្មវត្ថុនៃរឿងក្តីលែងលះ ដែលមានការពាក់ព័ន្ធនឹងឋានៈបុគ្គល គឺតុលាការនឹងអនុវត្តទៅតាមឆន្ទានុសិទ្ធិ ហើយនីតិវិធីទាំងនោះនឹងអនុលោមដូចការកំណត់ក្នុង ច្បាប់ស្តីពីនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ ផងដែរ។[109] ការចាត់ចែងរក្សាការពារ ត្រូវបានដឹកនាំដោយ តុលាការដែលកំពុងទទួលបន្ទុកលើរឿងក្តីលែងលះហើយ តុលាការអនុវត្តការចាត់ចែងរក្សាការពារនេះត្រូវមានសមត្ថកិច្ចផ្តាច់មុខ។[110] ចំពោះករណីដែលការចាត់ចែងរក្សាការពារ ជាការស្នើសុំតាមរយៈពាក្យសុំដីកាសម្រេចចាត់ចែងរក្សាការពារពីភាគីលែងលះ ពាក្យសុំដីកាសម្រេចនេះ ត្រូវតែធ្វើឡើងក្នុងទម្រង់ជាលាយលក្ខណ៍អក្សរ ដោយត្រូវបញ្ជាក់ឲ្យច្បាស់ពីឈ្មោះ និងអាសយដ្ឋាន។

បន្ថែមពីនេះ នៅក្នុងពាក្យសុំក៏ត្រូវបញ្ជាក់បន្ថែមពីខ្លឹមសារទាមទារ, សិទ្ធិ និងទំនាក់ទំនងគតិយុត្ត, ព្រមទាំងមូលហេតុនៃភាពចាំបាច់។[111] ភាគីដែលដាក់ពាក្យសុំ ក៏ត្រូវមានកាតព្វកិច្ចបង់ពន្ធចំនួន ៥,០០០ (ប្រាំពាន់) រៀល ទៅតុលាការ។[112] គួរបញ្ជាក់ផងដែរថា ដីកាសម្រេចការពារនេះ ចុងចម្លើយក៏មានសិទ្ធិក្នុងការដាក់ពាក្យសុំតវ៉ាផងដែរ។[113] ភាគីមានសិទ្ធិក្នុងការប្តឹងជំទាស់ដីកាសម្រេចរក្សាការពារនេះ ក្នុងរយៈពេល ២ (ពីរ) សប្តាហ៍។[114] ដូច្នេះ បានសេចក្តីថា ដីកាសម្រេចរក្សាការពារ នឹងត្រូវបានតុលាការចាប់ផ្តើមការអនុវត្ត កាលបើគ្មានការប្តឹងតវ៉ាជំទាស់ ក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍។ គួរបញ្ជាក់ផងដែរថា ការចេញដីកាសម្រេចការពារនេះ គ្រាន់តែជាដីកាសម្រេចដែលត្រូវអនុវត្តបណ្តោះអាសន្នតែប៉ុណ្ណោះ នៅមុនពេលដែលតុលាការធ្វើការសម្រេចចុងក្រោយបង្អស់តាមរយៈសាលក្រម។

បន្ថែមត្រង់ចំណុចនេះ ចៅក្រមមានឆន្ទានុសិទ្ធិ ក្នុងការចេញដីកាសម្រេចចាត់ចែងរក្សាការពារ ក្នុងករណីដែលចាំបាច់ កាលបើបានស្វែងយល់ពីស្ថានភាព និងការព្រួយបារម្ភរបស់ភាគី ហើយធ្វើការសម្រេចមួយចំនួន

[109] មាត្រា២១ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/រកម/០៦១០/០០៨, ០៨ មិថុនា ២០១០។

[110] មាត្រា៥៣៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

[111] មាត្រា៥៣៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

[112] មាត្រា៥៣៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

[113] មាត្រា៥៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

[114] មាត្រា៥៦១ នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

ដូចជា៖ ការបំបែកលំនៅឋានរបស់សហព័ទ្ធ, ការគ្រប់គ្រងថែរក្សាកូនៗ, សោហ៊ុយចិញ្ចឹមបីបាច់កូន និងជាពិសេសលើទ្រព្យសម្បត្តិរបស់ភាគីជាដើម។[115]

### ៣.៤.៤.១. ការកំណត់អំពីការរស់នៅរបស់សហព័ទ្ធ

ការលែងលះដោយមិនមានការព្រមព្រៀងរមែងកើតឡើង ពីការរស់នៅមិនចុះសម្រុងគ្នារវាងសហព័ទ្ធ។ ការមិនចុះសម្រុងទាំងអស់នោះ មានករណីខ្លះធ្ងន់ធ្ងរខ្លាំងពេក រហូតឈានដល់ភាគីប្តី ឬ ប្រពន្ធហ៊ានប្រព្រឹត្តអំពើហិង្សាលើសហព័ទ្ធដូចជា៖ ហិង្សាផ្លូវកាយ, ហិង្សាផ្លូវចិត្ត និងហិង្សាផ្លូវភេទរបស់ភាគីជាដើម។ ហេតុនេះបើមានករណីណាចាំបាច់ ដោយយោងតាមមូលហេតុខាងលើ តុលាការក៏អាចចេញដីកាសម្រេច ក្នុងការបំបែកលំនៅដ្ឋានរបស់ប្តីប្រពន្ធ ក្នុងគោលបំណងដើម្បីការពារសុវត្ថិភាពរបស់ជនរងគ្រោះ ជាភាគី ប្រពន្ធ ឬ ប្តី និងកូនកុំឲ្យបន្តក្លាយជាជនរងគ្រោះ ដែលងាយនឹងទទួលរងអំពើហិង្សាក្នុងគ្រួសារ ក្នុងអំឡុងពេលលែងលះ។[116] ជាទូទៅ នៅពេលដែលកើតមានអំពើហិង្សាភ្លាម អាជ្ញាធរមានសមត្ថកិច្ច នឹងប្រញាប់ចាប់វិធានការបណ្តោះអាសន្នស្របច្បាប់ ដូចដែលមានបញ្ញត្តិក្នុងមាត្រា៤៣ មាត្រា ៤៨ និងមាត្រា ៤៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់។[117] នៅពេលដែលកើតមានអំពើហិង្សាក្នុងគ្រួសារកើតឡើង គឺជាពេលដែលជនរងគ្រោះគប្បីដាក់ពាក្យសុំទៅតុលាការ ឲ្យចេញដីការក្សាការពារមកលើសុវត្ថិភាពរបស់ខ្លួន ហើយតុលាការនឹងសម្រេចចេញដីកាការពារដោយឆន្ទានុសិទ្ធិ បន្ទាប់ពីបានពិចារណាទៅលើរឿងក្តី។[118] ចំពោះដីការក្សាការពារនេះ ចែកចេញជា ២ ដំណាក់កាល គឺ៖ ទី១ ជាប្រភេទដីការក្សាការពារបណ្តោះអាសន្ន ដែលមានរយៈពេល ២ខែ កាលបើនៅក្នុងគ្រួសាររបស់ភាគីលែងលះបានកើតនៅអំពើហិង្សាភ្លាម។ និងទី២ ជាប្រភេទដីការក្សាការពារ ដែលមានរយៈពេលដល់ទៅ ៦ខែ ក្នុងអំឡុងពេលដំណើរនីតិវិធីរបស់តុលាការ និងមិនទាន់ចេញនូវសាលក្រម។[119] នៅក្នុងការអនុវត្តប្រសិនបើកើតមាននូវអំពើហិង្សា នោះតុលាការនឹងហាមឃាត់មិនឲ្យភាគីដែលប្រព្រឹត្តហិង្សា មកបន្តស្នាក់នៅជាមួយភាគីម្ខាងទៀតដែលជាជនរងគ្រោះឡើយ ឬ ហាមឃាត់មិនឲ្យមកក្បែរតំបន់ដែលភាគីរងគ្រោះកំពុងរស់នៅ

---

[115] មាត្រា៩៨៣ នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[116] មាត្រា២០ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ, លេខ នស/រកម/១០០៥/០៣១, ២៤ តុលា ២០០៥។

[117] មាត្រា១៤ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ, លេខ នស/រកម/១០០៥/០៣១, ២៤ តុលា ២០០៥។

[118] មាត្រា១៦ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ, លេខ នស/រកម/១០០៥/០៣១, ២៤ តុលា ២០០៥។

[119] មាត្រា២៣ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ, លេខ នស/រកម/១០០៥/០៣១, ២៤ តុលា ២០០៥។

ឬ ក៏តុលាការសម្រេចបំបែកលំនៅឋានរវាងភាគីតែម្តង។[120] ទង្វើទាំងអស់នេះគឺជាការជួយការពារជនរងគ្រោះប្រឆាំងនឹងអំពោះហិង្សាក្នុងគ្រួសារ ហើយក៏ដើម្បីធានាការបន្តលំហូរនីតិវិធីលែងលះដោយគ្មានការព្រមព្រៀង។

**៣.៤.៤.២. ការថែរក្សាកូនជាបណ្តោះអាសន្ន**

ការចេញដីកាសម្រេចចាត់ចែងកូនបណ្តោះអាសន្នពីតុលាការ កើតមាននៅករណីដែលភាគីលែងលះមិនបានព្រមព្រៀងគ្នា ក្នុងការពិភាក្សាកំណត់ពីសិទ្ធិអំណាចមេបាលើកូន ហើយកំពុងតែប្រឈមនឹង ការដណ្តើមសិទ្ធិអំណាចមេបានេះទៅវិញទៅមក។ នៅពេលដែលចៅក្រមពុំទាន់អាចធ្វើការបែងចែកនៅឡើយ អំពីការបែងចែកការគ្រប់គ្រងកូនទៅលើភាគីខាងណា ចៅក្រមអាចធ្វើចេញដីកាសម្រេចចាត់ចែងកូន ជាបណ្តោះអាសន្នសិនបាន។ ការសម្រេចនេះ កើតឡើងតាមការស្នើសុំរបស់ភាគី ឬ ក៏កើតឡើងតាមឆន្ទានុសិទ្ធិរបស់ចៅក្រម។[121] ការចាត់ចែងអំណាចមេបាទៅលើកូនៗ ចៅក្រមពិចារណាសម្រេចដោយឈរលើ មូលដ្ឋានប្រយោជន៍របស់កូន។ ក្នុងករណីដែលកូនមានសមត្ថភាពគ្រប់គ្រាន់ ក្នុងការបង្ហាញឆន្ទៈអំពីការយល់ព្រមទៅជាមួយភាគីខាងណាមួយនោះចៅក្រមត្រូវធ្វើការសម្រេចតាមឆន្ទៈរបស់កូន។ យ៉ាងណាមិញ ប្រសិនបើកូន ពុំទាន់មានសមត្ថភាពនៅក្នុងការបង្ហាញឆន្ទៈនៅឡើយទេ ចៅក្រមនឹងសម្រេចការចាត់ចែងបណ្តោះអាសន្ន លើការថែរក្សាកូន ទៅឲ្យភាគីខាងឪពុក ឬ ម្តាយ ដោយយកគោលការណ៍ឧត្តមប្រយោជន៍របស់កូនមកធ្វើជាមូលដ្ឋានក្នុងការសម្រេច។[122] ជាទូទៅអានុភាពនៃការចាត់ចែងបណ្តោះអាសន្ន តាមរយៈដីកាសម្រេចនេះ មានអានុភាពតែក្នុងអំឡុងពេលនីតិវិធីការលែងលះ តែប៉ុណ្ណោះ ហើយអានុភាពនៃការចាត់ចែងបណ្តោះអាសន្ននេះ នឹងបញ្ចប់ទៅវិញ នៅពេលដែលមានការសម្រេចជាស្ថាពរលើការប្តឹងទាមទារអំណាចមេបាលើកូន ដោយសាលក្រមស្ថាពររបស់តុលាការ។

**៣.៤.៤.៣. ការថែរក្សាទ្រព្យជាបណ្តោះអាសន្ន**

ការចេញដីកាសម្រេចលើការថែរក្សាទ្រព្យជាបណ្តោះអាសន្ន មាននៅក្នុងអំឡុងពេល ដែលបណ្តឹងលែងលះកំពុងស្ថិតក្នុងនីតិវិធីនៅឡើយហើយ មិនទាន់មានសាលក្រម សម្រេចលើការទាមទារបែងចែកទ្រព្យសម្បត្តិ។ ក្នុងអំឡុងពេលនៃនីតិវិធីលែងលះ ភាគីនៃបណ្តឹងលែងលះតែងមានការព្រួយបារម្ភទៅលើ បញ្ហាទ្រព្យសម្បត្តិដោយភ័យខ្លាចភាគីម្ខាង ព្យាយាមយកទ្រព្យសម្បត្តិទាំងនោះទៅកែប្រែ ឬ លក់ ឬ ផ្ទេរ ឬ បំផ្លាញចោលនូវទ្រព្យសម្បត្តិទាំងនោះអស់ មុនពេលដែលតុលាការសម្រេច លើការបែងចែកទ្រព្យសម្បត្តិ។ ដូច្នេះ ភាគីដែលមានការព្រួយបារម្ភ អាចដាក់ពាក្យសុំទៅតុលាការដើម្បីសុំឲ្យតុលាការចេញដីកាសម្រេច លើការចាត់ចែងរក្សាការពារជា

[120] មាត្រា២៥ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ, លេខ នស/រកម/១០០៥/០៣១, ២៤ តុលា ២០០៥។

[121] មាត្រា២១ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/រកម/០៦១០/០០៨, ០៨ មិថុនា ២០១០។

[122] មាត្រា៩ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ, លេខ ៤៤/២៥ អង្គការសហប្រជាជាតិ, ០២ កញ្ញា ១៩៩០។

បណ្តោះអាសន្នចំពោះទ្រព្យសម្បត្តិទាំងនោះបាន។[123] បន្ថែមពីនេះទៀតតុលាការ ក៏ត្រូវគិតពិចារណាលើការចាត់ចែងនូវហិរញ្ញវត្ថុ ជាបណ្តោះអាសន្នផងដែរ។ចំណុចនេះ គឺផ្តោតសំខាន់ដល់ការកំណត់ហិរញ្ញវត្ថុ ចាំបាច់សម្រាប់ចិញ្ចឹមផ្គត់ផ្គង់កូនៗដែលនៅក្នុងបន្ទុក ក្នុងអំឡុងពេលដែល ឪពុក និងម្តាយកំពុងតែប្តឹងលែងលះគ្នា ហើយការទាមទារបែងចែកទ្រព្យសម្បត្តិ ក៏មិនទាន់មានការសម្រេចដោយតុលាការ។ តុលាការ ត្រូវសម្រេចការចាត់ចែងបណ្តោះអាសន្ននេះ លើមូលដ្ឋានគ្រឹះមួយចំនួនដូចជា៖ ផ្អែកលើសេចក្តីត្រូវការរបស់កូន, លទ្ធភាពដែលភាគីអាចផ្តល់ឲ្យបាន, និងគួបផ្សំលើស្ថានភាពហិរញ្ញវត្ថុជាក់ស្តែងរបស់ភាគី។ បើតុលាការស្វែងយល់ថា ក្នុងអំឡុងពេលលែងលះ មានភាគីណាម្ខាងកំពុងជួបបញ្ហាហិរញ្ញវត្ថុធ្ងន់ធ្ងរតុលាការ ក៏អាចចេញនូវដីកាចាត់ចែងផ្នែកហិរញ្ញវត្ថុបណ្តោះអាសន្ននេះ ដោយគិតគូរបញ្ចូលទាំងការឧបត្ថម្ភដល់ភាគីដែលកំពុងខ្វះខាតនោះផងដែរ អាស្រ័យលើការពិចារណា និងឆន្ទានុសិទ្ធិរបស់តុលាការ។[124]

### ៣.៤.៥. នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅក្នុងវិវាទលែងលះដោយគ្មានការព្រមព្រៀង ត្រូវដោះស្រាយឡើងដោយឆ្លងកាត់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះ ដឹកនាំឡើងដោយចៅក្រម និងក្រឡាបញ្ជីព្រមជាមួយវត្តមាន របស់ភាគីនៃបណ្តឹងលែងលះ។ នៅក្នុងករណីខ្លះ ក៏មានវត្តមានរបស់មេធាវីតំណាងដោយអាណត្តិ កាលបើភាគីបានពឹងពាក់មេធាវីនៅក្នុងដំណើរនីតិវិធី។ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះ ត្រូវរៀបចំឡើងមិនលើសពី ៣០ថ្ងៃ បន្ទាប់ពីភាគីបានដាក់បណ្តឹងលែងលះទៅតុលាការ។[125] ការកំណត់ជាក់លាក់អំពីកាលបរិច្ឆេទនៃ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺត្រូវកំណត់ឡើងដោយឆន្ទានុសិទ្ធិរបស់តុលាការ តែខាងតុលាការ ក៏ត្រូវលៃលកយកកាលបរិច្ឆេទណាដែលភាគីទាំងសងខាងអាចចូលរួមបាន។[126] ការលែងលះដោយគ្មានការព្រមព្រៀង ត្រូវតែឆ្លងកាត់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល មុននឹងឈានដល់ការទាញហេតុផលផ្ទាល់មាត់។ ត្រង់ចំណុចនេះ គួរឲ្យកត់សម្គាល់ឃើញថា លំហូរនៃនីតិវិធីការលែងលះដោយគ្មានការព្រមព្រៀង មានលក្ខណៈខុសប្លែកពីការលែងលះដោយព្រមព្រៀង ពីព្រោះថាការលែងលះដោយព្រមព្រៀងមិនទាមទារឲ្យមាននីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ជាចាំបាច់ឡើយ។

មូលហេតុដែលនាំឲ្យតុលាការ ត្រូវដឹកនាំនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះឡើង គឺដើម្បីជាឱកាសមួយសម្រាប់ឲ្យគូភាគីទាំងសងខាង បានមកជួបជុំគ្នានៅឯតុលាការ ដើម្បីនិយាយនៅចំពោះមុខគ្នាពី

[123] មាត្រា៩៣០ នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។
[124] មាត្រា៩៨៣ នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។
[125] មាត្រា៨០ នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។
[126] មាត្រា១០៥(១) នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

បញ្ហានៃវិវាទ ការអះអាង និងការបំភ្លឺទាំងឡាយ ទាក់ទងនឹងការលែងលះ។ ជាពិសេស ការរៀបចំនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះឡើង គឺដើម្បីឲ្យតុលាការ ទទួលបានច្បាស់ពីចំណុចវិវាទ និងបានរៀបចំភស្តុតាងទាំងឡាយដែលភាគីបានដាក់ជូនមកតុលាការ។[127] ទន្ទឹមនឹងនេះដែរ តុលាការអាចបង្គាប់ ឲ្យភាគីធ្វើការបំភ្លឺបន្ថែមចំពោះចំណុចមិនច្បាស់នៃបណ្តឹង ឬ ឯកសារត្រៀម ឬ ធ្វើការសាកសួរដល់ភាគីបន្ថែម។[128] ចំណែក ភាគីនៃបណ្តឹងលែងលះវិញ មានកាតព្វកិច្ចចូលរួមជាមួយតុលាការ ដោយស្មោះត្រង់ចំពោះតុលាការ លើការអះអាងនូវរាល់អង្គហេតុ និងឯកសារភស្តុតាង។ គួរបញ្ជាក់ផងដែរថា នៅក្នុងការអនុវត្តជាក់ស្តែង តុលាការរៀបចំនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះ ដោយអសាធារណៈ ពោលគឺប្រព្រឹត្តទៅនៅក្នុងបន្ទប់របស់ចៅក្រមដែលទទួលបន្ទុកលើរឿងក្តីលែងលះ។[129] តុលាការ ត្រូវបង្គាប់ឲ្យដើមចោទថ្លែងការណ៍អំពីបណ្តឹងទាមទាររបស់ខ្លួនដោយផ្ទាល់មាត់។[130] ចំពោះការអនុវត្តជាក់ស្តែងវិញ មេធាវីតំណាងអាណាត្តិអាចថ្លែងការណ៍ជំនួសកូនក្តីបាន។ បន្ថែមពីនេះ នៅក្នុងនីតិវិធីនេះ ភាគីទាំងពីរក៏ត្រូវដាក់ជូននូវមធ្យោបាយតទល់ ឬ មធ្យោបាយការពារខ្លួនមកតុលាការ។[131]

ម៉្យាងវិញទៀត នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះ ត្រូវតែមានការកត់ត្រាឲ្យបានច្បាស់លាស់ដើម្បីងាយស្រួលក្នុងដំណើរនីតិវិធី។ ដូច្នេះ ក្រឡាបញ្ជីត្រូវមានកាតព្វកិច្ច កត់ត្រានូវកំណត់ហេតុពាក់ព័ន្ធនឹងរឿងក្តីលែងលះ ដែលបានធ្វើឡើងនៅគ្រប់កាលបរិច្ឆេទទាំងអស់។[132] ក្រឡាបញ្ជីត្រូវកត់ត្រានូវ សញ្ញាណរឿងក្តី, ឈ្មោះចៅក្រម និងក្រឡាបញ្ជីដែលបានចូលរួម រួមជាមួយនឹងឈ្មោះភាគី និងបុគ្គលដែលពាក់ព័ន្ធផ្សេងទៀត, ពេលវេលា និងទីកន្លែង។ ក្រុមប្រឹក្សាជំនុំជម្រះត្រូវពិនិត្យលើកំណត់ត្រានោះរួចហើយធ្វើការចុះហត្ថលេខាផងដែរ។[133] លើសពីនេះទៅទៀត ក្រឡាបញ្ជីក៏ត្រូវកត់ត្រាបន្ថែមពាក់ព័ន្ធនឹងចំណុចសារធាតុមួយចំនួនដែលមាននៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដូចជា កត់ត្រាអំពីកម្មវត្ថុ, ខ្លឹមសារដែលជាការទាមទារ ពិសេសកម្មវត្ថុដែលនាំឲ្យកើតមានវិវាទ, អង្គហេតុ ការអះអាង និងការស្នើសុំផ្សេងៗ, និងសកម្មភាពផ្សេងៗទៀត ដែលភាគីបានធ្វើអំឡុងពេលនៃនីតិវិធីនោះ។[134] ដោយហេតុថា កំណត់ត្រានេះសំខាន់ និងមានការជាប់ពាក់ព័ន្ធទៅនីតិវិធីបន្តទៀត កាលបើភាគីមិនយល់ព្រមសះជា នោះភាគីនៃបណ្តឹងលែងលះមានសិទ្ធិក្នុងការពិនិត្យមើលកំណត់ត្រា

[127] មាត្រា១០៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

[128] មាត្រា៩០(១) នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

[129] មាត្រា១០៥(២) នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

[130] សាស្ត្រាចារ្យ កេត សុជាតិ (កញ្ញា ២០១៧), *សង្ខេបលំហូរនីតិវិធីរដ្ឋប្បវេណី*, ទំព័រ៦២។

[131] មាត្រា៩៣-៩៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

[132] មាត្រា១០៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

[133] មាត្រា១១០ នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

[134] មាត្រា១១១ នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

ដែលធ្វើឡើងដោយក្រឡាបញ្ជី ហើយប្រសិនការពិនិត្យនោះភាគីមិនយល់ស្របនឹងចំណុចកត់ត្រាមួយណានោះ ភាគីមានសិទ្ធិក្នុងការប្តឹងតវ៉ាលើកំណត់ត្រា ដែលបានធ្វើឡើងដោយក្រឡាបញ្ជី។[135] ចំណុចដែលសំខាន់មួយទៀត នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះ តុលាការអាចចេញដីកាសម្រេចទាក់ទងនឹងការស្នើសុំមួយចំនួនបាន។[136]

### ៣.៤.៦. នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់

នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ គឺជានីតិវិធីសំខាន់មួយ ដែលចាំបាច់ត្រូវតែធ្វើឡើងនៅក្នុងសាលសវនាការ មុននឹងឈានដល់ការសម្រេចសេចក្តីពីតុលាការទៅលើបណ្តឹងលែងលះ។[137] តុលាការត្រូវប្រញាប់កោះហៅគូភាគី ឲ្យបន្តចូលរួមនៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ បន្ទាប់ពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបានបញ្ចប់ទៅ។[138] ទន្ទឹមនឹងនេះ ចំពោះកាលបរិច្ឆេទជាក់លាក់ នៅក្នុងការប្រព្រឹត្តទៅនៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់វិញ គឺអាស្រ័យលើសិទ្ធិសម្រេចរបស់តុលាការ។ ទោះបីជាតុលាការមានសិទ្ធិក្នុងការសម្រេចកាលបរិច្ឆេទនៃនីតិវិធីទាញហេតុផលផ្ទាល់មាត់ក៏ដោយ ក៏តុលាការត្រូវរើសយកកាលបរិច្ឆេទណាដែលភាគីទាំងសងខាងអាចមានវត្តមានចូលរួមបាន។[139] ហើយសម្រាប់ការអនុវត្តជាក់ស្តែងវិញ តុលាការតែងធ្វើការសាកសួរភាគីទាំងសងខាងនៅថ្ងៃដែលអាចចូលរួមបាន មុននឹងសម្រេចកំណត់កាលបរិច្ឆេទ។ ចំណែកឯទីកន្លែង នៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ សម្រាប់បណ្តឹងលែងលះ គឺមានជាប់ពាក់ព័ន្ធទៅនឹងឋានៈបុគ្គល, ឯកជនភាព និងសេចក្តីថ្លៃថ្នូររបស់ភាគី ដូចនេះហើយច្បាប់មិនបានតម្រូវឲ្យធ្វើនីតិវិធីទាញហេតុផលផ្ទាល់មាត់នេះនៅសាលសវនាការជាសាធារណៈនោះទេ ពោលគឺអាចរៀបចំបាននៅក្នុងសាលសវនាការ ក៏ប៉ុន្តែត្រូវតែមានលក្ខណៈអសាធារណៈ ដែលមានតែបុគ្គលពាក់ព័ន្ធក្នុងរឿងក្តីលែងលះនោះប៉ុណ្ណោះដែលអាចចូលរួមបាន។[140]

នៅក្នុងនីតិវិធីទាញហេតុផលផ្ទាល់មាត់នេះ តុលាការបង្គាប់ឲ្យភាគីទាំងសងខាង ធ្វើសេចក្តីថ្លែងការណ៍ពីលទ្ធផលទាំងឡាយដែលទទួលបានបន្ទាប់ពីបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។[141] ត្រង់ចំណុចនេះ ចំពោះការអនុវត្តជាក់ស្តែង គឺភាគីភាគច្រើននិយម ពឹងពាក់មេធាវីតំណាងដោយអាណត្តិ ធ្វើនូវសេចក្តីថ្លែងការណ៍

135 មាត្រា១១២ នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។
136 មាត្រា១០៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។
137 មាត្រា១១៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។
138 មាត្រា១១៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។
139 មាត្រា១១៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។
140 មាត្រា១៦ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/រកម/០៦១០/០០៨, ០៨ មិថុនា ២០១០។
141 មាត្រា១១៦(១) នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

ជំនួស។ ក៏ប៉ុន្តែ ក្នុងស្ថានភាពដែលភាគីណាម្ខាងនៃបណ្តឹងលែងលះគ្មានសមត្ថភាពគ្រប់គ្រាន់ក្នុងការធ្វើសេចក្តីថ្លែងការណ៍ដោយខ្លួនឯង ហើយមិនមានលទ្ធភាពគ្រប់គ្រាន់ទៅពឹងពាក់មេធាវីតំណាងដោយអាណត្តិទេ នោះចៅក្រមដែលកំពុងទទួលបន្ទុកលើរឿងក្តីលែងលះ អាចជួយថ្លែងជំនួសភាគីបាន ដោយធ្វើការសាកសួរភាគីឲ្យបានច្បាស់លាស់បន្ថែមថា តើការថ្លែងការណ៍នេះពិតជាត្រឹមត្រូវតាមឆន្ទៈរបស់ខ្លួនហើយ ឬនៅ? ទោះបីជាចៅក្រមជួយធ្វើការថ្លែងការណ៍បញ្ជាក់ចំពោះភាគីដែលខ្វះខាតលទ្ធភាពក៏ដោយ តែចៅក្រមដែលទទួលបន្ទុកលើរឿងក្តីលែងលះនៅតែមានស្មារតីជានានូវអព្យាក្រឹត្យ និងយុត្តិធម៌ជានិច្ចលើចំណាត់ការរឿងក្តី។ ចូលមកដល់ដំណាក់កាលនេះភាគីនៅតែមានសិទ្ធិក្នុងការអះអាងបន្ថែម និងដាក់ភស្តុតាងបន្ថែមទៀតបាន តែការបន្ថែមទាំងនោះត្រូវឲ្យមានលក្ខណៈត្រឹមត្រូវតាមច្បាប់ដែលបានកំណត់។[142] បន្ថែមពីនេះទៅទៀត នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ទាំងការអះអាង និងគ្រប់ភស្តុតាងទាំងឡាយរបស់ភាគីលែងលះ តុលាការត្រូវពិនិត្យវិនិច្ឆ័យឲ្យកាន់តែលម្អិត និងត្រូវតែច្បាស់លាស់ លើសពីសកម្មភាពដែលធ្លាប់បានធ្វើនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។ តុលាការនឹងធ្វើការពិនិត្យរាល់ភស្តុតាងទាំងឡាយ ហើយលើកមកជជែកវែកញែក និងសួរដេញដោលភាគីក្នុងសាលសវនាការ។[143]

ជាទូទៅ ភស្តុតាងទាំងនោះត្រូវបានពិនិត្យតាមឆន្ទានុសិទ្ធិរបស់តុលាការ ឬ តាមការស្នើសុំរបស់ភាគី ដូចជា៖ តុលាការទទួលបានការបំភ្លឺបន្ថែម ទៅលើរឿងក្តីលែងលះ តាមរយៈការសាកសួរសាក្សី។ ដែល «សាក្សី» គឺសំដៅដល់បុគ្គលទាំងឡាយដែលបានដឹង ឬ បានឮ បានឃើញហេតុការណ៍ពីអតីតកាល ហើយលើកយកហេតុការណ៍នោះមកបង្ហាញនៅតុលាការ។ តុលាការនឹងកោះហៅសាក្សីក្នុងរយៈពេលយ៉ាងតិច ២ (ពីរ) សប្តាហ៍មុននីតិវិធីទាញហេតុផលផ្ទាល់មាត់ចាប់ផ្តើម ហើយនៅពេលដែលសាក្សីបានចូលមកបំភ្លឺក្នុងសាលសវនាការ តុលាការនឹងសាកសួរដេញដោល អង្គហេតុមួយចំនួនដែលសាក្សីបានដឹងទាក់ទង នឹងសហព័ទ្ធទាំងពីរដែលកំពុងធ្វើសកម្មភាពប្តឹងលែងលះ។[144]

រីឯការសាកសួរភាគីលែងលះវិញ គឺចាំបាច់ណាស់សម្រាប់តុលាការ ដែលត្រូវតែសាកសួរទៅកាន់ភាគីដើមចោទ និងចុងចម្លើយឲ្យធ្វើការអះអាង ដើម្បីប្រមូលយកព័ត៌មានទាំងឡាយពាក់ពន្ធ័រឿងក្តី។ ភាគីតែងឆ្លើយបំភ្លឺ ឬ សារភាព ឬ បដិសេធចោលនូវការអះអាងទៅវិញទៅមកនៅចំពោះមុខតុលាការ។ លើសពីនេះ គឺការត្រួតពិនិត្យតាមរយៈការធ្វើកោសលវិច័យ។ តុលាការសម្រេចធ្វើកោសលវិច័យ ចំពោះករណីដែលចាំបាច់មួយចំនួន ក្នុងការត្រួតពិនិត្យ រាល់ភស្តុតាងដែលពុំអាចមើលឃើញនឹងភ្នែកទទេបាន នោះតុលាការត្រូវពឹងពាក់ លើ

[142] មាត្រា១១៦ (៣) នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

[143] មាត្រា១២៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

[144] មាត្រា១៣២ នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

អ្នកជំនាញក្នុងពិនិត្យ ភស្តុតាងទាំងអស់នោះ ដើម្បីជាការធានានូវយុត្តិធម៌ និងតម្លាភាពជូនគូភាគី។[145] ជាពិសេសគឺ ភស្តុតាងជាឯកសារផ្សេងៗទៀត ដែលពាក់ព័ន្ធ តុលាការត្រូវយកមកពិនិត្យវិនិច្ឆ័យអំពីតម្លៃគតិយុត្តរបស់ឯកសារទាំងនេះ។ ជាការពិតណាស់ ភស្តុតាងឯកសារផ្សេងៗ ដែលពាក់ព័ន្ធនឹងវិវាទលែងលះទាំងអស់នោះមានដូចជា៖ សំបុត្រអាពាហ៍ពិពាហ៍, សំបុត្រកំណើតរបស់កូន, និងបញ្ជីទ្រព្យសម្បត្តិ ជាដើម។

ជាចុងក្រោយ តុលាការអនុញ្ញាតឲ្យភាគីនីមួយៗ ធ្វើការទាញហេតុផលផ្ទាល់មាត់ជាលើកចុងក្រោយមុនពេលបញ្ចប់នីតិវិធីទាញហេតុផលផ្ទាល់មាត់។[146] ទន្ទឹមនឹងនេះ នៅក្នុងដំណាក់កាលនីតិវិធីទាញហេតុផលផ្ទាល់មាត់ ក្រឡាបញ្ជី មានកាតព្វកិច្ចសំខាន់ក្នុងការកត់ត្រារាល់សកម្មភាព និងហេតុការណ៍ទាំងឡាយជូនតុលាការ។ ក្រឡាបញ្ជីត្រូវកត់ត្រានូវ សញ្ញាណនៃរឿងក្តី, ឈ្មោះចៅក្រម និងក្រឡាបញ្ជីដែលបានចូលរួម រួមជាមួយនឹងឈ្មោះភាគី និងបុគ្គលដែលពាក់ព័ន្ធផ្សេងទៀត, ពេលវេលា និងទីកន្លែង។ ក្រុមប្រឹក្សាជំនុំជម្រះត្រូវពិនិត្យលើកំណត់ត្រានោះ រួចហើយធ្វើការចុះហត្ថលេខាផងដែរ។[147]

លើសពីនេះទៅទៀត ក្រឡាបញ្ជីក៏ត្រូវកត់ត្រាបន្ថែមពាក់ព័ន្ធនឹងចំណុចសារធាតុមួយចំនួនដែលមាននៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ដូចជា កត់ត្រាអំពីសេចក្តីថ្លែងការណ៍របស់ភាគីលែងលះ, សាក្សី និងសកម្មភាពផ្សេងៗទៀតដែលភាគីបានធ្វើអំឡុងពេលនៃនីតិវិធីនោះ។[148] ចំណែកឯចៅក្រមវិញត្រូវកំណត់ការបរិច្ឆេទមិនឲ្យលើសពី ៣០ថ្ងៃ ដើម្បីធ្វើការប្រកាសសាលក្រម បន្ទាប់ពីបានបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់។[149]

### ៣.៤.៧. ការសម្រេចសេចក្តី

រឿងក្តីលែងលះដោយគ្មានការព្រមព្រៀង ឈានមកដល់នីតិវិធីចុងក្រោយបង្អស់ គឺការចេញនូវសាលក្រមសម្រេចលើបណ្តឹងទាមទារលែងលះ។ អនុលោមតាមស្មារតី នៃច្បាប់ស្តីពីនីតិវិធីរដ្ឋប្បវេណី និងច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល បានបញ្ញត្តិថាការសម្រេចសេចក្តីលើបណ្តឹងលែងលះ គឺត្រូវសម្រេចដោយការចេញសាលក្រមពីតុលាការ។ នីតិវិធីនៃការចេញសាលក្រមលែងលះ ត្រូវបានរៀបរាប់ដូចខាងក្រោម។ មួយវិញទៀត នៅក្នុងការធ្វើសេចក្តីសម្រេច ទៅលើរឿងក្តីលែងលះដោយគ្មានការព្រមព្រៀង តុលាការមានឆន្ទានុសិទ្ធិសម្រេចចេញសាលក្រមលែងលះដល់ភាគី ឬ តុលាការសម្រេចបដិសេធចោលនូវបណ្តឹងលែងលះ។

---

[145] មាត្រា១៤៣-១៤៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

[146] មាត្រា១១៦(៥) នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

[147] មាត្រា១១៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

[148] មាត្រា១១៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

[149] មាត្រា១៨២ នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

### ៣.៤.៧.១. ការចេញសាលក្រមលែងលះ

ចៅក្រមដែលទទួលបន្ទុកដោះស្រាយបណ្តឹងលែងលះ ត្រូវធ្វើការសម្រេចសេចក្តី តាមរយៈសាលក្រម កាលបើយល់ឃើញថាត្រូវបញ្ចប់ការវិនិច្ឆ័យលើរឿងក្តី ដោយផ្អែកលើលទ្ធផលដែលតុលាការទទួលបាននៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់។[150] ក្នុងន័យនេះ «សាលក្រម» គឺសំដៅដល់ការសម្រេចសេចក្តីរបស់តុលាការ ដែលធ្វើឡើងក្នុងទម្រង់ជាលិខិត មានលក្ខណៈគ្រប់គ្រាន់តាមទម្រង់ដែលច្បាប់កំណត់ និងផ្អែកលើមូលដ្ឋានច្បាប់ ព្រមទាំងបានឆ្លងការទាញហេតុផលដោយផ្ទាល់មាត់។[151] ជាគោលការណ៍ទូទៅនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី សាលក្រមកើតឡើង ដោយឆ្លងកាត់ការវិនិច្ឆ័យពីតុលាការ។ តុលាការធ្វើការវិនិច្ឆ័យ និងសម្រេចតែលើការទាមទាររបស់ភាគីតែប៉ុណ្ណោះនៅក្នុងសាលក្រម ពោលគឺតុលាការមិនអាចសម្រេចចេញសាលក្រមបានឡើយ ប្រសិនបើគ្មានការទាមទារពីភាគី។[152] យ៉ាងណាមិញ ចំពោះការលែងលះ គឺមានករណីពិសេសកំណត់ដោយច្បាប់ ចំពោះការសម្រេចក្នុងសាលក្រម។ ចំពោះបណ្តឹង ទាមទារលែងលះ កាលបើតុលាការសម្រេចចេញសាលក្រមលែងលះដល់ភាគី នោះតុលាការត្រូវតែមានកាតព្វកិច្ច ក្នុងការកំណត់អំពីអំណាចមេបាលើកូន និងការចាត់ចែងទ្រព្យសម្បត្តិរបស់ភាគី តាមឆន្ទានុសិទ្ធិរបស់តុលាការ កាលបើពុំមានពាក្យស្នើសុំពីភាគី។[153] ត្រង់ចំណុចនេះ គួរឲ្យកត់សម្គាល់ និងបានបង្ហាញថា តុលាការមានឆន្ទានុសិទ្ធិលើការសម្រេច ទោះបីជាគ្មានការទាមទារពីភាគីក៏ដោយ តែតុលាការត្រូវធ្វើការសម្រេចពីអំណាចមេបានេះ ដោយឆ្លងកាត់ការពិចារណាលើយោបល់របស់កូន និងអាយុកូន។[154]

លើសពីនេះទៅទៀត ទាក់ទងនឹងទម្រង់នៅក្នុងការសរសេរសាលក្រម តុលាការត្រូវសរសេរអំពីចំណុចសំខាន់មួយចំនួនឲ្យបានច្បាស់លាស់ដូចជា៖ តុលាការដែលមានសមត្ថកិច្ច, ថ្ងៃ ខែ ឆ្នាំនៃនីតិវិធី, ឈ្មោះ ឬនាមករណ៍របស់ភាគីពាក់ព័ន្ធ, កម្មវត្ថុ, អង្គហេតុ, ចំណុចវិវាទ ,សំអាងហេតុ និងការធ្វើឡើងនូវសេចក្តីសម្រេចបញ្ចប់។ ចៅក្រមជំនុំជម្រះត្រូវមានកាតព្វកិច្ចចុះហត្ថលេខា និងត្រាលើសាលក្រមលែងលះនោះផងដែរ។[155] សាលក្រមលែងលះត្រូវតែប្រកាសដោយតុលាការ នៅក្នុងសាលវនាការ ដើម្បីឲ្យសាលក្រមនោះមានអានុភាព។[156] ការប្រកាសសាលក្រមត្រូវតែធ្វើឡើងក្នុងអំឡុងពេល ១ (មួយ)ខែ គិតចាប់ពីថ្ងៃដែលបញ្ចប់ការទាញហេតុផល

[150] មាត្រា១៨០ នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

[151] មាត្រា១៧៩(១) នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

[152] មាត្រា១៨២ នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

[153] មាត្រា២២ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/រកម/០៦១០/០០៨, ០៨ មិថុនា ២០១០។

[154] មាត្រា២២(១) នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/រកម/០៦១០/០០៨, ០៨ មិថុនា ២០១០។

[155] មាត្រា១៨៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

[156] មាត្រា១៨៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

ដោយផ្ទាល់មាត់។[157] ហើយលិខិតសាលក្រមនោះត្រូវតែបញ្ជូន ទៅឲ្យគូភាគីក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ គិតចាប់ពីថ្ងៃដែលបានប្រកាសសាលក្រម។[158] ទន្ទឹមនឹងនេះ ការប្រកាសសាលក្រម ត្រូវធ្វើជាសាធារណៈ ដោយប្រធានក្រុមប្រឹក្សាជំនុំជម្រះ ហើយការប្រកាសនេះអាចធ្វើឡើងបានដោយមាន ឬ គ្មានវត្តមានរបស់គូភាគីនៅក្នុងពេលប្រកាសសាលក្រម។[159] ជាពិសេស ពាក់ព័ន្ធទៅនឹងអត្តពន្ធភាពនៃសាលក្រមលែងលះ គឺសាលក្រមមិនអាចលុប ឬ កែប្រែបានឡើយ លើកលែងតែក្នុងករណីដែលមានចែងក្នុងមាត្រា ១៩២ នៃក្រមនីតិវិធីរដ្ឋប្បវេណី អំពីចំណុចដែលច្បាប់បានអនុញ្ញាតឲ្យកែតម្រូវបាន។ ការកែតម្រូវលើសាលក្រមត្រូវតែធ្វើឡើង តាមរយៈដីកាសម្រេចកែតម្រូវ។[160]

### ៣.៤.៧.២. ការសម្រេចមិនឲ្យមានការលែងលះ

យ៉ាងណាមិញ ទោះបីជាមានការប្តឹងទាមទារលែងលះពីភាគីក៏ដោយ តែតុលាការត្រូវធ្វើការពិចារណាជាមុនសិន មុននឹងសម្រេច។ តុលាការសម្រេចសេចក្តី ដោយធានាមិនឲ្យមានការបំពានផលប្រយោជន៍ និងធានារក្សាសណ្តាប់ធ្នាប់សាធារណៈ។ ដូចនេះ ការប្តឹងទាមទារលែងលះទាំងអស់ មិនសុទ្ធតែត្រូវបានតុលាការសម្រេចឲ្យបញ្ចប់ទំនាក់ទំនងឡើយ។ តុលាការ មានឆន្ទានុសិទ្ធិច្រានចោលការប្តឹងទាមទារ បើតុលាការយល់ឃើញថាការទាមទារនោះនាំឲ្យប៉ះពាល់ធ្ងន់ធ្ងរទៅលើផលប្រយោជន៍ភាគី ឬ ការទាមទារនោះផ្ទុយនឹងភាពសុចរិត។[161]

### ក. ស្ថានភាពលំបាកធ្ងន់ធ្ងរ

តុលាការសម្រេចលើកចោលការប្តឹងទាមទារលែងលះ កាលបើតុលាការសង្កេតឃើញថា ការទាមទារលែងលះពីខាងដើមចោទអាចបណ្តាលឲ្យ ភាគីម្ខាងទៀតធ្លាក់ខ្លួនក្នុងស្ថានភាពលំបាកធ្ងន់ធ្ងរខ្លាំង ក្នុងការទ្រទ្រង់ជីវភាពរបស់ខ្លួន ឬ កូន ដែលនឹងបង្កឲ្យស្ថិតក្នុងភាពក្រីក្រលំបាកតោកយ៉ាកខ្លាំង ឬ មានភាពឈឺចាប់ខ្លាំង ឬ មានព្យាសនកម្មទៅស្ថានភាពផ្លូវចិត្តធ្ងន់ធ្ងរ។ ជាក់ស្តែងស្ថានភាពបែបនេះ ច្រើនតែកើតមានចំពោះករណី ដែលសហព័ទ្ធម្ខាងមានជំងឺធ្ងន់ធ្ងរ, មានវ័យជរា មិនអាចប្រកបរបរចិញ្ចឹមជីវិតបាន។ ស្ថានភាពទាំងនេះនឹងនាំឲ្យមានជាប់ទាក់ទង ឬ មានឥទ្ធិលដល់ការធ្វើសេចក្តីសម្រេចរបស់តុលាការ។ ស្ថានភាពលំបាកធ្ងន់ធ្ងរខ្លាំងរបស់សហព័ទ្ធអាចនឹងបណ្តាលឲ្យតុលាការសម្រេចច្រានចោលការប្តឹងទាមទារលែងលះ ទៅតាមឆន្ទានុសិទ្ធិរបស់តុលាការ។[162]

---

[157] មាត្រា១៨៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

[158] មាត្រា១៩០ នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

[159] មាត្រា១៨៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

[160] មាត្រា១៩១-១៩២ នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

[161] មាត្រា៩៧៨(២)-៩៧៨(៣) នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[162] មាត្រា៩៧៨(២) នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

**ខ. ទាមទារផ្ទុយពីភាពសុចរិត**

ការទាមទារដែលមាន លក្ខណៈផ្ទុយពីភាពសុចរិត ក៏ជាកត្តាមួយទៀត ដែលតុលាការសម្រេចចិត្តច្រានចោលនូវការប្តឹងទាមទារលែងលះផងដែរ។ តុលាការ នឹងច្រានចោលការលែងលះទាំងឡាយណា ដែលតុលាការពិចារណាឃើញថា ភាគីមិនមានឆន្ទៈសុចរិតនៅក្នុងអាពាហ៍ពិពាហ៍។ ជាក់ស្តែង ឆន្ទៈមិនសុចរិតទាំងនោះមានដូចជា ភាគីដើមចោទដែលបានប្តឹងទាមទារលែងលះ មិនបានខិតខំបំពេញកាតព្វកិច្ចសហព័ទ្ធ ក្នុងការជួយសង្គ្រោះគ្នាទៅវិញទៅមក, មិនបានសហការគ្នា, ឬ ភាគីនោះបែរជាគេចទៅរស់នៅផ្សេងគ្នា ដោយសារតែការធ្វេសប្រហែស ឬ គ្មានឆន្ទៈទទួលខុសត្រូវក្នុងក្រុមគ្រួសារ។ ករណីផ្សេងទៀត ដែលតុលាការសម្រេចច្រានចោលការប្តឹងទាមទារលែងលះ គឺដោយសារតែរកឃើញថា ភាគីមានឆន្ទៈមិនពិត ក្នុងការទាមទារលែងលះដើម្បីគោលបំណងណាផ្សេងដែលផ្ទុយនឹងច្បាប់។ សកម្មភាពទាំងឡាយណាដែលមានលក្ខណៈផ្ទុយនឹងភាពសុចរិត តុលាការនឹងសម្រេចច្រានចោលការប្តឹងទាមទារលែងលះនោះដោយឆន្ទានុសិទ្ធិ។[163]

**៣.៤.៧.៣. ការប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់**

នៅក្នុងនីតិវិធីរដ្ឋប្បវេណី ដែលដោះស្រាយទៅលើបណ្តឹងលែងលះ ភាគីមានសិទ្ធិធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ក្នុងចន្លោះពេលកំណត់ដោយច្បាប់ កាលបើមិនសុខចិត្តចំពោះសេចក្តីសម្រេចមិនទាន់ចូលជាស្ថាពររបស់តុលាការដែលជំនុំជម្រះលើកទី១។ ភាគីលែងលះ មានសិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍, បណ្តឹងសាទុក្ខ និងបណ្តឹងជំទាស់ជាដើម។[164]

**ក. បណ្តឹងឧទ្ធរណ៍**

ភាគីលែងលះដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់តុលាការដើម មានសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ នៅមុនពេលដែលសាលក្រមនោះបានចូលជាស្ថាពរ។ តាមគោលការណ៍នៃច្បាប់ បណ្តឹងឧទ្ធរណ៍ ជាប្រភេទមួយនៃបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ចំពោះសាលក្រមរបស់សាលាដំបូងរាជធានីខេត្តដែលមិនទាន់ចូលជាស្ថាពរ។[165] ភាគីដែលធ្វើបណ្តឹងឧទ្ធរណ៍ ហៅថា «ដើមបណ្តឹងឧទ្ធរណ៍» ហើយភាគីម្ខាងទៀតហៅថា «ចុងបណ្តឹងឧទ្ធរណ៍»។ ចំពោះបណ្តឹងឧទ្ធរណ៍នេះ ភាគីមានសិទ្ធិប្តឹងក្នុងអំឡុងពេល ១ (មួយ)ខែ គិតចាប់ពីថ្ងៃដែលភាគីលែងលះបានទទួលការបញ្ជូនលិខិតសាលក្រម ឬ ថ្ងៃដែលបានជូនដំណឹងអំពីដីកាសម្រេចរបស់តុលាការ។[166] ចំណែកឯ របៀបនៃការដាក់បណ្តឹងឧទ្ធរណ៍វិញ គឺដើមបណ្តឹងឧទ្ធរណ៍ ត្រូវធ្វើពាក្យបណ្តឹង ដែលមានសរសេរអំពីអត្តសញ្ញាណភាគី, សញ្ញាណនៃសាលក្រមលែងលះនៃការជំនុំជម្រះលើកទី១ ជាពិសេសបញ្ជាក់ឲ្យច្បាស់នូវ

[163] មាត្រា៩៧៨(៣) នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[164] មាត្រា២៥៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

[165] មាត្រា២៥៩(ក) នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

[166] មាត្រា២៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

មូលហេតុនៃការទាមទារ រួចយកពាក្យបណ្តឹងឧទ្ធរណ៍នោះទៅដាក់នៅតុលាការដើម។ តុលាការដើម ត្រូវប្រញាប់ធ្វើការបញ្ជូនសំណុំរឿងលែងលះនោះ ទៅកាន់តុលាការនៃបណ្តឹងឧទ្ធរណ៍ដើម្បីបន្តនីតិវិធី។[167] ពាក់ព័ន្ធនឹងនីតិវិធីនៃការជំនុំជម្រះក្តី នៅសាលាឧទ្ធរណ៍វិញ គឺអនុវត្តនីតិវិធីដូចគ្នានឹងនីតិវិធីនៃការជំនុំជម្រះលើកទី១ ដែលមានបញ្ញត្តិក្នុងគន្ថី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីដែរ លើកលែងតែបញ្ញត្តិពិសេសមួយចំនួនដែលច្បាប់កំណត់តែប៉ុណ្ណោះ។[168] នៅក្នុងការអនុវត្តជាក់ស្តែងចំពោះរឿងក្តីលែងលះ តែងតែមានពាក់ព័ន្ធនឹងការទាមទារច្រើនចំណុចដូចជា ការទាមទារបញ្ចប់ទំនាក់ទំនងរវាងសហព័ទ្ធ, ការបែងចែកសិទ្ធិអំណាចមេបា និងការបែងចែកទ្រព្យសម្បត្តិជាដើម ដោយហេតុនេះហើយ ភាគីលែងលះអាចនឹងមានចំណុចខ្លះ យល់ស្របនឹងការសម្រេចរបស់តុលាការ ហើយចំណុចខ្លះទៀត ភាគីមិនសុខចិត្តនឹងការសម្រេចរបស់តុលាការ។ ដូច្នេះ សាលាឧទ្ធរណ៍អាចប្រកាសឲ្យអនុវត្តបណ្តោះអាសន្ន ត្រង់ចំណុចទាំងឡាយណាដែលភាគីមិនបានបន្តប្តឹងឧទ្ធរណ៍ តាមពាក្យសុំដោយការចេញដីកាសម្រេចបាន។[169] ក្នុងករណីដែលតុលាការនៃបណ្តឹងឧទ្ធរណ៍ យល់ឃើញថា សាលក្រមនៃការជំនុំជម្រះលើកទី១ ត្រឹមត្រូវហើយ នោះតុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវច្រានចោលបណ្តឹងឧទ្ធរណ៍ របស់ដើមបណ្តឹងឧទ្ធរណ៍។[170] ម្យ៉ាងវិញទៀត តុលាការនៃបណ្តឹងឧទ្ធរណ៍ ត្រូវលុបចោលសាលក្រមរបស់តុលាការដើម បើយល់ឃើញថា សាលក្រមនៃការជំនុំជម្រះលើកទី១ មិនត្រឹមត្រូវ ឬ នីតិវិធីនៅតុលាការទី១នោះ ផ្ទុយនឹងច្បាប់ធ្ងន់ធ្ងរ។[171]

### ខ. បណ្តឹងសាទុក្ខ

ភាគីលែងលះដែលមានមូលហេតុថា ការសម្រេចសេចក្តីរបស់សាលាឧទ្ធរណ៍មិនត្រឹមត្រូវ តាមធម្មនុញ្ញភាពនៃរដ្ឋធម្មនុញ្ញ ឬ ច្បាប់ ឬ បទដ្ឋានគតិយុត្ត មានសិទ្ធិបន្តធ្វើបណ្តឹងសាទុក្ខបាន នៅមុនពេលដែលសាលដីកានោះបានចូលជាស្ថាពរ។[172] តាមគោលការណ៍នៃច្បាប់ បណ្តឹងសាទុក្ខ ជាប្រភេទមួយនៃបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ អំពីការទាមទារឲ្យវិនិច្ឆ័យពីភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃសាលក្រម ឬ សាលដីកាចុងក្រោយចំពោះតែការអនុវត្តច្បាប់តែប៉ុណ្ណោះ។[173] ភាគីលែងលះជាប្តី ឬ ប្រពន្ធដែលធ្វើបណ្តឹងសាទុក្ខ ហៅថា «ដើម-បណ្តឹងសាទុក្ខ» ហើយភាគីម្ខាងទៀតហៅថា «ចុងបណ្តឹងសាទុក្ខ»។ ពាក់ព័ន្ធនឹងរបៀបនៃការដាក់បណ្តឹង

[167] មាត្រា២៦៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

[168] មាត្រា២៧៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

[169] មាត្រា២៧១ នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

[170] មាត្រា២៧៧(១) នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

[171] មាត្រា២៧៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

[172] មាត្រា២៨៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

[173] មាត្រា២៥៩(ខ) នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

សាទុក្ខវិញ គឺដើមបណ្តឹងសាទុក្ខ ត្រូវធ្វើពាក្យបណ្តឹងដែលមាន បញ្ជាក់ច្បាស់នូវមូលហេតុដែលផ្ទុយនឹងច្បាប់របស់សាលដីកាសាលាឧទ្ធរណ៍ រួចយកពាក្យបណ្តឹងសាទុក្ខនោះទៅដាក់នៅតុលាការដើម។ តុលាការដើម ត្រូវប្រញាប់ធ្វើការបញ្ជូនសំណុំរឿងលែងលះនោះ ទៅកាន់តុលាការកំពូលដើម្បីបន្តនីតិវិធី។[174] ចំណែកឯនីតិវិធីនៃការជំនុំជម្រះក្តីលែងលះនៅតុលាការកំពូលវិញ គឺអនុវត្តនីតិវិធីដូចគ្នានឹង នីតិវិធីនៃការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ ដូចដែលច្បាប់បានបញ្ញត្តិក្នុងជំពូក២ គន្លឹ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីដែរ លើកលែងតែបញ្ញត្តិពិសេសមួយចំនួនដែលច្បាប់កំណត់តែប៉ុណ្ណោះ។[175] តុលាការកំពូល ឬ ហៅថា តុលាការនៃបណ្តឹងសាទុក្ខ អាចប្រកាសឲ្យអនុវត្តបណ្តោះអាសន្ន ត្រង់ចំណុចទាំងឡាយណាដែលភាគីមិនបានបន្តប្តឹងសាទុក្ខ តាមពាក្យសុំដោយការចេញដីកាសម្រេចបាន។[176] តុលាការនៃបណ្តឹងសាទុក្ខ ធ្វើការសម្រេចបដិសេធចោលនូវសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ តែក្នុងករណីសេចក្តីសម្រេចនោះមិនត្រឹមត្រូវទៅតាមច្បាប់ដូចមានចែងក្នុងមាត្រា ២៨៤ និងមាត្រា២៨៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឬ សម្រេចបដិសេធចោលដោយយល់ឃើញ ពីភាពមិនត្រឹមត្រូវនៃសេចក្តីសម្រេចរបស់តុលាការមុនៗ តាមរយៈការវិនិច្ឆ័យរបស់ចៅក្រម។[177]

### គ. បណ្តឹងជំទាស់

បណ្តឹងជំទាស់ គឺជាបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ដែលបណ្តឹងនេះ ភាគីធ្វើការប្តឹងជំទាស់ចំពោះដីកាសម្រេចរបស់តុលាការ។[178] នៅក្នុងរឿងក្តីលែងលះ មានករណីខ្លះដែលតុលាការបានចេញនូវដីកាសម្រេច ក្នុងដំណាក់កាលណាមួយនៃដំណើរនីតិវិធីដូចដែលបានរៀបរាប់ពីខាងលើ។ ភាគីមានសិទ្ធិ ដាក់បណ្តឹងជំទាស់នេះ ចំពោះដីកាសម្រេចទាំងឡាយណាដែលភាគី មិនសុខចិត្ត ដោយយល់ឃើញថា មានការប៉ះពាល់ដល់ប្រយោជន៍របស់ខ្លួន។ ចំពោះបណ្តឹងជំទាស់នេះ ភាគីមានសិទ្ធិប្តឹងក្នុងអំឡុងពេល ១ (មួយ )សប្តាហ៍ គិតចាប់ពីថ្ងៃដែលភាគីលែងលះបានទទួលដំណឹងនេះអំពីដីកាសម្រេចពីតុលាការ។[179]

ទាំងអស់ខាងលើនេះ គឺជាលំហូរនីតិវិធីនៃការលែងលះដោយគ្មានការព្រមព្រៀង។ បន្ទាប់ពីមានការសម្រេចលែងលះដល់គូភាគីជាស្ថាពរដោយតុលាការរួចមក នោះនាំឲ្យមានការចាប់ផ្តើមអានុភាពនៃការលែងលះ។ គួរបញ្ជាក់ផងដែរថា ទាំងការលែងលះដោយការព្រមព្រៀង និងការលែងលះដោយគ្មានការព្រមព្រៀង គឺសុទ្ធតែបន្សល់នូវអានុភាពក្រោយការលែងលះដោយគូភាគីទាំងសងខាង។

[174] មាត្រា២៦៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

[175] មាត្រា២៨៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

[176] មាត្រា២៩៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

[177] មាត្រា២៩៩-៣០០ នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

[178] មាត្រា២៥៩(គ) នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

[179] មាត្រា៣០៣(១) នៃក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

ដូចនេះ បន្ទាប់ពីបានសិក្សាស្រាវជ្រាវក្នុងជំពូកទី២ អំពីនីតិវិធីនៃការលែងលះដោយការព្រមព្រៀង និង ជំពូកទី៣ អំពីនីតិវិធីនៃការលែងលះដោយមិនមានការព្រមព្រៀង រួចមកហើយនៅក្នុងជំពូកចុងក្រោយ ដែលជាជំពូកទី៤ នេះនឹងបកស្រាយអំពីអានុភាពនៃការលែងលះ។

# ជំពូកទី៤
# អនុភាពនៃការលែងលះ

# ជំពូកទី៤
# អានុភាពនៃការលែងលះ

ក្រោយពេលដែលតុលាការប្រកាសសាលក្រម ឬ សាលដីកាលែងលះដែលចូលជាស្ថាពររួចរាល់ហើយ នាំឲ្យសេចក្តីសម្រេចទាំងនោះ បង្កើតនូវអានុភាពដល់ភាគី ទាំងភាគីដែលសម្រេចលែងលះដោយការព្រមព្រៀង និងភាគីដែលលែងលះដោយគ្មានការព្រមព្រៀង។ អានុភាពនៃការលែងលះមានដូចជា៖ (៤.១.) **ការកាត់ផ្តាច់ទំនាក់ទំនងគតិយុត្ត**, និង (៤.២.) **សិទ្ធិ និងភាតព្វកិច្ចបន្សល់ក្រោយការលែងលះ**។

## ៤.១. ការកាត់ផ្តាច់ទំនាក់ទំនងគតិយុត្ត

អានុភាពចម្បងដែលកើតចេញពីការលែងលះ គឺការផ្តាច់ទំនាក់ទំនងគតិយុត្តរវាងសហព័ទ្ធ។ ការកាត់ផ្តាច់ទំនាក់ទំនងគតិយុត្តទាំងនោះរួមមាន៖ (៤.១.១.) **ការកាត់ផ្តាច់ចំណងគតិយុត្តរវាងសហព័ទ្ធ** និង (៤.១.២.) **ការកាត់ផ្តាច់ទំនាក់ទំនងញាតិពន្ធ**។

### ៤.១.១. ការកាត់ផ្តាច់ចំណងគតិយុត្តរវាងសហព័ទ្ធ

នៅពេលដែលបុរស និងស្ត្រីដែលមានពេញវ័យនីតិភាព ហើយរៀបអាពាហ៍ពិពាហ៍ ដោយបានចុះសំបុត្រអាពាហ៍ពិពាហ៍ជាមួយគ្នាដោយស្របច្បាប់ នោះពួកគេបានបង្កើតឡើងនូវចំណងគតិយុត្ត ដែលទទួលស្គាល់ដោយច្បាប់ថា ពួកគេត្រូវជាសហព័ទ្ធនឹងគ្នាចាប់ពីពេលនោះតទៅ។[180] នៅពេលដែលសហព័ទ្ធទាំងពីរបានលែងលះគ្នា នោះអានុភាពនៃការលែងលះបានកាត់ផ្តាច់ ចំណងគតិយុត្តរវាងសហព័ទ្ធ ចាប់ពីពេលសាលក្រមលែងលះចូលជាស្ថាពរ។ ត្រង់ចំណុចនេះ បានសេចក្តីថា រវាងភាគីប្តី និងប្រពន្ធ មិនមានចំណងទំនងទំនងគតិយុត្តដែលបានទទួលស្គាល់ដោយច្បាប់ទៀតឡើយ បន្ទាប់ពីសាលក្រមលែងលះចូលជាស្ថាពរ។ ចំណែកឯករណីដែលធ្លាប់បានកើតឡើងនៅក្នុងសង្គមជាក់ស្តែងមួយចំនួនវិញ មានភាគីខ្លះបានលែងលះគ្នា ជាស្ថាពររួចហើយ ក្រោយមកទៀតក៏បានសះជានឹងគ្នា ព្រមទាំងវិលមករួមរស់ជាមួយគ្នាវិញ ត្រង់ករណីនេះប្រសិនបើភាគីមិនបានទៅចុះសំបុត្រអាពាហ៍ពិពាហ៍ជាមួយគ្នាម្តងទៀតទេ នោះទំនាក់ទំនងរបស់ភាគី មិនត្រូវបានច្បាប់បន្តទទួលស្គាល់ថាជាសហព័ទ្ធនឹងគ្នាឡើយ ព្រោះសាលក្រមលែងលះរបស់ភាគីបានចូលជាស្ថាពរទៅហើយ។

### ៤.១.២. ការកាត់ផ្តាច់ទំនាក់ទំនងញាតិពន្ធ

អានុភាពនៃការលែងលះ មិនមែនត្រឹមតែកាត់ផ្តាច់ទំនាក់ទំនងរវាងសហព័ទ្ធនោះទេ ការលែងលះថែមទាំងនាំឲ្យមានការកាត់ផ្តាច់ដល់ទំនាក់ទំនងញាតិពន្ធ ផងដែរ។ ជាទូទៅ នៅក្នុងច្បាប់រដ្ឋប្បវេណីនៃប្រទេសកម្ពុជាបានកំណត់ប្រភេទញាតិជា បីប្រភេទ៖ ញាតិលោហិត សហព័ទ្ធ និងញាតិពន្ធ។[181] ញាតិលោហិត គឺជា

[180] មាត្រា៩៣៨(២) និងមាត្រា៩៤៨ នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[181] មាត្រា៩៣៨ នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

សាច់ញាតិដែលមានជាប់ខ្សែឈាមផ្ទាល់ ជាមួយនឹងបុគ្គលណាម្នាក់។ ញាតិពន្ធ គឺសំដៅដល់សាច់ញាតិដែលមិនមានជាប់ខ្សែឈាមនឹងបុគ្គល ជាប្ដី ឬ ប្រពន្ធ តែជាញាតិខាងសហព័ទ្ធរបស់ បុគ្គលជាប្ដី ឬ ប្រពន្ធនោះ ដែលនិយាយតាមន័យសាមញ្ញ គឺញាតិសាច់ថ្លៃ។ ញាតិពន្ធ នេះកើតមានឡើងបន្ទាប់ពីមានចំណងអាពាហ៍ពិពាហ៍រវាងសហព័ទ្ធ ដែលនាំឲ្យមានការភ្ជាប់សាច់ញាតិ នៃភាគីទាំងសងខាង។ ហេតុនេះញាតិពន្ធ ក៏នឹងត្រូវបានបញ្ចប់ទៅវិញនៅពេលដែល ចំណងអាពាហ៍ពិពាហ៍បានបញ្ចប់ទៅវិញដូចគ្នា។ ពោលគឺ ក្រោយការលែងលះបុគ្គលជាប្ដី ឬ ប្រពន្ធ មិនមានបន្សល់ទំនាក់ទំនងញាតិពន្ធបន្តទៀតឡើយ។[182]

ចំណែកឯ នៅក្នុងការរស់នៅប្រចាំថ្ងៃវិញ ថ្វីត្បិតតែច្បាប់បានបញ្ញត្តិថា ទំនាក់ទំនងញាតិពន្ធ បានកាត់ផ្ដាច់នៅពេលមានការលែងលះរវាងភាគីដែលធ្លាប់ជាសហព័ទ្ធនឹងគ្នាក៏ពិតមែន ក៏ប៉ុន្តែ ប្រសិនបើរវាងញាតិពន្ធរបស់ភាគីខាងប្ដី ឬ ប្រពន្ធដែលលែងលះរួច គ្មានការខឹង គ្មានបញ្ហា ឬ ទំនាស់ គុំគួន នឹងគ្នានោះទេ ពួកគេនៅតែរាប់អានគ្នាបានជាធម្មតា។

## ៤.២. សិទ្ធិ និងកាតព្វកិច្ចបន្សល់ក្រោយការលែងលះ

ការលែងលះ ត្រូវបានបែងចែកជា ពីរប្រភេទ៖ គឺការលែងលះដោយព្រមព្រៀង និងការលែងលះដោយគ្មានការព្រមព្រៀង។ ចំពោះការលែងលះដែលមានការព្រមព្រៀងរវាងភាគីទៅលើការបែងចែកសិទ្ធិ និងកាតព្វកិច្ចនោះតុលាការនឹងសម្រេចសេចក្ដីទៅតាមឆន្ទៈរបស់ភាគី ដោយការចេញនូវដីកាសម្រេច។[183] ចំណែកឯការលែងលះដោយគ្មានការព្រមព្រៀងវិញ នោះតុលាការនឹងសម្រេចលើបណ្ដឹងទាមទារទាំងនោះ ដោយយកគោលការណ៍ច្បាប់ធ្វើជាមូលដ្ឋានក្នុងការសម្រេច តាមរយៈការប្រកាសសាលក្រម។ ជារួម នៅក្រោយការលែងលះ នឹងបន្សល់ទុកនូវអានុភាពដូចជា (**៤.២.១.**) **សិទ្ធិបន្សល់ក្រោយការលែងលះ** និង (**៤.២.២.**) **កាតព្វកិច្ចបន្សល់ក្រោយការលែងលះ**។

### ៤.២.១ សិទ្ធិបន្សល់ក្រោយការលែងលះ

ទោះបីអាពាហ៍ពិពាហ៍ត្រូវបានបញ្ចប់ក៏ពិតមែន ក៏ប៉ុន្តែនៅក្រោយការលែងលះបានបន្សល់ទុកនូវសិទ្ធិមួយចំនួនចំពោះភាគី។ ក្នុងការបែងចែកសិទ្ធិ ជាទូទៅតុលាការនឹងបែងចែកតាមឆន្ទៈព្រមព្រៀងរបស់ភាគី ក៏ប៉ុន្តែប្រសិនបើសិទ្ធិទាំងនោះ ភាគីមិនបានបែងចែកទេ ឬ ភាគីមិនអាចពិភាក្សាគ្នាបានជោគជ័យលើការបែងចែកសិទ្ធិនោះតុលាការនឹងធ្វើការបែងចែកសិទ្ធិទាំងនោះទៅឲ្យភាគី តាមមូលដ្ឋានច្បាប់។ សិទ្ធិដែលបន្សល់ក្រោយការលែងលះ មានដូចជា៖ សិទ្ធិទទួលបានអត្តាធិនភាព, សិទ្ធិក្នុងការប្រើប្រាស់នាមត្រកូល, សិទ្ធិលើអំណាចមេបា, សិទ្ធិលើទ្រព្យសម្បត្តិ, សិទ្ធិក្នុងការបង្កើតអាពាហ៍ពិពាហ៍ថ្មី, និងការបញ្ចប់ករណីយកិច្ចសហព័ទ្ធជាដើម។

[182] មាត្រា៩៤១ នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[183] មាត្រា៣៥ នៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង, នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០។

### ៤.២.១.១. សិទ្ធិទទួលបានអត្តាធិនភាពដដែល

ជាបឋមការឲ្យនិយមន័យពាក្យ «អត្តាធិនភាព» គឺសំដៅដល់ស្ថានភាពមួយដែលផ្តល់ឲ្យ អនីតិជនរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន ឬ រួចផុតពីអំណាចមេបា ហើយមានសមត្ថភាពដូចនីតិជនដែរ។[184] នៅក្នុងក្រមរដ្ឋប្បវេណីមាត្រា ២១(២) បានបញ្ញត្តិយ៉ាងច្បាស់ថាអនីតិជន ដែលបានរៀបអាពាហ៍ពិពាហ៍ ត្រូវទទួលស្គាល់ថាបានអត្តាធិនភាពក្នុងការអនុវត្តសកម្មភាពដូចនីតិជនដែរ។ បានសេចក្តីថា ក្រោយពីមានចំណងអាពាហ៍ពិពាហ៍របស់អនីតិជន គឺជននោះ បានទទួលអត្តាធិនភាពតាមការសន្មតនៃច្បាប់ ថាមាននីតិភាពរួចហើយ។[185] នីតិភាពនេះគឺជា សិទ្ធិដែលកំណត់ដោយច្បាប់សម្រាប់អនីតិជន ដែលបានរៀបអាពាហ៍ពិពាហ៍រួចដោយមិនចាំបាច់តម្រូវឲ្យមាន ការប្រកាសពីនីតិភាពដោយតុលាការ ព្រមទាំងមិនត្រូវបានបាត់បង់ទៅវិញឡើយ ទោះបីជា ចំណងអាពាហ៍ពិពាហ៍បានឈានដល់ការលែងលះជាស្ថាពរហើយ។ ត្រង់ចំណុចនេះ ច្បាប់រដ្ឋប្បវេណីនៅតែផ្តល់នីតិភាពដដែល ដោយមូលហេតុថា ភាគច្រើនរូបវន្តបុគ្គលដែលឪពុក ឬ ម្តាយ បានព្រមព្រៀងឲ្យរៀបអាពាហ៍ពិពាហ៍ គឺដោយសារគ្រួសារផ្ទាល់ និងសង្គមមានផ្នត់គំនិតថាបុគ្គលនោះបានចាស់ចិត្តចាស់គំនិតមិនមែនជាក្មេងដែលមិនមានសមត្ថភាពក្នុងការសម្រេចសកម្មភាពផ្សេងៗទៀត នៅក្នុងសកម្មភាពទូទៅឡើយ ហេតុនេះជននោះសាកសមនឹងទទួលស្គាល់ថាមាននីតិភាព។ មួយវិញទៀត បុគ្គលដែលមានសិទ្ធិរៀបអាពាហ៍ពិពាហ៍ មុនដល់នីតិភាព ត្រូវមានអាយុយ៉ាងតិច១៥ឆ្នាំ ដែលអាយុនេះក៏បិតនៅក្បែរវ័យនីតិភាព ១៨ឆ្នាំផងដែរ។[186] ដូច្នេះ ច្បាប់សន្មតថា ជននោះមានសមត្ថភាពគ្រប់គ្រាន់ក្នុងក្រុមគ្រួសារ និងការចូលរួមសកម្មភាពប្បវេណីប្រចាំថ្ងៃ ដូចនីតិជនទូទៅផងដែរ។ សរុបមក នៅក្រោយការលែងលះ ភាគីដែលទទួលបានអត្តាធិនភាពតាមរយៈអាពាហ៍ពិពាហ៍ នៅតែមានសិទ្ធិទទួលបាននូវអត្តាធិនភាពនោះដដែល។[187]

### ៤.២.១.២. សិទ្ធិក្នុងការប្រើប្រាស់នាមត្រកូល

នៅក្នុងអំឡុងពេលរៀបអាពាហ៍ពិពាហ៍ មានសហព័ទ្ធមួយចំនួន ជាពិសេសគឺ សហព័ទ្ធខាងស្ត្រី ភាគច្រើននិយមប្រើប្រាស់នាមត្រកូលរបស់ស្វាមី។ ដោយឡែក ការប្រើប្រាស់នាមត្រកូលរបស់ភាគីម្ខាងទៀត នៅក្នុងអំឡុងពេលនៃអាពាហ៍ពិពាហ៍បែបនេះ ពុំមែនជាបញ្ហាចោទអ្វីឡើយ ពាក់ព័ន្ធជាមួយនឹងអានុភាព ដែលបន្សល់ក្រោយពេលដែលភាគីបានលែងលះ។ មូលហេតុថា នៅក្រោយពេលលែងលះ ភាគីប្តី ឬ ប្រពន្ធ ដែលបានប្តូរនាមត្រកូលថ្មីតាមសហព័ទ្ធរបស់ខ្លួននោះ គឺអាចមានសិទ្ធិនៅក្នុងការបន្តប្រើប្រាស់ នាមត្រកូលរបស់អតីតសហព័ទ្ធបានដដែល ឬ ក៏ភាគីមានសិទ្ធិក្នុងការផ្លាស់ប្តូរទៅប្រើប្រាស់នាមត្រកូលរបស់ខ្លួន នៅមុនពេលរៀប

[184] សន្ទានុក្រមលេខ១៨៣ នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[185] មាត្រា៩៦៨ នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[186] មាត្រា៩៤៨ នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[187] មាត្រា២១(៣) នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

អាពាហ៍ពិពាហ៍ក៏បាន។[188] ដូចនេះ នៅក្រោយការលែងលះ ភាគីប្តី ឬ ប្រពន្ធមានសិទ្ធិក្នុងការប្រើប្រាស់នាមត្រកូលទៅតាមឆន្ទៈរបស់ខ្លួន។

**៤.២.១.៣. សិទ្ធិលើអំណាចមេបា**

នៅក្រោយការលែងលះ តុលាការនឹងសម្រេចអំពីភាគីណាដែលមានសិទ្ធិអំណាចមេបាទៅលើកូនៗ។ អ្នកមានសិទ្ធិអំណាចមេបា គឺសំដៅលើអ្នកដែលមានសិទ្ធិ និងករណីយកិច្ច ត្រូវចិញ្ចឹមបីបាច់ថែរក្សាកូនដែលជាអនីតិជន និងជួយគ្រប់គ្រងទ្រព្យឲ្យកូន។[189] នៅក្នុងការលែងលះដោយការព្រមព្រៀង ឪពុកម្តាយដែលសម្រេចចិត្តលែងលះ ត្រូវធ្វើការពិភាក្សាគ្នាដើម្បីសម្រេចអំពីអ្នកដែលមានសិទ្ធិអំណាចមេបាទៅលើកូន។ បន្ទាប់មកតុលាការនឹងធ្វើការសម្រេចអំពីអំណាចមេបាលើកូន តាមឆន្ទៈព្រមព្រៀងរបស់ភាគី។[190] ចំណែកឯករណី នៃការលែងលះដោយគ្មានការព្រមព្រៀងវិញ បើឪពុក និងម្តាយពុំមានការព្រមព្រៀងគ្នា សម្រេចបែងចែកអំណាចមេបាបានទេ នាំឲ្យភាគីត្រូវទាមទារអំណាចមេបានេះតាមរយៈការទាមទារបន្ទាប់បន្សំនៅក្នុងបណ្តឹងលែងលះ ហើយទុកឲ្យតុលាការធ្វើការសម្រេច អំពីអ្នកដែលមានអំណាចមេបាចំពោះកូន។[191] តុលាការនឹងសម្រេចឲ្យភាគីមានអំណាចមេបា ដោយពិចារណាលើផលប្រយោជន៍របស់កូន។ ប៉ុន្តែប្រសិនបើកូនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការយល់ដឹង និងមានការសម្រេចចិត្តផ្ទាល់ខ្លួនសមស្របក្នុងការសម្រេចចិត្ត តុលាការនឹងធ្វើការសម្រេចតាមឆន្ទៈរបស់កូន។[192] ក្នុងករណីដែល កូននោះមិនទាន់កើត នៅមុនពេលលែងលះ នោះអ្នកមានអំណាចមេបាលើកូន គឺជាភាគីខាងម្តាយ។[193] ម៉្យាងទៀត ប្រសិនបើអ្នកមានអំណាចមេបាដែលត្រូវបានកំណត់ដោយតុលាការ ជាអកុសល ទទួលមរណភាព នោះឪពុក ឬ ម្តាយដែលមិនបានទទួលអំណាចមេបាពីតុលាការ នឹងត្រូវក្លាយជាអ្នកមានអំណាចមេបាវិញម្តង។[194] គួរបញ្ជាក់ផងដែរថា នៅពេលដែលតុលាការធ្វើការដោះស្រាយលើរឿងក្តីរដ្ឋប្បវេណីដែលពាក់ព័ន្ធនឹងឋានៈបុគ្គល ទោះបីជាភាគីលែងលះ មិនបានទាមទារអំណាចមេបានៅក្នុងបណ្តឹងលែងលះ ហើយថែមទាំងមិនបានបង្ហាញឆន្ទៈនៃការបែងចែកអំណាចមេបាលើកូនៗ ក៏តុលាការនៅតែមានសិទ្ធិអំណាចក្នុងការសម្រេចអំពីអំណាចមេបា ទៅតាមឆន្ទានុសិទ្ធិ។[195]

---

[188] មាត្រា៩៨១ នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[189] មាត្រា១០៣៤ នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[190] មាត្រា១០៣៧(១) នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[191] មាត្រា១០៣៧(៣) នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[192] មាត្រា៩ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ, លេខ ៤៤/២៥ អង្គការសហប្រជាជាតិ, ០២ កញ្ញា ១៩៩០។

[193] មាត្រា១០៣៧(២) នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[194] មាត្រា១០៥១(៣) នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[195] មាត្រា២២(១) នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/រកម/០៦១០/០០៨, ០៨ មិថុនា ២០១០។

ទន្ទឹមនឹងនេះផងដែរ ចំពោះឪពុក ឬ ម្ដាយដែលពុំទទួលបានអំណាចមេបាលើកូនតាមការសម្រេចរបស់តុលាការ ក្រោយការលែងលះ ក៏ឪពុក ឬ ម្ដាយនោះនៅតែមានសិទ្ធិក្នុងការចូលជួបកូន និងប្រាស្រ័យទាក់ទងគ្នាជាមួយកូនដដែល។[196] បន្ថែមត្រង់ចំណុចនេះ គឺការចូលជួប និងការប្រាស្រ័យទាក់ទងជាមួយកូនៗ តម្រូវឲ្យឪពុក និងម្ដាយដែលបានលែងលះ ធ្វើការពិភាក្សាគ្នាលើការកំណត់វិធីនៃការណាត់ជួប និងករណីយកិច្ចលើសោហ៊ុយចាំបាច់សម្រាប់កូន ពីភាគីដែលមិនមានអំណាចមេបា។ បើការពិភាក្សាអំពីការកំណត់វិធីនៃការណាត់ជួបកូន និងករណីយកិច្ចលើសោហ៊ុយចាំបាច់កូន ពុំបានលទ្ធផលសម្រេចទេ នោះតុលាការត្រូវសម្រេចកំណត់អំពីវិធីនៃការចូលជួប និងករណីយកិច្ចទាំងនោះ។[197] លើសពីនេះទៅទៀត ឪពុក ឬ ម្ដាយដែលពុំមានអំណាចមេបាលើកូន ក៏នៅតែមានសិទ្ធិក្នុងការទាមទារឲ្យអ្នកដែលមានអំណាចមេបា រាយការណ៍អំពីស្ថានភាពទាំងឡាយរបស់កូន។[198] ការកំណត់ដោយច្បាប់រដ្ឋប្បវេណីត្រង់ចំណុចនេះ បានបង្ហាញឲ្យឃើញថា ទោះបីអាពាហ៍ពិពាហ៍រវាងឪពុក និងម្ដាយ មានការបែកបាក់រវាងគ្នាយ៉ាងណាក្ដី ក៏ប៉ុន្តែចំពោះការបែកបាក់នេះ គោលបំណងនៃច្បាប់ នៅតែឈរលើគោលការណ៍មួយដែលការពារមិនឲ្យមានការប៉ះពាល់ដល់ផលប្រយោជន៍របស់កូនៗ ហើយក៏មិនមានលក្ខណៈចាប់បង្ខំណាមួយដែលនាំឲ្យមានការកាត់ផ្ដាច់ទំនាក់ទំនង ជាពិសេសមនោសញ្ចេតនារវាងឪពុក ឬ ម្ដាយ ជាមួយកូនៗ នោះឡើយ។ ដូច្នេះ ការលែងលះមានអានុភាពត្រឹមតែកាត់ផ្ដាច់ទំនាក់ទំនងរវាងសហព័ទ្ធប៉ុណ្ណោះ ក៏ប៉ុន្តែការលែងលះមិនបានកាត់ផ្ដាច់ទំនាក់ទំនងរវាងឪពុក ឬ ម្ដាយ ជាមួយនឹងកូនៗទេ។ អានុភាពនៃការលែងលះ នៅតែផ្ដល់សិទ្ធិអំណាចមេបាដល់ភាគីឪពុក ឬ ម្ដាយ តាមឆន្ទៈតែភាគីបានព្រមព្រៀងគ្នា ឬ តាមការឆន្ទៈរបស់កូន ឬ តាមការសម្រេចដោយតុលាការ។

#### ៤.២.១.៤. សិទ្ធិលើទ្រព្យសម្បត្តិ

សហព័ទ្ធដែលបានចាប់ដៃកសាងគ្រួសាររួមគ្នា តែងតែមាននូវទ្រព្យសម្បត្តិដែលខិតខំស្វែងរកជាមួយគ្នានៅក្នុងអំឡុងពេលដែលមានចំណងអាពាហ៍ពិពាហ៍ ដូចនេះហើយនៅពេលដែលមានការលែងលះ ប្រាកដណាស់ថា សហព័ទ្ធនឹងត្រូវធ្វើការបែងចែងនូវទ្រព្យសម្បត្តិទាំងនោះ។ អនុលោមតាម ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ប្រព័ន្ធទ្រព្យសម្បត្តិប្ដីប្រពន្ធបានបែងចែកជា ពីរប្រភេទ គឺ៖ ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា និងប្រព័ន្ធទ្រព្យសម្បត្តិកំណត់ដោយច្បាប់។[199] នៅពេលលែងលះ ការបែងចែកទ្រព្យសម្បត្តិ គឺអាស្រ័យលើឆន្ទៈ និងការពិភាក្សារវាងភាគីលែងលះ ហើយតុលាការសម្រេចលើការបែកចែកនោះ ស្របតាមការព្រមព្រៀងរបស់ភាគីក្នុង

[196] មាត្រា១០៤០(១) នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[197] មាត្រា១០៤០(២) និងមាត្រា១០៤០(៣) នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[198] មាត្រា១០៤១ នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[199] មាត្រា៩៦៩ នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

ការបែងចែកទ្រព្យសម្បត្តិក្រោយការលែងលះ។[200] ម្យ៉ាងវិញទៀត នៅពេលមានការលែងលះ តុលាការនឹងធ្វើការបែងចែកទ្រព្យសម្បត្តិ ដោយពឹងផ្អែកលើកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ដែលភាគីលែងលះបានធ្វើទុកជាមុននៅក្រសួងយុត្តិធម៌។ ដូចនេះ តុលាការសម្រេចចំពោះសិទ្ធិ លើទ្រព្យសម្បត្តិក្រោយការលែងលះ ដោយការព្រមព្រៀង នឹងដោយពឹងផ្អែកលើកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ។[201]

យ៉ាងណាមិញ បើភាគីលែងលះ មិនអាចពិភាក្សាគ្នាចុះសម្រុងលើការព្រមព្រៀង បែងចែកទ្រព្យសម្បត្តិ និងមិនបានបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធជាមួយគ្នា នោះតុលាការមានសិទ្ធិបែងចែកទ្រព្យសម្បត្តិទាំងនោះតាមបណ្ដឹងទាមទារ ដោយអនុលោមតាមការកំណត់នៅក្នុងច្បាប់រដ្ឋប្បវេណី។[202] ពាក់ព័ន្ធនឹងការបែងចែកទ្រព្យសម្បត្តិរវាងប្ដីប្រពន្ធនេះ ច្បាប់បានកំណត់ទ្រព្យសម្បត្តិជា ពីរប្រភេទគឺ៖ ទ្រព្យសម្បត្តិរួម និងទ្រព្យសម្បត្តិដោយឡែក។

### ក. ទ្រព្យសម្បត្តិរួម

ទ្រព្យសម្បត្តិរួម គឺសំដៅដល់ទ្រព្យសម្បត្តិទាំងឡាយរបស់សហព័ទ្ធទាំងពីររួមគ្នា (ក្រៅពីទ្រព្យ ដែលបានកំណត់ក្នុងក្រមរដ្ឋប្បវេណីថាជាទ្រព្យសម្បត្តិដោយឡែក) ហើយជាពិសេសទ្រព្យសម្បត្តិរួមនេះ គឺសហព័ទ្ធទទួលបានក្នុងអំឡុងពេលដែលមាននូវចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ជាមួយគ្នា។[203] ចំពោះទ្រព្យសម្បត្តិរួមក្នុងករណីដែលគ្មានការព្រមព្រៀងរវាងភាគីលែងលះនោះទេ តុលាការនឹងធ្វើការបែងចែកទ្រព្យសម្បត្តិរួមនោះជា ២ (ពីរ)ចំណែកស្មើៗគ្នា ទៅឲ្យភាគីប្ដី និងប្រពន្ធដែលបានលែងលះ។[204] ចំណែកឯ ទិដ្ឋភាពនៅក្នុងសង្គមជាក់ស្ដែងវិញ ភាគច្រើនភាគីខាងបុរសជាអ្នកចេញទៅខាងក្រៅផ្ទះ ដើម្បីប្រកបការងារ យកមកទ្រទ្រង់ជីវភាពគ្រួសារ ហើយបន្ទុកកិច្ចការគេហកិច្ចក៏ត្រូវបានធ្លាក់មកលើភាគីខាងប្រពន្ធជាអ្នករ៉ាប់រង។ ដោយយល់ឃើញពីបញ្ហានេះ ទើបច្បាប់បានកំណត់ឲ្យច្បាស់បន្ថែមថា ការងារគេហកិច្ច ត្រូវចាត់ទុកថាមានតម្លៃស្មើការងារខាងក្រៅផ្ទះដែរ។[205] ដំណោះស្រាយនេះបានបង្ហាញឲ្យឃើញ ពីការឲ្យតម្លៃ ស្មើគ្នារវាងបុរស និងស្ត្រី និងបានការពារប្រយោជន៍ស្មើគ្នា រវាងប្រជាជនទាំងពីរភេទ នៅក្នុងសង្គមផងដែរ។ ការលើកកម្ពស់ និងការឲ្យតម្លៃទៅលើស្ត្រីបែបនេះ មានធម្មនុញ្ញភាព ស្របទៅតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា នៅត្រង់បញ្ញត្តិនៃមាត្រា៣៦។ ហេតុនេះ នាំឲ្យពេលមានការលែងលះ ទ្រព្យសម្បត្តិរួមត្រូវតែធ្វើការបែងចែកជាពីរចំណែកស្មើគ្នា។ បន្ថែមត្រង់

[200] មាត្រា៩៨០(១) នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[201] មាត្រា៩៦៩(១) នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[202] មាត្រា៩៦៩(២) នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[203] មាត្រា៩៧៣ នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[204] មាត្រា៩៨០(២) នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[205] មាត្រា៩៨០(៣) នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

ចំណុចនេះ ការងារគេហកិច្ច ត្រូវបានការទទួលស្គាល់ និងផ្តល់តម្លៃដោយច្បាប់ ពីព្រោះការងារគេហកិច្ច និងការងារស្វែងរកប្រាក់ចំណូល គឺសុទ្ធសឹងតែជាកាតព្វកិច្ច ដែលប្តីប្រពន្ធត្រូវសហការគ្នានៅក្នុងរង្វង់គ្រួសារ។

ដោយឡែក តុលាការអាចធ្វើការបែងចែកទ្រព្យសម្បត្តិរួមឲ្យទៅភាគីខាងណាមួយច្រើនជាង លុះត្រាតែតុលាការបានពិចារណា ឃើញលើស្ថានភាពផ្សេងៗមួយចំនួនតាមការស្នើសុំរបស់ភាគី ស្របតាមរយៈភស្តុតាងដែលភាគីបានដាក់មកឲ្យតុលាការពិនិត្យ។ ស្ថានភាពទាំងនោះមានដូចជា ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗលើទ្រព្យសម្បត្តិរួម ឬ ការធ្វើលទ្ធកម្មផ្សេងៗ ក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ឬ សកម្មភាពថែរក្សា និងការខិតខំបង្កបង្កើនទ្រព្យ ក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ឬ កម្រិតនៃការរស់នៅរបស់ភាគី ឬ ស្ថានភាពផ្ទាល់ខ្លួនរបស់ភាគីពាក់ព័ន្ធនឹងអាយុ សុខភាពផ្លូវកាយ និងផ្លូវចិត្ត របស់ភាគីជាដើម។ ស្ថានភាពទាំងអស់ខាងលើនេះ នឹងមានឥទ្ធិពលដល់ការសម្រេចលើទំហំនៃការទទួលបានទ្រព្យសម្បត្តិរួម តាមរយៈការបែងចែកដោយតុលាការ។[206]

### ខ. ប្រព័ន្ធទ្រព្យសម្បត្តិដោយឡែក

ទ្រព្យសម្បត្តិដោយឡែក គឺសំដៅដល់ទ្រព្យដែលជាកម្មសិទ្ធិ របស់សហព័ទ្ធតែម្ខាងៗ។ ទ្រព្យសម្បត្តិដោយឡែកមានដូចជា៖ ទ្រព្យសម្បត្តិដែលសហព័ទ្ធមានមុនពេលមានចំណងអាពាហ៍ពិពាហ៍ ទ្រព្យសម្បត្តិដែលទទួលបានដោយប្រទានកម្ម សន្តតិកម្ម អច្ច័យទានក្នុងអំឡុងពេលរៀបអាពាហ៍ពិពាហ៍ ឬ ទ្រព្យសម្បត្តិដែលជាតម្លៃតប ដែលទទួលបានពីការចាត់ចែងទ្រព្យសម្បត្តិដោយឡែកទាំងនោះ។[207] នៅពេលដែលមានការលែងលះទ្រព្យសម្បត្តិដោយឡែក មានលក្ខណៈសាមញ្ញ និងមិនស្មុគស្មាញក្នុងការបែងចែក ដូចការបែងចែកទ្រព្យសម្បត្តិរួមឡើយ ពីព្រោះភាគីមានសិទ្ធិទទួលបាននូវទ្រព្យសម្បត្តិដោយឡែករបស់ខ្លួនទាំងអស់ ត្រឡប់ទៅវិញរៀងៗខ្លួន។ ជាមួយគ្នានោះផងដែរ ពាក់ព័ន្ធនឹងការអាស្រ័យនៅលើទ្រព្យសម្បត្តិដោយឡែក របស់សហព័ទ្ធម្ខាងទៀត ដែលតែងកើតមានក្នុងសង្គមជាក់ស្តែង គឺសិទ្ធិអាស្រ័យនៅនោះ នឹងត្រូវបញ្ចប់នៅពេលភាគីបញ្ចប់ឋានៈជាសហព័ទ្ធនឹងគ្នា តាមរយៈការចូលជាស្ថាពរនៃសាលក្រមលែងលះ។[208] ពិសេសបន្ថែមលើចំណុច នៃការបែងចែកទ្រព្យសម្បត្តិក្រោយការលែងលះនេះ ច្បាប់រដ្ឋប្បវេណីបានកំណត់ថានៅពេលមានអាពាហ៍ពិពាហ៍ សហព័ទ្ធគឺជាសន្តតិជនជានិច្ច[209] តែនៅពេលមានការលែងលះចូលជាស្ថាពរ បានសេចក្តីថា ភាគីលែងមានឋានៈជាសហព័ទ្ធនឹងគ្នាតទៅទៀត ថែមទាំងត្រូវបាត់បង់សិទ្ធិជាសន្តតិជនជានិច្ចក្នុងការទទួលបាននូវចំណែកមរតករបស់ភាគីម្ខាងទៀតផងដែរ។

---

[206] មាត្រា៩៨០(២) ចំណុច(ខ) នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[207] មាត្រា៩៧២ នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[208] មាត្រា៩៧៧(២) នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[209] មាត្រា១១៦១ នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

#### ៤.២.១.៥ សិទ្ធិក្នុងការបង្កើតចំណងអាពាហ៍ពិពាហ៍ថ្មី

អានុភាពនៃការលែងលះ បានផ្តល់សិទ្ធិដល់ភាគី ក្នុងការបង្កើតនូវចំណងអាពាហ៍ពិពាហ៍ថ្មី តាមឆន្ទៈរបស់ភាគី។ នៅក្នុងអំឡុងពេលមានចំណងអាពាហ៍ពិពាហ៍ជាមួយគ្នា ភាគីត្រូវបានហាមឃាត់ដោយច្បាប់ មិនឲ្យមានចំណងអាពាហ៍ពិពាហ៍បន្ថែមជាមួយនឹងបុគ្គលដទៃផ្សេងទៀតឡើយ។[210] នៅពេលមានសាលក្រមលែងលះ ដែលបានចូលជាស្ថាពរ បានសេចក្តីថា ភាគីមានសិទ្ធិសេរីភាពឡើងវិញ ក្នុងការរៀបអាពាហ៍ពិពាហ៍ ដោយស្របច្បាប់ម្តងទៀត។ ទន្ទឹមនឹងនេះ រយៈពេលដែលភាគីខាងបុរស មានសិទ្ធិក្នុងការរៀបអាពាហ៍ពិពាហ៍ថ្មី មិនត្រូវបានដាក់កំហិតដោយច្បាប់រដ្ឋប្បវេណីឡើយ។ រីឯខាងនារីវិញ ច្បាប់រដ្ឋប្បវេណីបានកំណត់អំពី រយៈពេលដែលនារីមានសិទ្ធិក្នុងការរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ម្តងទៀត។ បន្ទាប់ពីលែងលះ នារីត្រូវរង់ចាំរយៈពេល ១២០ថ្ងៃ ទើបអាចរៀបអាពាហ៍ពិពាហ៍ថ្មីបាន។ ការរៀបអាពាហ៍ពិពាហ៍ថ្មីនេះ ក៏អាចធ្វើឡើងបានមុនរយៈពេលកំណត់ ១២០ថ្ងៃ កាលបើមាន លិខិតបញ្ជាក់ពីគ្រូពេទ្យថា នារីនោះគ្មានផ្ទៃពោះ។[211] ការកំណត់រយៈពេលក្នុងការរៀបអាពាហ៍ពិពាហ៍ថ្មីបែបនេះ គឺមិនបានបំពានដល់សិទ្ធិរបស់នារីឡើយ ដោយមូលហេតុថា ច្បាប់កំណត់ដូចនេះ គឺដើម្បីការពារករណីកុំឲ្យមានការយល់ច្រឡំ លើទំនាក់ទំនងញាតិរបស់ទារកក្នុងផ្ទៃម្តាយ ពោលគឺកុំឲ្យមានការពិបាកក្នុងការបែងចែកអំពីបុរសដែលជាឪពុករបស់ទារក។ តែក្នុងករណីដែល ស្ត្រីមានការបញ្ជាក់ច្បាស់លាស់ថាគ្មានផ្ទៃពោះ គឺមានសិទ្ធិរៀបចំណងអាពាហ៍ពិពាហ៍ថ្មី។ ជារួមក្រោយការលែងលះ ភាគីទាំងសងខាង សុទ្ធតែមានសិទ្ធិសេរីភាពឡើងវិញ ក្នុងការរៀបអាពាហ៍ពិពាហ៍សារជាថ្មីម្តងទៀត។

#### ៤.២.១.៦ ការបញ្ចប់ករណីយកិច្ចសហព័ទ្ធ

ជាការពិតណាស់ ក្នុងអំឡុងពេលរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា សហព័ទ្ធនឹងត្រូវមានករណីយកិច្ចរួមគ្នា។ ករណីយកិច្ចរួមគ្នាទាំងនោះមានដូចជា៖ ករណីយកិច្ចរួមរស់ជាមួយគ្នា, ករណីយកិច្ចសហការគ្នា, និងករណីយកិច្ចជួយសង្គ្រោះគ្នាទៅវិញទៅមក។[212] ករណីយកិច្ចរួមរស់ជាមួយគ្នា គឺសំដៅដល់ការរស់នៅក្រោមដំបូលតែមួយ រស់នៅលក្ខណៈជាប្តីប្រពន្ធនឹងគ្នា។ ករណីយកិច្ចសហការគ្នា គឺការជួយកសាងក្រុមគ្រួសារ ឲ្យមានភាពរីកចម្រើនទៅមុខ ជាពិសេសនោះគឺ សហការគ្នាក្នុងការចិញ្ចឹមបីបាច់ថែរក្សាកូន និងផ្ទះសម្បែង។ ករណីយកិច្ចជួយសង្គ្រោះគ្នាទៅវិញទៅមក គឺសំដៅលើប្តី និងប្រពន្ធត្រូវជួយដោះស្រាយបញ្ហាជាដើម។ ទាំងនេះ គឺជា ករណីយកិច្ចដែលសហព័ទ្ធ គួរធ្វើពេលកំពុងមានចំណងអាពាហ៍ពិពាហ៍។ ដូច្នេះនៅពេលភាគីលែងលះ បណ្តាលឲ្យភាគីរួចផុតពីករណីយកិច្ចសហព័ទ្ធទាំងឡាយនោះ ដោយសារអានុភាពនៃសាលក្រម ឬ សាលដីកាលែងលះស្ថាពរ។

---

[210] មាត្រា៩៤៩ នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[211] មាត្រា៩៥០ នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[212] មាត្រា៩៦៦ នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

### ៤.២.២. កាតព្វកិច្ចបន្សល់ក្រោយការលែងលះ

ការលែងលះ គឺជាការបញ្ចប់ទំនាក់ទំនងគតិយុត្តរវាងសហព័ទ្ធដែលនៅរស់។ ទោះបីទំនាក់ទំនងគតិយុត្តនេះត្រូវបានបញ្ចប់ក៏ដោយក្តី ប៉ុន្តែអានុភាពនៃការលែងលះ បានបន្សល់ទុកនូវសិទ្ធិ និងកាតព្វកិច្ចដល់គូភាគីដដែល។ ពាក់ព័ន្ធនឹងការបន្សល់នូវកាតព្វកិច្ចនេះ ភាគីក៏មានសិទ្ធិក្នុងការពិភាក្សាគ្នា លើការបែងចែកកាតព្វកិច្ចដូចការពិភាក្សាលើការបែងចែកសិទ្ធិដែរ។ ក្នុងករណីដែលភាគីមានការព្រមព្រៀងគ្នា លើការបែងចែកកាតព្វកិច្ចនោះតុលាការរដ្ឋប្បវេណី នឹងសម្រេចទៅតាមឆន្ទៈរបស់ភាគី។តែផ្ទុយមកវិញ ប្រសិនបើភាគីដែលលែងលះមិនអាចពិភាក្សាគ្នាបានសម្រេចលើការបែងចែកកាតព្វកិច្ចនាំឲ្យការបែងចែកនេះ នឹងត្រូវបានសម្រេចដោយតុលាការ។

#### ៤.២.២.១. អាហារកាតព្វកិច្ច

អាហារកាតព្វកិច្ច គឺសំដៅដល់កិច្ចដែលត្រូវបំពេញតាមច្បាប់ ឬ តាមសេចក្តីសម្រេចរបស់តុលាការ ដែលតម្រូវឲ្យបុគ្គលណាម្នាក់ ឬ ច្រើននាក់ត្រូវបង់ប្រាក់ ឬ ទ្រព្យដើម្បីទៅផ្គត់ផ្គង់ជីវភាពរស់នៅ របស់បុគ្គលផ្សេងទៀតដែលបុគ្គលនោះមានទំនាក់ទំនងញាតិនឹងគ្នា។[213] អាហារកាតព្វកិច្ចនៅក្នុងការលែងលះ ភាគីអាចធ្វើការពិភាក្សាព្រមព្រៀងគ្នា លើកាតព្វកិច្ចនេះ ក៏ប៉ុន្តែប្រសិនបើភាគីមិនអាចពិភាក្សាលើការបែងចែកកាតព្វកិច្ចនេះឲ្យបានសម្រេច ភាគីអាចដាក់ជាចំណុចទាមទារបន្ទាប់បន្សំក្នុងបណ្តឹងលែងលះ ហើយឲ្យតុលាការធ្វើការសម្រេចឲ្យបាន។[214] អាហារកាតព្វកិច្ចដែលបន្សល់ក្រោយការលែងលះមានដូចជា៖ អាហារកាតព្វកិច្ចចំពោះកូន និងអាហារកាតព្វកិច្ចចំពោះសហព័ទ្ធក្នុងករណីពិសេស។

##### ក. អាហារកាតព្វកិច្ចចំពោះកូន

ការលែងលះបានធ្វើឲ្យទំនាក់ទំនងគតិយុត្តរវាងឪពុក និងម្តាយបែកបាក់គ្នា តែទោះបីជាយ៉ាងនោះក៏ដោយឪពុក និងម្តាយដែលលែងលះ នៅតែត្រូវចិញ្ចឹមកូន រហូតដល់កូនពេញវ័យមាននីតិភាព។ ឪពុក ឬ ម្តាយ ដែលមានអំណាចមេបាទៅលើកូន ត្រូវមានកាតព្វកិច្ចចិញ្ចឹមបីបាច់ថែរក្សាកូន និងជួយគ្រប់គ្រងលើកូន។[215] ចំណែកឪពុក ឬ ម្តាយ ដែលមិនមានអំណាចមេបាលើកូនវិញ ក៏ត្រូវមានកាតព្វកិច្ចទទួលបន្ទុកលើសោហ៊ុយចាំបាច់ក្នុងការចិញ្ចឹមបីបាច់ថែរក្សាកូនបង្កើតរបស់ខ្លួនផងដែរ។[216] ដូចនេះ ក្រោយការលែងលះ ឪពុក និងម្តាយនៅតែត្រូវមានកាតព្វកិច្ចក្នុងការផ្តល់អាហារកាតព្វកិច្ចដល់កូនរបស់ខ្លួនដដែល ពីព្រោះឪពុក ឬ ម្តាយដែលបានលែងលះរួចហើយនោះ គឺនៅតែជាញាតិខ្សែផ្ទាល់របស់កូនជានិច្ច។[217]

---

[213] សន្ទានុក្រមលេខ២០២ នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[214] មាត្រា១១៤២ នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[215] មាត្រា១០៣៤ នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[216] មាត្រា១០៤០(១) នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[217] មាត្រា១១៤០ នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

នៅក្នុងការអនុវត្តជាក់ស្តែង ប្រសិនបើភាគីខាងឪពុក ឬម្តាយ បដិសេធមិនផ្តល់អាហារកាតព្វកិច្ចនេះដល់កូនរបស់ខ្លួនទេ នោះភាគីម្ខាងទៀតអាចដាក់បណ្តឹងទាមទារអាហារកាតព្វកិច្ចទៅតុលាការបាន ដើម្បីទាមទារឲ្យភាគីម្ខាងទៀតផ្តល់នូវអាហារកាតព្វកិច្ចដល់កូន។ យ៉ាងណាមិញនៅក្នុងសង្គមបច្ចុប្បន្ន ក៏មានករណីខ្លះទៀតភាគីបដិសេធមិនព្រមទទួលយកអាហារកាតព្វកិច្ច ក្នុងការជួយចិញ្ចឹមកូន ដោយសារតែ ភាគីមានលទ្ធភាពគ្រប់គ្រាន់ក្នុងការចិញ្ចឹមបីបាច់ថែរក្សា និងផ្គត់ផ្គង់កូន ពិសេសនោះ គឺមិនចង់ឲ្យមានទំនាក់ទំនង វែងឆ្ងាយបន្តទៀត ជាមួយអតីតសហព័ទ្ធ។ នៅក្នុងករណីបែបនេះ ការសម្រេចរបស់តុលាការក្នុងការអនុវត្តជាក់ស្តែង ក៏មិនបានចាប់បង្ខំឲ្យ ភាគីត្រូវតែទទួលយកអាហារកាតព្វកិច្ចនោះដែរ។

**ខ. អាហារកាតព្វកិច្ចចំពោះសហព័ទ្ធ**

អាហារកាតព្វកិច្ចចំពោះសហព័ទ្ធក្រោយការលែងលះនេះ មិនមានបញ្ញត្តិជាថ្មីម្តងទៀតនៅក្នុងក្រមរដ្ឋប្បវេណីបច្ចុប្បន្ននេះទេ តែកាតព្វកិច្ចនេះមានបញ្ញត្តិ នៅក្នុងច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ក្នុងមាត្រា ៧៦។ ជាពិសេសបញ្ញត្តិនៃមាត្រា ៧៦ របស់ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារនេះ មិនទាន់និរាករណ៍នៅឡើយទេ។[218] ស្មារតីច្បាប់បានកំណត់ថា ភាគីណាម្ខាងដែលគ្មានកំហុស ហើយភាគីនោះ នឹងត្រូវប្រឈមជាមួយបញ្ហាសេដ្ឋកិច្ចធ្ងន់ធ្ងរក្រោយការលែងលះ នោះភាគីដែលរងគ្រោះអាចទាមទារឲ្យ អតីតសហព័ទ្ធបំពេញនូវអាហារកាតព្វកិច្ចដល់ខ្លួនបាន។ ការសម្រេចលើការទាមទារនេះ គឺអាស្រ័យលើ ការពិចារណាលើស្ថានភាពជាក់ស្តែងរបស់ភាគីរងគ្រោះ ជាមួយនឹងភស្តុតាងដែលបានដាក់ជូនមកតុលាការ។ គួរបញ្ជាក់ផងដែរថា អាហារកាតព្វកិច្ចចំពោះកូន និងអាហារកាព្វកិច្ចចំពោះសហព័ទ្ធទាំងនេះ គឺសុទ្ធតែជាកាតព្វកិច្ចដែលបានបន្សល់ទុកនៅក្រោយការលែងលះ។

**៤.២.២.២. កាតព្វកិច្ចសងសំណងជម្ងឺចិត្ត**

កាតព្វកិច្ចសងសំណងជម្ងឺចិត្ត ត្រង់ចំណុចនេះ គឺចង់សំដៅដល់ការសំណងរដ្ឋប្បវេណីទាំងឡាយណាដែលបណ្តាលមកពីអំពើអនីត្យានុកូល នៅក្នុងការលែងលះ។ ក្នុងករណីដែលភាគីម្ខាងនៃការលែងលះគ្មានកំហុសទាល់តែសោះ ហើយភាគីនោះត្រូវរងនូវព្យាសនកម្មពីភាគីម្ខាងទៀត ទាំងផ្លូវកាយ ផ្លូវចិត្ត និងផ្នែកសំភារៈ នោះភាគីដែលរងគ្រោះមានសិទ្ធិ ក្នុងការប្តឹងទាមទារឲ្យមានការសងនូវសំណងជម្ងឺចិត្ត និង សំណងលើការខូចខាតផ្សេងៗ។ ការប្តឹងទាមទារសំណងខូចខាត ដែលមានជាប់ពាក់ព័ន្ធនឹងបណ្តឹងលែងលះ ភាគីមានសិទ្ធិក្នុងការបញ្ចូលចំណុចទាំងនោះនៅក្នុងបណ្តឹងតែមួយទៅតុលាការ។[219] ភាគីលែងលះ មានកាតព្វកិច្ចក្នុងការសងសំណងជម្ងឺចិត្ត កាលបើតុលាការសម្រេចឲ្យទទួលខុសត្រូវ លើកាតព្វកិច្ចនោះដោយសាលក្រមស្ថាពរ។

[218] មាត្រា៧៨ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី, លេខ នស/រកម/០៥១១/០០៧, ៣១ ឧសភា ២០១១។

[219] មាត្រា១១ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/រកម/០៦១០/០០៨, ០៨ មិថុនា ២០១០។

**៤.២.២.៣. កាតព្វកិច្ចចំពោះតតិយជន**

កាតព្វកិច្ចចំពោះតតិយជន គឺសំដៅលើការដែលសហព័ទ្ធត្រូវទទួលខុសត្រូវបំពេញកាតព្វកិច្ចជូនជនដទៃទៀតដែលមានឋានៈជា ម្ចាស់បំណុល ដែលត្រូវបានច្បាប់ទទួលស្គាល់។ សហព័ទ្ធទាំងពីរ ត្រូវសាមគ្គីគ្នា ក្នុងការទទួលខុសត្រូវ ចំពោះកាតព្វកិច្ច និងករណីយកិច្ចផ្សេងៗ ដែលសហព័ទ្ធបានព្រមព្រៀង ជាមួយតតិយជន ដែលបានធ្វើឡើងក្នុងទម្រង់ជាលាយលក្ខណ៍អក្សរ នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។[220] ត្រង់ចំណុចនេះ បានសេចក្ដីថា ទោះបីភាគីមានការលែងលះជាមួយគ្នាក៏ដោយ តែភាគីទាំងពីរនៅតែត្រូវមានកាតព្វកិច្ចទទួលខុសត្រូវចំពោះតតិយជនដែលជាម្ចាស់បំណុល លើបំណុលទាំងឡាយណា ដែលបានជំពាក់នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ជាមួយគ្នា។ បើបំណុលនោះ ជាបំណុលរួម នោះភាគីត្រូវទទួលខុសត្រូវដោយសាមគ្គីភាព ហើយក្នុងករណីបំណុលនោះ ជាបំណុលដោយឡែក នោះភាគីម្ខាងៗ ត្រូវទទួលខុសត្រូវលើបំណុលនោះរៀងៗខ្លួន។ សរុបមក ថ្វីត្បិតតែចំណងអាពាហ៍ពិពាហ៍ត្រូវបានបញ្ចប់ដោយការលែងលះក៏ដោយក្ដី តែអានុភាពនៃការលែងលះមិននាំឲ្យបញ្ចប់នូវកាតព្វកិច្ចមួយចំនួន ដូចដែលបានរៀបរាប់ខាងលើនេះ។

[220] មាត្រា៩៧៥(ខ) នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ជាទីអវសានតៃប្រធានបទនេះ គឺការសរុបនូវខ្លឹមសារដែលមាននៅក្នុងប្រធានបទសារណានេះទាំងមូល។ ជាក់ស្តែង បន្ទាប់ពីបានសិក្សាស្រាវជ្រាវទៅលើប្រធានបទ «**ការលែងលះរវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរនៅកម្ពុជា**» រួចមក បានបង្ហាញថា ចំណុចចាប់ផ្តើមដែលនាំឲ្យមានការលែងលះ គឺមូលហេតុដែលកើតឡើងពីបញ្ហាដែលនាំឲ្យសហព័ទ្ធប្រាស់ចាក ពីកម្មវត្ថុនៃការថែរក្សាចំណងអាពាហ៍ពិពាហ៍ឲ្យបានឋិតថេរគង់វង្ស។ នៅពេលដែលសហព័ទ្ធរស់នៅបាត់បង់មនោសញ្ចេតនា និងរស់នៅមិនចុះសម្រុងគ្នា នោះនាំឲ្យមានការលែងលះកើតឡើង។ សហព័ទ្ធមានសិទ្ធិក្នុងការរំលាយចំណងអាពាហ៍ពិពាហ៍នោះទៅវិញ ដោយការទាមទារលែងលះនៅតុលាការ។ សហព័ទ្ធ ត្រូវបង្ហាញតុលាការឲ្យឃើញពីកម្មវត្ថុ និងមូលហេតុនាំឲ្យកើតមានការលែងលះ។ មូលហេតុនៃការលែងលះអាចមានច្រើនប្រភេទ តែមូលហេតុទាំងនោះ ត្រូវតែមានលក្ខណៈសមហេតុសមផល ដូចដែលច្បាប់រដ្ឋប្បវេណីបានកំណត់នៅក្នុងមាត្រា ៩៧៨។ តាមរយៈការស្រាវជ្រាវក្នុងប្រធានបទនេះ ការលែងលះនៅក្នុងប្រទេសកម្ពុជា ចែកចេញជាពីរប្រភេទគឺ ការលែងលះដោយការព្រមព្រៀង និងការលែងលះដោយគ្មានការព្រមព្រៀង។ ការលែងលះដោយមានការព្រមព្រៀង គឺជាការលែងលះដែលសហព័ទ្ធទាំងពីរមានឆន្ទៈស្របគ្នា ក្នុងការព្រមព្រៀងលែងលះ ហើយថែមទាំងបានព្រមព្រៀងគ្នារួចទាំងស្រុង ក្នុងការកំណត់អំពីការបែងចែកសិទ្ធិ និងកាតព្វកិច្ចផ្សេងៗទៀតក្រោយការលែងលះ។ តែផ្ទុយមកវិញ ប្រសិនបើភាគីមានការខ្វែងគំនិតគ្នា មិនអាចពិភាក្សាគ្នាបានទេ នៅក្នុងការទាមទារលែងលះ ដោយទោះបីជាការខ្វែងគំនិតនោះតែផ្នែកណាមួយ ឬ ទាំងស្រុង នាំឲ្យការទាមទារលែងលះនោះ ច្បាប់ចាត់កំណត់ថាជាការលែងលះដោយគ្មានការព្រមព្រៀង។ ចំពោះការលែងលះដោយគ្មានការព្រមព្រៀងនេះ គឺជាការប្តឹងទាមទារលែងលះ ដោយភាគីមានការខ្វែងគំនិតគ្នានៅផ្នែកណាមួយ ឬទាំងស្រុងនៃការបែងចែក និងការកាត់ផ្តាច់ទំនាក់ទំនងគតិយុត្ត ហើយទាមទារឲ្យមានការសម្រេចដោះស្រាយពីតុលាការ។

ចំពោះនីតិវិធីក្នុងការដោះស្រាយការលែងលះនៅកម្ពុជាវិញ គឺត្រូវអនុលោមទៅតាមនីតិវិធីរដ្ឋប្បវេណី គួបផ្សំជាមួយនឹងច្បាប់នីតិវិធីមួយចំនួនទៀតអាស្រ័យលើលក្ខខណ្ឌនៃការទាមទារលែងលះ។ បទដ្ឋានគតិយុត្តដែលត្រូវអនុលោមរួមជាមួយក្រមនីតិវិធីរដ្ឋប្បវេណី សម្រាប់ដោះស្រាយការលែងលះនៅកម្ពុជាមានដូចជា៖ ច្បាប់ស្តីពីនីតិវិធីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ២០១០ សម្រាប់ដោះស្រាយការលែងលះដោយការព្រមព្រៀង និងច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ឆ្នាំ២០១០ សម្រាប់ការដោះស្រាយ នៅក្នុងនីតិវិធីនៃលែងលះដោយគ្មានការព្រមព្រៀង។ នីតិវិធីនៅក្នុងការដោះស្រាយការលែងលះដោយការព្រមព្រៀង មិនមានលក្ខណៈស្មុគស្មាញ ដូចការលែងលះដោយគ្មានការព្រមព្រៀងឡើយ ដោយសារតែភាគីបានឯកភាពគ្នាជាមុន ក្នុងការកាត់ផ្តាច់ទំនាក់ទំនងគតិយុត្ត និងការព្រមព្រៀងលើការបែងចែក សិទ្ធិអំណាចមេបា ទ្រព្យសម្បត្តិ អាហារកាតព្វកិច្ច

និងករណីយកិច្ចផ្សេងៗទៀតជាច្រើន។ ជាចុងក្រោយ បន្ទាប់ពីតុលាការបានបញ្ចប់នីតិវិធីក្នុងការលែងលះដោយចេញនូវសេចក្ដីសម្រេច ឬ សាលក្រម នោះបង្កើតឲ្យមានអានុភាពនៃការលែងលះ។ អានុភាពនៃការលែងលះគឺមានពាក់ព័ន្ធនឹងការបែងចែកផ្សេងៗ នៅក្រោយការលែងលះចំពោះភាគី។ ការកំណត់លើការបែងចែកទាំងនោះ តុលាការនឹងសម្រេចស្របតាមឆន្ទៈព្រមព្រៀងរបស់ភាគី។ តែផ្ទុយមកវិញ ប្រសិនបើភាគីមិនអាចពិភាក្សាគ្នាបានសម្រេច លើការបែងចែកផ្សេងទៀតទេ នោះតុលាការនឹងសម្រេចបែងចែកសិទ្ធិ និងកាតព្វកិច្ចទាំងនោះអាស្រ័យលើការកំណត់នៅក្នុងបញ្ញត្តិច្បាប់រដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។ គួរបញ្ជាក់ផងដែរមិនមែនរាល់ការប្ដឹងទាមទារលែងលះទាំងអស់ សុទ្ធតែទទួលបានការឯកភាពសម្រេចឲ្យភាគីលែងលះដោយតុលាការឡើយ។ នៅក្នុងករណីខ្លះ តុលាការសម្រេចបដិសេធមិនសម្រេចឲ្យមានការលែងលះ ដោយយល់ឃើញថា ការលែងលះនោះមានភាពមិនសុចរិត ឬ ការរកឃើញនូវឆន្ទៈមិនពិតប្រាកដរបស់ភាគីដែលទាមទារលែងលះ។ ចំពោះភាគីដែលមិនសុខចិត្តនឹង សេចក្ដីសម្រេចរបស់តុលាការដើម ត្រង់ចំណុចណាមួយ ឬទាំងស្រុង ក៏មានសិទ្ធិក្នុងការធ្វើបណ្ដឹងឧបាស្រ័យបន្តទៅតុលាការជាន់ខ្ពស់ផងដែរ។

សរុបសេចក្ដីមក ទាំងអស់ខាងលើនេះគឺជាការបង្ហាញអំពីលំហូរនីតិវិធីនៃការលែងលះរវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ នៅកម្ពុជា ចាប់តាំងពីពេលដែលទំនាក់ទំនងអាពាហ៍ពិពាហ៍នោះកើតមានមូលហេតុបង្កឲ្យមានការលែងលះ រហូតដល់ការអនុវត្តលំហូរនីតិវិធីនៃការលែងលះ និងការសម្រេចសេចក្ដីដោយតុលាការចំពោះការលែងលះនៅកម្ពុជា។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីបានឆ្លងកាត់ការសិក្សាស្រាវជ្រាវអំពីប្រធានបទ «**ការលែងលះរវាងពលរដ្ឋខ្មែរ និង ពលរដ្ឋខ្មែរ នៅកម្ពុជា**» រួចមក នាងខ្ញុំសង្កេតឃើញថា ការលែងលះ គឺមានលក្ខណៈស្មុគស្មាញច្រើនជាង ការរៀបចំអាពាហ៍ពិពាហ៍ទៅទៀត មិនតែប៉ុណ្ណោះការលែងលះថែមទាំងបានបន្សល់នូវគុណវិបត្តិជាច្រើនដល់ សង្គមជាតិ ដល់ភាគីលែងលះ និងដល់បុគ្គលពាក់ព័ន្ធផ្សេងទៀត ជាពិសេសគឺកូនៗ របស់សហព័ទ្ធដែល សម្រេចចិត្តលែងលះគ្នា។ ការខាតបង់ ដែលបង្កមកពីការលែងលះមានច្រើនយ៉ាងដូចជា៖ ការខាតបង់ទ្រព្យ សម្បត្តិ ការខាតពេលវេលា ការបាត់បង់សុភមង្គល ពិសេសគឺការប៉ះពាល់ទៅដល់កិត្តិយសក្រុមគ្រួសារ។ ទាំង នេះ ជាមូលហេតុដែលនាំឲ្យនាងខ្ញុំមានសំណូមពរចំនួន បី ទាក់ទងនឹងការលែងលះរវាងពលរដ្ឋខ្មែរ នៅកម្ពុជា។

សំណូមពរទី១ ៖ គឺនាងខ្ញុំសូមសំណូមពរឲ្យ ពលរដ្ឋខ្មែរ ទាំងអស់ដែលរៀបអាពាហ៍ពិពាហ៍គប្បីមានការ ខន្តី យោគយល់ និងអធ្យាស្រ័យដល់គ្នាឲ្យបានច្រើន ព្រមទាំងមេត្តាគិតគូរឲ្យបានវែងឆ្ងាយមុននឹងសម្រេចចិត្ត លែងលះ ពីព្រោះថា ការលែងលះបន្សល់ទុកនូវគុណវិបត្តិ និងព្យាសនកម្មជាច្រើន។

សំណូមពរទី២ ៖ គឺ ទោះបីជាប្រទេសកម្ពុជាយើង មាននូវច្បាប់គ្រប់គ្រាន់ក្នុងការដោះស្រាយនៅពេល មានការលែងលះរួចហើយក្តី ប៉ុន្តែនាងខ្ញុំសូមសំណូមពរ ឲ្យស្ថាប័នពាក់ព័ន្ធទាំងអស់ ធ្វើការផ្សព្វផ្សាយដល់ ពលរដ្ឋខ្មែរ ឲ្យមានការយល់ដឹងកាន់តែច្បាស់ និងទូលំទូលាយបន្ថែមទៀតអំពីការលែងលះ ព្រោះបច្ចុប្បន្ននេះ នៅមានប្រជាពលរដ្ឋខ្មែរមួយចំនួន នៅពុំទាន់បានយល់ច្បាស់ ឬ នៅមានការ ភាន់ច្រឡំនៅឡើយ។

ចំពោះសំណូមពរទី៣ ដែលជាសំណូមពរចុងក្រោយ នៅក្នុងសារណានេះ ៖ គឺនាងខ្ញុំសូមសំណូមពរទៅ ដល់ស្ថាប័នមានសមត្ថកិច្ច គឺស្ថាប័នតុលាការដែលមានយុត្តាធិការទៅលើរឿងក្តីលែងលះ សូមធ្វើការដឹកនាំ នីតិវិធី និងដោះស្រាយរឿងក្តីលែងលះ ឲ្យប្រព្រឹត្តទៅបានលឿន ពីព្រោះថា ចំណាត់ការយឺតយ៉ាវអាចនឹងបង្កឲ្យ កើតមានផលប៉ះពាល់កាន់តែច្រើន ទៅលើប្រយោជន៍ភាគី ជាពិសេសនោះ គឺប៉ះពាល់ដល់ផលប្រយោជន៍របស់ កូនៗ ដែលកំពុងរងចាំការសម្រេចអំពីអំណាចមេបា និងការផ្តល់នូវអាហារកាតព្វកិច្ច។

# ឯកសារយោង

# ឯកសារយោង

## ១. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា, ឆ្នាំ១៩៩៣។
- អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ, ឆ្នាំ១៩៩០។
- ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, ឆ្នាំ២០០៦។
- ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, ឆ្នាំ២០០៧។
- ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, ឆ្នាំ១៩៨៩។
- ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ, ឆ្នាំ២០០៥។
- ច្បាប់ស្តីពីឯកពន្ធភាព, ឆ្នាំ២០០៦។
- ច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, ឆ្នាំ២០១០។
- ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល, ឆ្នាំ២០១០។
- ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី, ឆ្នាំ២០១១។
- ច្បាប់ស្តីពីសញ្ជាតិ, ឆ្នាំ២០១៨។
- អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន, ឆ្នាំ២០០០។
- ប្រកាសលេខ ២៨ កយប្រក/០៧ នៃទីស្តីការក្រសួងយុត្តិធម៌, ឆ្នាំ២០០៧។
- ប្រកាសលេខ ៥៤ កយប្រក/០៩ ស្តីពីប្រភេទពាក្យសុំដែលតម្រូវឲ្យបង់ពន្ធ, ឆ្នាំ២០០៩។
- ប្រកាស ស្តីពី នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ, ឆ្នាំ២០១៣។

## ២. សៀវភៅ និងស្នាដៃនិពន្ធ

- ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រជាជាតិជប៉ុន (JICA) និងក្រសួងយុត្តិធម៌, ឆ្នាំ២០០៨, សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី។
- ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រជាជាតិជប៉ុន (JICA) និងក្រសួងយុត្តិធម៌, ឆ្នាំ២០១២, សេចក្តីពន្យល់អំពីក្រមរដ្ឋប្បវេណី។
- លោកសាស្ត្រាចារ្យ ហ៊ី សោភា, សៀវភៅនីតិវិធីរដ្ឋប្បវេណី។
- លោកសាស្ត្រាចារ្យ កេត សុជាតិ, ឆ្នាំ២០១៧, សៀវភៅសង្ខេបលំហូរនីតិវិធីរដ្ឋប្បវេណី។
- លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត, ឆ្នាំ២០១៧, សៀវភៅជំនួយស្មារតីនីតិគ្រួសារ។

## ៣. ប្រភពផ្សេងៗ

- វចនានុក្រម សម្ដេចព្រះសង្ឃរាជ ជួន ណាត។
- សន្ធានុក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា។
- សាលាត្រាជូ, អត្ថបទបោះផ្សាយ, ដកស្រង់ចេញពី https://salatraju.com/Publications/Published%20Articles
- Freshnews, យល់ដឹងផ្នែកច្បាប់៖ នីតិវិធីក្នុងការលែងលះ, ដកស្រង់ចេញពី http://freshnewsasia.com/index.php/en/localnews/97443-2018-09-02-03-33-22.html ។
- លោកជំទាវ ងួន មករា, បទសម្ភាសន៍ដោយ ទូរទស្សន៍ BTV, កម្មវិធីច្បាប់៖ ការលែងលះ, ឆ្នាំ២០១៧។

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធទី១ ៖ ក្រមនីតិវិធីរដ្ឋប្បវេណីពាក់ព័ន្ធនឹងការលែងលះ** 

- ប្រកាសលេខ ២៨ កយប្រក/០៧ នៃទីស្ដីការក្រសួងយុត្តិធម៌, ឆ្នាំ២០០៧។
- ប្រកាសលេខ ៥៤ កយប្រក/០៩ ស្ដីពីប្រភេទពាក្យសុំដែលតម្រូវឲ្យបង់ពន្ធ, ឆ្នាំ២០០៩។
- ប្រកាស ស្ដីពី នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ, ឆ្នាំ២០១៣។

**ឧបសម្ព័ន្ធទី២ ៖ ទម្រង់លិខិតរដ្ឋបាលពាក់ព័ន្ធនឹងការលែងលះ**

- កិច្ចព្រមព្រៀងលែងលះ។
- ពាក្យបណ្ដឹងលែងលះ។
- ពាក្យសុំតំណាងដោយអាណត្តិ។
- លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ។
- សេចក្ដីថ្លែងការណ៍។
- ពាក្យសុំបញ្ចូលភស្តុតាង។
- ពាក្យសុំឲ្យកោះហៅសាក្សី។
- ពាក្យសុំថតចម្លងសំណុំរឿង។
- ដីកាកោះ និងលិខិតអញ្ជើញ។
- របាយការណ៍អំពីការបញ្ជូន។
- លិខិតសុំពន្យាពេលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។
- លិខិតសុំពន្យាពេលនីតិវិធីទាញហេតុផលផ្ទាល់មាត់។
- កំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។
- កំណត់ហេតុស្ដីពីនីតិវិធីទាញហេតុផលផ្ទាល់មាត់។
- របាយការណ៍នៃរឿងក្ដីលែងលះ។
- ពាក្យបណ្ដឹងសាទុក្ខ។
- សាលក្រមលែងលះ។
- សាលដីកាលែងលះ។

# ឧបសម្ព័ន្ធទី១

# ក្របខបទដ្ឋានគតិយុត្ត

# ប្រកាស

# ស្តីពី

# នីតិវិធីនៃការចុះបញ្ជី

# កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

រៀបចំដោយ
ក្រុមការងារក្រសួងយុត្តិធម៌
និង
ទីប្រឹក្សាផ្នែកច្បាប់របស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA)
ប្រចាំក្រសួងយុត្តិធម៌
p

ក្រសួងយុត្តិធម៌
បោះពុម្ពលើកទីមួយ ចំនួន ៥០០ ក្បាល
នៅរាជធានីភ្នំពេញ ខែ កុម្ភៈ ឆ្នាំ ២០១៤

ប្រកាស ស្តីពី
នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

ត្រូវបានបោះពុម្ព នៅរាជធានីភ្នំពេញ
ដោយគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ (ដំណាក់កាលទី ៤)
នៅក្រសួងយុត្តិធម៌ នៃព្រះរាជាណាចក្រកម្ពុជា នៅឆ្នាំ ២០១៤

គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ
គឺជាគម្រោងសហប្រតិបត្តិការបច្ចេកទេស
រវាង
ក្រសួងយុត្តិធម៌
និង
ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA)

## ប្រធានក្រុមការងារតាក់តែងច្បាប់

| | | |
|---|---|---|
| ឯកឧត្តម | **អង្គ វង្សវឌ្ឍនា** | រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ |

## សមាសភាពក្រុមការងារក្រសួងយុត្តិធម៌ដែលទទួលបន្ទុកតាក់តែងប្រកាសស្តីពី "ការចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធ"

| | | |
|---|---|---|
| លោកជំទាវ | **ចាន់ សុទ្ធាវី** | រដ្ឋលេខាធិការនៃក្រសួងយុត្តិធម៌ (ប្រធាន) |
| ឯកឧត្តម | **យាន ស៊ីណា** | អតីតអនុរដ្ឋលេខាធិការនៃក្រសួងយុត្តិធម៌ |
| លោក | **ឥត្យ ឫទ្ធី** | ចៅក្រមនៃក្រសួងយុត្តិធម៌ |
| កញ្ញា | **ម៉ៅ ធិរុណា** | អគ្គនាយករង នៃអគ្គនាយកដ្ឋានបច្ចេកទេសនៃក្រសួងយុត្តិធម៌ |
| លោកស្រី | **សូរ ដានី** | អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុនៃក្រសួងយុត្តិធម៌ |
| លោក | **ទូច ថារិទ្ធ** | ប្រធាននាយកដ្ឋានកិច្ចការរដ្ឋប្បវេណីនៃក្រសួងយុត្តិធម៌ |
| លោក | **កែវ សេដ្ឋា** | អតីតអនុប្រធាននាយកដ្ឋានកិច្ចការរដ្ឋប្បវេណីនៃក្រសួងយុត្តិធម៌ |
| លោក | **ហុក ច័ន្ទសុវណ្ណារ៉ា** | អនុប្រធានការិយាល័យកិច្ចការរដ្ឋប្បវេណីនៃក្រសួងយុត្តិធម៌ |
| លោក | **អុល ធីរៈ** | អនុប្រធានការិយាល័យកិច្ចការអយ្យការនៃក្រសួងយុត្តិធម៌ |
| កញ្ញា | **ឡាយ លីនណា** | អនុប្រធានការិយាល័យបច្ចេកទេសនៃក្រសួងយុត្តិធម៌ |
| កញ្ញា | **សួន ណារី** | មន្ត្រីគ្រប់គ្រងរដ្ឋបាលនៃក្រសួងយុត្តិធម៌ |

## ជំនាញការរបស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) ប្រចាំក្រសួងយុត្តិធម៌

| | | |
|---|---|---|
| លោក | Issei SAKANO | អតីតទីប្រឹក្សាច្បាប់នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |
| លោក | Hiroshi KIYOHARA | អតីតទីប្រឹក្សាច្បាប់នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |
| លោក | Masayoshi HARADA | អតីតទីប្រឹក្សាច្បាប់នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |
| លោកស្រី | Emiko KANETAKE | អតីតទីប្រឹក្សាច្បាប់នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |
| លោកស្រី | Ayako TAMIYA | អតីតទីប្រឹក្សាច្បាប់នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |
| លោកស្រី | Miha ISOI | ទីប្រឹក្សាច្បាប់នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |

## សមាសភាពសាស្ត្រាចារ្យជប៉ុនដែលបានប្រឹក្សាយោបល់ក្នុងការរៀបចំប្រកាស

| | | |
|---|---|---|
| លោក | Akio MORISHIMA | សាស្ត្រាចារ្យកិត្តិយសនៃសាកលវិទ្យាល័យ Nagoya (ប្រធាន) |
| លោក | Ikufumi NIIMI | សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Meiji |
| លោក | Michitaro URAKAWA | សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Waseda |
| លោក | Kaoru KAMATA | សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Waseda |
| លោក | Yutaka YAMAMOTO | សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Kyoto |
| លោក | Tsuneo MATSUMOTO | សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Hitotsubashi |
| លោក | Yoshihisa NOMI | សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Gakushuin |

| | | |
|---|---|---|
| លោក | Toshifumi MINAMI | អតីតចៅក្រមសាលាឧទ្ធរណ៍នៃទីក្រុងតូក្យូ |
| លោក | Toyohiro NOMURA | សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Gakushu-in |
| លោក | Masayuki TANAMURA | សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Waseda |
| លោក | Keita SATO | សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Chuo |
| លោក | Atsushi MOTOYAMA | សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Ritsumeikan |
| លោក | Hiroshi MATSUO | សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Keio |
| លោក | Hisaya HATANAKA | ជំនួយការសាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Fukuoka |
| លោក | Keisuke ENDO | មន្ត្រីនៃការិយាល័យកិច្ចការរដ្ឋប្បវេណីនៃក្រសួងយុត្តិធម៌ |
| លោក | Kazuo UESAKA | សាស្ត្រាចារ្យនៃនាយកដ្ឋានកិច្ចសហប្រតិបត្តិការអន្តរជាតិនៃក្រសួងយុត្តិធម៌ |

## សមាសភាពលេខាធិការដ្ឋានរបស់ក្រុមប្រឹក្សាយោបល់

| | | |
|---|---|---|
| លោក | Atsuhito YOSHIMOTO | អ្នកស្រាវជ្រាវនៃមជ្ឈមណ្ឌលច្បាប់រដ្ឋប្បវេណី និងពាណិជ្ជកម្មអន្តរជាតិ |
| លោក | Hisashi NAGAYA | អ្នកស្រាវជ្រាវនៃមជ្ឈមណ្ឌលច្បាប់រដ្ឋប្បវេណី និងពាណិជ្ជកម្មអន្តរជាតិ |

**អ្នកបកប្រែ** :

| | | |
|---|---|---|
| លោក | **គីម ពេជ្រដា** | អតីតជំនួយការ នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |
| លោក | **កែម ពិសី** | អតីតជំនួយការ នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |
| លោក | **កែម ចាន់នី** | អតីតមន្ត្រីច្បាប់ជាន់ខ្ពស់ នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |
| លោក | **ឡៀប សុខសិរីយស** | អតីតជំនួយការផ្នែកច្បាប់ នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |
| លោក | **ខ៊ែត ណារ័ត្ន** | មន្ត្រីច្បាប់ នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |
| លោក | **សោម រតនា** | ជំនួយការផ្នែកច្បាប់ នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |
| កញ្ញា | **ស៊ី ច័ន្ទជីវ៉ា** | ជំនួយការរដ្ឋបាល នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |

# ប្រកាស
# ស្តីពី
# នីតិវិធីនៃការចុះបញ្ជី កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

## ជំពូកទី ១- បទប្បញ្ញត្តិទូទៅ


ប្រការ ១ - គោលដៅ ........................................ ២
ប្រការ ២ - គោលបំណង ........................................ ២
ប្រការ ៣ - វិសាលភាព ........................................ ២


## ជំពូកទី ២- សមត្ថកិច្ចចុះបញ្ជី


ប្រការ ៤ - ស្ថាប័នមានសមត្ថកិច្ចលើការចុះបញ្ជី ........................................ ២


## ជំពូកទី ៣- ការបង្កើត ការគ្រប់គ្រងក្រណ្ឌ និងអំឡុងពេលរក្សាទុកឯកសារក្នុងក្រណ្ឌ

### ផ្នែកទី ១- ការបង្កើតក្រណ្ឌ


ប្រការ ៥ - ការបង្កើតក្រណ្ឌ ........................................ ៣
ប្រការ ៦ - ក្រណ្ឌទទួលពាក្យសុំ ........................................ ៣
ប្រការ ៧ - ក្រណ្ឌចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ........................................ ៤
ប្រការ ៨ - ក្រណ្ឌសម្រាក់ដាក់ឯកសារពាក្យសុំ ........................................ ៤
ប្រការ ៩ - ក្រណ្ឌលើកចោល ........................................ ៤
ប្រការ ១០ - ក្រណ្ឌសម្រាក់ដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ ........................................ ៤
ប្រការ ១១ - ក្រណ្ឌសម្រាប់ដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី ........................................ ៤


### ផ្នែកទី ២- ការគ្រប់គ្រងក្រណ្ឌ


ប្រការ ១២ - ការគ្រប់គ្រងក្រណ្ឌ ........................................ ៥


### ផ្នែកទី ៣- អំឡុងពេលរក្សាទុកឯកសារក្នុងក្រណ្ឌ


ប្រការ ១៣ - ការរក្សាទុកឯកសារក្នុងក្រណ្ឌទទួលពាក្យសុំ និងក្រណ្ឌចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ........................................ ៥
ប្រការ ១៤ - អំឡុងពេលរក្សាទុកឯកសារក្នុងក្រណ្ឌសម្រាប់ដាក់ពាក្យសុំ ក្រណ្ឌលើកចោល ក្រណ្ឌសម្រាប់ដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ ក្រណ្ឌសម្រាប់ដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី ........................................ ៥


## ជំពូកទី ៤- បទប្បញ្ញត្តិទូទៅ នៃពាក្យសុំចុះបញ្ជី


ប្រការ ១៥ - ពាក្យសុំចុះបញ្ជី ........................................ ៥
ប្រការ ១៦ - ទម្រង់នៃពាក្យសុំចុះបញ្ជី ........................................ ៦
ប្រការ ១៧ - ឯកសារភ្ជាប់ជាមួយពាក្យសុំចុះបញ្ជី ........................................ ៦

ប្រការ ១៨ - ការប្រគល់ច្បាប់ដើមនៃឯកសារភ្ជាប់.....................................................................៧

**ជំពូកទី ៥- ពាក្យសុំចុះបញ្ជី**

ប្រការ ១៩ - ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ.......................................................៧
ប្រការ ២០ - ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ .....................................៨
ប្រការ ២១ - ពាក្យសុំចុះបញ្ជីអំពីការកែតម្រូវ ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ.......................៨
ប្រការ ២២ - ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដោយមូលហេតុ រំលាយអាពាហ៍ពិពាហ៍ ឬ កំជាប់ពាក្យ .......................................................................៩
ប្រការ ២៣ - ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដោយមូលហេតុ មោឃភាព ការលុបចោល ឬ ការរំលាយកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ.......................១០
ប្រការ ២៤ - ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដោយមូលហេតុ សហព័ទ្ធណាម្នាក់បានស្លាប់...............................................................................១០
ប្រការ ២៥ - ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដោយផ្អែកលើ សាលក្រម ឬ សាលដីកាស្ថាពរ រំលាយអាពាហ៍ពិពាហ៍ និងការបែងចែកទ្រព្យសម្បត្តិ..១១
ប្រការ ២៦ - ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ តាមសេចក្តីសម្រេចរបស់តុលាការ ដោយផ្អែកលើបញ្ញត្តិនៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែល មិនមែនជាបណ្តឹង..........................................................................................១១
ប្រការ ២៧ - ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដោយផ្អែកតាម សាលក្រម ឬ សាលដីកាស្ថាពរ ដែលបានកំណត់ក្នុងច្បាប់ស្តីពីការអនុវត្ត ក្រមរដ្ឋប្បវេណី មាត្រា ៣០ កថាខណ្ឌទី ៣ ចំនុច ឃ ...........................................១២
ប្រការ ២៨ - ពាក្យសុំចុះបញ្ជីអំពីកាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍...........................................១២

**ជំពូកទី ៦- ការទទួល ការពិនិត្យពាក្យសុំចុះបញ្ជី និងពាក្យសុំឲ្យពិនិត្យឡើងវិញ**

ប្រការ ២៩ - ការទទួលពាក្យសុំចុះបញ្ជី .....................................................................................១៣
ប្រការ ៣០ - ការដកពាក្យសុំចុះបញ្ជី.........................................................................................១៣
ប្រការ ៣១ - ការពិនិត្យពាក្យសុំចុះបញ្ជី.......................................................................................១៣
ប្រការ ៣២ - ការកែតម្រូវ និងការលើកចោលពាក្យសុំចុះបញ្ជី .........................................................១៣
ប្រការ ៣៣ - ការប្រគល់ឯកសារភ្ជាប់ឲ្យវិញ .................................................................................១៤
ប្រការ ៣៤ - ពាក្យសុំឲ្យពិនិត្យឡើងវិញចំពោះការលើកចោលរបស់មន្ត្រីចុះបញ្ជី .................................១៤
ប្រការ ៣៥ - ចំណុចដែលត្រូវចុះបញ្ជីក្នុងសន្លឹកចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ.......................១៤
ប្រការ ៣៦ - អានុភាពនៃការចុះបញ្ជី........................................................................................១៤

**ជំពូកទី ៧- របៀបចុះបញ្ជី និងចងក្រងទុកក្នុងក្រឡា**

ប្រការ ៣៧ - របៀបចុះបញ្ជីក្នុងក្រឡាទទួលពាក្យសុំ.......................................................................១៥

ប្រការ ៣៨ - របៀបចុះបញ្ជីក្នុងក្រូណូចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ.......................................១៥
ប្រការ ៣៩ - របៀបចុះបញ្ជីក្នុងក្រូណូចុះបញ្ជីអំពីការផ្លាស់ប្ដូរកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ...........១៥
ប្រការ ៤០ - របៀបចុះបញ្ជីក្នុងក្រូណូចុះបញ្ជីអំពីការកែតម្រូវកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ...........១៦
ប្រការ ៤១ - របៀបចុះបញ្ជីក្នុងក្រូណូចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ.១៦
ប្រការ ៤២ - របៀបចុះបញ្ជីក្នុងក្រូណូចុះបញ្ជីអំពីកាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍..................១៦
ប្រការ ៤៣ - វិធីកត់ត្រាការចុះបញ្ជីអំពីខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ........................១៧
ប្រការ ៤៤ - របៀបចងក្រងរក្សាទុកក្នុងក្រូណូសម្រាប់ដាក់ឯកសារពាក្យសុំ.......................................១៧
ប្រការ ៤៥ - របៀបចងក្រងរក្សាទុកក្នុងក្រូណូលើកចោល ........................................................................១៧
ប្រការ ៤៦ - របៀបចងក្រងរក្សាទុកក្នុងក្រូណូសម្រាប់ដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ.........................១៧
ប្រការ ៤៧ - របៀបចងក្រងរក្សាទុកក្នុងក្រូណូសម្រាប់ដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី....១៨

## ជំពូកទី ៨- នីតិវិធីនៃការចេញលិខិតបញ្ជាក់

ប្រការ ៤៨ - របៀបដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ .......................................................................១៨
ប្រការ ៤៩ - ការចេញលិខិតបញ្ជាក់.................................................................................................១៨

## ជំពូកទី ៩- អវសានប្បញ្ញត្តិ

ប្រការ ៥០ - កាលបរិច្ឆេទ នៃការអនុវត្ត..........................................................................................១៩

ឧបសម្ព័ន្ធទី ១ - ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ...................................................២០
ឧបសម្ព័ន្ធទី ២ - ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្ដូរកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ.............................២១
ឧបសម្ព័ន្ធទី ៣ - ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្ដូរឈ្មោះ ឬ អាសយដ្ឋាន .............................................២២
ឧបសម្ព័ន្ធទី ៤ - ពាក្យសុំចុះបញ្ជីអំពីការកែតម្រូវការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ..............២៣
ឧបសម្ព័ន្ធទី ៥ - ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ.....................២៤
ឧបសម្ព័ន្ធទី ៦ - ពាក្យសុំចុះបញ្ជីអំពីកាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍ ..........................................២៥
ឧបសម្ព័ន្ធទី ៧ - ពាក្យសុំឲ្យចេញលិខិតបញ្ជាក់.........................................................................................២៦
ឧបសម្ព័ន្ធទី ៨ - សន្លឹកក្រដាសទទួលពាក្យសុំ ..........................................................................................២៧
ឧបសម្ព័ន្ធទី ៩ - សន្លឹកចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ..........................................................២៨
ឧបសម្ព័ន្ធទី ១០ - សន្លឹកចុះបញ្ជីការផ្លាស់ប្ដូរកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ......................................២៩
គំរូចុះបញ្ជី ១ - សន្លឹកក្រដាសទទួលពាក្យសុំ .............................................................................................៣០
គំរូចុះបញ្ជី ២ - ការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ (សន្លឹកចុះបញ្ជី)...............................................៣១
គំរូចុះបញ្ជី ៣ - ការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ (សន្លឹកចុះបញ្ជី) (វិធីកត់ត្រា)............................៣២
គំរូចុះបញ្ជី ៤ - ការផ្លាស់ប្ដូរកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ (សន្លឹកចុះបញ្ជី) ..........................................៣៤
គំរូចុះបញ្ជី ៥ - ការផ្លាស់ប្ដូរកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ (សន្លឹកចុះបញ្ជី) (វិធីកត់ត្រា) .........................៣៥
គំរូចុះបញ្ជី ៦ - ការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ (សន្លឹកចុះបញ្ជី) ................................៣៧

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

លេខ : ៨០.ក.ប.ក្រ.ក/១៣

# ប្រកាស

# ស្តីពី

# នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើក្រមរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី



មហាវិថីសម្តេចសុធារស ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ : 023 216 322 023 2 7 841

# ប្រកាស
# ស្តីពី
# នីតិវិធីនៃការចុះបញ្ជី កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១ : គោលដៅ**

ប្រកាសនេះ មានគោលដៅធានានូវប្រសិទ្ធភាព នៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដែលបង្កើតអានុភាពរវាងបុគ្គលដែលបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ឲ្យបានត្រឹមត្រូវតាមក្រមរដ្ឋប្បវេណី និងច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ។

**ប្រការ ២ : គោលបំណង**

គោលបំណងនៃប្រកាសនេះ គឺអនុញ្ញាតឲ្យប្តីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា អាចធ្វើការចុះបញ្ជីកិច្ចសន្យាអំពីទំនាក់ទំនងទ្រព្យសម្បត្តិនៅមុន ឬ ក្រោយការរៀបអាពាហ៍ពិពាហ៍បាន ដើម្បីកំណត់ឲ្យបានច្បាស់លាស់ អំពីទំនាក់ទំនងទ្រព្យសម្បត្តិប្តីប្រពន្ធ។

**ប្រការ ៣ : វិសាលភាព**

ប្រកាសនេះ មានវិសាលភាពអនុវត្តទៅលើចំណុច ដូចខាងក្រោម ៖

- ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ
- ការចុះបញ្ជីអំពីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ
- ការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ
- នីតិវិធីនៃការចេញលិខិតបញ្ជាក់។

## ជំពូកទី ២
## សមត្ថកិច្ចចុះបញ្ជី

**ប្រការ ៤ : ស្ថាប័នមានសមត្ថកិច្ចលើការចុះបញ្ជី**

១- នាយកដ្ឋានកិច្ចការរដ្ឋប្បវេណី នៃក្រសួងយុត្តិធម៌ មានសមត្ថកិច្ចលើការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ។

២- មន្ត្រីដែលទទួលបន្ទុកកិច្ចការដែលទាក់ទងនឹងការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ (មន្ត្រីចុះបញ្ជី) ត្រូវនៅក្នុងនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី ។

គំរូចុះបញ្ជី ៧ - ការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ (សន្លឹកចុះបញ្ជី) (វិធីកត់ត្រា) ........ ៣៨
គំរូចុះបញ្ជី ៨ - ការផ្លាស់ប្ដូរឈ្មោះ ឬ អាសយដ្ឋានជាអាទិ៍ (សន្លឹកចុះបញ្ជី)........................................ ៣៩

៣- ក្រូណូទាក់ទងនឹងការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ត្រូវរក្សាទុកនៅក្នុងនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី ។

## ជំពូកទី ៣
## ការបង្កើត ការគ្រប់គ្រងក្រូណូ និងរយៈពេលរក្សាទុកឯកសារក្នុងក្រូណូ
### ផ្នែកទី ១
### ការបង្កើតក្រូណូ

**ប្រការ ៥ : ការបង្កើតក្រូណូ**

នាយកដ្ឋានកិច្ចការរដ្ឋប្បវេណី ត្រូវបង្កើតក្រូណូ ដូចខាងក្រោម ៖

១. ក្រូណូទទួលពាក្យសុំ
២. ក្រូណូចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ
៣. ក្រូណូសម្រាប់ដាក់ឯកសារពាក្យសុំ
៤. ក្រូណូលើកចោល
៥. ក្រូណូសម្រាប់ដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ
៦. ក្រូណូសម្រាប់ដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី

**ប្រការ ៦ : ក្រូណូទទួលពាក្យសុំ**

១- ក្រូណូទទួលពាក្យសុំ គឺជាក្រូណូសម្រាប់ចុះព័ត៌មាន ដូចជា ឈ្មោះ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ និងចុះលេខទទួលពាក្យសុំនៅលើពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្ដូរកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ និងពាក្យសុំលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ។

២- សន្លឹកក្រដាសទទួលពាក្យសុំ ដែលដាក់ក្នុងក្រូណូ ត្រូវមានតារាងបែងចែកខ្ទង់ ដូចខាងក្រោមនេះ ៖

- លេខរៀងទទួលពាក្យ
- កាលបរិច្ឆេទ នៃការទទួលពាក្យ
- ប្រភេទ នៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ
- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ
- ជាប្ដីប្រពន្ធ
- បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា
- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាង (ប្រសិនបើមាន)
- ផ្សេងៗ

**ប្រការ ៧ : ក្រេណូចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ**

១- ក្រេណូចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ គឺជាក្រេណូសម្រាប់ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ចុះបញ្ជីអំពីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។

២- សន្លឹកចុះបញ្ជី ដែលដាក់ក្នុងក្រេណូ ត្រូវមានតារាងបែងចែកខ្ទង់ ដូចខាងក្រោមនេះ ៖

- លេខចុះបញ្ជី និង លេខទទួលពាក្យសុំ
- ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា
- ការផ្លាស់ប្តូរឈ្មោះ និងអាសយដ្ឋាន
- កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍
- គោលបំណង និងមូលហេតុនៃការចុះបញ្ជី
- ខ្លឹមសារកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ
- ការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ
- ការលុបការចុះបញ្ជី អំពីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

**ប្រការ ៨ : ក្រេណូសម្រាប់ដាក់ឯកសារពាក្យសុំ**

ក្រេណូសម្រាប់ដាក់ឯកសារពាក្យសុំ គឺជាក្រេណូសម្រាប់ដាក់ពាក្យសុំចុះបញ្ជី និងឯកសារភ្ជាប់ ដែលមន្ត្រីចុះបញ្ជីបានទទួលពីអ្នកដាក់ពាក្យសុំ ។

**ប្រការ ៩ : ក្រេណូលើកចោល**

ក្រេណូលើកចោល គឺជាក្រេណូសម្រាប់ដាក់លិខិតលើកចោលពាក្យសុំចុះបញ្ជីរបស់មន្ត្រីចុះបញ្ជី។

**ប្រការ ១០ : ក្រេណូសម្រាប់ដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ**

ក្រេណូសម្រាប់ដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ គឺជាក្រេណូសម្រាប់ដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ ព្រមទាំងដាក់សេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងឯកសារដែលភ្ជាប់មកជាមួយ ។

**ប្រការ ១១ : ក្រេណូសម្រាប់ដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី**

ក្រេណូសម្រាប់ដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី គឺជាក្រេណូសម្រាប់ដាក់ពាក្យសុំឲ្យធ្វើការបញ្ជាក់ ចំពោះចំណុចដែលបានចុះ ឬ មិនបានចុះនៅក្នុងបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ។

p

## ផ្នែកទី ២
## ការគ្រប់គ្រងក្រុណា

ប្រការ ១២ : ការគ្រប់គ្រងក្រុណា

ក្រុណា គឺត្រូវគ្រប់គ្រង និងរក្សាទុកនៅនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី នៃក្រសួងយុត្តិធម៌ ។

## ផ្នែកទី ៣
## អំឡុងពេលរក្សាទុកឯកសារក្នុងក្រុណា

**ប្រការ ១៣ : ការរក្សាទុកឯកសារក្នុងក្រុណាទទួលពាក្យសុំ និងក្រុណាចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ**

ឯកសារក្នុងក្រុណាទទួលពាក្យសុំ និងក្រុណាចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ត្រូវរក្សាទុកជានិរន្តរ៍ ។

**ប្រការ ១៤ : អំឡុងពេលរក្សាទុកឯកសារក្នុងក្រុណាសម្រាប់ដាក់ឯកសារពាក្យសុំ ក្រុណាលើកចោល ក្រុណាសម្រាប់ដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ ក្រុណាសម្រាប់ដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី**

១- អំឡុងពេលរក្សាទុកឯកសារក្នុងក្រុណាសម្រាប់ដាក់ឯកសារពាក្យសុំ មានរយៈពេល ១០ ឆ្នាំ គិតចាប់ពីថ្ងៃដាក់ពាក្យសុំ ។

២- អំឡុងពេលរក្សាទុកឯកសារក្នុងក្រុណាលើកចោល មានរយៈពេល ១០ ឆ្នាំ គិតចាប់ពីថ្ងៃចេញលិខិតលើកចោល ។

៣- អំឡុងពេលរក្សាទុកឯកសារក្នុងក្រុណាសម្រាប់ដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ មានរយៈពេល ១០ ឆ្នាំ គិតចាប់ពីថ្ងៃដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ ។

៤- អំឡុងពេលរក្សាទុកឯកសារក្នុងក្រុណាសម្រាប់ដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី មានរយៈពេល ១០ ឆ្នាំ គិតចាប់ពីថ្ងៃដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី ។

## ជំពូកទី ៤
## បទប្បញ្ញត្តិទូទៅ នៃពាក្យសុំចុះបញ្ជី

**ប្រការ ១៥ : ពាក្យសុំចុះបញ្ជី**

១- រាល់ពាក្យសុំចុះបញ្ជីទាក់ទងនឹងកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ។ ពាក្យសុំច្បាប់ដើម ត្រូវមានហត្ថលេខា ឬ ស្នាមម្រាមដៃរបស់អ្នកដាក់ពាក្យសុំ ដោយភ្ជាប់មកជាមួយនូវច្បាប់ថតចម្លងនៃច្បាប់ដើមនោះ ។

២- ជាគោលការណ៍ ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ត្រូវធ្វើឡើងរួមគ្នា។ លើកលែងតែករណីដូចខាងក្រោម អាចដាក់ពាក្យសុំតែម្នាក់ឯងបាន ៖

ក. ការផ្លាស់ប្តូរ ឬ ការកែតម្រូវតែ ឈ្មោះ អាសយដ្ឋាន ថ្ងៃខែឆ្នាំកំណើត ប្តីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា។

ខ. ការចុះបញ្ជី ដោយផ្អែកលើសាលក្រម ឬ សាលដីកា ឬ ដីកាសម្រេចស្ថាពរ ប្តីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ដូចមានចែងនៅក្នុងមាត្រា ៣០ កថាខណ្ឌទី ៣ ចំណុច ខ, គ, ឃ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី។

៣- រាល់ពាក្យសុំចុះបញ្ជីខាងលើ អ្នកតំណាងក៏អាចកាន់យកមកដាក់នៅ ចំពោះមុខមន្ត្រីចុះបញ្ជីជំនួសប្តីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបានដែរ ។

៤- បុគ្គល ឬ អ្នកតំណាង ដែលដាក់ពាក្យសុំចុះបញ្ជី ត្រូវយកពាក្យសុំនោះ មកដាក់នៅនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី នៃក្រសួងយុត្តិធម៌ដោយផ្ទាល់ ។

**ប្រការ ១៦ : ទម្រង់នៃពាក្យសុំចុះបញ្ជី**

១- ទម្រង់នៃពាក្យសុំចុះបញ្ជី ត្រូវសរសេរបាវចនានៃព្រះរាជាណាចក្រកម្ពុជា ពាក្យសុំចុះបញ្ជី ឈ្មោះ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ ឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាង (ប្រសិនបើមាន) ហើយត្រូវគោរពចូលមករដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ព្រមទាំងមានចុះកាលបរិច្ឆេទ និងហត្ថលេខា ឬស្នាមម្រាមដៃរបស់អ្នកដាក់ពាក្យសុំ ។

២- ក្រៅពីនេះ ត្រូវសរសេរបន្ថែមនូវចំណុចមួយចំនួនទៀតតាមប្រភេទនៃពាក្យសុំចុះបញ្ជីទាក់ទងនឹងកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ (ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ជាអាទិ៍) ដូចមានចែងក្នុងជំពូកទី ៥ (ពាក្យសុំចុះបញ្ជី) នៃប្រកាសនេះ ។

**ប្រការ ១៧ : ឯកសារភ្ជាប់ជាមួយពាក្យសុំចុះបញ្ជី**

១- នៅពេលដាក់ពាក្យសុំចុះបញ្ជី អ្នកដាក់ពាក្យសុំចុះបញ្ជីទាក់ទងនឹងកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ (ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ជាអាទិ៍) ដូចមានចែងក្នុងជំពូកទី ៥ (ពាក្យសុំចុះបញ្ជី) នៃប្រកាសនេះ ត្រូវផ្តល់ឯកសារចាំបាច់មួយចំនួនទៅឲ្យនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី ទៅតាមប្រភេទនៃពាក្យសុំចុះបញ្ជីនោះ ។

២- ចំពោះពាក្យសុំចុះបញ្ជី ដែលអ្នកតំណាងយកមកដាក់ ដូចមានចែងក្នុងប្រការ ១៥ កថាខណ្ឌទី៣ ត្រូវភ្ជាប់លិខិតប្រគល់សិទ្ធិតំណាងផងដែរ ។

ប្រការ ១៨ : ការប្រគល់ច្បាប់ដើមនៃឯកសារភ្ជាប់

១- ចំពោះឯកសារដែលភ្ជាប់ជាមួយនឹងពាក្យសុំ អ្នកដាក់ពាក្យសុំអាចទាមទារឲ្យប្រគល់វិញនៅពេលដាក់ពាក្យសុំ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្ត ចំពោះលិខិតប្រគល់សិទ្ធិតំណាង ។

២- ដើម្បីទាមទារឲ្យប្រគល់ឯកសារភ្ជាប់ អ្នកដាក់ពាក្យសុំត្រូវភ្ជាប់ជាមួយនឹងពាក្យសុំនោះ នូវឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់ថា ការសរសេរនៅក្នុងឯកសារនោះគ្មានភាពខុសពីច្បាប់ដើម ។

៣- ក្នុងករណីដែលប្រគល់ច្បាប់ដើមនៃឯកសារភ្ជាប់ មន្ត្រីចុះបញ្ជីត្រូវឲ្យអ្នកទទួលការប្រគល់សរសេរនៅក្នុងឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នូវការណ៍ ដែលខ្លួនបានទទួលការប្រគល់ឯកសារនោះ និងចុះហត្ថលេខា ។

## ជំពូកទី ៥
## ពាក្យសុំចុះបញ្ជី

ប្រការ ១៩ : ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ

១- ប្រសិនបើមានការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ប្ដីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា អាចដាក់ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធបាន ។

២- ក្រៅពីចំណុចដូចមានចែងនៅក្នុងកថាខណ្ឌទី១ នៃប្រការ ១៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរបន្ថែមនូវចំណុច ដូចខាងក្រោម ៖

ក– ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា

ខ– គោលបំណងនៃការចុះបញ្ជី

គ– មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ)

ឃ– ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ

ង– កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍ ក្នុងករណីដែលអ្នកដាក់ពាក្យសុំបានរៀបអាពាហ៍ពិពាហ៍។

ឯកសារភ្ជាប់:

- កិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ
- សំបុត្រអាពាហ៍ពិពាហ៍ ក្នុងករណីដែលអ្នកដាក់ពាក្យសុំបានរៀបអាពាហ៍ពិពាហ៍
- វិញ្ញាបនបត្របញ្ជាក់អំពីព័ត៌មានដែលបានចុះនៅក្នុងសៀវភៅចុះបញ្ជី (សៀវភៅចុះបញ្ជីអចលនវត្ថុ សៀវភៅគោលបញ្ជីដីធ្លី សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ សៀវភៅចុះបញ្ជីផលុបភោគ) ក្នុងករណីដែលកិច្ចសន្យានេះ ពាក់ព័ន្ធនឹងបញ្ហាដីធ្លី
- លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនបើមាន)
- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន

## ប្រការ ២០ : ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

១- ប្រសិនបើមានការផ្លាស់ប្តូរនូវចំណុចដែលបានចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ប្តីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ត្រូវដាក់ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្តូរនោះ ។

២- ក្រៅពីចំណុចដូចមានចែងនៅក្នុងកថាខណ្ឌទី១ នៃប្រការ ១៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរបន្ថែមនូវចំណុច ដូចខាងក្រោម ៖

ក- ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា

ខ- គោលបំណងនៃការចុះបញ្ជី

គ- មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទនៃការផ្លាស់ប្តូរ)

ឃ- ចំណុចដែលត្រូវផ្លាស់ប្តូរ

- ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធថ្មី
- ឈ្មោះ ឬ អាសយដ្ឋានថ្មី

ឯកសារភ្ជាប់:

- កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធថ្មី
- សាលក្រម ឬ ដីកាសម្រេចផ្លាស់ប្តូរ
- លិខិតបញ្ជាក់អំពីការផ្លាស់ប្តូរអាសយដ្ឋាន
- វិញ្ញាបនបត្របញ្ជាក់អំពីព័ត៌មានដែលបានចុះនៅក្នុងសៀវភៅចុះបញ្ជី (សៀវភៅចុះបញ្ជីអចលនវត្ថុ សៀវភៅគោលបញ្ជីដីធ្លី សៀវភៅចុះបញ្ជីសិទ្ធិផ្ទុលអចិន្ត្រៃយ៍ សៀវភៅចុះបញ្ជីផលុបភោគ) ក្នុងករណីដែលកិច្ចសន្យានេះពាក់ព័ន្ធនឹងបញ្ហាដីធ្លីក្រោយពេលមានការផ្លាស់ប្តូរ
- លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនបើមាន)
- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន

## ប្រការ ២១ : ពាក្យសុំចុះបញ្ជីអំពីការកែតម្រូវ ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

១- នៅពេលកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ត្រូវបានចុះបញ្ជីរួចហើយ បើពិនិត្យឃើញថាមានកំហុស ឬ ខកខានមិនបានចុះបញ្ជី ប្តីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ត្រូវដាក់ពាក្យសុំចុះបញ្ជីកែតម្រូវ។

២- ក្រៅពីចំណុចដូចមានចែងនៅក្នុងកថាខណ្ឌទី១ នៃប្រការ ១៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរបន្ថែមនូវចំណុច ដូចខាងក្រោម ៖

ក- គោលបំណង

ខ- មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទដែលបានកែតម្រូវ)

គ- ចំណុចដែលត្រូវកែតម្រូវ

- ឈ្មោះ
- អាសយដ្ឋាន

- ថ្ងៃ ខែ ឆ្នាំកំណើត
- កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍
- ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

ឯកសារភ្ជាប់:

- កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ
- សំបុត្រអាពាហ៍ពិពាហ៍
- វិញ្ញាបនបត្របញ្ជាក់អំពីព័ត៌មានដែលបានចុះនៅក្នុងសៀវភៅចុះបញ្ជី (សៀវភៅចុះបញ្ជីអចលនវត្ថុ សៀវភៅគោលបញ្ជីដីធ្លី សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ សៀវភៅចុះបញ្ជីផលុបភោគ) ក្នុងករណីដែលកិច្ចសន្យានេះ ពាក់ព័ន្ធនឹងបញ្ហាដីធ្លីក្រោយពេលមានការកែតម្រូវ
- លិខិតបញ្ជាក់អាសយដ្ឋាន
- លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនបើមាន)
- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន

**ប្រការ ២២ : ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដោយមូលហេតុរំលាយអាពាហ៍ពិពាហ៍ ឬ កំដាប់ពាក្យ**

១- ប្រសិនបើប្តីប្រពន្ធបានរំលាយអាពាហ៍ពិពាហ៍ ឬ ប្រសិនបើបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបានរំលាយកំដាប់ពាក្យ ប្តីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាត្រូវដាក់ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។

២- ក្រៅពីចំណុចដូចមានចែងនៅក្នុងកថាខណ្ឌទី១ នៃប្រការ ១៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរបន្ថែមនូវចំណុច ដូចខាងក្រោម ៖

ក- ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា

ខ- គោលបំណងនៃការចុះបញ្ជី

គ- មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទរំលាយអាពាហ៍ពិពាហ៍ ឬ កំដាប់ពាក្យ)

ឯកសារភ្ជាប់:

- ដីកាសម្រេច ដែលរំលាយអាពាហ៍ពិពាហ៍តាមការព្រមព្រៀង
- លិខិតបញ្ជាក់អំពីការចូលជាស្ថាពរនៃដីកាសម្រេច
- កិច្ចព្រមព្រៀង ឬ ការជូនដំណឹងពីការរំលាយកំដាប់ពាក្យ
- លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនបើមាន)
- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន

**ប្រការ ២៣ : ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដោយមូលហេតុមោឃភាព ការលុបចោល ឬ ការរំលាយកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ**

១- ប្រសិនបើកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដែលបានចុះបញ្ជីរួច ត្រូវបានមោឃៈ រំលាយ ឬ លុបចោល ប្តីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានោះ ត្រូវដាក់ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។

២- ក្រៅពីចំណុចដូចមានចែងនៅក្នុងកថាខណ្ឌទី១ នៃប្រការ ១៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរបន្ថែមនូវចំណុច ដូចខាងក្រោម ៖

ក- ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា

ខ- គោលបំណងនៃការចុះបញ្ជី

គ- មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទនៃមោឃភាព, ការលុបចោល, ការរំលាយកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ)

ឯកសារភ្ជាប់:

- សាលក្រម ឬ សាលដីកាស្ថាពរ ដែលបញ្ជាក់ថាកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ត្រូវបានមោឃៈ លុបចោល ឬ រំលាយ
- លិខិតបញ្ជាក់អំពីការចូលជាស្ថាពរនៃសាលក្រម ឬសាលដីកា
- កិច្ចព្រមព្រៀង ឬ ការជូនដំណឹង ដែលបញ្ជាក់ពីការលុបចោល ឬ រំលាយកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ
- លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនបើមាន)
- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន

**ប្រការ ២៤ : ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដោយមូលហេតុសហព័ទ្ធណាម្នាក់បានស្លាប់**

១- ប្រសិនបើសហព័ទ្ធណាម្នាក់បានស្លាប់ ឬ ប្រសិនបើបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបានស្លាប់ សហព័ទ្ធដែលនៅរស់ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាដែលនៅរស់ ត្រូវដាក់ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។

២- ក្រៅពីចំណុចដូចមានចែងនៅក្នុងកថាខណ្ឌទី១ នៃប្រការ ១៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរបន្ថែមនូវចំណុច ដូចខាងក្រោម ៖

ក- ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា

ខ- គោលបំណងនៃការចុះបញ្ជី p

គ- មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទនៃមរណភាព)

ឯកសារភ្ជាប់:

- សំបុត្រមរណភាព
- លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនបើមាន)

- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន

**ប្រការ ២៥ : ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដោយផ្អែកលើសាលក្រម ឬ សាលដីកាស្ថាពរ រំលាយអាពាហ៍ពិពាហ៍ និងការបែងចែកទ្រព្យសម្បត្តិ**

១- ប្រសិនបើមានសេចក្តីសម្រេចអំពីការបែងចែកទ្រព្យសម្បត្តិក្នុងសាលក្រម ឬ សាលដីការំលាយអាពាហ៍ពិពាហ៍ដែលបានចូលជាស្ថាពរ អតីតសហព័ទ្ធណាម្នាក់ ត្រូវដាក់ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។

២- ក្រៅពីចំណុចដូចមានចែងនៅក្នុងកថាខណ្ឌទី១ នៃប្រការ ១៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរបន្ថែមនូវចំណុច ដូចខាងក្រោម ៖

ក– ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា

ខ– គោលបំណងនៃការចុះបញ្ជី

គ– មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទនៃសាលក្រម ឬ សាលដីកាស្ថាពរ)

ឯកសារភ្ជាប់:

- សាលក្រម ឬ សាលដីការំលាយអាពាហ៍ពិពាហ៍ និងការបែងចែកទ្រព្យសម្បត្តិដែលបានចូលជាស្ថាពរ
- លិខិតបញ្ជាក់អំពីការចូលជាស្ថាពរនៃសាលក្រម ឬសាលដីកា
- លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនបើមាន)
- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន

**ប្រការ ២៦ : ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ តាមសេចក្តីសម្រេចរបស់តុលាការ ដោយផ្អែកលើបញ្ញត្តិនៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង**

១- ប្រសិនបើតុលាការសម្រេចសេចក្តី អំពីការបែងចែកទ្រព្យសម្បត្តិ ដោយការរំលាយអាពាហ៍ពិពាហ៍ ដោយផ្អែកលើបញ្ញត្តិនៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ហើយសេចក្តីសម្រេចនោះបានចូលជាស្ថាពរ អតីតសហព័ទ្ធណាម្នាក់ត្រូវដាក់ពាក្យសុំលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។

២- ក្រៅពីចំណុចដូចមានចែងនៅក្នុងកថាខណ្ឌទី១ នៃប្រការ ១៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរបន្ថែមនូវចំណុច ដូចខាងក្រោម ៖

ក– ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា

ខ– គោលបំណងនៃការចុះបញ្ជី

គ– មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទនៃសេចក្តីសម្រេចរបស់តុលាការ)

ឯកសារភ្ជាប់:

- ដីកាសម្រេចការបែងចែកទ្រព្យសម្បត្តិដោយការលែងលះអាពាហ៍ពិពាហ៍ ដែលបានចូលជាស្ថាពរ
- លិខិតបញ្ជាក់អំពីការចូលជាស្ថាពរនៃដីកាសម្រេច
- លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនបើមាន)
- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន

**ប្រការ ២៧ : ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដោយផ្អែកតាមសាលក្រម ឬ សាលដីកាស្ថាពរ ដែលបានកំណត់ក្នុងច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី មាត្រា ៣០ កថាខណ្ឌទី ៣ ចំនុច ឃ**

១- នៅពេលមានសាលក្រម ឬ សាលដីកាស្ថាពរដែលកំណត់ក្នុងច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី មាត្រា ៣០ កថាខណ្ឌទី ៣ ចំនុច ឃ ភាគីណាម្នាក់ ត្រូវដាក់ពាក្យសុំលុបការចុះបញ្ជី។

២- ក្រៅពីចំណុចដូចមានចែងនៅក្នុងកថាខណ្ឌទី១ នៃប្រការ ១៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរបន្ថែមនូវចំណុច ដូចខាងក្រោម ៖

ក– ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា

ខ– គោលបំណងនៃការចុះបញ្ជី

គ– មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទនៃសាលក្រម ឬ សាលដីកាស្ថាពរ)

ឯកសារភ្ជាប់:

- សាលក្រម ឬ សាលដីកាស្ថាពរ
- លិខិតបញ្ជាក់អំពីការចូលជាស្ថាពរនៃសាលក្រម ឬសាលដីកា
- លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនបើមាន)
- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន

**ប្រការ ២៨: ពាក្យសុំចុះបញ្ជីអំពីកាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍**

១- នៅពេលដែលបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា បានរៀបអាពាហ៍ពិពាហ៍ ក្រោយពីបានធ្វើការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ បុគ្គលនោះត្រូវដាក់ពាក្យសុំចុះបញ្ជីបន្ថែម អំពីកាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍។

២- ក្រៅពីចំណុចដូចមានចែងនៅក្នុងកថាខណ្ឌទី១ នៃប្រការ ១៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរបន្ថែមនូវចំណុច ដូចខាងក្រោម ៖

ក– ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា

ខ– គោលបំណងនៃការចុះបញ្ជី

គ– កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍

ឯកសារភ្ជាប់:

- សំបុត្រអាពាហ៍ពិពាហ៍
- លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនបើមាន)
- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន

## ជំពូកទី ៦
## ការទទួល ការពិនិត្យពាក្យសុំចុះបញ្ជី និងពាក្យសុំឲ្យពិនិត្យឡើងវិញ

**ប្រការ ២៩ : ការទទួលពាក្យសុំចុះបញ្ជី**

នៅពេលមន្ត្រីចុះបញ្ជី បានទទួលពាក្យសុំចុះបញ្ជី មន្ត្រីចុះបញ្ជីត្រូវចុះនិទ្ទេសនៅលើពាក្យសុំនោះ នូវលេខរៀងទទួលពាក្យសុំ កាលបរិច្ឆេទ និងឈ្មោះនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី ព្រមទាំងហត្ថលេខាបំព្រួញ និងឈ្មោះមន្ត្រីចុះបញ្ជីនោះ ។

**ប្រការ ៣០ : ការដកពាក្យសុំចុះបញ្ជី**

ពាក្យសុំចុះបញ្ជីអាចដកបានមុនពេលការចុះបញ្ជីត្រូវបានបញ្ចប់ ដោយត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ។

**ប្រការ ៣១ : ការពិនិត្យពាក្យសុំចុះបញ្ជី**

១- មន្ត្រីចុះបញ្ជី ត្រូវពិនិត្យពាក្យសុំ និងឯកសារភ្ជាប់ ។

២- នៅពេលពិនិត្យពាក្យសុំ ដែលមានចែងនៅក្នុងកថាខណ្ឌទី១ ខាងលើនេះ បើមន្ត្រីចុះបញ្ជីមានវិមតិសង្ស័យនោះ មន្ត្រីចុះបញ្ជីអាចធ្វើការសាកសួរបន្ថែមទៅអ្នកដាក់ពាក្យសុំ ឬ អ្នកតំណាងនោះបាន ។

**ប្រការ ៣២ : ការកែតម្រូវ និងការលើកចោលពាក្យសុំចុះបញ្ជី**

១- មន្ត្រីចុះបញ្ជី ត្រូវចេញលិខិតបង្គាប់ឲ្យកែតម្រូវ ដោយកំណត់អំឡុងពេលសមរម្យ និងជូនដំណឹងទៅអ្នកដាក់ពាក្យសុំ ក្នុងករណីដែលមន្ត្រីចុះបញ្ជីពិនិត្យឃើញថា ពាក្យសុំចុះបញ្ជីធ្វើឡើងពុំត្រឹមត្រូវ ដោយមានមូលហេតុ ដូចខាងក្រោម ៖

- ព័ត៌មាន និងបែបបទក្នុងពាក្យសុំចុះបញ្ជីមិនស្របតាមប្រកាសនេះ
- ពុំបានផ្តល់ឯកសារដែលចាំបាច់
- ខ្លឹមសារនៅក្នុងពាក្យសុំ និងឯកសារភ្ជាប់មិនស្របគ្នា
- ពាក្យសុំចុះបញ្ជីនោះធ្លាប់បានដាក់ និងចុះបញ្ជីម្តងរួចមកហើយ
- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំនៅក្នុងពាក្យសុំ មិនស្របគ្នាជាមួយនឹងការចុះបញ្ជី

- ពុំបានបង់សោហ៊ុយ ឬ
- ពាក្យសុំនោះ មិនអនុលោមតាមលក្ខខណ្ឌនៃប្រកាសនេះ ឬ ច្បាប់ ឬ បទដ្ឋានគតិយុត្ត ផ្សេងទៀត ដែលពាក់ព័ន្ធ។

៦-ក្នុងករណីអ្នកដាក់ពាក្យសុំចុះបញ្ជី ពុំបានកែតម្រូវនៅក្នុងអំឡុងពេលសមរម្យនោះទេ មន្ត្រីចុះបញ្ជី ត្រូវចេញលិខិតលើកចោលពាក្យសុំចុះបញ្ជីនោះ ហើយជូនដំណឹងទៅអ្នកដាក់ពាក្យសុំ ។

## ប្រការ ៣៣ : ការប្រគល់ឯកសារភ្ជាប់ឲ្យវិញ

ក្នុងករណីពាក្យសុំចុះបញ្ជីត្រូវបានដក ឬ លើកចោល មន្ត្រីចុះបញ្ជីត្រូវប្រគល់ឯកសារភ្ជាប់ឲ្យទៅអ្នកដាក់ពាក្យសុំវិញ បើមានការស្នើសុំ ។

## ប្រការ ៣៤ : ពាក្យសុំឲ្យពិនិត្យឡើងវិញចំពោះការលើកចោលរបស់មន្ត្រីចុះបញ្ជី

១- ការលើកចោលពាក្យសុំរបស់មន្ត្រីចុះបញ្ជី ដូចមានចែងក្នុងប្រការ ៣២ នៃប្រកាសនេះ អ្នកដាក់ពាក្យសុំចុះបញ្ជីមានសិទ្ធិដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ ទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

២- ពាក្យសុំឲ្យពិនិត្យឡើងវិញក្នុងកថាខណ្ឌទី១ ខាងលើនេះ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ពិនិត្យ និង សម្រេច ហើយជូនដំណឹងទៅអ្នកដាក់ពាក្យសុំនោះ ។

## ប្រការ ៣៥ : ចំណុចដែលត្រូវចុះបញ្ជីក្នុងសន្លឹកចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

ចំណុចដែលត្រូវចុះបញ្ជីក្នុងសន្លឹកចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ មានដូចខាងក្រោម ៖

- ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត អាសយដ្ឋានរបស់ភាគី
- កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍
- គោលបំណងនៃការចុះបញ្ជី
- មូលហេតុនៃការចុះបញ្ជី និងកាលបរិច្ឆេទ
- ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

## ប្រការ ៣៦ : អានុភាពនៃការចុះបញ្ជី

ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ មានអានុភាពនៅពេលដែលចុះហត្ថលេខា និង ប្រថាប់ត្រារបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

p

# ជំពូកទី ៧
# របៀបចុះបញ្ជី និងរបៀបរក្សាទុកក្នុងក្រូណូ

**ប្រការ ៣៧ : របៀបចុះបញ្ជីក្នុងក្រូណូទទួលពាក្យសុំ**

នៅពេលដែលមន្ត្រីចុះបញ្ជី បានទទួលពាក្យសុំចុះបញ្ជី មន្ត្រីចុះបញ្ជីត្រូវសរសេរចូលក្នុងសន្លឹកក្រដាសទទួលពាក្យសុំនូវព័ត៌មាន ដូចមានចែងក្នុងកថាខណ្ឌទី២ ប្រការ ៦ នៃប្រកាសនេះ ។

**ប្រការ ៣៨ : របៀបចុះបញ្ជីក្នុងក្រូណូចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ**

១- បន្ទាប់ពីមន្ត្រីចុះបញ្ជីបានពិនិត្យពាក្យសុំ និងឯកសារភ្ជាប់ដែលបានកំណត់ក្នុងប្រការ ១៩ (ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ) រួច មន្ត្រីចុះបញ្ជីត្រូវសរសេរចូលក្នុងសន្លឹកចុះបញ្ជីនូវចំណុចដូចខាងក្រោមនេះ ៖

- ឈ្មោះ អាសយដ្ឋាន និងថ្ងៃ ខែ ឆ្នាំកំណើតរបស់ភាគីនៃកិច្ចសន្យា
- ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា
- កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍
- គោលបំណងនៃការចុះបញ្ជី
- មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទនៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ)

២- ចំពោះសន្លឹកចុះបញ្ជីនៅក្នុងកថាខណ្ឌទី១ នៃប្រការនេះ មន្ត្រីចុះបញ្ជីត្រូវចុះលេខចុះបញ្ជីផ្អែកលើលេខរៀងទទួលពាក្យសុំ ហើយចុះហត្ថលេខាបំព្រួញដើម្បីបញ្ជាក់ថា **"បានពិនិត្យរួច"** រួចបញ្ជូនទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ពិនិត្យ និងសម្រេច។

៣- បន្ទាប់ពីទទួលបានហត្ថលេខា និងត្រារបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ មន្ត្រីចុះបញ្ជីត្រូវរក្សាទុកសន្លឹកចុះបញ្ជីនៅក្នុងក្រូណូ ទៅតាមលំដាប់លេខចុះបញ្ជី។

**ប្រការ ៣៩ : របៀបចុះបញ្ជីក្នុងក្រូណូចុះបញ្ជីអំពីការផ្លាស់ប្ដូរកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ**

១- បន្ទាប់ពីពាក្យសុំ និងឯកសារភ្ជាប់ ដែលបានកំណត់ក្នុងប្រការ ២០ (ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្ដូរកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ) ត្រូវបានពិនិត្យដោយមន្ត្រីចុះបញ្ជីរួច មន្ត្រីចុះបញ្ជីត្រូវសរសេរ គោលបំណងនៃការចុះបញ្ជី មូលហេតុ និងកាលបរិច្ឆេទ ព្រមទាំងខ្លឹមសារនៃកិច្ចសន្យាទាំងអស់ឡើងវិញ នៅក្នុងសន្លឹក **"ផ្លាស់ប្ដូរ"** ។

២- ចំពោះការផ្លាស់ប្ដូរខ្លឹមសារកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធក្នុងកថាខណ្ឌទី១ នៃប្រការនេះ មន្ត្រីចុះបញ្ជីត្រូវចុះហត្ថលេខាបំព្រួញដើម្បីបញ្ជាក់ថា **"បានពិនិត្យរួច"** រួចបញ្ជូនទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ពិនិត្យ និងសម្រេច។

៣- បន្ទាប់ពីទទួលបានហត្ថលេខា និងត្រារបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ មន្ត្រីចុះបញ្ជីត្រូវរក្សាទុកសន្លឹកចុះបញ្ជីនៅក្នុងក្រូណូ ទៅតាមលំដាប់លេខចុះបញ្ជី។

៤- ចំពោះការផ្លាស់ប្តូរឈ្មោះ ឬ អាសយដ្ឋាន មន្ត្រីចុះបញ្ជីត្រូវសរសេរឈ្មោះ ឬ អាសយដ្ឋានថ្មី មូលហេតុនៃការផ្លាស់ប្តូរ និងកាលបរិច្ឆេទនៃការផ្លាស់ប្តូរ ចូលក្នុងសន្លឹកដែលបានចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធរួចហើយ នៅក្នុងខ្ទង់ពាក់ព័ន្ធនឹង "ការផ្លាស់ប្តូរឈ្មោះ និង អាសយដ្ឋាន" រួចមន្ត្រីចុះបញ្ជីត្រូវចុះហត្ថលេខា កាលបរិច្ឆេទ និងឈ្មោះរបស់មន្ត្រីចុះបញ្ជីនោះ។

**ប្រការ ៤០ : របៀបចុះបញ្ជីក្នុងក្រូណូចុះបញ្ជីអំពីការកែតម្រូវកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ**

បញ្ញត្តិនៃប្រការ ៣៩ (របៀបចុះបញ្ជីក្នុងក្រូណូចុះបញ្ជីអំពីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ) នៃប្រកាសនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការចុះបញ្ជីអំពីការកែតម្រូវកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ។

**ប្រការ ៤១ : របៀបចុះបញ្ជីក្នុងក្រូណូចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ**

១- បន្ទាប់ពីពាក្យសុំ និងឯកសារភ្ជាប់ដែលបានកំណត់ក្នុងប្រការ ២២ (ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដោយមូលហេតុ រំលាយអាពាហ៍ពិពាហ៍ ឬ កំជាប់ពាក្យ) ប្រការ ២៣ (ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដោយមូលហេតុ មោឃភាព ការលុបចោល ឬ ការរំលាយកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ) ប្រការ ២៤ (ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដោយមូលហេតុសហព័ទ្ធណាម្នាក់បានស្លាប់) ប្រការ ២៥ (ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដោយផ្អែកលើសាលក្រម ឬ សាលដីកាស្ថាពរ រំលាយអាពាហ៍ពិពាហ៍ និងការបែងចែកទ្រព្យសម្បត្តិ) ប្រការ ២៦ (ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ តាមសេចក្តីសម្រេចរបស់តុលាការ ដោយផ្អែកលើបញ្ញត្តិនៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង) និងប្រការ ២៧ (ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដោយផ្អែកតាមសាលក្រម ឬ សាលដីកាស្ថាពរ ដែលបានកំណត់ក្នុងច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី មាត្រា ៣០ កថាខណ្ឌទី ៣ ចំណុច ឃ) ត្រូវបានពិនិត្យដោយមន្ត្រីចុះបញ្ជីរួច មន្ត្រីចុះបញ្ជីត្រូវសរសេរអំពីគោលបំណង មូលហេតុ និងកាលបរិច្ឆេទ នៅក្នុងសន្លឹកចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធត្រង់ខ្ទង់ "ការលុបការចុះបញ្ជីអំពីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ" ។

២- ចំពោះសន្លឹកចុះបញ្ជីក្នុងកថាខណ្ឌទី១ នៃប្រការនេះ មន្ត្រីចុះបញ្ជីត្រូវចុះហត្ថលេខាបំព្រួញដើម្បីបញ្ជាក់ថា **"បានពិនិត្យរួច"** រួចបញ្ជូនទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ពិនិត្យ និងសម្រេច។

៣- បន្ទាប់ពីទទួលបានហត្ថលេខា និងត្រារបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ មន្ត្រីចុះបញ្ជីត្រូវរក្សាទុកសន្លឹកចុះបញ្ជីនៅក្នុងក្រូណូ ទៅតាមលំដាប់លេខចុះបញ្ជី។

**ប្រការ ៤២ : របៀបចុះបញ្ជីក្នុងក្រូណូចុះបញ្ជីអំពីកាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍**

បន្ទាប់ពីពាក្យសុំ និងឯកសារភ្ជាប់ដែលបានកំណត់ក្នុងប្រការ ២៨ (ពាក្យសុំចុះបញ្ជីអំពីកាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍) ត្រូវបានពិនិត្យដោយមន្ត្រីចុះបញ្ជីរួច មន្ត្រីចុះបញ្ជីត្រូវសរសេរអំពី

កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍នៅខ្ទង់ "កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍" នៅក្នុងសន្លឹកចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ហើយមន្ត្រីចុះបញ្ជីត្រូវចុះហត្ថលេខា កាលបរិច្ឆេទ និងឈ្មោះរបស់មន្ត្រីចុះបញ្ជី។

**ប្រការ ៤៣ : វិធីកត់ត្រាការចុះបញ្ជីអំពីខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ**

១- ពាក់ព័ន្ធនឹងការចុះបញ្ជីអំពីខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ នៅត្រង់ខ្ទង់ "ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ" ឬ ខ្ទង់ "ការផ្លាស់ប្ដូរទ្រព្យសម្បត្តិប្ដីប្រពន្ធ" មន្ត្រីចុះបញ្ជីក៏អាចចុះថា **"ដូចខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធដែលបានភ្ជាប់មកជាមួយ"** រួចភ្ជាប់នូវលិខិតថតចម្លងនៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធនោះជាមួយគ្នាក្នុងសន្លឹកចុះបញ្ជីនៃក្រេណូបាន។ ក្នុងករណីនេះ មន្ត្រីចុះបញ្ជីត្រូវកត់ត្រានូវលេខចុះបញ្ជី និង លេខទទួល នៅក្នុងលិខិតថតចម្លងនៃកិច្ចសន្យា ដែលបានភ្ជាប់មកជាមួយនោះ ហើយមន្ត្រីចុះបញ្ជីត្រូវចុះហត្ថលេខាបំព្រួញដើម្បីបញ្ជាក់ថា "បានពិនិត្យរួច" រួចបញ្ជូនទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ពិនិត្យ និង សម្រេច។

២- ក្រោយពេលពិនិត្យ និងសម្រេចរួច រដ្ឋមន្ត្រីក្រសួងយុត្តិធម៌នឹងចុះហត្ថលេខា និងប្រថាប់ត្រានៅគ្រប់សន្លឹកនៃលិខិតថតចម្លងដែលបានភ្ជាប់មកជាមួយ។

**ប្រការ ៤៤ : របៀបចងក្រងរក្សាទុកក្នុងក្រេណូសម្រាប់ដាក់ឯកសារពាក្យសុំ**

ក្រោយពេលរដ្ឋមន្ត្រីក្រសួងយុត្តិធម៌បានចុះហត្ថលេខា និងប្រថាប់ត្រារួច មន្ត្រីចុះបញ្ជីត្រូវចងក្រងរក្សាទុកពាក្យសុំចុះបញ្ជី និង ឯកសារភ្ជាប់ក្នុងក្រេណូសម្រាប់ដាក់ឯកសារពាក្យសុំ ទៅតាមលំដាប់លេខរៀង និងកាលបរិច្ឆេទទទួលពាក្យសុំ ។

**ប្រការ ៤៥ : របៀបចងក្រងរក្សាទុកក្នុងក្រេណូលើកចោល**

នៅពេលដែលមន្ត្រីចុះបញ្ជី បានលើកចោលពាក្យសុំចុះបញ្ជី មន្ត្រីចុះបញ្ជីត្រូវចងក្រងរក្សាទុកលិខិតលើកចោលក្នុងក្រេណូលើកចោល ទៅតាមលំដាប់លេខលិខិតលើកចោល និងកាលបរិច្ឆេទ ។

**ប្រការ ៤៦ : របៀបចងក្រងរក្សាទុកក្នុងក្រេណូសម្រាប់ដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ**

ក្រោយពីបានទទួលសេចក្ដីសម្រេចចុងក្រោយរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ មន្ត្រីចុះបញ្ជីត្រូវចងក្រងរក្សាទុកសេចក្ដីសម្រេចចុងក្រោយរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ពាក្យសុំឲ្យពិនិត្យឡើងវិញ និងឯកសារភ្ជាប់ ក្នុងក្រេណូសម្រាប់ដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ ទៅតាមលំដាប់លេខពាក្យសុំឲ្យពិនិត្យឡើងវិញ និងកាលបរិច្ឆេទ ។

p

**ប្រការ ៤៧ ៖ របៀបចងក្រងរក្សាទុកក្នុងក្រួណូសម្រាប់ដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី**

រាល់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី មន្ត្រីចុះបញ្ជីត្រូវចងក្រងរក្សាទុកពាក្យសុំនោះ នៅក្នុងក្រួណូសម្រាប់ដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី ទៅតាមលំដាប់លេខនៃការទទួលពាក្យសុំឲ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី និងកាលបរិច្ឆេទ ។

## ជំពូកទី ៨
## នីតិវិធីនៃការចេញលិខិតបញ្ជាក់

**ប្រការ ៤៨ ៖ របៀបដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់**

១- ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ។

២- ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ ត្រូវដាក់នៅនាយកដ្ឋានកិច្ចការរដ្ឋប្បវេណីនៃក្រសួងយុត្តិធម៌ ។

៣- ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ ត្រូវសរសេរនូវចំណុច ដូចខាងក្រោម ៖

- គោលបំណងនៃពាក្យសុំ ៖ ការសុំឲ្យចេញលិខិតបញ្ជាក់
- ឈ្មោះ ឬ នាមករណ៍ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់
- ឈ្មោះរបស់អ្នកតំណាងនីតិបុគ្គល ក្នុងករណីដែលអ្នកដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ជានីតិបុគ្គល
- ចំណុចដែលត្រូវធ្វើការបញ្ជាក់
- ចំនួនលិខិតបញ្ជាក់
- កាលបរិច្ឆេទនៃការដាក់ពាក្យសុំ និងហត្ថលេខា ឬ ស្នាមម្រាមដៃ ។

៤- អ្នកដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ត្រូវបង់សោហ៊ុយសេវា ដូចបានកំណត់តាមបទប្បញ្ញត្តិ ឬ ប្រកាសរួម របស់ក្រសួងយុត្តិធម៌ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ប្រការ ៤៩ ៖ ការចេញលិខិតបញ្ជាក់**

១- នៅពេលបានទទួលពាក្យសុំឲ្យចេញលិខិតបញ្ជាក់ មន្ត្រីចុះបញ្ជីត្រូវថតចម្លងចេញពីសន្លឹកចុះបញ្ជីក្នុងក្រួណូចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ទៅឲ្យអ្នកដាក់ពាក្យសុំ ដោយត្រូវសរសេរនៅលើឯកសារថតចម្លងថា ៖

- បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
- កាលបរិច្ឆេទ (ថ្ងៃទី..........ខែ.........ឆ្នាំ.........)
- ហត្ថលេខាបំពេញរបស់មន្ត្រីចុះបញ្ជី និង ហត្ថលេខា និង ប្រថាប់ត្រារបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ក៏អាចឲ្យរដ្ឋលេខាធិការទទួលបន្ទុកកិច្ចការរដ្ឋប្បវេណី ចុះហត្ថលេខាជំនួសបានដែរ។

២- ក្រោយពីបានទទួលពាក្យសុំឲ្យចេញលិខិតបញ្ជាក់ ក្រសួងយុត្តិធម៌ត្រូវចេញលិខិតបញ្ជាក់ឲ្យអ្នកដាក់ពាក្យសុំនោះ ដោយពុំមានការយឺតយ៉ាវ យ៉ាងយូរបំផុតមិនឲ្យលើសពីរយៈពេល ៣ ថ្ងៃ ។

# ជំពូកទី ៩
# អវសានប្បញ្ញត្តិ

**ប្រការ ៥០ : កាលបរិច្ឆេទ នៃការអនុវត្ត**

ប្រកាសនេះ ត្រូវអនុវត្តក្រោយពេលប្រាំមួយខែបានកន្លងហួស គិតចាប់ពីថ្ងៃចុះហត្ថលេខា ។

ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១៣

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

អង្គ វង្សវឌ្ឍានៈ

p

# ឧបសម្ព័ន្ធទី២
# ទម្រង់លិខិតរដ្ឋបាល
# ពាក់ព័ន្ធនឹងការលែងលះ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

---

# កិច្ចព្រមព្រៀងលែងលះ

ខ្ញុំបាទឈ្មោះ ភេទ ប្រុស ឆ្នាំកំណើត 1980 ជនជាតិខ្មែរ-តៃឡូង មុខរបរៈ អាជីវករ និង នាងខ្ញុំឈ្មោះ ភេទ ស្រី ឆ្នាំកំណើត 1983 ជនជាតិខ្មែរ មុខរបរៈ មេផ្ទះ មានទីលំនៅបច្ចុប្បន្ន ផ្ទះលេខៈ 102 E₀ ផ្លូវលេខៈ 21 សង្កាត់ៈ ទន្លេបាសាក់ ខណ្ឌៈ ចំការមន រាជធានីភ្នំពេញ ។

សូមធ្វើកិច្ចព្រមព្រៀងលែងលះគ្នាដូចខាងក្រោម ៖

ខ្ញុំបាទឈ្មោះ ត្រូវជាប្តី និង នាងខ្ញុំឈ្មោះ ត្រូវជាប្រពន្ធ បានចាប់ផ្តើមរស់នៅជាគ្រួសារមកអស់រយៈ ចំនួន 10 ឆ្នាំមកហើយ ពុំដែលបានចុះសម្រុងគ្នាក្នុងនាមជាប្តីប្រពន្ធឡើយ តែតែងតែមានទំនាស់ជាមួយគ្នាជាប្រចាំ ទោះបីជាមានការសម្របសម្រួល សម្រុះសម្រួលពីឪពុកម្តាយ បងប្អូន ញាតិមិត្តក៏ដោយ ក៏នៅតែមិនឯកភាព និងចុះសម្រុងជាមួយគ្នាឡើយ ។ ដូច្នេះ ដើម្បីបញ្ចប់នូវភាពពុំចុះសម្រុងក្នុងគ្រួសារជាបន្តទៀត យើងខ្ញុំទាំងពីរនាក់ បានព្រមព្រៀងឯកភាពចែកផ្លូវគ្នា ដោយបញ្ឈប់ការទទួលស្គាល់គ្នាជាប្តី និងប្រពន្ធបន្តទៀត ចាប់ពីថ្ងៃខែឆ្នាំនេះតទៅ ហើយការព្រមព្រៀងនេះ គឺធ្វើឡើងដោយស្ម័គ្រចិត្ត ដោយគ្មានការគំរាមកំហែង គៀបសង្កត់ ឬបង្ខិតបង្ខំពីភាគីណាមួយឡើយ ។

ចំពោះកូនចំនួន 02 នាក់ គឺៈ

1. ឈ្មោះ ភេទប្រុស អាយុ 09 ឆ្នាំ
2. ឈ្មោះ ភេទស្រី អាយុ ០.. ឆ្នាំ

បានឯកភាពគ្នាឱ្យកូនឈ្មោះ នៅឈ្មោះ ជាឪពុក ជាអ្នកមានអំណាចមេបា និង កូនឈ្មោះ នៅឈ្មោះ ជាម្តាយ ជាអ្នកមានអំណាចមេបា ។ ហើយ ក៏បានឯកភាពគ្នាទៀតថា នឹងមិនហាមឃាត់ភាគីម្ខាងណាក្នុងការសុំជួបកូនឡើយ ។

ចំពោះ ~~[illegible]~~ ទ្រព្យសម្បត្តិ ភាគីទាំងសងខាងព្រមព្រៀងឯកភាពគ្នាបែងចែកផ្ទះដែលកំពុងរស់នៅសព្វថ្ងៃឱ្យទៅឈ្មោះ ប្រពន្ធ និង ព្រមប្រគល់ឡាន ម៉ាក ពាក់ស្លាកលេខ ឱ្យទៅ ជាប្តី ។

ពេលស្ដិនដាក់ទៅដៃក្រោយ គាត់សោកស្ដាយទៅទៀតរកពាក្យពេចន៍ថ្មីទៀត គាត់ទាំងសងខាងចាំមាន សិទ្ធិទាមទារ ស្រុតអង់អាចទីតាំងទៅវិញទៅមកទៀត ។

ក្នុងការលែង គាត់សោកស្ដាយនិងគោរពតាមពាក្យសន្យានេះ និងទទួលខុសត្រូវទាំងស្រុងនៅចំពោះមុខច្បាប់ជាធរមាន ។

ចំពោះកូនប្រុស ឈើងខ្ញុំទាំងពីរនាក់ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ម្ដាយ ។

ធ្វើនៅភ្នំពេញ ថ្ងៃ ខែ ឆ្នាំ

ភាគីទីពីរ

ស្នាមមេដៃស្ដាំភាគីខ្លួន

គំរូ
ពាក្យសុំលែងលះ
ក្នុងការព្រមព្រៀង

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យបណ្តឹងលែងលះ

**ដើមចោទ** ៖ ឈ្មោះ.................... ភេទ......... អាយុ...... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
លេខ............... មានទីលំនៅបច្ចុប្បន្ន..................................................................។

**ចុងចម្លើយ** ៖ ឈ្មោះ.................... ភេទ......... អាយុ...... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
លេខ............... មានទីលំនៅបច្ចុប្បន្ន..................................................................។

**សូមគោរពចូលមក**
**ឯកឧត្តមប្រធានសាលាដំបូង**..........................

**កម្មវត្ថុ** ៖ សុំឲ្យតុលាការចេញដីកាសម្រេច មានខ្លឹមសារដូចខាងក្រោម ៖

១- ឲ្យ ដើមចោទ និងចុងចម្លើយ ផ្តាច់សមគ្គសង្វាស់ តាមផ្លូវច្បាប់ ។

២-សម្រេចឲ្យ (ដើមចោទ/ចុងចម្លើយ) ជាអ្នកមានអំណាចមេបាលើកូនឈ្មោះ.........

៣-សម្រេចឲ្យ (ដើមចោទ/ចុងចម្លើយ) បង់អាហារកាតព្វកិច្ច និងអាចចូលសួរសុខទុក្ខកូនតាមច្បាប់កំណត់ ។

៤-សម្រេចឲ្យ ដើមចោទ មានសិទ្ធិលើទ្រព្យសម្បត្តិដូចខាងក្រោម៖

..................................................................................................................

៥-សម្រេចឲ្យ ចុងចម្លើយ មានសិទ្ធិលើទ្រព្យសម្បត្តិដូចខាងក្រោម៖

..................................................................................................................

៦-សម្រេចឲ្យ ដើមចោទ សងបំណុលដូចខាងក្រោម៖
(បើមានសូមសរសេរ)...........................................................................................

៧-សម្រេចឲ្យ ចុងចម្លើយ សងបំណុលដូចខាងក្រោម៖
(បើមានសូមសរសេរ)...........................................................................................

**យោង** ៖ -សំបុត្រអាពាហ៍ពិពាហ៍លេខ.......ចុះថ្ងៃទី...................... របស់.......................។
- ..................................................................................................................

កាលពីថ្ងៃទី.....ខែ.....ឆ្នាំ..... នាងខ្ញុំ/ខ្ញុំបាទ បាចចអាពាហ៍ពិពាហ៍ ជាឈ្មោះ......................... ។ ប៉ុន្តែក្នុងកំឡុងពេលអាពាហ៍ពិពាហ៍ ឈ្មោះនេះ (សរសេរពីមូលហេតុដែលនាំឲ្យមានការទាមទារ) .................................................................................................................................................។

អាស្រ័យហេតុនេះ សូម **ឯកឧត្តមប្រធាន** មេត្តាទទួល និងសម្រេចតាមការប្តឹងសុំខាងលើដោយក្តីអនុគ្រោះ ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

ធ្វើនៅ................... ថ្ងៃទី......... ខែ......... ឆ្នាំ២០១......

| | |
|---|---|
| ស្នាមមេដៃស្តាំចុងចម្លើយ | ស្នាមមេដៃស្តាំដើមចោទ |
| (ស្នាមមេដៃស្តាំ) | (ស្នាមមេដៃស្តាំ) |

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

លេខ 1077
ថ្ងៃទី 08 ខែ 11 ឆ្នាំ 2016

## ពាក្យបណ្តឹង

**ដើមបណ្តឹង:** ឈ្មោះ ភេទប្រុស អាយុ ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិរាជានុកូល សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង ។

**ចុងចម្លើយ:** ឈ្មោះ ភេទស្រី អាយុ ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិរកាកោង ឃុំរកាកោង១ស្រុកមុខកំពូល ខេត្តកណ្តាល ។

## សូមគោរពជូន

## លោកប្រធាន សាលាដំបូងខេត្តកណ្តាល

*សូមទានជ្រាប !*

**កម្មវត្ថុ:** សំណើសុំឱ្យតុលាការចេញសាលក្រមដោយវិនិច្ឆ័យសេចក្តីដូចខាងក្រោម:

១- សុំលែងលះពីប្រពន្ធឈ្មោះ ។

២- សុំសិទ្ធិគ្រប់គ្រង និងមានអំណាចមេបាលើកូនឈ្មោះ ភេទប្រុស អាយុ ឆ្នាំ ។

៣- សុំសិទ្ធិគ្រប់គ្រងរថយន្តម៉ាក Hilander ពណ៌ទឹកមាស សេរីឆ្នាំ២០០១ ផ្លាកលេខ ភ្នំពេញ ចំនួន០១គ្រឿង ។

៤- ផ្ទះលេខ WC សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រគល់ឱ្យកូនឈ្មោះ និងកូនឈ្មោះ ។

៥- ប្រគល់:

-ផ្ទះល្វែងនៅផ្សាររកាកោង ស្រុកមុខកំពូល ខេត្តកណ្តាល

-ដីនៅភូមិចុងព្រែក ឃុំរកាកោង២ ស្រុកមុខកំពូល ខេត្តកណ្តាល

-ដីទំហំ ២៥ម៉ែត្រ គុណ ១៤០ម៉ែត្រ នៅស្រុកមុខកំពូល ខេត្តកណ្តាល

-រថយន្តម៉ាក Lexus RX ៣០០ ពណ៌ស សេរីឆ្នាំ១៩៩៩ ផ្លាកលេខ ភ្នំពេញ ចំនួន០១គ្រឿង

-រថយន្តម៉ាក Visto ពណ៌ស ចំនួន០១គ្រឿង

-គ្រឿងអលង្ការ មួយចំនួនកំពុងលក់ដូរ

-កូនប្រុសឈ្មោះ អាយុ ឆ្នាំ ឱ្យទៅប្រពន្ធឈ្មោះ មានសិទ្ធិគ្រប់គ្រង និងមានអំណាចមេបា

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទមានកិត្តិយសសូមជម្រាប **លោកប្រធាន** មេត្តាជ្រាបថា៖ ខ្ញុំបាទឈ្មោះ និងឈ្មោះ បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាជាប្តីប្រពន្ធតាំងពីឆ្នាំ១៩៩៣ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ។ បន្ទាប់ពីខ្ញុំបាទ និងប្រពន្ធឈ្មោះ ចាប់ដៃគ្នាជាប្តីប្រពន្ធមកគឺពួកយើងខ្ញុំមានកូនប្រុសចំនួន ០២នាក់ គឺឈ្មោះ អាយុ ឆ្នាំ និងឈ្មោះ អាយុ ឆ្នាំ និងមានទ្រព្យសម្បត្តិរួមមួយចំនួនទៀត ។ ប៉ុន្តែដោយហេតុថា ការរួមរស់ជាមួយគ្នាមិនចុះសម្រុងគ្នា ណាមួយខ្ញុំបាទ និងប្រពន្ធបានរស់នៅបែកគ្នាអស់រយៈពេល ៥-៦ឆ្នាំមកហើយ ជាក់ស្តែងខ្ញុំបាទអស់មនោសញ្ចេតនាជាប្តីប្រពន្ធតទៅទៀតហើយ ហេតុដូច្នេះ ខ្ញុំបាទប្តឹងសុំឱ្យតុលាការចេញសាលក្រមដោយវិនិច្ឆ័យសេចក្តីដូចខាងក្រោម:

១- សុំលែងលះពីប្រពន្ធឈ្មោះ ។

២- សុំសិទ្ធិគ្រប់គ្រង និងមានអំណាចមេបាលើកូនឈ្មោះ ភេទប្រុស អាយុ ឆ្នាំ ។

៣- សុំសិទ្ធិគ្រប់គ្រងលើរថយន្តម៉ាក Hilander ពណ៌ទឹកមាស សេរីឆ្នាំ២០០១ ផ្លាកលេខ ភ្នំពេញ ចំនួន០១គ្រឿង ។

៤- ផ្ទះលេខ WC សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រគល់ឱ្យកូនឈ្មោះ និងកូនឈ្មោះ ។

៥- ប្រគល់:

-ផ្ទះល្វែងនៅផ្សាររកាកោង ស្រុកមុខកំពូល ខេត្តកណ្តាល

-ដីនៅភូមិចុងព្រែក ឃុំរកាកោង២ ស្រុកមុខកំពូល ខេត្តកណ្តាល

-ដីទំហំ ២៥ម៉ែត្រ គុណ ១៥០ម៉ែត្រ នៅស្រុកមុខកំពូល ខេត្តកណ្តាល

-រថយន្តម៉ាក Lexus RX ៣០០ ពណ៌ស សេរីឆ្នាំ១៩៩៩ ផ្លាកលេខ ភ្នំពេញ ចំនួន០១គ្រឿង

-រថយន្តម៉ាក Visto ពណ៌ស ចំនួន០១គ្រឿង

-គ្រឿងអលង្ការ មួយចំនួនកំពុងលក់ដូរ

-កូនប្រុសឈ្មោះ អាយុ ឆ្នាំ ឱ្យទៅប្រពន្ធឈ្មោះ មានសិទ្ធិគ្រប់គ្រង និងមានអំណាចមេបា

អាស្រ័យសេចក្តីដូចបានជម្រាបជូនខាងលើ សូម **លោកប្រធាន** មេត្តាពិនិត្យ ទទួល និងសម្រេចតាមពាក្យបណ្តឹងរបស់ខ្ញុំបាទ ដូចមានចែងក្នុងកម្មវត្ថុខាងលើ ដោយក្តីអនុគ្រោះ ។

សូម **លោកប្រធាន** ទទួលនូវការគោរពអានដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

ធ្វើនៅ, ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៦

**ស្នាមមេដៃស្តាំ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមហ៊ុនមេធាវី ខ្មែរអប្សរា
KHMER APSARA LAW FIRM
លេខ.................ក ម ខ អ /១៩

សាលាដំបូងខេត្តកណ្ដាល
ចូល
លេខ: 198
ថ្ងៃទី 28 ខែ 01 ឆ្នាំ 2019
ម៉ោង 3 និង 07 នាទី

# ពាក្យសុំតំណាងដោយអាណត្តិ

ខ្ញុំបាទមេធាវី អត្តលេខ: និងលោកមេធាវី អត្តលេខ: ជាសមាជិកមេធាវីនៃ **ក្រុមហ៊ុនមេធាវី ខ្មែរអប្សរា** និងជាមេធាវីតំណាងដោយអាណត្តិឱ្យឈ្មោះ ក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ: ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់សាលាដំបូងខេត្តកណ្ដាល។

ទូរស័ព្ទទំនាក់ទំនងលេខ: /

**សូមគោរពជូន**
**លោក ប្រធានសាលាដំបូងខេត្តកណ្ដាល**

*សូមទានជ្រាប។*

**កម្មវត្ថុ:** ស្ដីពីមេធាវីតំណាងដោយអាណត្តិនៅក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ: ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់សាលាដំបូងខេត្តកណ្ដាល។

28/01/19

**យោង:**
- ច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី
- ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា
- លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិរបស់ឈ្មោះ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៩។

តបតាមកម្មវត្ថុ និងយោងខាងលើ យើងខ្ញុំសូមជម្រាបជូន **លោកប្រធាន** មេត្តាជ្រាបថា: ឈ្មោះ បានប្រគល់សិទ្ធិឱ្យយើងខ្ញុំ ធ្វើជាមេធាវីតំណាងដោយអាណត្តិ និងមានសិទ្ធិអំណាចធ្វើកិច្ចការអាណត្តិនៅក្នុងសំណុំរឿងរដ្ឋប្បវេណីដូចមានចែងក្នុងកម្មវត្ថុខាងលើ។

អាស្រ័យហេតុនេះ សូម **លោកប្រធាន** មេត្តាទទួលស្គាល់យើងខ្ញុំជាមេធាវីតំណាងនៅក្នុងរឿងរដ្ឋប្បវេណីខាងលើនេះទៅតាមនីតិវិធីច្បាប់ ដោយក្ដីអនុគ្រោះ។

*ថ្ងៃច័ន្ទ ៨រោច ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២*
*រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៩*

មេធាវី. មេធាវី.

AVOCAT ATTORNEY AT LAW
KINGDOM OF CAMBODIA

អាស័យដ្ឋាន: ផ្ទះលេខ ៥A, ផ្លូវលេខ ២៨៥, សង្កាត់បឹងកក់១, ខណ្ឌទួលគោក, រាជធានីភ្នំពេញ
ទូរស័ព្ទលេខ: ០៩៩ ៧១៦ ៦៧១ / ០១៦ ៧១៦ ៦៧១ Email: pich_sorya@yahoo.com / web: apsaralaw.com

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ

នាងខ្ញុំឈ្មោះ                    អាយុ     ជនជាតិខ្មែរ សញ្ជាតិខ្មែរ អាសយដ្ឋានបច្ចុប្បន្ន ភូមិរកាកោង ឃុំរកាកោង១ ស្រុកមុខកំពូល ខេត្តកណ្ដាល។

## សូមប្រគល់សិទ្ធិជូន

លោកមេធាវី **ពេជ្រ សូរិយា** អត្តលេខ: ៥១៣ លោកមេធាវី **គីម សម្បត្តិ** អត្តលេខ: ១២៣៣ ជាសមាជិកមេធាវីនៃ **ក្រុមហ៊ុនមេធាវី ខ្មែរអរប្បេរា** ដែលមានការិយាល័យផ្ទះលេខ       ផ្លូវលេខ២៨៥ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ដើម្បីធ្វើជាមេធាវីតំណាងដោយអាណត្តិ និងធ្វើកិច្ចការដោយអាណត្តិឱ្យនាងខ្ញុំនៅក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ:              ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់សាលាដំបូងខេត្តកណ្ដាល។

**<u>បញ្ជាក់:</u>** រាល់ការចំណាយលើការបង់ពន្ធ ឬការចំណាយផ្សេងៗពាក់ព័ន្ធទៅនឹងរឿងក្ដីជាបន្ទុករបស់នាងខ្ញុំជាអាណត្តិទាយក។ ក្នុងករណីមិនបានគោរពកាតព្វកិច្ចនេះ នាងខ្ញុំសុខចិត្តទទួលខុសត្រូវនូវរាល់ការខាតបង់ផលប្រយោជន៍នានាដោយខ្លួនឯង។

លោក **មេធាវី** ដែលបានទទួលសិទ្ធិធ្វើជាមេធាវីតំណាងដោយអាណត្តិ មានសិទ្ធិអំណាចធ្វើជំនួសនូវរាល់បណ្ដឹងដែលពាក់ព័ន្ធក្នុងរឿងក្ដី និងធ្វើនូវរាល់សកម្មភាពដែលស្របទៅនឹងស្មារតីនៃក្រមនីតិវិធីរដ្ឋប្បវេណីចាប់ពីថ្ងៃដែលនាងខ្ញុំផ្ដិតមេដៃនេះតទៅ។

*ថ្ងៃច័ន្ទ ៨រោច ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២*
*រាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៩*
**ស្នាមមេដៃស្ដាំ**

**បានឃើញ និង យល់ព្រម**
*ថ្ងៃច័ន្ទ ៨រោច ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២*
*រាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៩*

មេធាវី
AVOCAT
ATTORNEY
AT LAW
KINGDOM OF CAMBODIA

មេធាវី.          មេធាវី.

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល
ចូល លេខៈ 390
ថ្ងៃទី 27 ខែ 02 ឆ្នាំ 2019
ម៉ោង 2 និង 50 នាទី

## សេចក្ដីថ្លែងការណ៍

ខ្ញុំបាទឈ្មោះ ភេទប្រុស អាយុ ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានទីលំនៅ បច្ចុប្បន្ន ភូមិរាជានុកូល សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង។

## សូមគោរពជូន

## លោក គឹម រ័ត្នណារិន ចៅក្រមសាលាដំបូងខេត្តកណ្ដាល

**កម្មវត្ថុ** ៖ សំណើសុំផ្លាស់ប្ដូរសេចក្ដីថ្លែងការណ៍ ក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ ចុះថ្ងៃទី ០៨ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់សាលាដំបូងខេត្តកណ្ដាល។

**យោង** ៖ -ដីកាកោះ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកណ្ដាល។
-សេចក្ដីថ្លែងការណ៍ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៩។
-ពាក្យបណ្ដឹង ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៦។
-សំណុំរឿងរដ្ឋប្បវេណីលេខ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់សាលាដំបូងខេត្តកណ្ដាល។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមជម្រាបជូន **លោកចៅក្រម** មេត្តាជ្រាបថា៖ ខ្ញុំបាទឈ្មោះ និងឈ្មោះ បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាជាប្ដីប្រពន្ធតាំងពីឆ្នាំ ១៩៩៣។ បន្ទាប់ពីខ្ញុំបាទ និងប្រពន្ធឈ្មោះ ចាប់ដៃគ្នាជាប្ដីប្រពន្ធមកគឺពួកយើងខ្ញុំមានកូនប្រុសចំនួន ០២នាក់ គឺឈ្មោះ អាយុ ឆ្នាំ និងឈ្មោះ អាយុ ១២ឆ្នាំ និងមានទ្រព្យសម្បត្តិរួមមួយចំនួនទៀត។ **<u>ប៉ុន្តែដោយហេតុថា</u>** ការរួមរស់ជាមួយគ្នាមិនចុះសម្រុងគ្នា ណាមួយខ្ញុំបាទអស់មនោសញ្ចេតនាជាប្ដីប្រពន្ធតទៅទៀតហើយ ហេតុនេះខ្ញុំបាទឈ្មោះ សុខចិត្តដាក់ពាក្យបណ្ដឹងសុំលែងលះទៅសាលាដំបូងខេត្តកណ្ដាល។

តាមខ្លឹមសារនៃពាក្យបណ្ដឹង ទ្រព្យសម្បត្តិរួមទាំងអស់ដូចដែលបានរៀបរាប់បានប្រគល់ឱ្យម្ដាយ និងកូនពីរនាក់ តែតាមសេចក្ដីថ្លែងការណ៍ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៩ ទ្រព្យរួមទាំងនោះខ្ញុំបានសម្រេចប្រគល់ឱ្យម្ដាយ និងកូនស្រីឈ្មោះ តែពីរនាក់ ម្ដាយនិងកូនតែប៉ុណ្ណោះ ចំណែកឯកូនឈ្មោះ ជាបន្ទុករបស់ខ្ញុំបាទ មិនឱ្យទាមទារទ្រព្យសម្បត្តិទាំងនោះទេ។ ក្រោយពីតុលាការខេត្តកណ្ដាលមានចំណាត់ការលើរឿងក្ដីខ្ញុំបាទ និងក្រោយពីខ្ញុំបាទធ្វើសេចក្ដីថ្លែងការណ៍ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៩ កន្លងមកឃើញថា ភាគីឈ្មោះ ចេះតែបង្កបញ្ហា ដែលធ្វើឱ្យរាំងស្ទះនីតិវិធីរបស់តុលាការ ផ្ទុយពីអ្វីដែលខ្ញុំបាទបានសន្យាខាងលើ ទើបខ្ញុំបាទសម្រេចចិត្តកែប្រែសេចក្ដីថ្លែង

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងខេត្តកណ្ដាល
លេខ: 486
ថ្ងៃទី 14 ខែ 3 ឆ្នាំ 2019
ម៉ោង 8 និង 10 នាទី

# ពាក្យសុំបញ្ចូលភស្តុតាង

នាងខ្ញុំឈ្មោះ ជាចុងចម្លើយនៅក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ: ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់សាលាដំបូងខេត្តកណ្ដាល។

## សូមគោរពចូលមក

## លោក គីម រ័ត្នណារិន អនុប្រធានសាលាដំបូងខេត្តកណ្ដាល

*សូមទានជ្រាប។*

**កម្មវត្ថុ៖** ស្នើសុំបញ្ចូលភស្តុតាងក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ: ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់សាលាខេត្តកណ្ដាល។

**យោង៖** សំណុំរឿងរដ្ឋប្បវេណីលេខ: ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់សាលាខេត្តកណ្ដាល។

តបតាមកម្មវត្ថុ និងយោងខាងលើ នាងខ្ញុំសូមជម្រាបជូន **លោកចៅក្រម** មេត្តាជ្រាបថា: កាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៩ តុលាការបានបញ្ចប់នីតិវិធីត្រៀមទាញហេតុផលលើកទី២ ចំពោះសំណុំរឿងរដ្ឋប្បវេណីលេខ: ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់សាលាដំបូងខេត្តកណ្ដាល ហើយតុលាការបានទុកពេលវេលាឲ្យចំនួន ០២សប្ដាហ៍ ដើម្បីភាគីដាក់បញ្ចូលភស្តុតាង។ ដូចនេះ ដើម្បី **លោកចៅក្រម** មានមូលដ្ឋានកាន់តែរឹងមាំក្នុងការពិចារណា និងសម្រេចសេចក្ដីក្នុងសំណុំរឿងខាងលើ នាងខ្ញុំសូមអនុញ្ញាតដាក់បញ្ចូលភស្តុតាងដូចខាងក្រោម៖

១. សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ លេខ: ០៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៤ ចេញដោយមេឃុំរការកោង២។

២. សំបុត្របញ្ជាក់កំណើត លេខ: ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៩ របស់កូនប្រុសច្បងឈ្មោះ ចេញដោយមេឃុំរការកោង២។

៣. សំបុត្របញ្ជាក់កំណើត លេខ: ៧៧ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៩ របស់កូនស្រីឈ្មោះ ចេញដោយមេឃុំរការកោង២។

៤. សៀវភៅស្នាក់នៅ លេខ: ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១០។

៥. ដី មានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី លេខ: / រកII ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៨ បញ្ជាក់ដោយមេឃុំរការកោង២។

៦. ដី មានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី លេខ: / រកII ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៨ បញ្ជាក់ដោយមេឃុំរការកោង២។

៧. ដី មានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី លេខ: មព ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០៦ បញ្ជាក់ដោយអភិបាលរងស្រុកមុខកំពូល។

សាលាដំបូងខេត្តបន្ទាយមានជ័យ
លេខ...
ថ្ងៃទី... ខែ... ឆ្នាំ...
ម៉ោង...

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យសុំឲ្យកោះហៅសាក្សី

ខ្ញុំបាទឈ្មោះ                    អាយុ២៨ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិ២ សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ជាចុងចំលើយ (                    )

**សូមគោរពជូន**

**លោកប្រធានសាលាដំបូងខេត្តបន្ទាយមានជ័យ**

<u>កម្មវត្ថុ</u> សំណើសុំកោះហៅសាក្សីឲ្យចូលមកឆ្លើយបំភ្លឺក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នាថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៨ ម៉ោង៨ព្រឹក។

<u>យោង</u> .សំណុំរឿងរដ្ឋប្បវេណីលេខ      ចុះថ្ងៃទី០៦.១១.២០១៨ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ។

តាមកម្មវត្ថុ និង យោងខាងលើនេះ ខ្ញុំបាទ សូមគោរពជំរាបជូន **លោកប្រធាន**មេត្តាជ្រាបថា ៖ ខ្ញុំបាទត្រូវបានប្រពន្ធឈ្មោះ                    ប្តឹងសុំលែងលះពីខ្ញុំបាទ។ ព័ន្ធរឿងក្តីនេះ មានការវិវាទក្នុងរឿងទ្រព្យសម្បត្តិ ខ្ញុំសូមបញ្ជាក់ថា ចំពោះទ្រព្យសម្បត្តិមានដី និងផ្ទះនៅលើដី និងម៉ូតូមួយគ្រឿងដែលប្រពន្ធទាមទារថាជាទ្រព្យរួមនោះ គឺមិនត្រឹមត្រូវទេ។ ដី និងផ្ទះនៅលើដី និងម៉ូតូមួយគ្រឿងជាទ្រព្យសម្បត្តិដោយឡែករបស់ខ្ញុំបាទ គឺ៖

១.ដី និងផ្ទះនៅលើដី ជារបស់ឪពុកម្តាយខ្ញុំបាទ ចែកឲ្យក្រោយពេលរៀបការ។

២.ម៉ូតូ១គ្រឿង គឺជាម៉ូតូដែលប្អូនខ្ញុំបាទឈ្មោះ                    ឲ្យខ្ញុំបាទខ្ចីជិះទៅធ្វើការ មានសាក្សីដឹងលឺ ៖

.ឈ្មោះ                    ភេទស្រី អាយុ      ឆ្នាំ នៅភូមិ២ សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ជាម្តាយខ្ញុំបាទ។

.ឈ្មោះ                    ភេទប្រុស អាយុ      ឆ្នាំ នៅភូមិសូភី សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

ខ្ញុំបាទមានសំណូមពរ សុំឲ្យតុលាការកោះអញ្ជើញសាក្សី ដើម្បីបំភ្លឺការពិតជូនតុលាការពេលសវនាការ។

អាស្រ័យដូចបានគោរពជូនខាងលើនេះសូម **ប្រធាន** មេត្តាសំរេច តាមសំណូមពរ ខ្ញុំបាទ ដោយក្តីអនុគ្រោះ។

សូម **លោកប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

ធ្វើនៅថ្ងៃទី ១៥ ខែវិច្ឆកា ឆ្នាំ២០១៨

ស្នាមមេដៃស្តាំ

បញ្ជូនទៅ...
ដើម្បីចាត់ការតាមនីតិវិធីច្បាប់
បន្ទាយមានជ័យ, ថ្ងៃទី 15 ខែ 11 ឆ្នាំ 2018
ប្រធានសាលាដំបូង

28/2

PLG PEACE LAW GROUP

ក្រុមមេធាវី សន្តិភាព
PEACE LAW GROUP
លេខ: ៩៧៨ ក.ម.ស

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

3389 2h30
02 9 19

## ពាក្យសុំថតចម្លងសំណុំរឿង

ខ្ញុំបាទឈ្មោះ អត្តលេខៈ ជាមេធាវីនៅការិយាល័យ **ក្រុមមេធាវីសន្តិភាព** មានទីស្នាក់ការផ្ទះលេខ២៩C ផ្លូវលេខ២៨០ សង្កាត់អូឡាំពិក ខណ្ឌចំការមន រាជធានីភ្នំពេញ ជាមេធាវី តំណាងដោយអាណត្តិ ឲ្យឈ្មោះ ។

**សូមគោរពចូលមក**

**ឯកឧត្តមប្រធានសាលាឧទ្ធរណ៍**

*ជាទីគោរព !*

**__កម្មវត្ថុ__**: សុំថតចម្លងឯកសារក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ:២៣២ ចុះថ្ងៃទី ០២ ខែឧសភា ឆ្នាំ ២០១៩ របស់សាលាឧទ្ធរណ៍ ។

**__យោង__**: - ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី
- ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា
- លិខិតតំណាងដោយអាណត្តិចុះថ្ងៃទី ៣០.០៨.២០១៩ របស់ក្រុមមេធាវីសន្តិភាព។

តាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំបាទសូមជំរាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថាៈ ខ្ញុំបាទបានទទួលសិទ្ធិជាមេធាវីតំណាងដោយអាណត្តិឲ្យឈ្មោះ ក្នុងសំណុំរឿងខាងលើគឺពុំទាន់បានថតចម្លងឯកសារក្នុងសំណុំរឿង នៅឡើយ។

អាស្រ័យហេតុនេះសូម **ឯកឧត្តមប្រធាន** មេត្តាចាត់ថតចម្លងឯកសារក្នុងសំណុំរឿងផ្តល់ដល់រូប ខ្ញុំបាទដោយសេចក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

ថ្ងៃ សុក្រ ១កើត ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៩

**ហត្ថលេខា និងត្រា**

AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

មេធាវី.

26/19

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្ដាល**

## លិខិតអញ្ជើញ

**យើង គីម រ័ត្នណារិន ចៅក្រមសាលាដំបូងខេត្តកណ្ដាល**

អញ្ជើញ ៖ មេធាវី អត្តលេខ នៃក្រុមមេធាវី មានអាសយដ្ឋាននៅ ផ្ទះលេខ ១០-B2 E₀E, ផ្លូវលេខ ២១១ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ជាមេធាវីតំណាងអាណត្តិឱ្យ ឈ្មោះ ។

| | |
|---|---|
| សញ្ញាណរឿងក្ដី និង ភាគី | សំណុំរឿងរដ្ឋប្បវេណីលេខ ១០៧៧ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៦<br>ការទាមទារដោយដើមចោទ ៖ **ប្ដឹងសុំលែងលះប្រពន្ធ**<br>+ ដើមចោទឈ្មោះ អាទ ប្រុស<br>+ ចុងចម្លើយឈ្មោះ អាទ ស្រី |
| កាលបរិច្ឆេទ និងទីកន្លែងដែលបង្ហាញខ្លួន | ថ្ងៃទី ២២ ខែ មេសា ឆ្នាំ **២០១៩** វេលាម៉ោង ០២ និង ០០ នាទី~~ព្រឹក~~/រសៀល<br>☑ សាលាដំបូងខេត្តកណ្ដាល ☐ បន្ទប់សវនាការទី....... ☑ បន្ទប់ "ឆ" |
| ប្រភេទនៃកាលបរិច្ឆេទ<br>( សំគាល់ដោយសញ្ញា ☑ ) | ☐ នីតិវិធីត្រៀម ☑ ទាញហេតុផលផ្ទាល់មាត់ ☐ ប្រកាសសាលក្រម<br>.................................................................................................... |
| ប្រភេទនៃឯកសារភ្ជាប់មកជាមួយ<br>( សំគាល់ដោយសញ្ញា ☑ ) | ឯកសារស្ដីពីចំណុចនៃការសាកសួរ<br>ឯកសារស្ដីពីចំណុចនៃការធ្វើកោសល្យវិច្ច័យ |
| ទណ្ឌកម្មជាអាទិ៍ក្នុងករណីដែលមិនបង្ហាញ ខ្លួនដោយគ្មានមូល ហេតុ ត្រឹមត្រូវ | -បើដើមចោទមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទលើកទី១ នៃនីតិវិធីត្រៀមសំរាប់ ការទាញហេតុផលទេតុលាការត្រូវច្រានចោលការទាមទាររបស់ដើមចោទនោះ ដោយសាលក្រមកំបាំង មុខ តាមមាត្រា២០០ នៃក្រមនីតិវិធិរដ្ឋប្បវេណី ។<br>-បើចុងចំលើយមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទលើកទី១ នៃនីតិវិធីត្រៀម សំរាប់ការទាញហេតុផលទេ តុលាការត្រូវបញ្ឈប់នីតិវិធីត្រៀមសំរាប់ការទាញ ហេតុផលដោយភ្លាមៗ ហើយកំណត់នូវកាលបរិច្ឆេទលើកទី១ នៃការទាញ ហេតុ ផលដោយផ្ទាល់មាត់ តាមមាត្រា ២០១ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។ |

សូមបង្ហាញខ្លួនដូច ដែលបានចែងខាងលើនេះ ។

ថ្ងៃពុធ ១៤រោច ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
កណ្ដាល, ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៩
**ចៅក្រម**

**គីម រ័ត្នណារិន**

យើង........................................ជា.......................
បានប្រគល់ដីកាកោះនេះឱ្យឈ្មោះ....................................
មានទីលំនៅបច្ចុប្បន្ននៅភូមិ...........................ឃុំ............
ស្រុក...........................ខេត្ត.........................នៅថ្ងៃទី
.................ខែ................ឆ្នាំ..............ហើយយើងបាន
ប្រាប់ថាសាមីខ្លួន ត្រូវប្រគល់ចុងដីកាកោះនេះ ដល់ក្រឡាបញ្ជី នៅពេលដែលខ្លួនចូលទៅចំពោះមុខតុលាការខេត្តកណ្ដាល។

**អ្នកទទួល** **អ្នកប្រគល់**

ក្រឡាបញ្ជី នៅ សុភាព

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល

# ដីកាកោះ

**យើង គឹម រ័ត្នណារិន ចៅក្រមសាលាដំបូងខេត្តកណ្ដាល**

អញ្ជើញ ៖ ឈ្មោះ ភេទ ស្រី អាយុ ឆ្នាំ សញ្ជាតិខ្មែរ មានអាសយដ្ឋានបច្ចុប្បន្ននៅ ភូមិរកាកោង ឃុំរកាកោង១ ស្រុកមុខកំពូល ខេត្តកណ្ដាល ជាចុងចម្លើយ។

| | |
|---|---|
| សញ្ញាណរឿងក្តី និង ភាគី | សំណុំរឿងរដ្ឋប្បវេណីលេខ ១០៧៧ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៦<br>ការទាមទារដោយដើមចោទ ៖ ប្តឹងសុំលែងលះប្រពន្ធ<br>+ ដើមចោទឈ្មោះ ភេទ ប្រុស<br>+ ចុងចម្លើយឈ្មោះ ភេទ ស្រី |
| កាលបរិច្ឆេទ និងទីកន្លែងដែលបង្ហាញខ្លួន | ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១៩ វេលាម៉ោង [illegible] និង [illegible] នាទី ~~ព្រឹក~~/រសៀល<br>☑សាលាដំបូងខេត្តកណ្ដាល ☐បន្ទប់សវនាការទី....... ☑បន្ទប់ "ឆ" |
| ប្រភេទនៃកាលបរិច្ឆេទ<br>( សំគាល់ដោយសញ្ញា ☑ ) | ☐នីតិវិធីត្រៀម ☑ទាញហេតុផលផ្ទាល់មាត់ ☐ប្រកាសសាលក្រម<br>.............................................................................................. |
| ប្រភេទនៃឯកសារភ្ជាប់មកជាមួយ<br>( សំគាល់ដោយសញ្ញា ☑ ) | ឯកសារស្តីពីចំណុចនៃការសាកសួរ<br>ឯកសារស្តីពីចំណុចនៃការធ្វើកោសល្យវិច្ច័យ |
| ទណ្ឌកម្មជាអាទិ៍ក្នុងករណីដែលមិនបង្ហាញ ខ្លួនដោយគ្មានមូល ហេតុ ត្រឹមត្រូវ | -បើដើមចោទមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទលើកទី១ នៃនីតិវិធីត្រៀមសំរាប់ ការទាញហេតុផលទេតុលាការត្រូវច្រានចោលការទាមទាររបស់ដើមចោទនោះ ដោយសាលក្រមកំបាំង មុខ តាមមាត្រា២០០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។<br>-បើចុងចំលើយមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទលើកទី១ នៃនីតិវិធីត្រៀម សំរាប់ការទាញហេតុផលទេ តុលាការត្រូវបញ្ឈប់នីតិវិធីត្រៀមសំរាប់ការទាញ ហេតុផលដោយភ្លាមៗ ហើយកំណត់នូវកាលបរិច្ឆេទលើកទី១ នៃការទាញ ហេតុ ផលដោយផ្ទាល់មាត់ តាមមាត្រា ២០១ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។ |

សូមបង្ហាញខ្លួនដូច ដែលបានចែងខាងលើនេះ ។

ថ្ងៃពុធ ១៤រោច ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
កណ្ដាល ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៩
ចៅក្រម

គឹម រ័ត្នណារិន

យើង................................ជា......................
បានប្រគល់ដីកាកោះនេះឱ្យឈ្មោះ..............................
មានទីលំនៅបច្ចុប្បន្ននៅភូមិ........................ឃុំ........................
ស្រុក........................ខេត្ត........................នៅថ្ងៃទី
............ខែ............ឆ្នាំ............ហើយយើងបាន
ប្រាប់ថាសាមីខ្លួន ត្រូវប្រគល់ចុងដីកាកោះនេះ ដល់ក្រឡាបញ្ជី នៅពេលដែលខ្លួនចូលទៅចំពោះមុខតុលាការខេត្តកណ្ដាល។

អ្នកទទួល　　　　　　អ្នកប្រគល់

ក្រឡាបញ្ជី នៅ សុភារ៉ា

សាលាដំបូងខេត្តកណ្តាល
ចូល
លេខៈ 628
ថ្ងៃទី 24 ខែ 5 ឆ្នាំ 2017
ម៉ោង 9 និង 37 នាទី

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## លិខិតស្នើសុំពន្យាពេលនីតិវិធីត្រៀម

ខ្ញុំបាទ ជាសមាជិកនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងជាតំណាងដោយអាណត្តិអោយឈ្មោះ ក្នុងសំណុំរឿងរដ្ឋប្បវេណីលេខៈ ចុះថ្ងៃទី០៨-១១-២០១៦ របស់សាលាដំបូងខេត្តកណ្តាល។

សូមគោរពចូលមក

## លោកប្រធានសាលាដំបូងខេត្តកណ្តាល

*សូមទានជ្រាប។*

**កម្មវត្ថុៈ** សុំពន្យាពេលក្នុងការចូលរួមត្រៀមទាញហេតុផល ក្នុងសំណុំរឿងរដ្ឋប្បវេណីលេខៈ ចុះថ្ងៃទី ០៨-១១-២០១៦ របស់សាលាដំបូងខេត្តកណ្តាល ដែលត្រូវធ្វើឡើងនៅថ្ងៃទី២៥-០៥-២០១៧ វេលាម៉ោង២រសៀល នោះមួយរយៈសិន។

**យោងៈ** - សំណុំរឿងរដ្ឋប្បវេណីលេខៈ ចុះថ្ងៃទី០៨-១១-២០១៦ របស់សាលាដំបូងខេត្តកណ្តាល។

- លិខិតតំណាងអាណត្តិ របស់ឈ្មោះ ចុះថ្ងៃទី២៣-០៥-២០១៧។

តបតាមកម្មវត្ថុនិងយោងខាងលើនេះ ខ្ញុំបាទសូមជំរាប **លោកប្រធាន** អោយបានជ្រាបថាៈ នៅថ្ងៃទី២៣-០៥-២០១៧ ឈ្មោះ ទើបតែបានមកពឹងពាក់ខ្ញុំបាទអោយតំណាងអាណត្តិក្នុងសំណុំរឿងខាងលើ ហើយខ្ញុំបាទមិនទាន់បានថតចំលងសំណុំរឿងនៅឡើយ ដូចនេះធ្វើអោយខ្ញុំបាទមិនមានពេលគ្រប់គ្រាន់ដើម្បីមើលសំណុំរឿង ដែលជាហេតុអាចធ្វើអោយខូចប្រយោជន៍យ៉ាងធ្ងន់ធ្ងរចំពោះកូនក្តីខ្ញុំបាទ។

អាស្រ័យហេតុនេះសូម **លោកប្រធាន** មេត្តាជួយពន្យាពេលមួយរយៈពេល ដោយអនុគ្រោះផងចុះ។

សូម **លោកប្រធាន** មេត្តាទទួលនូវការគោរពរាប់អានដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៧

ហត្ថលេខា និងត្រា

មេធាវី.

សាលាដំបូងខេត្តកណ្ដាល
លេខ: 609
ថ្ងៃទី 01 ខែ 4 ឆ្នាំ 2019
ម៉ោង 8 និង 20 នាទី

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យសុំពន្យារពេល

នាងខ្ញុំឈ្មោះ អាយុ ឆ្នាំ មានទីលំនៅបច្ចុប្បន្ន ភូមិរកាកោង ឃុំរកាកោង១ ស្រុកមុខកំពូល ខេត្តកណ្ដាល ជាចុងចម្លើយក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ: ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់សាលាដំបូងខេត្តកណ្ដាល។

## សូមគោរពចូលមក
## លោក គីម រ័ត្នណារិន ចៅក្រមសាលាដំបូងខេត្តកណ្ដាល

*សូមទានជ្រាប។*

**កម្មវត្ថុ:** សំណើសុំពន្យាពេលចូលរួមទាញហេតុផលដោយផ្ទាល់មាត់ ដែលនឹងប្រព្រឹត្តិទៅនៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៨ វេលាម៉ោង ០៨:០០ព្រឹក ទៅពេលក្រោយ។

**យោង:**
- សំណុំរឿង[redacted]: ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់សាលាដំបូងខេត្តកណ្ដាល
- ដីកាកោះ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកណ្ដាល។

តបតាមកម្មវត្ថុ និងយោងខាងលើ នាងខ្ញុំសូមជម្រាបជូន **លោកចៅក្រម** មេត្តាជ្រាបថា: នាងខ្ញុំបានទទួលដីកាកោះដើម្បីទាញហេតុផលដោយផ្ទាល់មាត់ នៅក្នុងសំណុំរឿងរដ្ឋប្បវេណីខាងលើ កាលពីពេលថ្មីៗកន្លងទៅនេះ ប៉ុន្តែ ដោយសារនាងខ្ញុំមានជម្ងឺ ពុំអាចចូលរួមបាន។ ហេតុដូច្នេះ នាងខ្ញុំពុំអាចចូលរួមការទាញហេតុផលដោយផ្ទាល់មាត់តាមដីកាកោះរបស់លោកបានឡើយ។

អាស្រ័យហេតុនេះ សូម **លោកចៅក្រម** មេត្តាពិនិត្យ និងសម្រេចលើកពេលទាញហេតុផលដោយផ្ទាល់មាត់ តាមកាលបរិច្ឆេទខាងលើនេះ ទៅពេលក្រោយ ដោយក្ដីអនុគ្រោះ។

សូមលោក **លោកចៅក្រម** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ។

*ថ្ងៃ...... ខែ...... ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២*
*ធ្វើនៅថ្ងៃទី..០១.. ខែ..មេសា..ឆ្នាំ២០១៩*

**ស្នាមមេដៃស្ដាំ**

ព្រះរាជាណាចក្រកម្ពុជា
មេធាវី
AVOCAT
ATTORNEY
AT LAW
KINGDOM OF CAMBODIA

01.04.19

មេធាវី.

ក្រឡាបញ្ជី សក ស័ក្តិសម

24/5

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាឧទ្ធរណ៍**

# លិខិតអញ្ជើញ

សំណុំរឿងរដ្ឋប្បវេណី

អញ្ជើញមេធាវី ជាអ្នកតំណាងដោយអាណត្តិឱ្យឈ្មោះ ។
អាសយដ្ឋានបច្ចុប្បន្ន៖ ផ្ទះលេខ ២៩C ផ្លូវ២៨០ សង្កាត់អូរឡាំពិក ខណ្ឌចំការមន រាជធានីភ្នំពេញ ។

| | |
|---|---|
| **សញ្ញាណនៃរឿងក្តី(លេខនិងភាគី) លែងលះ** | សំណុំរឿងក្តីលេខ ២៣២ ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៩<br>-ដើមចោទឈ្មោះ ភេទស្រី អាយុ ២៨ឆ្នាំ ជនជាតិខ្មែរ<br>-ចុងចម្លើយឈ្មោះ ភេទប្រុស អាយុ ២៩ឆ្នាំ ជនជាតិខ្មែរ |
| កាលបរិច្ឆេទ និងទីកន្លែងដែលត្រូវបង្ហាញខ្លួន | **ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១៩ វេលាម៉ោង ០៨:០០ នាទី ព្រឹក**<br>**តុលាការសាលាឧទ្ធរណ៍ សាលសវនាការបន្ទប់ទី ៣** |
| ប្រភេទដំណាក់កាលនៃនីតិវិធី | នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ |
| ប្រភេទនៃឯកសារភ្ជាប់មកជាមួយ | |
| ទណ្ឌកម្មជាអាទិ៍ ក្នុងករណីដែលមិនបាន បង្ហាញខ្លួន ដោយគ្មានមូលហេតុ<br>ត្រឹមត្រូវ | ១-ចំពោះសាមីភាគី : បើពុំចូលខ្លួន នោះតុលាការទទួលស្គាល់ថា សេចក្តីអះអាងអំពីចំណុចសាកសួររបស់ភាគីម្ខាងទៀតជាការពិតបាន។ តាមមាត្រា១៨០ កថាខ័ណ្ឌទី២, មាត្រា២៧៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។<br>២-ចំពោះសាក្សី : បើមិនព្រមចូលខ្លួនមកតុលាការដោយគ្មានមូលហេតុត្រឹមត្រូវ តុលាការអាចពិន័យជាប្រាក់ចំនួនមិនលើសពី ១.០០០.០០០ រៀល (មួយលានរៀល) ។ តាមមាត្រា១៣២ កថាខ័ណ្ឌ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។ |

សូមបង្ហាញខ្លួនតាមពេលវេលា និងទីកន្លែងដែលបានកំណត់ខាងលើនេះ ។

ថ្ងៃចន្ទ ២កើត ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
សាលាឧទ្ធរណ៍ ថ្ងៃទី ០២ ខែកញ្ញា ឆ្នាំ២០១៩
**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

ឃុន ភាពម៉េង

<u>បញ្ជាក់</u>៖ -ក្នុងករណីដែលមានជម្ងឺ ឬមានមូលហេតុផ្សេងទៀតដែលមិនអាចបង្ហាញខ្លួនបាន សូមដាក់ឯកសារបញ្ជាក់របស់វេជ្ជបណ្ឌិត ឬបញ្ជាក់មូលហេតុនោះជូនតុលាការ។
-ពេលបង្ហាញខ្លួន សូមយកដីកាកោះនេះជូនក្រឡាបញ្ជីទទួលបន្ទុក
-ទម្រង់នេះប្រើសម្រាប់ ភាគី, សាក្សី, អ្នកចូលរួមអន្តរាគមន៏ក្នុងបណ្តឹង
-អាសយដ្ឋានសាលាឧទ្ធរណ៍ : ផ្លូវតិរៈ វិថីព្រះស៊ីសុវត្ថិ សាលាឧទ្ធរណ៍-មហាអយ្យការ (ទល់មុខព្រះបរមរាជវាំង ក្នុងបរិវេណក្រសួងយុត្តិធម៌)

ក្រឡាបញ្ជ សក សក្តសម

24/7

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាឧទ្ធរណ៍**

សំណុំរឿងរដ្ឋប្បវេណី

# ដីកាកោះ

| | |
|---|---|
| បង្គាប់មកឈ្មោះ ភេទស្រី អាយុ ២៩ឆ្នាំ ជនជាតិខ្មែរ ។<br>អាសយដ្ឋានបច្ចុប្បន្ន៖ ភូមិ២ សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។ | |
| **សញ្ញាណនៃរឿងក្តី(លេខនិងភាគី) លេខលះ** | សំណុំរឿងក្តីលេខ ២៣២ ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៩<br>-ដើមចោទឈ្មោះ ភេទស្រី អាយុ ២៩ឆ្នាំ ជនជាតិខ្មែរ<br>-ចុងចម្លើយឈ្មោះ ភេទប្រុស អាយុ ២៩ឆ្នាំ ជនជាតិខ្មែរ |
| កាលបរិច្ឆេទ និងទីកន្លែងដែលត្រូវបង្ហាញខ្លួន | **ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១៩ វេលាម៉ោង ០៨:០០ នាទី ព្រឹក**<br>**តុលាការសាលាឧទ្ធរណ៍ សាលសវនាការបន្ទប់ទី ៣** |
| ប្រភេទដំណាក់កាលនៃនីតិវិធី | នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ |
| ប្រភេទនៃឯកសារភ្ជាប់មកជាមួយ | |
| ទណ្ឌកម្មជាអាទិ៍ ក្នុងករណីដែលមិនបាន បង្ហាញខ្លួន ដោយគ្មានមូលហេតុ ត្រឹមត្រូវ | ១-ចំពោះសាមីភាគី : បើពុំចូលខ្លួន នោះតុលាការទទួលស្គាល់ថា សេចក្តីអះអាងអំពីចំណុចសាកសួររបស់ភាគីម្ខាងទៀតជាការពិតបាន។ តាមមាត្រា១៩០ កថាខ័ណ្ឌទី២, មាត្រា២៧៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។<br>២-ចំពោះសាក្សី : បើមិនព្រមចូលខ្លួនមកតុលាការដោយគ្មានមូលហេតុត្រឹមត្រូវ តុលាការអាចពិន័យជាប្រាក់ចំនួនមិនលើសពី ១.០០០.០០០ រៀល (មួយលានរៀល) ។ តាមមាត្រា១៣២ កថាខ័ណ្ឌ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។ |
| សូមបង្ហាញខ្លួនតាមពេលវេលា និងទីកន្លែងដែលបានកំណត់ខាងលើនេះ ។<br>ថ្ងៃព្រហស្បតិ៍ ៧រោច ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣<br>សាលាឧទ្ធរណ៍ ថ្ងៃទី ២២ ខែសីហា ឆ្នាំ២០១៩<br>**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**<br>យុន ណាចម៉េង | |

<u>បញ្ជាក់</u>៖ -ក្នុងករណីដែលមានជម្ងឺ ឬមានមូលហេតុផ្សេងទៀតដែលមិនអាចបង្ហាញខ្លួនបាន សូមដាក់ឯកសារបញ្ជាក់របស់វេជ្ជបណ្ឌិត ឬបញ្ជាក់មូលហេតុនោះជូនតុលាការ។
-ពេលបង្ហាញខ្លួន សូមយកដីកាកោះនេះជូនក្រឡាបញ្ជីទទួលបន្ទុក
-ទម្រង់នេះប្រើសម្រាប់ ភាគី, សាក្សី, អ្នកចូលរួមអន្តរាគមន៍ក្នុងបណ្តឹង
-អាសយដ្ឋានសាលាឧទ្ធរណ៍ : ផ្លូវតិរៈ វិថីព្រះស៊ីសុវត្ថិ សាលាឧទ្ធរណ៍-មហាអយ្យការ (ទល់មុខព្រះបរមរាជវាំង ក្នុងបរិវេណក្រសួងយុត្តិធម៌)

24/8

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាខ្មុំទូរណ៍

## របាយការណ៍អំពីការបញ្ជូន

-ប្រអប់ខាងក្រោមត្រូវបំពេញដោយក្រឡាបញ្ជី :

| |
|---|
| -កាលបរិច្ឆេទផ្ញើចេញ៖ ថ្ងៃទី ២៣ ខែសីហា ឆ្នាំ ២០១៩ |
| សំណុំរឿងលេខ : ២៣២ ចុះថ្ងៃទី ០២-៥-២០១៩ |
| ឈ្មោះឯកសារផ្ញើចេញ៖ ដីកាកោះ ចុះថ្ងៃទី ២២-៨-១៩ (ទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី ២៣-៩-១៩ ម៉ោង ៨:០០ នាទីព្រឹក បន្ទប់៣) |
| ឈ្មោះអ្នកទទួលបន្ទុកកិច្ចការបញ្ជូន : សក ស័ក្តិសម (ក្រឡាបញ្ជី) |
| អាសយដ្ឋានអ្នកទទួលបន្ទុកកិច្ចការបញ្ជូន : សាលាខ្ទូរណ៍ |
| ឈ្មោះជនដែលត្រូវទទួលឯកសារបញ្ជូនទៅ : **ដើមចោទឈ្មោះ** |

-ហត្ថលេខាឬស្នាមម្រាមដៃអ្នកទទួលឯកសារជាក់ស្តែង ..............................



-ប្រអប់ខាងក្រោមត្រូវបំពេញដោយអ្នកប្រតិបត្តិការបញ្ជូន(កត្តាប្រៃសណីយ៍ ឬអាជ្ញាសាលា ឬក្រឡាបញ្ជី)

| | |
|---|---|
| ទីកន្លែងធ្វើការបញ្ជូនទៅ : | |
| កាលបរិច្ឆេទនៃការបញ្ជូន : | |
| **វិធីជាក់ស្តែងក្នុងការបញ្ជូន** | |
| □ ១ | បានប្រគល់ជូនជនដែលត្រូវទទួលការបញ្ជូនដោយផ្ទាល់ដៃ ។ |
| | □ខ្ញុំបានពន្យល់ជូនជនដែលត្រូវទទួលការបញ្ជូននូវខ្លឹមសារសង្ខេបនៃឯកសារដែលបានបញ្ជូន ពីព្រោះជននោះមិនចេះអានអក្សរ ។ |
| □ ២ | បានប្រគល់ឯកសារទៅអ្នកដែលមានការយល់ដឹងសមរម្យ ចំពោះការទទួលឯកសារនេះ ពីព្រោះខ្ញុំមិនបានជួបអ្នកត្រូវទទួលការបញ្ជូនដោយផ្ទាល់នៅកន្លែងដែលត្រូវបញ្ជូននោះទេ ។ |
| | □អ្នកបំរើ □អ្នកផ្សេងដែលនៅធ្វើការនៅទីនោះ □អ្នកនៅជាមួយ |
| | ឈ្មោះ................................................................ |
| □ ៣ | ឯកសារត្រូវបានទុកនៅទីកន្លែងធ្វើការបញ្ជូន ដោយហេតុថា: បុគ្គលខាងក្រោមនេះ មិនព្រមទទួលការបញ្ជូនដោយគ្មានហេតុផល ។ |
| | □ជនដែលត្រូវទទួលការបញ្ជូន □អ្នកបំរើ □អ្នកនៅជាមួយ □អ្នកផ្សេងដែលធ្វើការនៅទីនោះ |
| | ឈ្មោះ ................................................................ |
| □ ខ្ញុំបានបញ្ជូនឯកសារតាមវិធីដូចខាងលើ | |
| □ខ្ញុំមិនអាចធ្វើការបញ្ជូនឯកសារខាងលើនេះបានសម្រេចទេ ពីព្រោះនៅកន្លែងដែលត្រូវទទួលការបញ្ជូន ខ្ញុំមិនបានជួបនឹងជនដែលត្រូវទទួលការបញ្ជូន ឬជនដែលមានការយល់ដឹងសមរម្យក្នុងការទទួលឯកសារ នេះទេ ។ | |
| កាលបរិច្ឆេទធ្វើរបាយការណ៍: ថ្ងៃទី២៦ ខែ សីហា ឆ្នាំ ២០១៩ | |
| ឈ្មោះ និងហត្ថលេខាអ្នកធ្វើរបាយការណ៍:.......................................... | |

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្ត
បន្ទាយមានជ័យ

សំណុំរឿងរដ្ឋប្បវេណី
លេខ:
ចុះថ្ងៃទី ០៦-១១-២០១៨

# កំណត់ហេតុស្តីពីនិតិវិធីត្រៀមទាញហេតុផល

( មាត្រា ១១០ និង មាត្រា ១១១ )

## សញ្ញាណនៃរឿងក្តី

សំណុំរឿងរដ្ឋប្បវេណីលេខ ៦៨៦ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨

លោក **ជួន វណ្ណៈ** ចៅក្រម

លោក **ទៀវ ដារណា** ក្រឡាបញ្ជី

- កាលបរិច្ឆេទ: ១៤-១១-២០១៨ វេលាម៉ោង ៨ ព្រឹក

## ភាគីដែលបានបង្ហាញខ្លួន

-ដើមចោទលោកស្រី ភេទស្រី ថ្ងៃខែឆ្នាំកំណើត៣០-១២-១៩៩៥ មុខរបរកម្មករកាត់ដេរ ទីលំនៅបច្ចុប្បន្នភូមិខ្លាកូនចាស់ សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ។

-ចុងចម្លើយលោក ភេទប្រុស ថ្ងៃខែឆ្នាំកំណើត ០២-១២-១៩៩០ មុខរបរកម្មករកាត់ដេរ ទីលំនៅបច្ចុប្បន្នភូមិ ២ សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

អង្គហេតុដែលជាមូលហេតុនៃការទាមទារអោយតុលាការចេញសាលក្រម

១-ខ្លឹមសារដែលដើមចោទទាមទារអោយតុលាការចេញ :-

-សុំលែងលះពីចុងចម្លើយឈ្មោះ ។

-សុំអំណាចមេបាលើកូន ០១ នាក់

-សុំបែងចែកទ្រព្យសម្បត្តិរួមជាពីរ ។

-សុំអាហារកិច្ចផ្តាច់ចំនួន ៥០០០ ដុល្លា ។

-សុំរ៉ាប់រងពន្ធ។

២-ខ្លឹមសារដែលចុងចម្លើយទាមទារអោយតុលាការចេញ :- លែងលះ , ចែកទ្រព្យសម្បត្តិរួម។

ដំណាក់កាលផ្សះផ្សា

-ដើមចោទ និង ចុងចម្លើយព្រមសះជាគ្នា

**សេចក្ដីថ្លែងការណ៍របស់ដើមចោទ** : នាងខ្ញុំបានរៀបអាពាហ៍ពិពាហ៍ក្នុងឆ្នាំ ២០១៥ ព្រមទាំងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់។ការរួមរស់ជាមួយចុងចម្លើយមានកូនម្នាក់ឈ្មោះ ភេទប្រុស ថ្ងៃខែឆ្នាំកំណើត ២០-១២-២០១៥ កូនប្រុសម្នាក់នេះនាងខ្ញុំសុំអំណាចមេបា។ ចំពោះទ្រព្យសម្បត្តិរួមមានដី និង ផ្ទះសង់ពីលើដីទំហំ ១៥ ម៉ែត្រ គុណ ៥០ ម៉ែត្រ ខាងជើងទល់ផ្លូវ , ខាងត្បូងជាប់ព្រំដី ខាងលិចជាប់ព្រំដី , ខាងកើតជាប់ព្រំដីឈ្មោះ ស្ថិតនៅភូមិ ២ សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ , ម៉ូតូមួយគ្រឿងម៉ាកឌ្រីមសង់ ២០១៥ ពណ៌ខ្មៅ ស្លាកលេខ បជ នាងខ្ញុំសុំចែកជាពីរចំណែកស្មើរគ្នា ហើយសុំអោយចុងចម្លើយបង់អាហារកិច្ចចិញ្ចឹមកូនផ្ដាច់ចំនួន ៥000 ដុល្លា ។

បានជានាងខ្ញុំសុំលែងលះដោយសាររស់នៅមិនចុះសម្រុងគ្នា ចុងចម្លើយពេលផឹកស្រវឹងតែងយកកាំបិទមកកាប់ផ្ទះគំរាមដល់នាងខ្ញុំជារឿយៗ មិនតែប៉ុណ្ណោះដេញនាងខ្ញុំចេញពីផ្ទះទៀតផង។ មូលហេតុទាំងនេះហើយធ្វើនាងខ្ញុំអស់មនោសញ្ចេតនារួមរស់ជាមួយចុងចម្លើយតទៅទៀតបាន ទើបដាក់ពាក្យសុំលែងលះតាមច្បាប់។

**សេចក្ដីថ្លែងការណ៍របស់ចុងចម្លើយ** : ខ្ញុំបាទសុំឯកភាពលែងលះតាមសេចក្ដីថ្លែងការណ៍របស់ដើមចោទ ចំពោះកូនប្រុសម្នាក់ក៏ខ្ញុំបាទព្រមប្រគល់អំណាចមេបាអោយទៅដើមចោទដែរ ។ ចំណែកទ្រព្យសម្បត្តិដែលដើមចោទរៀបរាប់ខ្ញុំបាទមិនឯកភាពតាមទេ ពីព្រោះដីនេះគឺម្ដាយខ្ញុំបាទគាត់ចែកអោយប្ដីប្រពន្ធខ្ញុំបាទរស់នៅ ។ ចំពោះអាហារកិច្ចខ្ញុំបាទសុំចិញ្ចឹមកូនក្នុង ០១ ខែ ២០០,000រៀល។

**ចំណុចវិវាទ** : លែងលះ , ចែកទ្រព្យសម្បត្តិរួម , អាហារកិច្ច ។

តុលាការបញ្ឈប់នីតិវិធីត្រៀមទាញហេតុផល និង លើកយកមកធ្វើនិតិវិធីត្រៀមទាញហេតុផលផ្ទាល់មាត់នៅថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៨ វេលាម៉ោង ៨ ព្រឹក ។

បានអានអោយដើមចោទស្ដាប់ថាត្រឹមត្រូវហើយ ។ សុខចិត្តផ្ដិតមេដៃចំពោះមុខយើង ។

បញ្ឈប់កំណត់ហេតុនេះនៅវេលាម៉ោង បីសាមសិបនាទី នាថ្ងៃ ខែ ឆ្នាំ ដដែល ។

| ដើមចោទ | មេធាវី | ចុងចម្លើយ | ក្រឡាបញ្ជី | ចៅក្រម |
|---|---|---|---|---|
| | | | ឡៀវ ដារណា | ជួន ចណ្ណា |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្ត
បន្ទាយមានជ័យ

សំណុំរឿងរដ្ឋប្បវេណី
លេខ:
ចុះថ្ងៃទី ០៦-១១-២០១៨

## កំណត់ហេតុស្តីពីនិតិវិធីត្រៀមទាញហេតុផលលើកទី ២

( មាត្រា ១១០ និង មាត្រា ១១១ )

### សញ្ញាណនៃរឿងក្តី

សំណុំរឿងរដ្ឋប្បវេណីលេខ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨

លោក **ជួន វណ្ណៈ** ចៅក្រម

លោក **ទៀវ ដាណា** ក្រឡាបញ្ជី

- កាលបរិច្ឆេទ: ៣០-១១-២០១៨ វេលាម៉ោង ៩ ព្រឹក

### ភាគីដែលបានបង្ហាញខ្លួន

-ដើមចោទលោកស្រី ភេទស្រី ថ្ងៃខែឆ្នាំកំណើត៣០-១២-១៩៩៥ មុខរបរកម្មករកាត់ដេរ ទីលំនៅបច្ចុប្បន្នភូមិខ្លាកូនចាស់ សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ។

-ចុងចម្លើយលោក ភេទប្រុស ថ្ងៃខែឆ្នាំកំណើត ០២-១២-១៩៩០ មុខរបរកម្មករកាត់ដេរ ទីលំនៅបច្ចុប្បន្នភូមិ ២ សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

អង្គហេតុដែលជាមូលហេតុនៃការទាមទារអោយតុលាការចេញសាលក្រម

១-ខ្លឹមសារដែលដើមចោទទាមទារអោយតុលាការចេញ :-

-សុំលែងលះពីចុងចម្លើយឈ្មោះ ។

-សុំអំណាចមេបាលើកូន ០១ នាក់

-សុំបែងចែកទ្រព្យសម្បត្តិរួមជាពីរ ។

-សុំអាហារកិច្ចផ្តាច់ចំនួន ៥០០០ ដុល្លា ។

-សុំរ៉ាប់រងពន្ធ។

២-ខ្លឹមសារដែលចុងចម្លើយទាមទារអោយតុលាការចេញ :- លែងលះ , ចែកទ្រព្យសម្បត្តិរួម។

ដំណាក់កាលផ្សះផ្សា

-ដើមចោទ និង ចុងចម្លើយពុំព្រមសះជាគ្នា



សេចក្តីថ្លែងការណ៍របស់ដើមចោទ : នាងខ្ញុំសុំបន្ថែមថា ដីនេះម្តាយចុងចម្លើយចែកអោយនាងខ្ញុំ និងប្តីកាន់កាប់និងរស់នៅ ។ ចំពោះផ្ទះដែលសង់នៅលើដីសរុបអស់ប្រាក់ ៧៥០០ដុល្លា (ប្រាំពីរពាន់ប្រាំរយដុល្លា ) នៅពុំទាន់បានគិតពីតម្លៃជាងនៅឡើយទេ ។ ចំពោះថ្លៃជាងទើបតែអោយបានតែ ២០០ ដុល្លា នៅជំពាក់ថ្លៃជាងចំនួន១៩០០ ដុល្លា ទៀត នាងខ្ញុំសុំអោយចុងចម្លើយជួយសងថ្លៃជាងម្នាក់ពាក់កណ្តាលដែរ ។ ដើម្បីកុំអោយមានរឿងវែងឆ្ងាយនាងខ្ញុំសុំអោយចុងចម្លើយបង់ផ្តាច់ទាំងប្រាក់អាហារកិច្ច , ប្រាក់ទ្រព្យរួម ប្រាក់បំណុលជាងសរុបចំនួន ៧០០០ ដុល្លា។ ចំពោះម៉ូតូនាងខ្ញុំបានទិញពីប្អូនថ្លៃរួចហើយតម្លៃ ៥០០ ដុល្លា បើមិនជឿសុំតុលាការហៅc2ប្អូនថ្លៃមកសួរផង។

សេចក្តីថ្លែងការណ៍របស់ចុងចម្លើយ : ខ្ញុំបាទសុំរក្សាសេចក្តីថ្លែងការណ៍ក្នុងពេលត្រៀមលើកទីមួយដដែល តែក្នុងពេលនេះខ្ញុំបាទសុំបន្ថែមសេចក្តីថ្លែងការណ៍តបទៅដើមចោទថា ចំពោះផ្ទះដែលសង់នៅលើដីសរុបអស់ប្រាក់ប្រហែល ៤០០០ដុល្លា ចំពោះប្រាក់ថ្លៃជាងសរុបអស់ប្រហែលតែ ១៥០០ ដុល្លាតែប៉ុណ្ណោះ រឿងដើមចោទសុំប្រាក់ផ្តាច់ទាំងប្រាក់អាហារកិច្ច , ប្រាក់ទ្រព្យរួម ប្រាក់ បំណុលជាងសរុបចំនួន ៧០០០ ដុល្លានោះ ខ្ញុំបាទសុំបដិសេធ។ ដើម្បីកុំអោយវែងឆ្ងាយខ្ញុំបាទសុំបង់អោយដើមចោទផ្តាច់ចំនួន ១៥០០ ដុល្លា។

សេចក្តីថ្លែងការណ៍តបរបស់ដើមចោទ : នាងខ្ញុំសុំបដិសេធសេចក្តីថ្លែងការណ៍របស់ចុងចម្លើយត្រង់ចំណុចបង់ប្រាក់ផ្តាច់ចំនួន ១៥០០ ដុល្លា ។ បើចុងចម្លើយមិនយល់ព្រម នាងខ្ញុំសុំអោយតុលាការសម្រេចតាមច្បាប់។

សេចក្តីបំភ្លឺរបស់សាក្សីខាងដើមចោទឈ្មោះ ចំពោះដីដែលកូនសង់ផ្ទះនៅសព្វថ្ងៃខាងជន្លងខ្ញុំបាទបានប្រគល់អោយកូនកាន់កាប់ទាំងពីរនាក់ប្តីប្រពន្ធ ។ បន្ទាប់ពីបានដីហើយទើបខ្ញុំបាទរៀបចំចាត់ចែងធ្វើផ្ទះអោយកូន ហើយប្រាក់ដែលយកមកសាងសង់ផ្ទះខ្ញុំបាទពុំបានដឹងទេ ខ្ញុំបាទដឹងតែថ្លៃជាងដែលសរុបអស់ប្រាក់ចំនួន ២១០០ ដុល្លា ទើបតែសងបាន ២០០ ដុល្លា តែប៉ុណ្ណោះ នៅជំពាក់ប្រាក់ថ្លៃជាងចំនួន១៩០០ ដុល្លាទៀត ។

សេចក្តីបំភ្លឺរបស់សាក្សីខាងចុងចម្លើយឈ្មោះ នាងខ្ញុំពិតជាបានប្រគល់ដីអោយទៅកូនទាំងពីរនាក់មែន តែឥឡូវនាងខ្ញុំសុំយកវិញមិនអោយកូនទេ ។ នាងខ្ញុំពិតជាបានអោយលុយកូនធ្វើផ្ទះចំនួន ៣៥០០ ដុល្លា ត្រង់ថាផ្ទះធ្វើអស់លុយប៉ុន្មាននោះនាងខ្ញុំមិនដឹងទេ ។ ការជំពាក់ថ្លៃជាងក៏នាងខ្ញុំមិនបានដឹងដែរ។

សេចក្តីបំភ្លឺរបស់សាក្សីខាងចុងចម្លើយឈ្មោះ ខ្ញុំបាទពិតជាបានលក់ម៉ូតូនេះអោយទៅបងថ្លៃខ្ញុំពិតប្រាកដមែនក្នុងតម្លៃ ៥០០ ដុល្លា ហើយប្រាក់ចំនួន ៥០០ ដុល្លានោះ ខ្ញុំបាទបានទទួលពីបងរួចហើយ ។

ចំណុចវិវាទ : លែងលះ , ចែកទ្រព្យសម្បត្តិរួម , អាហារកិច្ច ។

តុលាការបញ្ឈប់នីតិវិធីត្រៀមទាញហេតុផល និង លើកយកមកធ្វើនិតិវិធីត្រៀមទាញហេតុផលផ្ទាល់មាត់នៅថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១៨ វេលាម៉ោង ៨ ព្រឹក ។

បានអានអោយដើមចោទស្តាប់ថាត្រឹមត្រូវហើយ ។ សុខចិត្តផ្តិតមេដៃចំពោះមុខយើង ។

បញ្ឈប់កំណត់ហេតុនេះនៅវេលាម៉ោង ដប់មួយ នាថ្ងៃ ខែ ឆ្នាំ ដដែល ។

| ដើមចោទ | ចុងចម្លើយ | សាក្សី | ក្រឡាបញ្ជី | ចៅក្រម |
|---|---|---|---|---|
| | | | នៀទ ដារណា | ជួន ទណ្ណា: |





**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាឧទ្ធរណ៍**

**សំណុំរឿងរដ្ឋប្បវេណី**

លេខ ./០២-០៥-២០១៩

**សាលដីកា**

លេខ

ចុះថ្ងៃទី ២៣-០៩-២០១៩

## កំណត់ហេតុស្ដីពីការទាញហេតុផលដោយផ្ទាល់មាត់

ឆ្នាំពីរពាន់ដប់ប្រាំបួន ខែកញ្ញា ថ្ងៃម្ភៃបី វេលាម៉ោងប្រាំបីនិងសាមសិបនាទីព្រឹក សភារដ្ឋប្បវេណីសាលាឧទ្ធរណ៍ បានធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ជាសាធារណៈ ដោយមាន៖

**សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ**

**ឯកឧត្តម យុន លាងម៉េង ប្រធានក្រុមប្រឹក្សា**

**លោក យូ ម៉ិនណា ចៅក្រមប្រឹក្សា**

**លោក លាង សំណាត់ ចៅក្រមប្រឹក្សា**

**តំណាងមហាអយ្យការ**

**លោក ង៉ែត សារ៉ាត ព្រះរាជអាជ្ញា**

**ក្រឡាបញ្ជី**

**លោក សក ស័ក្តិសម**

-ដើមចោទឈ្មោះ ភេទស្រី ថ្ងៃខែឆ្នាំកំណើត ៣០-១២-១៩៩៥ ជនជាតិខ្មែរ មានអាសយដ្ឋានបច្ចុប្បន្ន នៅភូមិ២ សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

-ចុងចម្លើយឈ្មោះ ភេទប្រុស ថ្ងៃខែឆ្នាំកំណើត ០២-១២-១៩៩០ ជនជាតិខ្មែរ មានអាសយដ្ឋានបច្ចុប្បន្ន នៅភូមិ២ សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

-អ្នកតំណាងដោយអាណត្តិឱ្យចុងចម្លើយឈ្មោះ មេធាវី ។

**នាពេលទាញហេតុផលដោយផ្ទាល់មាត់**

-ដើមចោទឈ្មោះ វត្តមាន

-ចុងចម្លើយឈ្មោះ អវត្តមាន

-មេធាវី វត្តមាន

-មេធាវី ជាអ្នកតំណាងដោយអាណត្តិឲ្យចុងចម្លើយឈ្មោះ បានធ្វើសេចក្តីថ្លែងការណ៍ថា៖ កូនក្តីខ្ញុំបាទបានប្តឹងឧទ្ធរណ៍នឹងសាលក្រមរដ្ឋប្បវេណីលេខ ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ត្រង់ចំណុច ទី៤, ទី៦, ទី៧ និងទី៨ ។ ខ្ញុំបាទសូមបញ្ជាក់នូវមូលហេតុនៃការប្តឹងឧទ្ធរណ៍ត្រង់ចំណុចនិមួយៗដូចតទៅ៖

ចំណុចទី៥ ទាក់ទងនឹងការឱ្យកូនក្តីខ្ញុំបាទ បង់អាហារកិច្ចចំនួន ២០០ ០០០ (ម្ភៃម៉ឺន) រៀល ក្នុងមួយខែ ឱ្យទៅដើមចោទ សម្រាប់ចិញ្ចឹមកូន រហូតដល់កូនមានវ័យនីតិភាព គឺកូនក្តីខ្ញុំបាទមិនសុខចិត្ត ដោយសុំបង់តាមលទ្ធភាពវិញ ព្រោះពុំមានលទ្ធភាព ប៉ុន្តែចម្លើយរបស់គាត់នៅក្នុងនីតិវិធីត្រៀមទាញហេតុផល គាត់យល់ព្រមបង់តាមចំនួននេះ លុះក្រោយមក នៅក្នុងពាក្យបណ្តឹងឧទ្ធរណ៍សុំបង់អាហារកិច្ចតាមលទ្ធភាពទៅវិញ ។

ចំណុចទី៦ ទាក់ទងនឹងការឱ្យកូនក្តីខ្ញុំបាទប្រគល់ម៉ូតូមួយគ្រឿង ម៉ាកឌ្រីមសង់ ២០១៥ ពណ៌ខ្មៅ ផ្លាកលេខ ប.ជ ទៅឱ្យដើមចោទ គឺកូនក្តីខ្ញុំបាទមិនសុខចិត្ត ដោយហេតុថា ម៉ូតូនេះ កូនក្តីខ្ញុំបាទខ្ចីប្អូនគាត់ជិះ ហើយឈ្មោះកម្មសិទ្ធិក៏ជាឈ្មោះប្អូនគាត់នៅឡើយដែរ ។

ចំណុចទី៧ ទាក់ទងនឹងការបង្គាប់ឱ្យកូនក្តីខ្ញុំបាទ ប្រគល់ប្រាក់ចំនួន ២.០០០ (ពីរពាន់) ដុល្លារអាមេរិក ទៅឱ្យដើមចោទ និងចំណុចទី៨ ទាក់ទងនឹងការបង្គាប់ឱ្យដើមចោទ និងកូនក្តីខ្ញុំបាទរួមគ្នាសងបំណុលរួម (ថ្លៃឈ្នួលជាង) ចំនួន ១.៩០០ (មួយពាន់ប្រាំបួនរយ) ដុល្លារអាមេរិក ម្នាក់ពាក់កណ្តាល ចំណុចទាំងពីរនេះ ខ្ញុំបាទសូមបញ្ជាក់ជារួម គឺកូនក្តីខ្ញុំបាទបានអះអាងថា លុយថ្លៃធ្វើផ្ទះជាលុយរបស់ម្តាយឱ្យយមកមកធ្វើផ្ទះ ហើយចំណាយធ្វើផ្ទះអស់ប្រហែលចំនួន ៤.០០០ (បួនពាន់) ដុល្លារអាមេរិករីឯថ្លៃឈ្នួលជាងធ្វើផ្ទះបានទូទាត់អស់ហើយ ។ ម្តាយគាត់ក៏បានមកបំភ្លឺនៅក្នុងនីតិវិធីត្រៀមទាញហេតុផល ដោយបានបញ្ជាក់ថា គាត់បានប្រគល់លុយឱ្យចំនួន ៣.៥០០ (បីពាន់ប្រាំរយ) ដុល្លារអាមេរិក ។ ដូច្នេះ ការបង្គាប់ឱ្យកូនក្តីខ្ញុំបាទប្រគល់ប្រាក់ចំនួន ២.០០០ (ពីរពាន់) ដុល្លារអាមេរិក ទៅឱ្យដើមចោទ និងការឱ្យកូនក្តី ខ្ញុំបាទរួមគ្នាសងបំណុលរួមម្នាក់ពាក់កណ្តាល គឺមិនត្រឹមត្រូវទេ ដោយសារការទូទាត់គ្នាមក ឃើញថា នៅសល់តែប្រហែលចំនួន ៥០០ (ប្រាំរយ) ដុល្លារអាមេរិក ប៉ុណ្ណោះ ។ ខ្ញុំបាទសំណូមពរបដិសេធសាលក្រមរដ្ឋប្បវេណីលេខ ៦៨ (គ) ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ត្រង់ចំណុច ទី៥, ទី៦, ទី ៧ និងទី៨ នៃសេចក្តីសម្រេចបញ្ចប់ ។

-ដើមចោទឈ្មោះ បានធ្វើសេចក្តីថ្លែងការណ៍ថា៖ ចំពោះគាត់ប្តឹងឧទ្ធរណ៍នឹងចំណុចការបង់អាហារកិច្ច នាងខ្ញុំមិនព្រមទេ ដោយហេតុថា មិនមែនគាត់អត់លទ្ធភាពនោះឡើយ ព្រោះគាត់ធ្វើជាជាងឡាន ។ ចំពោះម៉ូតូវិញ គឺនាងខ្ញុំបានទិញពីប្អូនថ្លៃនាងខ្ញុំក្នុងតម្លៃ ៥០០ (ប្រាំរយ) ដុល្លារអាមេរិក មិនមែនខ្ចីជិះទេ ប៉ុន្តែមិនបានធ្វើលិខិតទិញលក់ ហើយកាតគ្រីនៅនឹងនាងខ្ញុំ រីឯម៉ូតូនៅនឹងប្អូនថ្លៃនាងខ្ញុំ ។ ចំពោះការចំណាយធ្វើផ្ទះអស់ប្រាក់ចំនួន ១៥ ០០០ (មួយម៉ឺនប្រាំពាន់) ដុល្លារអាមេរិក មិនអស់ប្រហែលចំនួន ៤.០០០ (បួនពាន់) ដុល្លារអាមេរិក ដូចការលើកឡើងរបស់មេធាវីទេ ដោយផ្ទះនេះសាងសង់អំពីថ្ម ប្រក់ស័ង្កសីទទឹង ៥ (ប្រាំ) ម៉ែត្រ គុណ ១៦ (ដប់ប្រាំមួយ) ម៉ែត្រ ហើយការសាងសង់ គឺប៉ា និងបងប្អូននាងខ្ញុំ ជាជាងសាងសង់ ។

នាងខ្ញុំបានទទួលប្រាក់ពីម្ដាយក្មេកនាងខ្ញុំ សម្រាប់សាងសង់ផ្ទះ មានចំនួន ៣.០០០ (បីពាន់) ដុល្លារអាមេរិក តែប៉ុណ្ណោះ ។ ដូច្នេះ ការប្ដឹងឧទ្ធរណ៍របស់គាត់ មិនត្រឹមត្រូវទេ នាងខ្ញុំសូមបដិសេធទាំងស្រុង និងសំណូមពរតម្កល់សាលក្រមរបស់សាលាដំបូងខេត្តបន្ទាយមានជ័យ ទុកជាបានការដដែល ។

តំណាងមហាអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា៖ តំណាងមហាអយ្យការបានមកចូលរួមនាពេលទាញហេតុផលដោយផ្ទាល់មាត់នេះ គឺពាក់ព័ន្ធតែចំណុចការផ្ដល់អាហារកិច្ចតែប៉ុណ្ណោះ ។ ការដែលចៅក្រមសាលាដំបូងបានសម្រេចឱ្យចុងចម្លើយឈ្មោះ បង់អាហារកិច្ចចិញ្ចឹមកូនក្នុងមួយខែចំនួន ២០០.០០០ (ម្ភៃម៉ឺន) រៀល មានលក្ខណៈត្រឹមត្រូវហើយ ព្រោះចុងចម្លើយមានមុខរបរ ហើយចំនួននេះ គឺមានភាពសមល្មមហើយ ។ ដូច្នេះ ចំណុចនេះ មិនគប្បីក្រុមប្រឹក្សាជំនុំជម្រះសភារដ្ឋប្បវេណីសាលាឧទ្ធរណ៍ សម្រេចធ្វើការកែប្រែឡើយ ។

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ ប្រកាសថយទៅពិចារណាសម្រេច និងចេញមកវិញប្រកាសសាលដីកា ។

## សំអាងហេតុ

១-បណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី ០៨ ខែមករា ឆ្នាំ២០១៩ របស់ចុងចម្លើយឈ្មោះ ប្ដឹងឧទ្ធរណ៍នឹងសាលក្រមរដ្ឋប្បវេណីលេខ ៦៨ (គ) ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ២០១៨ របស់សាលា-ដំបូងខេត្តបន្ទាយមានជ័យ ត្រង់ចំណុច ទី៤, ទី៦, ទី៧ និងទី៨ នៃសេចក្ដីសម្រេចបញ្ចប់ ធ្វើឡើងក្នុងកំណត់ច្បាប់ ដែលអាចឱ្យក្រុមប្រឹក្សាជំនុំជម្រះសភារដ្ឋប្បវេណីសាលាឧទ្ធរណ៍ ធ្វើការទាញហេតុផលដោយផ្ទាល់មាត់បាន ផ្អែកតាមបញ្ញត្តិមាត្រា ២៦០ និងមាត្រា ២៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

២-ភាគីចុងចម្លើយ បានធ្វើសេចក្ដីថ្លែងការណ៍អំពីមូលហេតុដែលភាគីខ្លួនប្ដឹងឧទ្ធរណ៍នឹងសាលក្រមរដ្ឋប្បវេណីលេខ ៦៨ (គ) ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ត្រង់ចំណុច ទី៤, ទី៦, ទី៧ និងទី៨ នៃសេចក្ដីសម្រេចបញ្ចប់ ដោយបញ្ជាក់ថា៖

ក-ការដែលសាលាដំបូងខេត្តបន្ទាយមានជ័យ បានសម្រេចឱ្យភាគីខ្លួនបង់អាហារកិច្ច ក្នុងមួយខែ ចំនួន ២០០.០០០ (ម្ភៃម៉ឺន) រៀល ឱ្យទៅភាគីដើមចោទសម្រាប់ចិញ្ចឹមកូន ដោយភាគីខ្លួនមិនសុខចិត្ត និងសុំបង់តាមលទ្ធភាពវិញ ដោយមូលហេតុថា ភាគីខ្លួនពុំមានលទ្ធភាព ប៉ុន្តែការលើកឡើងនេះ ត្រូវបានភាគីដើមចោទបដិសេធ ដោយបញ្ជាក់ថា ភាគីចុងចម្លើយមានមុខរបរជាជាងឡាន ដូច្នេះ ភាគីចុងចម្លើយពុំអលទ្ធភាពក្នុងការបង់អាហារកិច្ចក្នុងមួយខែ ចំនួន ២០០.០០០ (ម្ភៃម៉ឺន) រៀល ឡើយ ហើយចំណុចនេះ តំណាងមហាអយ្យការក៏ពុំឯកភាពផងដែរ ។

ខ-ការដែលសាលាដំបូងខេត្តបន្ទាយមានជ័យ បានសម្រេចឱ្យភាគីខ្លួនប្រគល់ម៉ូតូ ១(មួយ) គ្រឿង ម៉ាកឌ្រីមសង់ ២០១៥ ពណ៌ខ្មៅ ផ្លាកលេខ ប.ជ ទៅឱ្យដើមចោទ ដោយភាគីខ្លួន

មិនសុខចិត្ត និងបានលើកឡើងថា ម៉ូតូនេះ គឺភាគីខ្លួនខ្ចីប្អូនជិះប៉ុណ្ណោះ ប៉ុន្តែ ការលើកឡើងនេះ ត្រូវបានភាគីដើមចោទបដិសេធ ដោយបញ្ជាក់ថា ម៉ូតូនេះ ខ្លួនបានទិញពីប្អូនថ្លៃក្នុងតម្លៃ ៥០០ (ប្រាំរយ) ដុល្លារអាមេរិក ហើយការបញ្ជាក់នេះ មានភាពស្របគ្នាទៅនឹងចម្លើយរបស់សាក្សីឈ្មោះ (ប្អូនថ្លៃដើមចោទ) ដែលបានបំភ្លឺនៅក្នុងនីតិវិធីតៀមទាញហេតុផលនៅសាលា-ដំបូង ថា ខ្លួនពិតជាបានលក់ម៉ូតូខាងលើនេះ ឱ្យទៅដើមចោទ ក្នុងតម្លៃ ៥០០ (ប្រាំរយ) ដុល្លារអាមេរិក ប្រាកដមែន និងបានទទួលប្រាក់គ្រប់ចំនួនរួចហើយ ។

គ-ការដែលសាលាដំបូងខេត្តបន្ទាយមានជ័យ បានសម្រេចឱ្យភាគីខ្លួន ប្រគល់ប្រាក់ចំនួន ២.០០០ (ពីរពាន់) ដុល្លារអាមេរិក ទៅឱ្យដើមចោទ ដោយភាគីខ្លួនមិនសុខចិត្ត និងបានលើកឡើងថា លុយក្នុងការសាងសង់ផ្ទះ គឺជាលុយដែលម្តាយខ្លួនឱ្យពួកខ្លួនចំនួន ៣.៥០០ (បីពាន់ប្រាំរយ) ដុល្លារអាមេរិក យកមកសាងសង់ ហើយការសាងសង់នេះអស់ប្រាក់ប្រហែល ៤.០០០ (បួនពាន់) ដុល្លារអាមេរិក ប៉ុន្តែការលើកឡើងនេះ ត្រូវបានភាគីដើមចោទបដិសេធ ដោយបញ្ជាក់ថា ការសាងសង់ផ្ទះនេះ ខ្លួនបានចំណាយអស់ប្រាក់ចំនួន ១៥ ០០០ (មួយម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ហើយខ្លួនបានទទួលប្រាក់ពីម្តាយសម្រាប់សាងសង់ផ្ទះតែចំនួន ៣.០០០ (បីពាន់) ដុល្លារអាមេរិក ប៉ុណ្ណោះ ។

ឃ-ការដែលសាលាដំបូងខេត្តបន្ទាយមានជ័យ បានសម្រេចឱ្យភាគីខ្លួន និងដើមចោទរួមគ្នាសងបំណុលរួម (ថ្លៃឈ្នួលជាង) ចំនួន ១.៩០០ (មួយពាន់ប្រាំបួនរយ) ដុល្លារអាមេរិក ម្នាក់ពាក់កណ្តាល ដោយភាគីខ្លួនមិនសុខចិត្ត និងបានលើកឡើងថា ថ្លៃឈ្នួលជាងក្នុងការសាងសង់ផ្ទះ បានទូទាត់រួចរាល់អស់ហើយ ប៉ុន្តែភាគីខ្លួនពុំមានភស្តុតាងបញ្ជាក់ពី ការទូទាត់ឡើយ ហើយការលើកឡើងនេះភាគីដើមចោទក៏មិនឯកភាពផងដែរ ។

៣-ផ្អែកតាមសំអាងហេតុខាងលើនេះ ក្រុមប្រឹក្សាជំនុំជម្រះសភារដ្ឋប្បវេណីសាលាឧទ្ធរណ៍ពិនិត្យឃើញថា ការទាមទាររបស់ភាគីចុងចម្លើយ សុំឱ្យក្រុមប្រឹក្សាជំនុំជម្រះសភារដ្ឋប្បវេណីសាលាឧទ្ធរណ៍ សម្រេចឡើងជាថ្មី ត្រង់សេចក្តីសម្រេចបញ្ចប់ ចំណុច ទី៤, ទី៦, ទី៧ និងទី៨ នៃសាលក្រម មិនមានមូលហេតុត្រឹមត្រូវឡើយ គប្បីច្រានចោល ។

៤-រឿងក្តីនេះ ចៅក្រមសាលាដំបូងខេត្តបន្ទាយមានជ័យ បានលើកយកសំអាងហេតុមកបញ្ជាក់មានលក្ខណៈត្រឹមត្រូវហើយ ។ ដូច្នេះ ក្រុមប្រឹក្សាជំនុំជម្រះសភារដ្ឋប្បវេណីសាលាឧទ្ធរណ៍ ឯកភាពតាមសំអាងហេតុរបស់ចៅក្រមសាលាដំបូង ដោយពុំចាំបាច់លើកយកសំអាងហេតុដដែលនេះ មកបញ្ជាក់ជាថ្មីទៀតឡើយ ។

៥-សេចក្តីសម្រេចបញ្ចប់នៃសាលក្រមរបស់សាលាដំបូងខេត្តបន្ទាយមានជ័យ មានមូលហេតុត្រឹមត្រូវ គប្បីក្រុមប្រឹក្សាជំនុំជម្រះសភារដ្ឋប្បវេណីសាលាឧទ្ធរណ៍តម្កល់ទុកជាបានការ ។ ចំណែកប្រាក់ប្រដាប់ក្តី គឺជាបន្ទុករបស់ភាគីចាញ់ក្តី ។

# សេចក្តីសម្រេចបញ្ចប់

១-ច្រានចោលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ០៨ ខែមករា ឆ្នាំ២០១៩ របស់ចុងចម្លើយឈ្មោះ ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ( ) ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ២០១៨ របស់សាលា-ដំបូងខេត្តបន្ទាយមានជ័យ ត្រង់ចំណុច ទី៥ ទី៦ ទី៧ និងទី៨ នៃសេចក្តីសម្រេចបញ្ចប់ ទុកជាបានការ ។

៣- ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីចុងចម្លើយ ។

សាលដីកានេះ ប្រកាសជាសាធារណៈ នៅថ្ងៃចន្ទ ១០រោច ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ២០១៩ ។

បញ្ឈប់កំណត់ហេតុ នៅវេលាម៉ោងប្រាំបួន និងសាមសិបនាទីព្រឹក ថ្ងៃខែឆ្នាំដដែល ។

ស្នាមមេដៃ **លឹម ស្រីយ៉ាន** ហត្ថលេខាមេធាវី **ផាត់ សុផល**

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| **សក ស័ក្តិសម** | **លាង សំណាត់, យូ ម៉ុនណា** | **ឃុន លាងម៉េង** |

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

បានឃើញ

ថ្ងៃចន្ទ ១០រោច ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

សាលា... ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៩

ក្រឡាបញ្ជី

ឃុន លាងម៉េង

សក ស័ក្តិសម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**តុលាការកំពូល**

សំណុំរឿងរដ្ឋប្បវេណីលេខ:
ចុះថ្ងៃទី ខែ ឆ្នាំ២០១៩

ថ្ងៃចន្ទ ៣កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ពស២៥៦៣.
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមករា ឆ្នាំ២០២០

## **របាយការណ៍**

តាមដីកាចាត់តាំងលេខ ច.ត ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៩ ឯកឧត្តម ប្រធានតុលាការកំពូល ឲ្យពិនិត្យអំពីទម្រង់ និង គតិច្បាប់នៃសំណុំរឿងលេខ ១៣១ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៩ របស់តុលាការកំពូល និង សាលដីកាលេខ "ណ" ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ រវាងៈ

**-ដើមចោទ (ដើមបណ្តឹងសាទុក្ខ)៖** ឈ្មោះ ភេទប្រុស អាយុ ឆ្នាំ ជាតិខ្មែរ មុខរបរនគរបាលជាតិ មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ០២ ផ្លូវលេខ៦១២ "ស្ទួន" សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

-អ្នកតំណាងដោយអាណត្តិ ៖ លោកមេធាវី ។

**-ចុងចម្លើយ (ដើមបណ្តឹងសាទុក្ខ) ៖** ឈ្មោះ ភេទស្រី អាយុ ឆ្នាំ ជាតិខ្មែរ មុខរបរអាជីវករលក់មាស "តូបលេខ៥៦" នៅផ្សារតាខ្មៅចាស់ មានទីលំនៅបច្ចុប្បន្ននៅភូមិតាខ្មៅ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល។

-អ្នកតំណាងដោយអាណត្តិ ៖ លោកស្រីមេធាវី ។

**កម្មវត្ថុនៃបណ្តឹងៈ**

១.សុំលែងលះប្រពន្ធឈ្មោះ

២.សុំសិទ្ធិគ្រប់គ្រងកូនម្នាក់ឈ្មោះ ស ផលវីរៈយុត្ត ភេទប្រុស អាយុ៩ ឆ្នាំ

៣.សុំបែកចែកទ្រព្យសម្បត្តិរួម មានដូចខាងក្រោមៈ

ក.ដីចំការមួយកន្លែងទំហំ ហិកតា ស្ថិតនៅភូមិខ្នាយ ឃុំតំបែរ ស្រុកតំបែរ ខេត្តត្បូងឃ្មុំ ដែលមានព្រំប្រទល់ខាងជើងទល់នឹង ផ្លូវលំ, ខាងត្បូងទល់នឹង , ខាងកើតទល់នឹង និង , និងខាងលិចទល់នឹង ។

ខ.ថវិកាដែលភាគី យកដីចំការចំនួន ០៥ ហិកតា ជាទ្រព្យសម្បត្តិរួម ទៅជូលឱ្យប្រជាពលរដ្ឋដាំដំឡូង តាំងពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៦ តម្លៃជូលដីសរុបទាំងអស់ចំនួន ៦០ ០០០ ០០០ (ហុកសិបលាន) រៀល។

គ.ថវិកាដែលបានមកពីការដឹកនាំ "គួកជេរ" ប្រជាពលរដ្ឋទៅទិញដីនៅខេត្តក្រចេះ ក្នុងតម្លៃមួយម៉ែត្រក្បាលដីទទួលបានកម្រៃ ៥០ (ហាសិប) ដុល្លារអាមេរិក ហើយលក់បានចំនួន ៣៩៨ ម៉ែត្រ ក្បាល គឺប្រាក់កម្រៃស្មើនឹងចំនួន ១៩ ៩០០ (មួយម៉ឺនប្រាំបួនពាន់ ប្រាំបួនរយ) ដុល្លារអាមេរិក "ចែកជា៣ចំណែក"។

ឃ.ដីភូមិមួយកន្លែង "ដើមភូមិ" ទទឹងទំហំ ៩៨ ម៉ែត្រ បណ្តោយ ៥០០ ម៉ែត្រ ស្ថិតនៅភូមិស្រែត្រែង ឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះ មានព្រំប្រទល់ខាងជើងទល់នឹង , ខាងត្បូងទល់នឹង , ខាងលិច ទល់នឹង ព្រៃរបោះ និងខាងកើតទល់នឹង ផ្លូវជាតិ

ង.ដីភូមិមួយកន្លែង ទទឹងទំហំ ១១២ ម៉ែត្រ បណ្តោយ ៥០០ ម៉ែត្រ ស្ថិតនៅភូមិស្រែត្រែង ឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះ មានព្រំប្រទល់ខាងជើងទល់ , ខាងត្បូងទល់នឹង , ខាងលិចទល់នឹង ព្រៃរបោះ និងខាងកើតទល់នឹង ផ្លូវជាតិ

ច.ដីភូមិមួយកន្លែង ទទឹងទំហំ ៥០ម៉ែត្រ បណ្តោយ ៥០០ ម៉ែត្រ ស្ថិតនៅភូមិស្រែត្រែង ឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះ មានព្រំប្រទល់ខាងជើងទល់នឹង , ខាងត្បូងទល់នឹង ផ្លូវរទេះ, ខាងលិចទល់នឹង ព្រៃរបោះ និងខាងកើតទល់នឹងផ្លូវជាតិ

ឆ.តូបលក់មាសមួយកន្លែង ទទឹងទំហំ ១ ម៉ែត្រ បណ្តោយ ១,២០ ម៉ែត្រ ១,២០ម៉ែត្រ ស្ថិតនៅភូមិតាខ្មៅ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល មានព្រំប្រទល់ខាងជើងទល់នឹង ផ្លូវចេញចូល, ខាងត្បូងទល់នឹង , ខាងកើត ទល់នឹង របងផ្សារ, និងខាងលិចទល់នឹងផ្លូវ ២០៣

**I.អំពីអង្គហេតុ**

ខ្លួននិងប្រពន្ធឈ្មោះ បានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី ហើយបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវ តាមច្បាប់លេខ ៣២ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០០៥។ ក្រោយពីរៀបអាពាហ៍ពិពាហ៍ហើយ ពួកខ្លួនមានទ្រព្យសម្បត្តិដូចរៀបរាប់ខាងលើ និងមានកូនសុំម្នាក់ឈ្មោះ ភេទប្រុស អាយុ ៩ ឆ្នាំ ។ ពួកខ្លួនគ្មានជំពាក់បំណុលគេទេ ហើយក៏គ្មានគេជំពាក់បំណុលពួកខ្លួនដែរ។ ពួកខ្លួនពុំអាចរួមរស់នៅជាមួយគ្នាតទៅទៀតបានទេ ដោយសាររស់នៅជាមួយគ្នា ចេះតែឈ្លោះរកាំរកូសនឹងគ្នាពុំចេះចប់ ហើយឈ្មោះ ត្រូវជាប្រពន្ធមិនដែលយកចិត្តទុកដាក់ចំពោះប្តី នៅពេលប្តីមានជម្ងឺមិនតែប៉ុណ្ណោះ ថែមទាំងផ្លាស់ប្តូរសៀវភៅគ្រួសារថ្មីដោយចិត្តឯង ម្តងជាពីរដង ក្នុងបំណងចង់យកទ្រព្យសម្បត្តិរួមទាំងអស់ ដោយបំបាត់ឈ្មោះ ខ្លួនចេញពីសៀវភៅគ្រួសារ។

ខ្លួនសុំបន្ថែមការទាមទារ ដោយសុំឱ្យតុលាការធ្វើការបែងចែកនូវគ្រឿងអលង្កាដែលមានតម្លៃចំនួន ៤ ០០០ (បួនពាន់) ដុល្លារអាមេរិក ជាពីចំណែកស្មើគ្នា និងសុំទាមទារទ្រព្យដែលខ្លួនមានមុនពេល

រៀបអាពាហ៍ពិពាហ៍ ដូចជាម៉ូតូមួយគ្រឿងម៉ាក HONDA ពណ៌ព្រីងទុំ ដែលចុងចម្លើយយកទៅលក់បានតម្លៃ ៣៥០ ដុល្លារអាមេរិក ,ប្រាក់ចំណងដៃអាពាហ៍ពិពាហ៍ដែលសល់ពីការទូទាត់រួចរាល់ហើយគឺ នៅសល់ចំនួន ៣ ១២០ (បីពាន់មួយរយម្ភៃ) ដុល្លារអាមេរិក សុំបែងចែកជាពីរចំណែកស្មើគ្នា។

**II.អំពីសេចក្ដីសម្រេចរបស់តុលាការ**

**ក.**សាលាដំបូងខេត្តកណ្ដាលបានសម្រេចតាមអំណាចសាលក្រមរដ្ឋប្បវេណីលេខ "ជ.ជ" ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៧ ៖

១.ឱ្យដើមចោទឈ្មោះ ស ខេមរា លែងលះ ពីចុងចម្លើយឈ្មោះ ។

២.ប្រគល់សិទ្ធិអំណាចមេបាឱ្យទៅចុងចម្លើយ លើកូន ០១ នាក់ ឈ្មោះ ភេទប្រុស អាយុ ៩ ឆ្នាំ តាមមាត្រា១០៣៧ នៃក្រមរដ្ឋប្បវេណី តែទុកសិទ្ធិឱ្យដើមចោទឈ្មោះ ជាឪពុកអាចទៅសួរសុខទុក្ខកូនបាន និងចេញសោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីថែរក្សាកូនទៅតាមលទ្ធភាព យោងតាមមាត្រា ១០៤០,១០៤១ និងមាត្រា១០៤២ នៃក្រមរដ្ឋប្បវេណី។

៣.បែងចែកទ្រព្យរួមជា២ ចំណែកស្មើគ្នាឱ្យទៅដើមចោទឈ្មោះ និងចុងចម្លើយឈ្មោះ រួមមាន៖

ក.ដីចំការមួយកន្លែងទំហំ ០៥ ហិកតា ស្ថិតនៅភូមិខ្វាយ ឃុំតំបែរ ស្រុកតំបែរ ខេត្តត្បូងឃ្មុំ ដែលមានព្រំប្រទល់ខាងជើងទល់នឹង ផ្លូវលំ ខាងត្បូងទល់នឹង ខាងកើតទល់នឹង និង ខាងលិចទល់នឹង ។

ខ.ដីភូមិមួយកន្លែង "ដើមភូមិ" ទទឹងទំហំ ៤៨ ម៉ែត្រ បណ្ដោយ ៥០០ ម៉ែត្រ ស្ថិតនៅភូមិស្រែត្រែង ឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះ មានព្រំប្រទល់ខាងជើងទល់នឹង ខាងត្បូងទល់នឹង ខាងលិច ទល់នឹង ព្រៃរបោះ និងខាងកើតទល់នឹង ផ្លូវជាតិ។

គ.ដីភូមិមួយកន្លែង ទទឹងទំហំ ១១២ ម៉ែត្រ x បណ្ដោយ ៥០០ ម៉ែត្រ ស្ថិតនៅភូមិស្រែត្រែង ឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះ មានព្រំប្រទល់ ខាងជើងទល់នឹង សូ ភ័ក្រ ខាងត្បូងទល់នឹង ខាងលិចទល់នឹង ព្រៃរបោះ និងខាងកើតទល់នឹង ផ្លូវជាតិ។

ឃ.ដីភូមិមួយកន្លែង ទទឹងទំហំ ៥០ម៉ែត្រ បណ្ដោយ ៥០០ ម៉ែត្រ ស្ថិតនៅភូមិស្រែត្រែង ឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះ មានព្រំប្រទល់ ខាងជើងទល់នឹង ខាងត្បូងទល់នឹង ផ្លូវរទេះ ខាងលិចទល់នឹង ព្រៃរបោះ ខាងកើតទល់នឹងផ្លូវជាតិ។

ង.តូបលក់មាសមួយកន្លែង ទទឹងទំហំ ១ ម៉ែត្រ x បណ្ដោយ ១,២០ ម៉ែត្រ ១,២០ ម៉ែត្រ ស្ថិតនៅភូមិតាខ្មៅ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល ដែលមានព្រំប្រទល់ខាងជើងទល់នឹង ផ្លូវចេញចូល ខាងត្បូងទល់នឹងឈ្មោះ ខាងកើត ទល់នឹង របងផ្សារ និងខាងលិចទល់នឹងផ្លូវ ២០៣។

ច.ផ្ទះជាន់ទី២ លេខ $E_{2B}$ ក្រុម១៧ ផ្លូវ១០៤ ស្ថិតនៅភូមិតាខ្មៅ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល។

ការទាមទារលើសពីនេះ ច្រានចោល។

៤.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

៥.សាលក្រមនេះ ទាញហេតុផលដោយផ្ទាល់មាត់ និងប្រកាសជាសាធារណៈ។

ទុកសិទ្ធិប្តឹងតវ៉ាក្នុងកំណត់ច្បាប់។ (ឯ.១៩)

សាលាដំបូងខេត្តកណ្តាល សម្រេចយ៉ាងនេះ ដោយសំអាងហេតុថា ៖

១.តាមការអះអាងរបស់គូភាគីឃើញថា ដើមចោទ និងចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍ និងចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមផ្លូវច្បាប់ តាមសំបុត្រអាពាហ៍ពិពាហ៍លេខ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ ២០០៥ រហូតដល់សព្វថ្ងៃ មានកូនប្រុសម្នាក់ឈ្មោះ ស ផលវិរៈយុត្ត ភេទប្រុស អាយុ ៩ ឆ្នាំ។

២.តាមពាក្យបណ្តឹងចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៦ និងតាមការអះអាងរបស់ដើមចោទ នាពេលនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ព្រមទាំងវត្ថុតាងនានា ដើមចោទនៅតែប្តឹងទាមទារលែងលះជាមួយចុងចម្លើយឈ្មោះ និងសុំទាមទារបែងចែកទ្រព្យរួម ដែលបានរៀបរាប់ខាងលើ ដដែល។

តុលាការយល់ឃើញថា ដីចំនួន ០៤ កន្លែង ដែលដើមចោទទាមទារបែងចែកជា ២រួមមាន៖

ក.ដីចំការមួយកន្លែងទំហំ ហិកតា ស្ថិតនៅភូមិខ្ជាយ ឃុំតំបែរ ស្រុកតំបែរ ខេត្តត្បូងឃ្មុំ ដែលមានព្រំប្រទល់ខាងជើងទល់នឹង ផ្លូវលំ ខាងត្បូងទល់នឹង ខាងកើតទល់នឹង និង ខាងលិចទល់នឹង ។

ខ.ដីភូមិមួយកន្លែង "ដើមភូមិ" ទទឹងទំហំ ៤៨ ម៉ែត្រ បណ្តោយ ៥០០ ម៉ែត្រ ស្ថិតនៅភូមិស្រែត្រែង ឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះ មានព្រំប្រទល់ខាងជើងទល់នឹង ខាងត្បូងទល់នឹង រុញ ខាងលិច ទល់នឹង ព្រៃរបោះ ខាងកើតទល់នឹង ផ្លូវជាតិ។

គ.ដីភូមិមួយកន្លែង ទទឹងទំហំ ១១២ ម៉ែត្រ x បណ្តោយ ៥០០ ម៉ែត្រ ស្ថិតនៅភូមិស្រែត្រែង ឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះ មានព្រំប្រទល់ ខាងជើងទល់ ខាងត្បូងទល់នឹង ខាងលិចទល់នឹង ព្រៃរបោះ ខាងកើតទល់នឹង ផ្លូវជាតិ។

ឃ.ដីភូមិមួយកន្លែង ទទឹងទំហំ ៥០ម៉ែត្រ x បណ្តោយ ៥០០ ម៉ែត្រ ស្ថិតនៅភូមិស្រែត្រែង ឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះ មានព្រំប្រទល់ ខាងជើងទល់នឹង អ្នកគ្រូ ខាងត្បូងទល់នឹង ផ្លូវរទេះ ខាងលិចទល់នឹង ព្រៃរបោះ ខាងកើតទល់នឹងផ្លូវជាតិ។

ង.តូបលក់មាសមួយកន្លែង ទទឹងទំហំ ១ ម៉ែត្រ x បណ្តោយ ១,២០ ម៉ែត្រ ១,២០ ម៉ែត្រ ស្ថិតនៅភូមិតាខ្មៅ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល មានព្រំប្រទល់ខាងជើងទល់នឹង ផ្លូវចេញចូល ខាងត្បូងទល់នឹង ខាងកើត ទល់នឹង របងផ្សា ខាងលិចទល់នឹងផ្លូវ ២០៣។

ពិតជាទ្រព្យសម្បត្តិរួមដែល កើតឡើងក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ពិតប្រាកដមែន បើយោងតាមសំបុត្រអាពាហ៍ពិពាហ៍លេខ ៣២ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០០៥ និងឯកសារភស្តុតាងនានាទាក់ទងនឹងដីចំនួន ០៤ កន្លែងនោះ រួមមាន៖ វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៣០៤០២០៥-០៤២៨

ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៣, វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៤,វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៤ ,លិខិតស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លី ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៦ និងលិខិតបញ្ជាក់របស់អតីតម្ចាស់គួបលក់មាស ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៧ ដូច្នេះគប្បីតុលាការសម្រេចបែងចែកទ្រព្យសម្បត្តិរួមរបស់ដើមចោទ និងចុងចម្លើយជាពីរចំណែកស្មើគ្នាតាមបញ្ញត្តិមាត្រា៩៧៨ និងមាត្រា ៩៨០ នៃក្រមនីតិរដ្ឋប្បវេណី។

៣.ដើមចោទឈ្មោះ ក៏បានទាមទារអោយក្នុងការបែងចែកទ្រព្យសម្បត្តិរួមផ្សេងៗទៀតដែលមានដូចជាៈ

ក.សុំបែងចែកថវិកាដែលភាគី យកដីចំការចំនួន ហិកតា ជាទ្រព្យសម្បត្តិរួមទៅជួលឱ្យប្រជាពលរដ្ឋដាំដំឡូង តាំងពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៦ ដែលតម្លៃជួលដីទាំងអស់សរុបចំនួន ៦០ ០០០ ០០០ (ហុកសិបលាន) រៀល។

ខ.សុំចែកថវិកាដែលបានមកពីការដឹកនាំប្រជាពលរដ្ឋទៅទិញដីនៅខេត្តក្រចេះ (ត្នួកជេរ) ក្នុងតម្លៃមួយម៉ែត្រក្បាលបាន ៥០ (ហាសិប) ដុល្លារអាមេរិក ហើយលក់បានចំនួន ៣៩៨ ម៉ែត្រ ក្បាល ប្រាក់កម្រៃស្មើ ១៩ ៩០០ (មួយម៉ឺនប្រាំបួនពាន់ ប្រាំបួនរយ) ដុល្លារអាមេរិក "ចែកជា៣ ចំណែក"។

តាមការអះអាងរបស់ដើមចោទ ចុងចម្លើយ និងភស្តុតាងនានា ក្នុងសំណុំរឿងទាក់ទងនឹងការទាមទារខាងលើនេះ តុលាការយល់ឃើញថា ដើមចោទ និងចុងចម្លើយ ពុំមានឯកសារណាមួយមកបញ្ជាក់ដែលអាចឱ្យតុលាការជឿបានថាពិតជាមានទ្រព្យខាងលើពិតប្រាកដជាក់ស្តែង ដែលអាចឱ្យតុលាការធ្វើការបែងចែកនោះទេ គប្បីតុលាការច្រានចោល ការទាមទាររបស់ដើមចោទចោល។

៤.តាមពាក្យបណ្តឹងចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៦ ដើមចោទមិនបានស្នើសុំឱ្យតុលាការបែងចែកលើផ្ទះល្វែងជាន់ទី២ ទំហំ ៤ម៉ែត្រ បណ្តោយ ១៥ម៉ែត្រ ស្ថិតនៅភូមិតាខ្មៅ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល និងមិនបានស្នើសុំសិទ្ធិគ្រប់គ្រងកូនប្រុសម្នាក់ឈ្មោះ អាយុ ៩ ឆ្នាំ ទេ ប៉ុន្តែតាមសេចក្តីថ្លែងការណ៍ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៦ របស់ដើមចោទនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដើមចោទបានស្នើសុំបន្ថែមឱ្យតុលាការសម្រេចចេញសាលក្រម បែងចែកផ្ទះ ជាន់ទី២ ទំហំ ៤ ម៉ែត្រ បណ្តោយ ១៥ម៉ែត្រ ស្ថិតនៅភូមិតាខ្មៅ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល ដែលជាទ្រព្យរួមជា ២ចំណែក និងសុំសិទ្ធិគ្រប់គ្រងកូន គប្បីតុលាការសម្រេចតាមមាត្រា១០៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ការទាមទារនេះ តុលាការយល់ឃើញថា ផ្ទះល្វែងជាន់ទី២ ទំហំ ៤ម៉ែត្រ បណ្តោយ ១៥ម៉ែត្រ ស្ថិតនៅភូមិតាខ្មៅ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល ក៏ជាទ្រព្យសម្បត្តិរួមរបស់ដើមចោទ និងចុងចម្លើយដែរ ព្រោះជាទ្រព្យសម្បត្តិដែលមាននៅក្រោយពេលអាពាហ៍ពិពាហ៍ បើយោងទៅតាមកិច្ចព្រមព្រៀងលក់ផ្ទះ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៣ រវាងឈ្មោះ និងឈ្មោះ និងលិខិតបញ្ជាក់

លេខ ៣៣៨/១៧ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៧ ដូច្នេះគប្បីតុលាការសម្រេចបែងចែកទ្រព្យសម្បត្តិរួមរបស់ដើមចោទ និងចុងចម្លើយជា ២ចំណែកស្មើគ្នាតាមបញ្ញត្តិមាត្រា៩៧៣ និងមាត្រា៩៨០ នៃក្រមរដ្ឋប្បវេណី។

៥.ដើមចោទសុំសិទ្ធិគ្រប់គ្រងកូនប្រុសឈ្មោះ អាយុ ៩ ឆ្នាំ តុលាការ និងសម្រេចពីអំណាចមេបានេះ តាមបញ្ញត្តិមាត្រា ១០៣៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

៦.តាមសេចក្តីថ្លែងការណ៍នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដើមចោទនៅ តែប្តឹងលែងលះពីចុងចម្លើយឈ្មោះ ហើយភាគីចុងចម្លើយក៏បានឯកភាពក្នុងការលែងលះ តុលាការយល់ឃើញថា ដើមចោទ និងចុងចម្លើយ ពិតជាមានឆន្ទៈក្នុងការលែងលះគ្នាពិតប្រាកដមែន គប្បីតុលាការសម្រេចតាមការព្រមព្រៀងរបស់គូភាគី។

៧.ចំពោះបន្ទុកនៃប្រាក់ប្រដាប់ក្តី តុលាការនិងសម្រេចតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា។

សាលក្រមនេះត្រូវបានឈ្មោះ មេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយឈ្មោះ ប្តឹងឧទ្ធរណ៍ តាមបណ្តឹងលេខ ០១២ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៨ ត្រង់សេចក្តីសម្រេចទាំងមូល។

**ខ.សាលាឧទ្ធរណ៍បានសម្រេចតាមអំណាចសាលដីការដ្ឋប្បវេណីលេខ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៩ ដូចខាងក្រោម ៖**

១.ច្រានចោលបណ្តឹងឧទ្ធរណ៍លេខ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ ២០១៨ របស់ចុងចម្លើយឈ្មោះ ជឹម សុផល ត្រង់ចំណុចទី១ និងទី២ នៃសេចក្តីសម្រេចបញ្ចប់ ជាអសារបង់។

២.តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តកណ្តាល ត្រង់ចំណុចទី១ និងទី២ នៃសេចក្តីសម្រេចបញ្ចប់ ទុកជាបានការ លើកលែងតែចំណុចទី៣ នៃសេចក្តីសម្រេចបញ្ចប់ ត្រូវលុបចោល ហើយសម្រេចជាថ្មី ដូចខាងក្រោមនេះ៖

ក. ធ្វើការបែងចែកទ្រព្យសម្បត្តិរួម រវាងដើមចោទឈ្មោះ និងចុងចម្លើយឈ្មោះ ជឹម សុផល ដូចតទៅ៖

ក.១/ដើមចោទឈ្មោះ ធ្វើលទ្ធកម្មនូវកម្មសិទ្ធិនៃដីទំហំ ២៩១២៨ ម² ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៣ មានទីតាំងស្ថិតនៅភូមិខ្លាយ ឃុំតំបែរ ស្រុកតំបែរ ខេត្តត្បូងឃ្មុំ។

ក.២/ចុងចម្លើយឈ្មោះ ជឹម សុផល ធ្វើលទ្ធកម្មនូវកម្មសិទ្ធិនៃដីទំហំ ២៩១២៨ ម² ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៣ មានទីតាំងស្ថិតនៅភូមិខ្លាយ ឃុំតំបែរ ស្រុកតំបែរ ខេត្តត្បូងឃ្មុំ។

ក.៣/បង្គាប់ឱ្យដើមចោទឈ្មោះ និងចុងចម្លើយឈ្មោះ ធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិនៃចំណុច ក.១ និងចំណុច ក.២ ឱ្យគ្នាទៅវិញទៅមក។

ខ.ច្រានចោលការទាមទាររបស់ដើមចោទឈ្មោះ ក្រៅពីចំណុចបែងចែកក្នុងចំណុច "ក" ខាងលើ។

៣.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ និងចុងចម្លើយ ។ (ឯ.៨២)

សាលាឧទ្ធរណ៍សម្រេចយ៉ាងនេះដោយសំអាងហេតុថា៖

១-ពាក្យបណ្តឹងឧទ្ធរណ៍លេខ ០១២ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ ២០១៨ របស់ចុងចម្លើយឈ្មោះ ប្តឹងឧទ្ធរណ៍ចំពោះសាលក្រមរដ្ឋប្បវេណីលេខ " " ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តកណ្តាល ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល បានធ្វើឡើងត្រឹមត្រូវតាមច្បាប់ ដែលអាចឱ្យសភារដ្ឋប្បវេណីនៃសាលាឧទ្ធរណ៍ ទទួលយកសំណុំរឿងរដ្ឋប្បវេណីលេខ ៣២១ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ មកធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ផ្អែកតាមមាត្រា ២៦០ និងមាត្រា២៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

២-ចុងចម្លើយឈ្មោះ បានធ្វើសេចក្តីថ្លែងការណ៍ថា ការដែលខ្លួនប្តឹងឧទ្ធរណ៍នឹងសាលក្រមរបស់សាលាដំបូងខេត្តកណ្តាល គឺដោយសារខ្លួនពុំសុខចិត្តចំពោះការបែងចែកទ្រព្យសម្បត្តិ ព្រោះថាដីទំហំ ៤៨ ម x ៥០០ ម ,ដីទំហំ ១១២ ម x ៥០០ ម និងដីទំហំ ៥០ ម x ៥០០ ម មានទីតាំងស្ថិតនៅភូមិស្រែត្រែង ឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះ ជាទ្រព្យសម្បត្តិដោយឡែក របស់ខ្លួនជាមួយនឹងប្តីមុន។ ចំពោះការសម្រេចឱ្យខ្លួនលែងលះពីដើមចោទ និងឱ្យខ្លួនជាអ្នកមានសិទ្ធិអំណាចមេបាចំពោះកូននោះ ខ្លួនឯកភាព។

៣-ដើមចោទឈ្មោះ បានធ្វើសេចក្តីថ្លែងការណ៍ថា ចំពោះតូប, ផ្ទះលេខ ២៨៩ E28 និងដីទាំងអស់ គឺជាទ្រព្យសម្បត្តិរួម។

៤-ផ្អែកតាមវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១០០៤០៣០៥-០១៦០ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៤, និងវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១០០៤០៣០៥-០១៦៩ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៤ ឃើញថា ដីពីរកន្លែងដែលមានក្បាលដីលេខ ១៦០ និងលេខ ១៦៩ គឺ ទ្រព្យសម្បត្តិរបស់ចុងចម្លើយ ដែលមេម៉ាយពីខ្មោចប្តីឈ្មោះ ហេតុដូច្នេះ ដីទាំងពីរប័ណ្ណនេះ គឺជាទ្រព្យដោយឡែករបស់ចុងចម្លើយ។

៥-តាមខ្លឹមសារនៃការទាមទាររបស់ដើមចោទ និងសេចក្តីថ្លែងការណ៍របស់គូភាគី ឃើញថា ដើមចោទមិនបានធ្វើការទាមទារបែងចែកផ្ទះជាន់ទី២ លេខ ២៨៩ E28 ក្រុម១៧ ផ្លូវ១០៤ ស្ថិតនៅភូមិតាខ្មៅ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល ហើយផ្ទះនោះ គឺជាកម្មសិទ្ធិរបស់កូនស្រីឈ្មោះ ស កណ្ណិការ។

ទី២៧ ខែកុម្ភៈ ឆ្នាំ២០១៣ មានទីតាំងស្ថិតនៅភូមិខ្ចាយ ឃុំតំបែរ ស្រុកតំបែរ ខេត្តត្បូងឃ្មុំ និងបង្គាប់គូភាគី ធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិនៃចំណុចក.១ និងចំណុច ក.២ ឱ្យគ្នាទៅវិញទៅមក ដោយហេតុថា ដីនេះមិនមែនជាទ្រព្យសម្បត្តិរួមទេ គឺជាប្រាក់ដោយឡែករបស់នាងខ្ញុំឈ្មោះ យកទៅទិញទាំងស្រុង ហើយជាក់ស្តែង លោក ក៏មានផ្ទះមួយល្វែងនៅភ្នំពេញ ដែលខ្លួនមិនទាមទារឡើយ។

២.មេធាវីតំណាងដោយអាណត្តិឱ្យដើមបណ្តឹងសាទុក្ខឈ្មោះ បានប្តឹងសាទុក្ខ ដោយលើកមូលហេតុថា ការអះអាងរបស់ឈ្មោះ ថា ដីទាំងបីកន្លែង ជាកេរ្តិ៍សល់ពីប្តីមុននោះ មិនត្រឹមត្រូវទេ ពីព្រោះឈ្មោះនេះ មិនបានប្រកាសចុះបញ្ជីអំពីទ្រព្យសម្បត្តិមុន ឬក្រោយរៀបអាពាហ៍ពិពាហ៍ជាមួយឈ្មោះ ទេ តាមកថាខណ្ឌទី១ វាក្យខណ្ឌទី១ នៃមាត្រា ៩៦៩, កថាខណ្ឌទី១ នៃមាត្រា ៩៧០ នៃក្រមរដ្ឋប្បវេណី។

៣.សាលាឧទ្ធរណ៍បានសម្រេចបែបនេះ ដោយសំអាងថា នៅក្នុងសំអាងហេតុទី៩ ពាក់ព័ន្ធនឹងដីទាំងពីរប័ណ្ណដែលមានក្បាលដីលេខ និងលេខ ១៦៩ គឺជាទ្រព្យដោយឡែករបស់ចុងចម្លើយ និងនៅក្នុងសំអាងហេតុទី៧ និងទី៨ ពាក់ព័ន្ធនឹងដីទំហំ ២៩១២៨ ម² មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ - ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៣ មានទីតាំងស្ថិតនៅភូមិខ្ចាយ ឃុំតំបែរ ស្រុកតំបែរ ខេត្តត្បូងឃ្មុំ ឱ្យទៅដើមចោទ និងចុងចម្លើយ នោះ គឺមិនមានភាពច្បាស់លាស់នោះទេ ពីព្រោះមិនមានលើកភស្តុតាងណាមួយមកបញ្ជាក់ថា ជាទ្រព្យសម្បត្តិរួមនោះឡើយ។ ប៉ុន្តែ បើពិនិត្យលើវិញ្ញាបនប័ត្រនេះឃើញថា មានឈ្មោះរបស់គូភាគីជាម្ចាស់កម្មសិទ្ធិ ដែលផ្ទុយពីការលើកឡើងរបស់ដើមបណ្តឹងសាទុក្ខឈ្មោះ ថា ជាទ្រព្យដោយឡែករបស់ខ្លួន ពីព្រោះយកប្រាក់ផ្ទាល់ខ្លួនមកទិញ ហើយការលើកឡើងនេះក៏មិនមានភស្តុតាងបញ្ជាក់ដែរ ។

៤. ការកត់សំគាល់៖ ការទាមទារដីរបស់ដើមចោទ សុទ្ធតែដីមានទំហំជាង ០២ ហិចតា ឯណោះ ប៉ុន្តែ តាមប័ណ្ណលេខ ១៦០ មានទំហំ ៥៨៩១ម² និងប័ណ្ណលេខ មានទំហំ ៨៩៧១ម² ប៉ុណ្ណោះ ដែលគប្បីតុលាការផ្ទៀងផ្ទាត់ភស្តុតាងទាំងនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមប្រធាន និងក្រុមប្រឹក្សាជំនុំជម្រះមេត្តាជ្រាប។

ចៅក្រមទទួលបញ្ជា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

...សាលាឧទ្ធរណ៍ភ្នំពេញ

លេខ:...........ចុះថ្ងៃទី...02...

ខែ...មករា...ឆ្នាំ...2020...

រឿង.....................

លេខ:...........ចុះថ្ងៃទី...14...

ខែ...6...ឆ្នាំ...2019...

# សេចក្តីសុំប្តឹងសាទុក្ខ

ឆ្នាំពីរពាន់.........ខែ...មករា.........ថ្ងៃទី...០២.........វេលាម៉ោង.....................

យើង.................................................ក្រឡាបញ្ជីសាលាឧទ្ធរណ៍ភ្នំពេញ។

បានឃើញ.....................................02.01.2020.....................................

ចូលមកចំពោះមុខយើងនៅសាលាឧទ្ធរណ៍ភ្នំពេញ ហើយសុំប្តឹងសាទុក្ខនឹងសាលដីកា.....................

លេខ...40.......ចុះថ្ងៃទី...06...ខែ...11...ឆ្នាំ ២០២០...គ្រង់ចំណុច.....................

.....................................................................................

.....................................................................................

.....................................................................................

.....................................................................................

.....................................................................................

ក្រែងពុំប្រាកដ យើងបានអានសេចក្តីប្តឹងនេះឲ្យសាមីខ្លួនស្តាប់ ហើយឲ្យចុះហត្ថលេខា រឺ ផ្តិតមេដៃជាមួយយើង។

| អ្នកប្តឹង | ក្រឡាបញ្ជី |
|---|---|
| ស្នាមមេដៃស្តាំ | ហត្ថលេខា |

.....................................................................................

| បានឃើញ | បានចំលងចេញត្រឹមត្រូវតាមច្បាប់ដើម ។ |
|---|---|
| ប្រធានក្រុមប្រឹក្សាជំនុំជំរះ | សាលាឧទ្ធរណ៍ ថ្ងៃទី...02...ខែ...មករា...ឆ្នាំ២០២០ |
| គួ_ពៅស៊ីន | ក្រឡាបញ្ជី |

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍
ផ្នែករដ្ឋប្បវេណី
លេខ 04 ម៉ោង 10h30
ថ្ងៃទី 02 01 20

# ពាក្យបណ្តឹងសាទុក្ខ

**ដើមចោទ:** ឈ្មោះ ភេទស្រី អាយុ ឆ្នាំ ជនជាតិខ្មែរ អាសយដ្ឋាន ភូមិរកាកោង ឃុំរកាកោង១ ស្រុកមុខកំពូល ខេត្តកណ្តាល។

**មេធាវីតំណាងដោយអាណត្តិរបស់ដើមចោទ:** លោកមេធាវី អត្តលេខ: ជាសមាជិកមេធាវីនៃ **ក្រុមហ៊ុនមេធាវី ខ្មែរអេប្បុវ** មានការិយាល័យ ផ្ទះលេខ៥អា ផ្លូវលេខ ២៨៥ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។ ទូរស័ព្ទលេខ:

**ចុងចម្លើយ:** ឈ្មោះ ភេទប្រុស អាសយដ្ឋាន ភូមិទេសអន្លុង សង្កាត់បឹងកន្សែង ក្រុងបានលុង ខេត្តរតនគិរី។

## សូមគោរពចូលមក

## ឯកឧត្តម ប្រធានសាលាឧទ្ធរណ៍

*សូមមេត្តាជ្រាប។*

**កម្មវត្ថុ:** សុំប្តឹងសាទុក្ខចំពោះសាលដីការដ្ឋប្បវេណីលេខ: ៤០ ក្រ.VII.ភស ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ទាំងមូល។

**យោង:** - សំណុំរឿងរដ្ឋប្បវេណីលេខ: ៣១០ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍

- សាលដីការដ្ឋប្បវេណីលេខ: ៤០ ក្រ.VII.ភស ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍។

តបតាមកម្មវត្ថុ និងយោងខាងលើ នាងខ្ញុំសូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា: កាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៩ សាលាឧទ្ធរណ៍បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់លើសំណុំរឿងរដ្ឋប្បវេណីលេខ: ៣១០ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៩ ហើយបានប្រកាសសាលដីការដ្ឋប្បវេណីលេខ: ៤០ ក្រ.VII.ភស ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ជាសាធារណ: នៅថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៩ ដោយសម្រេចតម្កល់សាលក្រមរដ្ឋប្បវេណីលេខ: ១៩ ... ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកណ្តាល មុកជាបានការដដែល។ ការសម្រេចសេចក្តីនេះ ពុំបានផ្តល់ភាពយុត្តិធម៌ជូននាងខ្ញុំឡើយ ទើបធ្វើឱ្យនាងខ្ញុំកើតទុក្ខមិនសុខចិត្ត និងសម្រេចចិត្តប្តឹងសាទុក្ខចំពោះសាលដីការដ្ឋប្បវេណីលេខ: ៤០ ក្រ.VII.ភស ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ត្រង់សេចក្តីសម្រេចបញ្ចប់ទាំងមូល។

អាស្រ័យហេតុនេះ សូម **ឯកឧត្តមប្រធាន** មេត្តាពិនិត្យ និងសម្រេចបញ្ជូនពាក្យបណ្តឹងសាទុក្ខ និងឯកសារសំណុំរឿងរបស់នាងខ្ញុំទៅតុលាការកំពូលតាមនីតិវិធីច្បាប់ ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ

ថ្ងៃព្រហស្បតិ៍ ៨កើត ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
រាជធានីភ្នំពេញ, ថ្ងៃទី០២ ខែមករា ឆ្នាំ២០២០
**ស្នាមមេដៃស្តាំ**

**បានឃើញ**
ថ្ងៃព្រហស្បតិ៍ ៨កើត ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ, ថ្ងៃទី០២ ខែមករា ឆ្នាំ២០២០
**ហត្ថលេខា និង ត្រា**
**មេធាវី**

AVOCAT
ATTORNEY
AT LAW
KINGDOM OF CAMBODIA

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល

សំណុំរឿងរដ្ឋប្បវេណី

លេខ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៦

សាលក្រមលេខ ធ

ចុះថ្ងៃ ចន្ទ ១០រោច ខែ ចេត្រ ឆ្នាំកុរ ឯកស័ក ព.ស២៥៦២

ត្រូវនឹងថ្ងៃទី ២៩ ខែ មេសា ឆ្នាំ២០១៩

# គោរពនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តកណ្ដាល

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នា

ថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩

**ចៅក្រមជំនុំជម្រះ**

លោក **គឹម រ័ត្នណារិន** ចៅក្រមសាលាដំបូងខេត្តកណ្ដាល

**ក្រឡាបញ្ជីសវនាការ**

លោក **នៅ សុគាព** ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្ដាល

-ដើមចោទឈ្មោះ ភេទប្រុស អាយុ ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅភូមិរាជានុកូល សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង ដែលមានលោក និងលោក ជាមេធាវីតំណាងដោយអាណត្តិ ។

-ចុងចម្លើយឈ្មោះ ភេទស្រី អាយុ ឆ្នាំ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅភូមិរកាកោង ឃុំរកាកោង១ ស្រុកមុខកំពូល ខេត្តកណ្ដាល ដែលមានលោក លោក និង លោក ជាមេធាវីតំណាងដោយអាណត្តិ។

## <u>អង្គហេតុ និង ចំណុចវិវាទ</u>

**១.ការទាមទារដោយដើមចោទ ៖**

សុំឲ្យតុលាការចេញសាលក្រមសម្រេចៈ

១-សុំលែងលះពីប្រពន្ធឈ្មោះ ។

២-សុំសិទ្ធិគ្រប់គ្រង និងមានអំណាចមេបាលើកូនឈ្មោះ ភេទប្រុស អាយុ ឆ្នាំ ។

៣-សុំសិទ្ធិគ្រប់គ្រងរថយន្តម៉ាក HIGHLANDER ពណ៌ទឹកមាស ស៊េរីឆ្នាំ២០០១ ផ្លាកលេខ ភ្នំពេញ- ចំនួន ០១គ្រឿង ។

៤-ផ្ទះលេខ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រគល់ឲ្យកូនឈ្មោះ និងកូនឈ្មោះ ។

៥-ប្រគល់ៈ

-ផ្ទះល្វែងនៅផ្សាររកាកោង ស្រុកមុខកំពូល ខេត្តកណ្ដាល

-ដីនៅភូមិចុងព្រែក ឃុំរកាកោង២ ស្រុកមុខកំពូល ខេត្តកណ្ដាល

-ដីទំហំ ២៥ម៉ែត្រ គុណ១៤០ម៉ែត្រ នៅស្រុកមុខកំពូល ខេត្តកណ្ដាល

-រថយន្តម៉ាក Lexus RX 300 ពណ៌ស ស៊េរីឆ្នាំ១៩៩៩ ផ្លាកលេខ ភ្នំពេញ- ចំនួន ០១គ្រឿង

-រថយន្តម៉ាក Visto ពណ៌ស ចំនួន ០១គ្រឿង

-គ្រឿងអលង្ការមួយចំនួនកំពុងលក់

-កូនស្រីឈ្មោះ អាយុ ឆ្នាំ ឲ្យទៅប្រពន្ធឈ្មោះ

មានសិទ្ធិគ្រប់គ្រង និងមានអំណាចមេបា

**២.ការពន្យល់ត្រួសៗអំពីរឿងក្តី**

ខ្ញុំបាទឈ្មោះ និងឈ្មោះ បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាជាប្តីប្រពន្ធតាំងពីឆ្នាំ១៩៩៣ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ។ បន្ទាប់ពីខ្ញុំបាទនិងប្រពន្ធចាប់ដៃគ្នាជាប្តីប្រពន្ធមកគឺពួកខ្លួនមានកូនចំនួន ០២នាក់ គឺកូនប្រុសទី១ ឈ្មោះ អាយុ ឆ្នាំ និងកូនស្រី ឈ្មោះ អាយុ ឆ្នាំ និងមានទ្រព្យសម្បត្តិរួមមួយចំនួនទៀត ប៉ុន្តែដោយហេតុថា ការរួមរស់ជាមួយគ្នាមិនចុះសម្រុងគ្នា ណាមួយខ្ញុំបាទ និងប្រពន្ធបានរស់នៅបែកគ្នាអស់រយៈពេល ៥-៦ ឆ្នាំមកហើយ ជាក់ស្តែងខ្ញុំបាទអស់មនោសញ្ចេតនាជាប្តីប្រពន្ធតទៅទៀតហើយ ។

**៣.ចំណុចវិវាទ និងចំណុចគ្មានវិវាទះ**

១-ដើមចោទឈ្មោះ ប្តឹងសុំលែងលះ តែចុងចម្លើយឈ្មោះ មិនឯកភាព ។ តើការប្តឹងសុំលែងលះមានមូលហេតុតាមផ្លូវច្បាប់ដែលអាចឲ្យតុលាការលើកយកមកពិចារណាបានដែររឺទេ?

២-ដើមចោទឈ្មោះ សុំបែងចែកទ្រព្យរួម តែចុងចម្លើយឈ្មោះ មិនឯកភាព ។ តើទ្រព្យទាំងអស់ដែលដើមចោទប្តឹងសុំបែងចែកនោះជាទ្រព្យសម្បត្តិរួម ឬយ៉ាងណា?

**៤.ការអះអាងរបស់គូភាគី ៖**

-ដើមចោទឈ្មោះ ដែលមានលោក ជាមេធាវីតំណាងដោយអាណត្តិបានថ្លែងការណ៍ថាៈ ស្នើសុំរក្សាខ្លឹមសារនិងការទាមទារដូចមានក្នុងសេចក្តីថ្លែងការណ៍ចុះថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ២០១៩ ទុកដដែល គឺ ខ្លួនឈ្មោះ និងឈ្មោះ បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាជាប្តីប្រពន្ធតាំងពីឆ្នាំ១៩៩៣ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ។ បន្ទាប់ពីខ្លួននិងប្រពន្ធចាប់ដៃគ្នាជាប្តីប្រពន្ធមកគឺពួកខ្លួនមានកូនចំនួន ០២នាក់ គឺកូនប្រុសទី១ ឈ្មោះ អាយុ ឆ្នាំ និងកូនស្រីទី២ ឈ្មោះ អាយុ ឆ្នាំ និងមានទ្រព្យសម្បត្តិរួមមួយចំនួនទៀត ប៉ុន្តែដោយហេតុថា ការរួមរស់ជាមួយគ្នាមិនចុះសម្រុងគ្នា ណាមួយខ្លួន និងប្រពន្ធបានរស់នៅបែកគ្នាអស់រយៈពេល ៥-៦ ឆ្នាំមកហើយ ជាក់ស្តែងខ្លួនអស់មនោសញ្ចេតនាជាប្តីប្រពន្ធតទៅទៀតហើយ ។ ហេតុនេះខ្លួនសុខចិត្តដាក់ពាក្យបណ្តឹងសុំលែងលះទៅសាលាដំបូងខេត្តកណ្តាល ។ តាមខ្លឹមសារនៃពាក្យបណ្តឹង ទ្រព្យសម្បត្តិរួមទាំងអស់ដូចដែលបានរៀបរាប់បានប្រគល់ឲ្យម្តាយនិងកូនពីរនាក់ តែតាមសេចក្តីថ្លែងការណ៍ចុះថ្ងៃទី ០៤ ខែមករា ឆ្នាំ ២០១៩ ទ្រព្យរួមទាំងនោះខ្លួនសម្រេចប្រគល់ឲ្យម្តាយ និងកូនស្រីឈ្មោះ តែពីរនាក់ ម្តាយនិងកូនតែប៉ុណ្ណោះ ចំណែកឯកូនប្រុសឈ្មោះ ជាបន្ទុករបស់ខ្លួន មិនឲ្យទាមទារទ្រព្យសម្បត្តិទាំងនោះទេ ។ ក្រោយពីតុលាការខេត្តកណ្តាលមានចំណាត់ការលើរឿងក្តីខ្លួន និងក្រោយពីខ្លួនបានធ្វើសេចក្តីថ្លែងការណ៍ ចុះថ្ងៃទី ០៤ ខែមករា ឆ្នាំ២០១៩ កន្លងមកឃើញថា ភាគីឈ្មោះ ចេះតែបង្កបញ្ហា ដែលធ្វើឲ្យរាំងស្ទះនីតិវិធីរបស់តុលាការ ផ្ទុយពីអ្វីដែលខ្លួនបានសន្យាខាងលើ ទើបខ្លួនសម្រេចចិត្តកែប្រែសេចក្តីថ្លែងការណ៍និងខ្លឹមសារនៃបណ្តឹងកន្លងមក គឺស្នើសុំឲ្យតុលាការបែងចែកទ្រព្យសម្បត្តិពាក់កណ្តាលម្នាក់ក្នុងនោះទ្រព្យសម្បត្តិរួមមានៈ

១-ផ្ទះលេខ WC សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ តម្លៃ ៣០០,០០០ $ (សាមសិបម៉ឺន)ដុល្លារអាមេរិក ។

២-ផ្ទះល្វែងនៅផ្សារកាកោង ស្រុកមុខកំពូល ខេត្តកណ្តាល តម្លៃ ១៥០,០០០ $ (ដប់ប្រាំម៉ឺនដុល្លាអាមេរិក) ។

៣-ដីនៅភូមិចុងព្រែក ឃុំរកាកោង២ ស្រុកមុខកំពូល ខេត្តកណ្ដាល តម្លៃ ៨០,០០០ $ (ប្រាំបីម៉ឺន)ដុល្លារអាមេរិក ។

៤-ដីទំហំ ២៥ម៉ែត្រ គុណ១៤០ម៉ែត្រ នៅស្រុកមុខកំពូល ខេត្តកណ្ដាល តម្លៃប្រហែល ៧០,០០០ $ (ប្រាំពីរម៉ឺន)ដុល្លារអាមេរិក ។

៥-រថយន្តម៉ាក Lexus RX 300 ពណ៌ស ស៊េរីឆ្នាំ១៩៩៩ ផ្លាកលេខ ភ្នំពេញ ចំនួន ០១គ្រឿង ។

៦-រថយន្តម៉ាក Visto ពណ៌ស ចំនួន ០១គ្រឿង ។

៧-គ្រឿងអលង្ការតម្លៃប្រហែល ៥០០,០០០ $ (ហាសិបម៉ឺន)ដុល្លារអាមេរិក កំពុងលក់ដូរ ។

ក្រោយមកខ្លួនបានពិនិត្យភស្តុតាងឃើញមានដីមួយកន្លែងទៀតនៅភូមិព្រែកជ្រៅ ដែលចុងចម្លើយបានដាក់ជូនតុលាការ ហេតុនេះសូមអោយតុលាការធ្វើការបែងចែកផង។ ចំពោះកូនប្រុសឈ្មោះ ជានីតិជន ដូច្នេះក៏ស្នើសុំឲ្យតុលាការសម្រេចនិងសាកសួរគាត់ដោយផ្ទាល់ចុះ ហើយចំពោះកូនស្រីឈ្មោះ ជាអនីតិជន វិញ បើសិនជាលោកតុលាការសម្រេចឲ្យកូនស្រីទៅឲ្យខាងចុងចម្លើយ ខ្លួនសុខចិត្តផ្ដល់អាហារកិច្ចកូនស្រីចំនួន ១.០០០.០០០រ (មួយលាន)រៀល ក្នុងមួយខែ។ ខ្លួននិងប្រពន្ធពុំមានជំពាក់បំណុលគេទេ។

-ចុងចម្លើយឈ្មោះ ដែលមានលោក បានថ្លែងតបថា: ខ្លួនពុំឯកភាពក្នុងការលែងលះទេ ។ ចំពោះកូនប្រុសឈ្មោះ ខ្លួនសុខចិត្តប្រគល់ជូនដើមចោទជាអ្នកចិញ្ចឹមបីបាច់ រីឯកូនស្រីឈ្មោះ ខ្លួនសុខចិត្តទទួលចិញ្ចឹមបីបាច់ ដោយមិនទាមទារអាហារកិច្ចទេ ។ ហើយចំពោះទ្រព្យសម្បត្តិរួមខ្លួនពុំឯកភាពបែងចែកទេ ព្រោះមានទ្រព្យដែលខាងដើមចោទប្ដឹងសុំបែងចែកនោះ វាមានការពាក់ព័ន្ធជាមួយបងប្អូនផងដែរ ហើយក៏ ដោយសារមូលហេតុនៃការលែងលះនេះព្រោះខាងដើមចោទបានចុះចោលខ្លួនរយៈពេល ៦ឆ្នាំ មកហើយ។ ទ្រព្យសម្បត្តិទាំងអស់ខ្លួនសុំគ្រប់គ្រងទាំងអស់។ ខ្លួនពុំមានជំពាក់បំណុលគេទេ។

-កូនស្រី ឈ្មោះ បានថ្លែងថា: ខ្លួនសុខចិត្តរស់នៅជាមួយម្ដាយ។

-កូនប្រុស ឈ្មោះ បានថ្លែងថា: ខ្លួនសម្រេចចិត្តរស់នៅមួយឪពុក។

-ដើមចោទឈ្មោះ សំណូមពរ: ស្នើសុំសំណូមពរអោយតុលាការសម្រេចឲ្យខ្លួនលែងលះពីចុងចម្លើយឈ្មោះ , សុំសិទ្ធិគ្រប់គ្រងកូនប្រុសឈ្មោះ និងសុំបែងចែកទ្រព្យរួម ។

-ចុងចម្លើយឈ្មោះ សំណូមពរៈ ស្នើសុំមិនធ្វើការបែងចែកទ្រព្យរួម និងសម្រេចផ្ដល់យុត្តិធម៌ដល់ខ្លួនដែលជាស្ត្រីទន់ខ្សោយ។

## **សំអាងហេតុ**

តាមលទ្ធផលនៃការសាកសួរគូភាគី និងពិនិត្យភស្តុតាង ក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ឃើញថា៖

១-ពាក្យបណ្ដឹង ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៦ របស់ឈ្មោះ ជាដើមចោទ មានលក្ខណៈត្រឹមត្រូវ បញ្ជាក់ឲ្យឃើញថា សាលាដំបូងខេត្តកណ្ដាលមានដែនសមត្ថកិច្ច ដើម្បីវិនិច្ឆ័យស្របច្បាប់នូវពាក្យបណ្ដឹង ហើយចេញសាលក្រមបានតាមមាត្រា ៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

២-គូភាគីបានរៀបអាពាហ៍ពិពាហ៍ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍លេខ សៀវភៅអាពាហ៍ពិពាហ៍លេខ ០/... ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៤ ចេញដោយមេឃុំរកាកោង២ ។

៣-គូភាគីពិតជាប្ដី - ប្រពន្ធត្រឹមត្រូវតាមផ្លូវច្បាប់ ហើយបានអស់មនោសញ្ចេតនាក្នុងការរួមរស់ជាមួយគ្នាតទៅទៀត ដែលធ្វើអោយទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាន គប្បីតុលាការពិចារណា និងសម្រេចទៅតាមមាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណី ។

ច-រថយន្ត LEXUS RX 300 ផ្លាកលេខ ភ្នំពេញ 2R- ពណ៌ស ឆ្នាំផលិត១៩៩៩ មានប័ណ្ណសម្គាល់យានយន្ត ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ២០១១ ដែលមានលោក ជាម្ចាស់កម្មសិទ្ធិ ។

ឆ-រថយន្ត KIA VISTO ផ្លាកលេខ ភ្នំពេញ 2T- ពណ៌ស ឆ្នាំផលិត២០០២ មានប័ណ្ណសម្គាល់យានយន្ត ចុះថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ២០១២ ដែលមានលោក ជាម្ចាស់កម្មសិទ្ធិ ។

ជ-ម៉ូតូ HONDA SUPER CUB 50 ផ្លាកលេខ 1BB- ពណ៌ខៀវចាស់ មានប័ណ្ណសម្គាល់ទោចក្រយានយន្ត ចុះថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ២០១១ ដែលមានលោក ជាម្ចាស់កម្មសិទ្ធិ ។

តុលាការយល់ឃើញថា ទ្រព្យសម្បត្តិដែលបានរៀបរាប់ខាងលើនេះគឺពិតជាទ្រព្យសម្បត្តិរួមរបស់គូភាគីពិតប្រាកដមែន បើទោះបីជាទ្រព្យសម្បតិមួយចំនួនមានតែឈ្មោះរបស់ភាគីណាម្ខាងជាម្ចាស់កម្មសិទ្ធិក៏ដោយ ប៉ុន្តែសុទ្ធតែជាទ្រព្យសម្បត្តិដែលទទួលបានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ដូច្នេះតុលាការគប្បីពិចារណាថា ជាទ្រព្យសម្បត្តិរួមរបស់គូភាគី ស្របតាមបញ្ញត្តិមាត្រា ៩៧៣ នៃក្រមរដ្ឋប្បវេណី ដូច្នេះនៅពេលមានបណ្ដឹងលែងលះ ក្នុងករណីដែលគូភាគីមិនអាចពីភាក្សាគ្នា ទាក់ទងនឹងការបែងចែកទ្រព្យសម្បត្តិនេះបានទេ តុលាការគប្បីពិចារណាបែងចែកទ្រព្យសម្បត្តិរួមជាពីរចំណែកស្មើគ្នាទៅតាមកំណត់ច្បាប់ ស្របតាមមាត្រា ៩៨០ កថាខណ្ឌទី ២ នៃក្រមនីតិវិធី ។

៩-ចំពោះការអះអាងអំពីទ្រព្យសម្បត្តិរួមរបស់គូភាគី ទាក់ទងទៅនឹង គ្រឿងអលង្ការតម្លៃប្រហែល ៥០០,០០០ $ ហាសិបម៉ឺនដុល្លារអាមេរិក ក៏ដូចជាគ្រឿងអលង្ការដែលមានក្នុងវិក័យប័ត្ររបស់ហាងគ្រឿងអលង្ការឃីហោ
លក់មាស ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ២០១១ , វិក័យប័ត្ររបស់ហាងលក់គ្រឿងអលង្ការឃីហោ លក់មាស ចុះថ្ងៃទី ៣០ខែតុលា ឆ្នាំ ២០១១ ,វិក័យប័ត្ររបស់ហាងលក់គ្រឿងអលង្ការឃីហោ ចុះថ្ងៃទី ២៥ ខែតុលា ឆ្នាំ ២០១១ និងវិក័យបត្ររបស់ហាងលក់គ្រឿងអលង្ការឃីហោ លក់មាស ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១១ នោះ តុលាការពិចារណាឃើញថាគ្រាន់ តែជាការអះអាងរបស់គូភាគីដែលថា ជាទ្រព្យសម្បត្តិរួម ដោយពុំមានឯកសារភស្តុតាងណាមួយបញ្ជាក់អោយបានច្បាស់ពីអត្តសញ្ញាណនៃទ្រព្យសម្បត្តិរួមនោះទេ ហេតុនេះគប្បីតុលាការមិនលើកយកចំណុចនេះមកពិចារណាឡើយ ។

១០-នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍គូភាគីអះអាងថា ពុំមានបំណុលរួមនោះទេ ហេតុដូច្នេះគប្បីតុលាការមិនលើកយកចំណុចនេះមកពិចារណាឡើយ ។

១១-ប្រាក់ប្រដាប់ក្ដីត្រូវអនុវត្តតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

## <u>សេចក្ដីសម្រេចបញ្ចប់</u>

១.ឲ្យដើមចោទឈ្មោះ លែងលះពីចុងចម្លើយឈ្មោះ ស្របតាមមាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណី។

២-ហាមឃាត់មិនឲ្យចុងចម្លើយរៀបអាពាហ៍ពិពាហ៍ថ្មីទៀត ប្រសិនបើអំឡុងពេល ១២០ ថ្ងៃ (មួយរយម្ភៃថ្ងៃ) ពុំទាន់កន្លងផុតគិតពីថ្ងៃសាលក្រមនេះចូលជាស្ថាពរ លើកលែងតែក្នុងករណីដែលដើមចោទមានផ្ទៃពោះមុនសាលក្រមនេះចូលជាស្ថាពរ ឬ ករណីដែលមានលិខិតបញ្ជាក់ពីការគ្មានផ្ទៃពោះពីវេជ្ជបណ្ឌិត តាមមាត្រា ៩៥០ នៃក្រមរដ្ឋប្បវេណី។

៣-កំណត់យកដើមចោទឈ្មោះ ជាអ្នកមានអំណាចមេបាលើកូនទី១ ឈ្មោះ ភេទប្រុស កើតថ្ងៃទី ២៩ ខែមេសា ឆ្នាំ១៩៩៧ មានសំបុត្របញ្ជាក់កំណើតលេខ ៧៦ សៀវភៅបញ្ជាក់កំណើតលេខ ០ /L ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ២០០៩ និងកំណត់យកចុងចម្លើយឈ្មោះ ជាអ្នកមានអំណាចមេបាលើកូនទី២ ឈ្មោះ ភេទស្រី កើត ថ្ងៃទី ២៩ ខែតុលា ឆ្នាំ២០០៧ មានសំបុត្របញ្ជាក់កំណើតលេខ ៧៧ សៀវភៅបញ្ជាក់កំណើតលេខ ០ /L ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៩ ។

៤-ភាគីដែលមិនមានអំណាចមេបា មានសិទ្ធចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូនបាន និងត្រូវផ្តល់សោហ៊ុយចាំបាច់ ដែលត្រូវទទួលបន្ទុក ដើម្បីគ្រប់គ្រងថែរក្សាកូនតាមលទ្ធភាព ហើយភាគីដែលមានអំណាចមេបា ត្រូវបង្ករលក្ខណៈងាយស្រួលដល់ភាគីម្ខាងទៀត តាមមាត្រា ១០៤០ នៃក្រមរដ្ឋប្បវេណី ។

៥-បង្គាប់ឲ្យដើមចោទឈ្មោះ ជាឪពុកបង់សោហ៊ុយចាំបាច់ដើម្បីចិញ្ចឹមបីបាច់ថែរក្សាកូនស្រីទី២ ឈ្មោះ លី កណ្ណិកា ក្នុងមួយខែ ១.០០០.០០០រ(មួយលាន)រៀល។

៦-បែងចែកទ្រព្យសម្បត្តិរួមទៅអោយដើមចោទឈ្មោះ និងចុងចម្លើយឈ្មោះ ជាពីរចំណែកស្មើគ្នានូវទ្រព្យសម្បត្តិរួមដូចខាងក្រោមៈ

ក-ដីមានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ រក॥ ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៨ បញ្ជាក់ដោយមេឃុំរកាកោង២ ។

ខ-ដី មានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ រក॥ ចុះថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០០៨ បញ្ជាក់ដោយមេឃុំរកាកោង២ ។

គ-ដីមានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ មព ចុះថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ២០០៦ បញ្ជាក់ដោយអភិបាលរងស្រុកមុខកំពូល ។

ឃ-ផ្ទះល្វែង មានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដី-ធ្លី លេខ លប ចុះថ្ងៃទី ១០ ខែធ្នូ ឆ្នាំ២០០៤ បញ្ជាក់ដោយចៅសង្កាត់ទួលសង្កែ ។

ង-ដី-ផ្ទះដមានពាក្យសុំលក់ដីលំនៅដ្ឋាន ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ២០០០ បញ្ជាក់ដោយមេឃុំរកាកោង១

ច-រថយន្ត LEXUS RX 300 ផ្លាកលេខ ភ្នំពេញ 2R- ពណ៌ស ឆ្នាំផលិត១៩៩៩ មានប័ណ្ណសម្គាល់យានយន្ត ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ២០១១ ។

ឆ-រថយន្ត KIA VISTO ផ្លាកលេខ ភ្នំពេញ 2T- ពណ៌ស ឆ្នាំផលិត២០០២ មានប័ណ្ណសម្គាល់យានយន្ត ចុះថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ២០១២ ។

ជ-ម៉ូតូ HONDA SUPER CUB 50 ផ្លាកលេខ 1BB- ពណ៌ខៀវចាស់ មានប័ណ្ណសម្គាល់ទោចក្រយានយន្ត ចុះថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ២០១១ ។

៥-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

**ចៅក្រម**

ហត្ថលេខា និងត្រាៈ **គឹម រ័ត្នណារិន**

---

**បានឃើញ**

**ចៅក្រម**

**គឹម រ័ត្នណារិន**

“បានចម្លងត្រឹមត្រូវតាមច្បាប់ដើម”

ថ្ងៃចន្ទ ១០រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស២៥៦២

កណ្តាល, ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៩

**ក្រឡាបញ្ជី**

**ឆៅ សុភាព**

បានទទួលថ្ងៃទី 16-05-2019.

បានទទួល 22.05.2019

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្ត
បន្ទាយមានជ័យ

សំណុំរឿងរដ្ឋប្បវេណី
លេខ
ចុះថ្ងៃទី ០៦ខែវិច្ឆិកាឆ្នាំ ២០១៨
សាលក្រម
លេខ:  ( )
ចុះថ្ងៃទី១៧ ខែ ធ្នូ ២០១៨

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តបន្ទាយមានជ័យ

កាលបរិច្ឆេទបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី០៧ ខែធ្នូ ឆ្នាំ ២០១៨។
កាលបរិច្ឆេទប្រកាសសាលក្រម : ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៨

## ចៅក្រម

លោក **ជួន វណ្ណា**: ចៅក្រមសាលាដំបូងខេត្តបន្ទាយមានជ័យ

## ក្រឡាបញ្ជី

លោក **ទៀវ ដារណា** ក្រឡាបញ្ជីសាលាដំបូងខេត្តបន្ទាយមានជ័យ

## សមាសភាពដែលបានបង្ហាញខ្លួន

-ដើមចោទឈ្មោះ ភេទស្រី ថ្ងៃខែឆ្នាំកំណើត ៣០-១២-១៩៩៥ ជាតិខ្មែរ មុខរបរ កម្មករទីលំនៅបច្ចុប្បន្នភូមិ២ សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ។

-ចុងចម្លើយឈ្មោះ ភេទប្រុស ថ្ងៃខែឆ្នាំកំណើត ០២-១២-១៩៩០ មុខរបរកម្មករ ទីលំនៅបច្ចុប្បន្ននៅភូមិ២ សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ។

## កម្មវត្ថុនៃបណ្តឹង

ខ្លឹមសារសាលក្រមដែលទាមទារដោយភាគី:

ក-ដើមចោទទាមទារអោយតុលាការចេញសាលក្រមៈ

១-សុំលែងលះពីចុងចម្លើយឈ្មោះ

២-សុំបែងចែកទ្រព្យសម្បត្តិរួមជាពីរចំណែកស្មើគ្នា

៣-សុំអំណាចមេបាលើកូនប្រុសម្នាក់

៤-សុំអាហារកិច្ចចិញ្ចឹមកូនផ្តាច់ ៥,០០០(ប្រាំពាន់)ដុល្លាអាមេរិក

៥-សុំរ៉ាប់រងប្រាក់ពន្ធ។

ខ-ចុងចម្លើយទាមទារអោយតុលាការចេញសាលក្រមៈ លែងលះ និងបែងចែកទ្រព្យសម្បត្តិរួម។

## អង្គហេតុ និងចំណុចវិវាទ

ក-អំពីដំណើរនៃរឿងក្តី:

ដើមចោទឈ្មោះ បានដាក់ពាក្យប្តឹងសុំលែងលះពីចុងចម្លើយឈ្មោះ ដោយអះអាងថា គាររស់នៅជាមួយចុងចម្លើយតែងតែមានរឿងរកាំរកូសជាមួយគ្នាជារឿយៗ ចុងចម្លើយចេះតែ គំរាមសម្លាប់ខ្លួនជារឿយៗពេលខឹងម្តងៗ ហើយសព្វថ្ងៃរវាងខ្លួន និងចុងចម្លើយបានរស់នៅបែកលំនៅសង្វាសគ្នាអស់រយៈពេល៥ខែមកហើយ ដោយសារខ្លាចមានគ្រោះថ្នាក់ដោយប្រការផ្សេងៗ ដូច្នេះហើយធ្វើអោយខ្លួនអស់មនោសញ្ចេតនារួមរស់ជាមួយគ្នាទើបដាក់ពាក្យសុំលែងលះតាមច្បាប់។

-អង្គហេតុដែលមានវិវាទៈ លែងលះ, ការបែងចែកទ្រព្យសម្បត្តិរួម

-អង្គហេតុដែលគ្មានវិវាទៈ គូភាគីបានរៀបអាពាហ៍ពិពាហ៍តាមច្បាប់, បែងចែកអំណាចមេបា

ខ-ការអះអាងរបស់ភាគីៈ

-ក្នុងពេលទាញហេតុផលដោយផ្ទាល់មាត់ដើមចោទឈ្មោះ បានធ្វើសេចក្តីថ្លែងការណ៍ថា ខ្លួននៅតែប្តឹងសុំអោយតុលាការចេញសាលក្រមសម្រេចអោយខ្លួនបានលែងលះ ពីចុងចម្លើយឈ្មោះ ដដែល ហើយទ្រព្យសម្បត្តិរួមខ្លួនសុំចែកជាពីរចំណែកស្មើគ្នា។ ដីសង់ផ្ទះម្តាយចុងចម្លើយចែកអោយខ្លួន និងប្តីកាន់កាប់រស់នៅ។ ចំពោះផ្ទះដែលសង់នៅលើដីសរុបអស់ប្រាក់ ៧,៥០០(ប្រាំពីរពាន់ប្រាំរយ)ដុល្លាអាមេរិក នៅពុំទាន់បានគិតពីតម្លៃជាងនៅឡើយទេ។ ចំពោះថ្លៃជាងទើបតែអោយបាន ២០០(ពីររយ)ដុល្លាអាមេរិក នៅជំពាក់ថ្លៃជាងចំនួន១,៩០០(មួយពាន់ប្រាំបួនរយ)ដុល្លាអាមេរិក ទៀត ខ្លួនសុំអោយចុងចម្លើយជួយសងថ្លៃជាង ម្នាក់ពាក់កណ្តាល។ ដើម្បីកុំអោយមានរឿងវែងឆ្ងាយ ខ្លួនសុំអោយចុងចម្លើយបង់ផ្តាច់ទាំងប្រាក់អាហារកិច្ច,ប្រាក់ទ្រព្យរួម,ប្រាក់បំណុលជាងសរុបចំនួន ៧,០០០(ប្រាំពីរពាន់) ដុល្លាអាមេរិក។ ចំពោះម៉ូតូខ្លួនបានទិញពីប្អូនថ្លៃរួចហើយតម្លៃ ៥០០(ប្រាំរយ)ដុល្លាអាមេរិក។

-ចុងចម្លើយបានធ្វើសេចក្តីថ្លែងការណ៍ថា ខ្លួនសុំឯកភាពលែងលះ និងអំណាចមេបា។ ចំណែកទ្រព្យសម្បត្តិដែលដើមចោទរៀបរាប់ គឺខ្លួនមិនឯកភាពតាមទេ ពីព្រោះដីនេះគឺដីរបស់ម្តាយខ្លួន ដែលបានអោយខ្លួន និងប្រពន្ធរស់នៅជាបណ្តោះអាសន្ន។ ចំពោះអាហារកិច្ចខ្លួនសុំចិញ្ចឹមកូនក្នុងមួយខែ ២០០,០០០(ម្ភៃម៉ឺន)រៀល រឿងដើមចោទសុំប្រាក់ផ្តាច់ទាំងប្រាក់អាហារកិច្ច, ប្រាក់ទ្រព្យរួម, ប្រាក់ជំពាក់ជាងសរុបចំនួន ៧,០០០(ប្រាំពីរពាន់)ដុល្លាអាមេរិកនោះ ខ្លួនសុំបដិសេធ តែដើម្បីកុំអោយវែងឆ្ងាយខ្លួនសុំបង់អោយដើមចោទផ្តាច់ចំនួន ១,៥០០(មួយពាន់ប្រាំ)ដុល្លាអាមេរិក។

-សេចក្តីបំភ្លឺរបស់សាក្សីខាងដើមចោទឈ្មោះ .. បានបញ្ជាក់ថា ដីដែលកូនសង់ផ្ទះនៅ សព្វថ្ងៃគឺខាងជន្លងខ្លួនបានប្រគល់ឲ្យកូនកាន់កាប់ទាំងពីរនាក់ប្តីប្រពន្ធ។ បន្ទាប់ពីបានដីហើយទើបខ្លួន បានចាត់ចែងធ្វើផ្ទះឲ្យកូន ហើយប្រាក់ដែលយកមកសាងសង់ផ្ទះនោះ ខ្លួនមិនបានដឹងទេ ខ្លួនដឹងតែថ្លៃជាង សរុបអស់ប្រាក់ចំនួន ២,១០០(ពីរពាន់មួយរយ)ដុល្លាអាមេរិក ទើបតែសងជាងបាន ២០០(ពីរយ)ដុល្លាអាមេរិក តែប៉ុណ្ណោះ ហើយនៅជំពាក់ប្រាក់ថ្លៃជាងចំនួន ១,៩០០(មួយពាន់ប្រាំបួនរយ)ដុល្លាអាមេរិកទៀត។

-សេចក្តីបំភ្លឺរបស់សាក្សីខាងចុងចម្លើយឈ្មោះ បានបញ្ជាក់ថា ខ្លួនបានប្រគល់ដីទៅឲ្យកូនទាំងពីរមែន តែគ្រាន់តែប្រគល់ឲ្យរស់នៅជាបណ្តោះអាសន្នតែប៉ុណ្ណោះ បើកូនលែងលះគ្នាខ្លួននឹងដកហូតយកដីនោះមកវិញ។ ខ្លួនបានឲ្យលុយកូនធ្វើផ្ទះចំនួន ៣,៥០០(បីពាន់ប្រាំរយ)ដុល្លាអាមេរិក ហើយថ្លៃធ្វើអស់ប៉ុន្មានទៀតក៏មិនដឹងដែរ។

-សេចក្តីបំភ្លឺរបស់សាក្សីឈ្មោះ បានបញ្ជាក់ថា ខ្លួនបានលក់ម៉ូតូទៅឲ្យបងថ្លៃខ្លួន ឈ្មោះ **លឹម ស្រីយ៉ាន** ក្នុងតំលៃ ៥០០(ប្រាំរយ)ដុល្លាអាមេរិក ហើយបានទទួលប្រាក់នោះរួចរាល់។

## សំអាងហេតុ

-តាមលទ្ធផលនៃការសាកសួរភាគី ក្នុងពេលធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ឃើញថា : ដើមចោទ និងចុងចម្លើយបានរួមរស់ជាមួយគ្នាក្នុងឆ្នាំ ! ព្រមទាំងបានចុះសំបុត្រអាពាហ៍ពិពាហ៍តាមច្បាប់។

-ក្នុងពេលត្រៀមទាញហេតុផល និងពេលទាញហេតុផលដោយផ្ទាល់មាត់ដើមចោទ និងចុងចម្លើយបាន ព្រមព្រៀងគ្នាលើចំណុចលែងលះ និងអំណាចមេបា។ តុលាការគប្បីសម្រេចតាមការព្រមព្រៀងរបស់សមេតិទ្ធ។

-ការទាមទារអាហារកិច្ចចិញ្ចឹមកូនផ្តាច់ចំនួន ៥,០០០(ប្រាំពាន់)ដុល្លាអាមេរិក របស់ដើមចោទ ហើយចុងចម្លើយសុំបង់អាហារកិច្ចចិញ្ចឹមកូនចំនួន ២០០,០០០(ម្ភៃម៉ឺន)រៀល ក្នុងមួយខែនោះ តុលាការគប្បីពិចារណាសម្រេចតាមលទ្ធភាពរបស់ភាគី ។

-ក្នុងពេលត្រៀមទាញហេតុផល និងពេលទាញហេតុផលដោយផ្ទាល់មាត់ ដើមចោទ និងចុងចម្លើយ មិនឯកភាពគ្នាលើទ្រព្យសម្បត្តិរួម ដោយដើមចោទអះអាងថា អោយតុលាការសម្រេចចែកទ្រព្យសម្បត្តិរួមជាពីរ ចំណែកស្មើគ្នា និងបានលើកឡើងថា ខ្លួនក៏បានចំណាយប្រាក់មួយចំនួនក្នុងការសាងសង់ផ្ទះដែរ រីឯចុងចម្លើយបានអះអាងថា ខ្លួនសុខចិត្តប្រគល់ប្រាក់ចំនួន ១,៥០០(មួយពាន់ប្រាំរយ)ដុល្លាអាមេរិក អោយទៅដើមចោទ។ ឃើញថាសេចក្ដីថ្លែងការណ៍អំពីថ្លៃចេញសាងសង់ផ្ទះនេះ គឺមិនមានភស្តុតាងច្បាស់លាស់ អំពីតំលៃនៃថ្លៃនោះទេ តុលាការគប្បីពិចារណាសម្រេចផ្អែកលើភស្តុតាងជាក់ស្តែង។

-កូនឈ្មោះ ភេទប្រុស កើតថ្ងៃខែឆ្នាំ ២០.១២.២០១៥ គូភាគីបានព្រមព្រាងគ្នា ប្រគល់អំណាចមេបាទៅឲ្យដើមចោទ។ គប្បីតុលាការសម្រេចតាមការព្រមព្រាងរបស់ភាគី។

-ចំពោះទ្រព្យសម្បត្តិដែលជាដី ដែលភាគីដើមចោទបានអះអាងថា ម្ដាយខាងចុងចម្លើយបានប្រគល់មកឲ្យពួកខ្លួនរស់នៅកាន់ទាំងពីនាក់នោះ គឺមិនមានភស្តុតាងជាលិខិតឯកសារណាដែលធ្វើឲ្យតុលាការជឿ បានឡើយ ហើយផ្ទុយទៅវិញម្ដាយរបស់ចុងចម្លើយបានបញ្ជាក់ថា បានប្រគល់ទៅភាគីរស់នៅមែន តែប្រគល់ឲ្យរស់នៅបណ្ដោះអាសន្នតែប៉ុណ្ណោះនឹងដកហូតយកមកវិញនៅពេលដែលភាគីលែងលះគ្នា។ ដូច្នេះដីនេះ ជាដីរបស់ម្ដាយចុងចម្លើយ គឺមិនមែនជាដីរួមរបស់គូភាគីនោះទេ គប្បីតុលាការមិនពិចារណាសម្រេចអំពីដី ដែលមិនមែនជាទ្រព្យរួមរបស់ភាគីឡើយ។

-ប្រាក់ប្រដាប់ក្ដីដើមចោទសុខចិត្តទទួលរ៉ាប់រង។

## សេចក្ដីសម្រេចបញ្ចប់

១/អោយដើមចោទឈ្មោះ ភេទស្រី ថ្ងៃខែឆ្នាំកំណើត ៣០-១២-១៩៩៥ និងចុងចម្លើយឈ្មោះ ភេទប្រុស ថ្ងៃខែឆ្នាំកំណើត ០២-១២-១៩៩០ ជាចុងចម្លើយលែងលះគ្នាចាប់ពីពេលនេះតទៅ។

២/អោយដើមចោទឈ្មោះ ដែលមានអត្តសញ្ញាណដូចខាងលើ មានអំណាចមេបាលើ កូនម្នាក់ឈ្មោះ ភេទប្រុស ថ្ងៃខែឆ្នាំកំណើត ២០-១២-២០១៥ តាមការព្រមព្រៀងរបស់គូភាគី ។

៣/ទុកសិទ្ធអោយឪពុកទៅសួរសុខទុក្ខកូនបានតាមមាត្រា ៩៧៨,៩៧៩, ១០៣៧ នៃក្រមរដ្ឋប្បវេណី។ មាតាបិតាត្រូវបំពេញសិទ្ធ និងករណីកិច្ចអប់រំថែទាំចិញ្ចឹមកូនអោយបានល្អ។

៤/អោយចុងចម្លើយឈ្មោះ ដែលមានអត្តសញ្ញាណដូចខាងលើ បង់អាហារកិច្ចចិញ្ចឹមកូន ចំនួន ២០០,០០០(ម្ភៃម៉ឺន)រៀល ក្នុងមួយខែអោយទៅដើមចោទសំរាប់ការចិញ្ចឹមកូន រហូតដល់កូនមានវ័យនីតិភាព។

៥/ប្រគល់ផ្ទះមួយល្វែងសង់អំពីថ្មប្រក់ស័ង្កសីទំហំ ៥ម៉ែត្រ គុណ ១៦ម៉ែត្រ លើដីដែលជាកម្មសិទ្ធរបស់ម្ដាយចុងចម្លើយ ស្ថិតនៅភូមិ២ សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ អោយទៅចុងចម្លើយឈ្មោះ កាន់កាប់ជាកម្មសិទ្ធចាប់ពីសាលក្រមចូលជាស្ថាពរតទៅ។

៦/ប្រគល់ម៉ូតូមួយគ្រឿងម៉ាកឌ្រីមសង់ ២០១៥ ពណ៌ខ្មៅ ស្លាកលេខ ប.ជ ១២៧៥ ទៅឲ្យដើមចោទ ឈ្មោះ ចាប់ពីសាលក្រមចូលជាស្ថាពរតទៅ។

៧/បង្គាប់អោយចុងចម្លើយឈ្មោះ ដែលមានអត្តសញ្ញាណដូចខាងលើ ប្រគល់ប្រាក់ចំនួន ២,០០០(ពីរពាន់)ដុល្លាអាមេរិក ទៅឲ្យដើមចោទឈ្មោះ ចាប់ពីសាលក្រមចូលជាស្ថាពរតទៅ។

៨/បង្គាប់អោយដើមចោទឈ្មោះ និងចុងចម្លើយឈ្មោះ រួមគ្នាសងបំណុល (ម្ដាយមីង ឈ្មោះ ជាង)ចំនួន ១,៩០០(មួយពាន់ប្រាំបួនរយ)ដុល្លាអាមេរិក ម្នាក់ពាក់កណ្ដាល ។

៩/ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ដើមចោទ។

១០/សាលក្រមនេះធ្វើការទាញហេតុផលដោយផ្ទាល់មាត់ និងបានប្រកាសជាសាធារណៈបើកសិទ្ធិប្តឹង ឧទ្ធរណ៍ ក្នុងកំណត់ច្បាប់។

ថ្ងៃច័ន្ទ ១០កើត ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

ធ្វើនៅបន្ទាយមានជ័យ ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៨

**ចៅក្រម**

ជួន ចន្ណា